សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មករា ឆ្នាំ 2012

# លីអាហូណា



## រៀនដើម្បីរីករាយជាមួយ
## នឹងព្រះគម្ពីរទាំងឡាយ
ទំព័រ 14, 16, 20

ចូរសម្លឹងឡើងលើ មិនមែនផ្លូវចំហៀងទេ ទំព័រ 42

សារលិខិតមួយសម្រាប់អ្នកទាំងឡាយណាដែលនឹង
បម្រើបេសកកម្ម ទំព័រ 48

កុមារ ឆ្នាំរបស់អ្នកជាមួយនឹងព្រះគម្ពីរមរមន ទំព័រ 60



ដើមឈើជីវិត ដោយ វៀលសុន ជេ អុង

នៅក្នុង នីហ្វៃទី1 8 លីហៃប្រាប់ពីការនិមិត្តរបស់លោកអំពីដើមឈើជីវិត ។ លោកបានមានប្រសាសន៍ថា ៖
« បន្ទាប់ពីឪពុកបានអធិស្ឋានដល់ព្រះអម្ចាស់ហើយ នោះឪពុកក៏បានឃើញទីវាលដ៏ធំ ហើយទូលាយមួយ ។
« ហើយហេតុការណ៍បានកើតឡើងថា ឪពុកបានឃើញដើមឈើមួយ ដែលមានផ្លែដ៏គួរធ្វើឲ្យមនុស្សសប្បាយរីករាយ ។
« ហើយហេតុការណ៍បានកើតឡើងថា ឪពុកបានដើរចូលទៅបេះផ្លែឈើនោះ ហើយទទួលទាន ហើយឪពុកឃើញថា
វាមានរស់ជាតិផ្អែមបំផុត គឺផ្អែមជាងអ្វីៗ ដែលឪពុកធ្លាប់បានភ្លក់ពីមុនមក ។ មែនហើយ ហើយឪពុកបានឃើញថា
ផ្លែឈើនោះមានពណ៌ស គឺសជាងអ្វីទាំងអស់ដែលឪពុកធ្លាប់បានឃើញមក ។ ...
« ហើយឪពុកបានឃើញដំបងដែកមួយ ហើយដំបងដែកនោះផ្តេកបណ្តោយតាមមាត់ទន្លេ
ហើយតម្រង់ទៅឯដើមឈើដែលឪពុកឈរជិត » ( នីហ្វៃទី1 8:9–11, 19 ) ។



20

## សារលិខិត


4 **សារលិខិតគណៈប្រធានទីមួយ**
**រស់នៅក្នុងជីវិតដ៏បរិបូរណ៍**
ដោយប្រធាន ថូម៉ាស អេស ម៉នសុន

7 **សារលិខិតការបង្រៀនសួរសុខទុក្ខ**
**ការថែរក្សា និងការបម្រើតាមរយៈការបង្រៀនសួរសុខទុក្ខ**


## អត្ថបទពិសេសៗ


16 **ការស្វែងរកចម្លើយទាំងឡាយនៅក្នុងព្រះគម្ពីរមរមន**
ដោយ សារ៉ា ឌី ស្មិធ
*សមាជិកប្រាំមួយរូបចែកចាយពីអ្វីដែលព្រះគម្ពីរមរមនបានធ្វើឱ្យមានភាពខុសគ្នាមួយនៅក្នុងជីវិតរបស់ពួកគេ ។*

20 **ការរកឃើញជាថ្មីនូវអច្ឆរិយវត្ថុពិភពលោកមួយ ... និងការជៀសវាងពីគ្រោះថ្នាក់នៃភាពព្រងើយកន្តើយខាងវិញ្ញាណ**
ដោយ អ័ដាម ស៊ី អូលសុន
*ដូចជាអ្នកស្រាវជ្រាវទាំងឡាយដែលបានទទួលចំណេះដឹងបន្ថែមហើយបន្ថែមទៀតអំពីភ្នំ ម៉ាឈូ ភីឈូ នោះយើងក៏អាចទទួលចំណេះដឹងបន្ថែមទៀតអំពីដំណឹងល្អជារៀងរាល់ពេលដែលយើងសិក្សាវាផងដែរ ។*

24 **ការស្គាល់នូវព្រះហស្តរបស់ព្រះនៅក្នុងពរជ័យប្រចាំថ្ងៃរបស់យើង**
ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន
*ការទូលសុំ « នំប៉័ងប្រចាំថ្ងៃរបស់យើង » នោះព្រះហស្តរបស់ព្រះ ជាផ្នែកដ៏សំខាន់ក្រៃលែងនៅក្នុងការរៀនដើម្បីទុកចិត្តទ្រង់ ។*

32 **ចច អ័លប៊ើត ស្មិធ ៖ លោកបានរស់នៅតាមអ្វីដែលលោកបានបង្រៀន**
ដោយ ធិឌ បាទិស
*សេចក្តីណែនាំមួយសម្រាប់កម្មវិធីសិក្សានៃបព្វជិតភាពមិលគីស្សាដែក និងសមាគមសង្គ្រោះនៅឆ្នាំនេះ ។*


នៅលើគម្រប
គូរដោយ ដេហ្វ វ៉ដ



## ផ្នែកទាំងឡាយ


8 **សៀវភៅកំណត់ចំណាំសន្និសីទ**

10 **ការបម្រើនៅក្នុងសាសនាចក្រ**
**ភាពជាអ្នកដឹកនាំតាមរបៀបរបស់ព្រះអម្ចាស់**
ដោយ ហ្វ្រេក មើវែល

12 **យើងនិយាយអំពីព្រះគ្រីស្ទ**
**គ្រូបង្រៀនសួរសុខទុក្ខបានដឹកនាំខ្ញុំទៅឯព្រះយេស៊ូវគ្រីស្ទ**
ដោយ ចេន ភី បោវើស៍

14 **គេហដ្ឋានរបស់យើង ក្រុមគ្រួសាររបស់យើង**
**ការជួយដល់កុមារឱ្យស្រលាញ់ព្រះគម្ពីរមរមន**
ដោយ ខ្លាយដ៍ ជេ វីល្លៀម

38 **សម្លេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

74 **ព័ត៌មានអំពីសាសនាចក្រ**

79 **គំនិតសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ**

80 **លុះត្រាជួបទៀត**
**ការរៀនសូត្រពីអ្នកជំនាញ**
ដោយ ចច ស៊ី រ៉ូប៊ីនសិន

## មជ្ឈិមវ័យវ័យក្មេង





**42 ពួកគេបាននិយាយមកកាន់យើង ចូរសម្លឹងទៅលើ**
ដោយ អែលឌើរ ខាល ប៊ី យុក
*តើមានអ្វីកើតឡើង នៅពេលដែលយើងសម្លឹងឡើងលើ ដើម្បីមើលពីរបៀបដែលព្រះវរបិតាសួគ៌មើលមកយើង ជាជាងការសម្លឹងទៅផ្លូវចំហៀង ដើម្បីមើលពីរបៀបដែលអ្នកដទៃទៀតមើលយើងនោះ ?*




**ចាំមើលថាតើអ្នកអាចរកឃើញរូបលីអាហូណា ដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ ចូរប្រើប្រាស់ត្រីវិស័យដើម្បីឆ្លងកាត់មហាសមុទ្រប៉ាស៊ីហ្វិក ។**

## យុវវ័យ


**46 ទៅកាន់គោលដៅ**

**48 ការរក្សាសេចក្ដីសញ្ញាទាំងឡាយ ៖ សារលិខិតមួយសម្រាប់អ្នកទាំងឡាយណាដែលនឹងបម្រើបេសកកម្ម**
ដោយ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន
*មានទូវគន្លឹះមួយដើម្បីមានអំណាចនៃទេវភាពទាំងឡាយជាមួយយើង ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ។*

**52 បាវចនាម៉្ងឆលឆ្នាំ 2012**
ដោយ គណៈប្រធានយុវនារី និងយុវជនទូទៅ
*« ចូរក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ ប្រយោជន៍ឱ្យពន្លឺរបស់អ្នកអាចបានទៅជាបមាណពីយដល់សាសន៍នានា » (គ. និង ស. 115:5) ។*

**54 ប័ណ្ណប្រកាស បញ្ចាំងពន្លឺចេញទៅ**

**55 មួយបន្ទាត់ម្ដងៗ គោលលទ្ធិ និងសេចក្ដីសញ្ញា 115:5**

**56 មកពីតំបន់បេសកកម្ម ព្រះឆ្លើយតមដល់ការអធិស្ឋានទាំងពីរ**
ខាឡូសស អាយវ៉ាន ហ្គាមីនឌៀ ប៉ាគីកូ

**57 ចូរស្មោះត្រង់**
ដោយ អែលឌើរ ហ្គេរ៉ុល កូសសែ
*អំឡុងការសម្ភាសន៍ដ៏សំខាន់មួយ ខ្ញុំត្រូវតែសម្រេចចិត្តយ៉ាងឆាប់រហ័ស ថាតើត្រូវស្មោះត្រង់ចំពោះការជឿ ទាំងឡាយរបស់ខ្ញុំឬទេ ។*











## កុមារ





**58 ថ្ម ព្រួញ និងដុំព្រិល**
ដោយ ដារីឌ អិល ហ្វ្រីសនេចត៍
*តើខ្ញុំអាចគេចផុតពីពួកអ្នកដែលចូលចិត្តធ្វើបាបគេដោយរបៀបណា ? ចូរក្លាយដូចជាសាំយូអែល សាសន៍លេមិន ។*

**60 ទទួលទាននូវព្រះគម្ពីរមរមន**
*សូមផាត់ពណ៌នៅលើតារាងនេះជារៀងរាល់សប្ដាហ៍ ពេលអ្នកអានព្រះគម្ពីរមរមន ។*

**63 សាក្សីពិសេស តើខ្ញុំសម្រេចគោលដៅរបស់ខ្ញុំបានដោយរបៀបណា ?**
ដោយ អែលឌើរ អិម រ័សុល បាឡឺដ

**64 ការនាំមេរៀនថ្នាក់កុមារមកក្នុងលំនៅដ្ឋាន សិទ្ធិជ្រើសរើសគឺជាអំណោយទានដើម្បីជ្រើសរើសសម្រាប់ខ្លួនរបស់យើងផ្ទាល់**

**66 រឿងទាំងឡាយរបស់ព្រះយេស៊ូវ ព្រះគម្ពីរមរមនបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ**
ដោយ ដាយអាន អិល មែនហ្គិម

**68 ការបង្កើតមិត្តភាពនៅជុំវិញមហាសមុទ្រប៉ាស៊ីហ្វិក**
ដោយ ជេន ហាន់សិន ឡាសេធី
*កុមារនៃអង្គការបឋមសិក្សាពីរដ្ឋយូថាហ៍ និងប្រទេសតុងហ្គា ស្គាល់គ្នាទៅវិញទៅមក ។*

**69 ទ្រង់គង់នៅទីនោះ**
ដោយ រ៉ូសម៉ារី អិម វិកស្យុម
*ព្រះវរបិតាសួគ៌ឮ និងឆ្លើយតបការអធិស្ឋានរបស់ក្មេងតូចគ្រប់គ្នា ។*

**70 សម្រាប់កុមារតូចៗ**

**ខែ ???? ឆ្នាំ 2012 វ៉ុល 12 លេខទី 1**
**លីអាហូណា 10481 258**

ទស្សនាវដ្ដីអន្តរជាតិជាផ្លូវការនៃសាសនាចក្រនៃព្រះ យេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ៖** ថូម៉ាស អេស ម៉នសុន, ហិនរី ប៊ី អាវរិង, ឌៀថើរ អេហ្វ អុជដូហ្វ

**ក្រុមនៃពួកសាវក 12 នាក់៖** ប៊យដ៍ ឃេ ផាកកឺ, អិល ថម ភែរី, រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, អិម រ័សុល បាឡឺដ, រីឆាដ ជេ ស្កត, របឺត ឌី ហែល, ជែហ្វ្រី អរ៍ ហូឡិន, ដេវីឌ អេ បែដណា, ឃ្វីនថិន អិលឃុក, ឌី ថត គ្រីស្តូហ្វឺសិន, និង នែល អិល អាន់ឌើរសិន

**អ្នកបោះពុម្ពផ្សាយ៖** ផល ប៊ី ភីបភ័រ
**អ្នកណែនាំ៖** ស្ទែនលី ជី អ៊ីលលីស, គ្រីស្តូហ្វឺល ហ្គោលដិន ជុញ្ញ័រ យ៉ូស៊ីហ្វិកូ គីគូកឃី

**នាយកផ្នែកចាត់ការ៖** ដេវីត អិល ហ្វ្រីចទីច
**អគ្គនាយកផ្នែកបោះពុម្ពផ្សាយ៖** វិនសិន អេ វ៉ែន
**នាយកផ្នែកក្រាភិច៖** អាល់លែន អ័រ ឡយប៊ិត

**អ្នកចាត់ការបោះពុម្ពផ្សាយ៖** អ័រ វាល ចនសុន
**ជំនួយការអ្នកចាត់ការបោះពុម្ពផ្សាយ៖** ជេនីហ្វឺ អែល គ្រីនវូឌ, អ័ដាម សេ អូសុន
**សហការីអ្នកបោះពុម្ពផ្សាយ៖** រ៉ាយអិន ខា
**ជំនួយការអ្នកបោះពុម្ពផ្សាយ៖** សូសាន បារីត
**បុគ្គលិកបោះពុម្ពផ្សាយ៖** ប្រ៊ីតថានី បាទី, ដេវីឌ អេ អេឌវឺឌ, ម៉ាថាយ ឌី ហ្វលីតុន, ឡារីន ផ័ទី ហ្គូន, ឡារី ហៀលលី, ការី កាស្ទីន, ជេននីហ្វឺ ម៉ាឌី, លៃ ម៉ាក់ឡាណាហាន, ម៉ែលីស្សា ម៉ឺរីល, ម៉ៃគល អ័រ ម៉ូរីស, សាលី ជេ អូឌីគីត, យ៉ូស្វេ ជេ ភើកឃី, ជេឌ អី ហ្វាស, ជេន ភីនបូរហ្វ, រីឆាត អិម រ៉មនី, ដូន អិល សៀ, ជេនីត ថូម៉ាស, ផល វេឌីបៀរហ្គ, ជូលី វីដេលលេខាធិការជាន់ខ្ពស់, ឡូរែល ធូស្តើរ, ម៉ារីស្សា អេ វីតឌីសុន, ម៉ាលីស្សា ហៀនទីណូ

**នាយកចាត់ចែងផ្នែកសិល្បៈ៖** ជេ ស្កុត នូតសុិន
**នាយកផ្នែកសិល្បៈ៖** ស្កុត វេន យេមផេន
**អ្នកគ្រប់គ្រងផលិតកម្ម៖** ជេន អាន ផេតធី
**អ្នករៀបចំប្លង់ជាន់ខ្ពស់៖** ស៊ី គីមបល ប៊ុត, ថូម៉ាស អេស ឆាល, ឃូលលីន ឃីងហ្គ័រ, អ៊ិរិច ភី ចនសិន, ស្កុត អឹម ម៉ោយ
**បុគ្គលផលិតកម្ម៖** ខាលី អរ អារូយ៉ូ, ឃូលីតទី ណាបាឃ័រ អុណី, ហាវូដ ជី ប្រោន, ជូលី ប៊ីរដីទ, រីហ្គីណោល ជេ គ្រីស្ទីនសិន, គីម ហ្វីនស្ទរមេឃើរ, កាតលីន ហាវូដ, ឌីនទីស ឃីរប៊ី, ប្រាយអ៊ិន ដបុលយូ ហ្គីហ្គី, ជីនទី ជេ ណីលសិន
**អ្នកបោះពុម្ព៖** ជេហ្វ អិល ម៉ាទីន

**នាយកផ្នែកបោះពុម្ព៖** ក្រីជ ឃេ ស៊ីជវីគន
**នាយកផ្នែកការចែកចាយ៖** អ៊ីវ៉ានឡាស៊ិន

**សំរាប់ជំនាវ និងតម្លៃខាងក្រៅសហរដ្ឋអាមេរិក និងកាណាដា សូមទាក់ទងមជ្ឈមណ្ឌលចែកចាយនៃសាសនាចក្រក្នុងមូលដ្ឋាន ឬអ្នកដឹកនាំវួដ ឬសាខា។ ផ្ញើការបោះពុម្ព ឬសំណួរទាំងឡាយតាមអ៊ិនធើរណិត liahona.lds.org, តាម *Liahona*, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA។**

*លីអាហូណា* (ព្រះគម្ពីរមរមនមានន័យថា «ត្រីវិស័យ» ឬ «វត្ថុនាំផ្លូវ») ត្រូវបាន បោះពុម្ពជាភាសា អាល់បេនី, អាមេនី, ប៊ីស្លាមៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហៃទី, ហិនឌី, ហុងហ្គារី, អាយឡែនឌិច, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាកាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, ណរវ៉េ, ប៉ូឡូញ, ព័រទុយហ្គាយ, រ៉ូម៉ានី, រុស្សី, សាម័រ, ស៊ីនហាឡា, ស្លូវ៉ានី, អេស្ប៉ាញ, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, តាមីល, តេលូហ្គូ, ថៃ, តុងហ្គា, អ៊ុយក្រែ,ន អ៊ើឌូ និងវៀតណាម។ (ភាពញឹកញាប់ប្រែប្រួលតាមភាសា)។

© 2012 ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង។ បោះពុម្ពនៅក្នុងសហរដ្ឋអាមេរិក។

អត្ថបទ និងរូបភាពផ្សេងៗនៅក្នុងទស្សនាវដ្ដី លីអាហូណា អាចថតចម្លងបាន ដើម្បីប្រើប្រាស់នៅតាមគេហដ្ឋាន មិននៅក្នុងសាសនាចក្រ តែមិនមែនសំរាប់ធ្វើអាជីវកម្ម។ រូបភាពមួយចំនួនមិនអាចថតចម្លងបានទេ ចំពោះរូបភាពមួយចំនួនដែលត្រូវបានហាមឃាត់។ បើមានសំណួរ លោកអ្នកអាចទាក់ទងជាមួយ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org.

**For Readers in the United States and Canada:**
January 2012 Vol. 12 No. 1. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address *must* be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (Visa, MasterCard, American Express) may be taken by phone. (Canada Poste Information: Publication Agreement #40017431)

POSTMASTER: Send address changes to Salt Lake Distribution Center, Church Magazines, PO Box 26368, Salt Lake City, UT 84126-0368.

# រឿងជាច្រើនទៀតនៅលើអ៊ីនធើរណែត Liahona.lds.org






## សម្រាប់មជ្ឈិមវ័យ

អត្ថបទមួយចំនួននៅក្នុងច្បាប់នេះ និយាយអំពីព្រះគម្ពីរទាំងឡាយ ជាពិសេសព្រះគម្ពីរមរមន ( សូមមើល ទំព័រ 14, 16, និង 20 ) ។ នៅក្នុងសន្និសីទទូទៅ ខែ មេសា ឆ្នាំ 2010 អែលឌើរ ដេវីឌ អេ បែដណា បានមានប្រសាសន៍អំពីរបៀបដែលការសិក្សាព្រះគម្ពីរមរមនអាចជួយពង្រឹងក្រុមគ្រួសារទាំងឡាយ ។ ដើម្បីអាន ឬស្ដាប់ប្រសាសន៍របស់លោក សូមចូលទៅកាន់ lds.org/general-conference/2010/04/watching-with-all-perseverance ។

អ្នកមគ្គុទេសក៍នៅឯភ្នំ ម៉ាឈូ ភីឈូ ផ្ដល់នូវយោបល់បីសម្រាប់ការសិក្សាដំណឹងល្អ ( សូមមើលទំព័រ 20 ) ។ សូមមើលរូបថតនៃអច្ឆរិយវត្ថុពិភពលោកនេះថែមទៀតនៅ liahona.lds.org ។

## សម្រាប់យុវវ័យ

បន្ទាប់ពីការអានដំបូន្មានរបស់អែលឌើរ ហូឡិន សម្រាប់អ្នកទាំងឡាយណាដែលនឹងបម្រើបេសកកម្ម រួចហើយ នោះអ្នកអាចរកអត្ថបទ និងព័ត៌មានបន្ថែមទៀត អំពីកិច្ចការផ្សព្វផ្សាយសាសនានៅ lds.org/study/topics/missionary-work ។

## ជាភាសារបស់អ្នក

*លីអាហូណា* និងឯកសារផ្សេងទៀតរបស់សាសនាចក្រ មានជាច្រើនភាសា សូមចូលទៅកាន់ www.languages.lds.org។

## ប្រធានបទនៅក្នុងទស្សនាវដ្ដីច្បាប់នេះ

*លេខតំណាងឱ្យទំព័រទីមួយនៃអត្ថបទ។*

*ការញៀន 16*
*សិទ្ធិជ្រើសរើស 24, 64*
*ពួកទេវតា 47*
*វិយោបថ 4, 42, 52, 63*
*ព្រះគម្ពីរមរមន 14, 16, 20, 40, 60, 66*
*សេចក្ដីសប្បុរស 7, 12, 32*
*ប្រវត្តិសាស្ត្រសាសនាចក្រ 32*
*ការប្រែចិត្តជឿ 16*
*សេចក្ដីក្លាហាន 4, 8, 57*
*សេចក្ដីសញ្ញា 48*
*គំរូ 52, 54, 57, 70, 72*
*សេចក្ដីជំនឿ 24, 57, 63*
*ក្រុមគ្រួសារ 14, 16, 79*
*ការធ្វើតាមព្រះវិញ្ញាណ 41*
*មិត្តភាព 47, 68*
*គោលដៅ 63*
*ការបង្រៀនតាមផ្ទះ 10*
*សេចក្ដីសង្ឃឹម 4, 16*
*ព្រះយេស៊ូវគ្រីស្ទ 24, 40, 66, 80*
*ភាពជាអ្នកដឹកនាំ 10*
*កិច្ចការផ្សព្វផ្សាយសាសនា 8, 32, 39, 41, 46, 48, 56, 70, 72*
*ម៉ូឆល 52, 54, 55, 56*
*ការអធិស្ឋាន 8, 24, 38, 42, 55, 58, 69*
*ព្យាការី 32*
*ការប្រែចិត្ត 16*
*ការចាប់ចិត្តលើភេទដូចគ្នា 47*
*ការសិក្សាព្រះគម្ពីរ 14, 16, 20, 40, 55, 60*
*ការបម្រើ 10, 12, 24, 32, 38, 46*
*ស្ម៊ីធ, ចច អ័លប៊ើត 32*
*ការបង្រៀន 14, 80*
*ការសាកល្បង 24, 40*
*ការបង្រៀនសួរសុខទុក្ខ 7, 12*

ដោយ ប្រធាន
ថូម៉ាស អេស ម៉នសុន



# រស់នៅក្នុងជីវិតដ៏បរិបូរណ៍

នៅក្នុងការចាប់ផ្ដើមនៃឆ្នាំថ្មីនេះ ខ្ញុំសូមអញ្ជើញពួកបរិសុទ្ធថ្ងៃចុងក្រោយគ្រប់ទីកន្លែង ឱ្យទទួលយកនូវការស្វែងរកផ្ទាល់ខ្លួនមួយ ឧស្សាហ៍ព្យាយាម និងសំខាន់នូវអ្វីដែលខ្ញុំហៅថា ជីវិតដ៏បរិបូរណ៍—ជាជីវិតដែលត្រូវបានបំពេញទៅដោយភាពបរិបូណ៌នៃភាពជោគជ័យ សេចក្ដីល្អ និងពរជ័យទាំងឡាយ ។ គឺដូចជាយើងបានរៀនមូលដ្ឋានគ្រឹះ នៅក្នុងសាលារៀនដែរ ខ្ញុំសូមផ្ដល់នូវគោលការណ៍មូលដ្ឋានគ្រឹះទាំងឡាយរបស់ខ្ញុំ ដើម្បីជួយយើងទាំងអស់គ្នាឱ្យទទួលបាននូវជីវិតដ៏បរិបូណ៌ ។

## សូមមានឥរិយាបទវិជ្ជមាន

*ចំនុចទីមួយ* នៅក្នុងគោលការណ៍មូលដ្ឋានគ្រឹះរបស់ខ្ញុំ គឺសំដៅលើឥរិយាបទ ។ វីល្លៀម ជេមស៍ ជាអ្នកត្រួសត្រាយផ្លូវចិត្តវិទូ និងទស្សនវិទូជនជាតិអាមេរិកាំងម្នាក់ បានសរសេរថា « ការផ្លាស់ប្ដូរដ៏អស្ចារ្យបំផុតនៃសម័យកាលរបស់យើង គឺការរកឃើញថា ដោយការផ្លាស់ប្ដូរឥរិយាបទនៅខាងក្នុងគំនិតរបស់ពួកគេ នោះមនុស្សលោកអាចផ្លាស់ប្ដូរទិដ្ឋភាពខាងក្រៅនៃជីវិតរបស់ពួកគេបានផងដែរ » ។ [1]

អ្វីៗជាច្រើននៅក្នុងជីវិតគឺពឹងផ្អែកទៅលើឥរិយាបទរបស់យើង ។ របៀបដែលយើងជ្រើសរើសដើម្បីមើលអ្វីៗ និងឆ្លើយតបចំពោះអ្នកដទៃ ធ្វើឱ្យកើតមានការផ្លាស់ប្ដូរទាំងអស់នោះ ។ ការធ្វើឱ្យល្អបំផុតតាមដែលយើងអាចធ្វើបាន ហើយបន្ទាប់មកជ្រើសរើសមានភាពសប្បាយរីករាយចំពោះកាលៈទេសៈទាំងឡាយរបស់យើង មិនថាវាជាអ្វីក៏ដោយនោះ អាចនាំមកនូវសន្តិភាព និងការសប្បាយចិត្ត ។

ឆាលលេស ស្វិនឌល—ជាអ្នកនិពន្ធ ជាអ្នកអប់រំ និងជាគ្រូគង្វាលគ្រីស្ទស្ថាន—បានមានប្រសាសន៍ថា ៖ « ចំពោះរូបខ្ញុំ ឥរិយាបទគឺសំខាន់ជាង ... អតីតកាល ... ជាងលុយកាក់ ជាងកាលៈទេសៈ ជាងភាពបរាជ័យ ជាងភាពជោគជ័យទាំងឡាយ ជាងអ្វីៗដែលមនុស្សផ្សេងទៀតគិត ឬនិយាយ ឬធ្វើ ។ វាសំខាន់ជាងអាការៈខាងក្រៅ ទេព្យកោសល្យពីកំណើត ឬជំនាញ ។ វានឹងបង្កើត ឬបំផ្លាញក្រុមហ៊ុនមួយ សាសនាចក្រមួយ និងគេហដ្ឋានមួយបាន ។ អ្វីដែលអស្ចារ្យនោះគឺ យើងមានជម្រើសមួយជារៀងរាល់ថ្ងៃ ចំពោះឥរិយាបទដែលយើងនឹងអោបក្រសោបយកសម្រាប់ថ្ងៃនោះ » ។ [2]

យើងមិនអាចបញ្ជាខ្យល់បានទេ ប៉ុន្តែយើងអាចបង្វែរក្ដោងបាន ។ ដើម្បីបានសុភមង្គល ភាពសុខសាន្ត និងភាពសុខដុមរមនាជាអតិបរិមា សូមឱ្យយើង *ជ្រើសរើស* ឥរិយាបទដ៏វិជ្ជមានមួយ ។



រចនារូបភាពដោយ ស្ទីវ ក្រេប

## សូមជឿលើខ្លួនឯង

*ចំនុចទីពីរ* គឺជឿ—លើខ្លួនឯង លើអ្នកដែលនៅជុំវិញអ្នក និងលើគោលការណ៍ដ៏អស់កល្បទាំងឡាយ ។

ចូរស្មោះត្រង់ជាមួយខ្លួនឯង ជាមួយអ្នកដទៃ និងជាមួយព្រះវរបិតាសួគ៌របស់អ្នក ។ នរណាម្នាក់ដែលមិនស្មោះត្រង់ជាមួយនឹងព្រះ រហូតទាល់តែយឺតពេល នោះគឺជា ខាឌីណាល វូលស៊ី ដែលតាមរយៈ សេកស្ពៀរ នោះជាអ្នកដែលបានចំណាយជីវិតដ៏យូរអង្វែង នៅក្នុងការបម្រើដល់មហាក្សត្របីអង្គ ហើយបានរីករាយជាមួយនឹងទ្រព្យសម្បត្តិ និងអំណាច ។ នៅទីបំផុត គាត់ត្រូវបានកាត់ផ្ដាច់នូវអំណាច និងទ្រព្យសម្បត្តិរបស់គាត់ ដោយស្ដេចដ៏ឆេវឆាវមួយអង្គ ។ ខាឌីណាល វូលស៊ី បានស្រែកយំថា ៖

*តើខ្ញុំមិនបានបម្រើព្រះរបស់ខ្ញុំតែពាក់កណ្ដាលកម្លាំងទេឬអី*
*ខ្ញុំបានបម្រើស្ដេចរបស់ខ្ញុំ ទ្រង់មិនទាំងមានព្រះជន្មវស្សារបស់ខ្ញុំផង*
*បានទុកឱ្យខ្ញុំនៅអាក្រាតចំពោះសត្រូវរបស់ខ្ញុំ ។*[3]

ថូម៉ាស ហ្វូលល័រ ជាសង្ឃ និងជាប្រវត្តិវិទូជនជាតិអង់គ្លេសម្នាក់ ដែលបានរស់នៅក្នុងសត្សវត្សទី 17 បានសរសេរសេចក្ដីពិតនេះថា ៖ « គាត់មិនជឿថា នោះមិនបានរស់នៅតាមជំនឿរបស់គាត់នោះទេ » ។[4]

ចូរកុំដាក់កម្រិតខ្លួនឯង និងកុំបណ្ដោយឱ្យអ្នកដទៃធ្វើឱ្យអ្នកជឿថា អ្នកនៅមានកម្រិតក្នុងអ្វីដែលអ្នកអាចធ្វើបាននោះឡើយ ។ សូមជឿលើខ្លួនឯង ហើយបន្ទាប់មករស់នៅដូច្នោះ ដើម្បីឈានទៅដល់លទ្ធភាពទាំងឡាយរបស់អ្នក ។

អ្នកអាចសម្រេចបាននូវអ្វីដែលអ្នកជឿថា អ្នកអាចធ្វើបាន ។ សូមទុកចិត្ត ហើយជឿជាក់ និងមានសេចក្ដីជំនឿ ។

## ប្រឈមមុខនឹងឧបសគ្គទាំងឡាយដោយសេចក្ដីក្លាហាន ។

សេចក្ដីក្លាហានក្លាយជាគុណសម្បត្តិមួយដ៏មានតម្លៃ និងដ៏មានអត្ថន័យ នៅពេលដែលវាមិនត្រូវបានធ្វើឱ្យទាក់ទងខ្លាំងទៅនឹងឆន្ទៈដើម្បីស្លាប់ដោយក្លាហាន ប៉ុន្តែជាការប្ដេជ្ញាចិត្តដើម្បីរស់នៅដោយត្រឹមត្រូវ ។

អ្នកនិពន្ធអត្ថបទខ្លីៗ និងអ្នកនិពន្ធកំណាព្យជនជាតិអាមេរិកាំងម្នាក់ឈ្មោះ រ៉ាហ្វ វ៉ាលដូ អិមើសុន បានមានប្រសាសន៍ថា ៖ « អ្វីក៏ដោយដែលអ្នកធ្វើ គឺអ្នកត្រូវការសេចក្ដីក្លាហាន ។ មិនថាអ្វីដែលអ្នកសម្រេចចិត្តនោះទេ តែងតែមាននរណាម្នាក់ប្រាប់ថា អ្នកខុស ។ តែងតែមានការលំបាកទាំងឡាយកើតឡើងដែលល្បួងអ្នកឱ្យជឿថា អ្នករិះគន់អ្នកគឺត្រឹមត្រូវ ។ ដើម្បីរៀបចំផែនការណ៍នៃវគ្គនៃសកម្មភាពមួយ ហើយអនុវត្តតាមដល់ទីបញ្ចប់នោះ តម្រូវឱ្យមាននូវសេចក្ដីក្លាហានដូចគ្នានឹងទាហានម្នាក់ត្រូវការដែរ ។ សេចក្ដីសុខសាន្តមាននូវជ័យជំនះរបស់វា ប៉ុន្តែវាត្រូវការបុរស និងស្ត្រីដ៏ក្លាហានដើម្បីយកបានជ័យជំនះទាំងនោះ » ។[5]

នឹងមានពេលវេលាទាំងឡាយដែលអ្នកនឹងមានចិត្តភ័យខ្លាច និងបាក់ទឹកចិត្ត ។ អ្នកអាចមានអារម្មណ៍ថា អ្នកទទួលបរាជ័យ ។ ឱកាសនៃការទទួលបានជ័យជំនះអាចមើលទៅដូចជាពិបាកពេក ។ ពេលខ្លះ អ្នកអាចមានអារម្មណ៍ដូចជា ដាវីឌ កំពុងតែព្យាយាមប្រយុទ្ធជាមួយនឹងកូលីយ៉ាត អញ្ចឹង ។ ប៉ុន្តែ ចូរចងចាំថា—ដាវីឌ *ពិតជាបាន* ឈ្នះ !

សេចក្ដីក្លាហានតម្រូវឱ្យមានការផ្ដួចផ្ដើមនូវកម្លាំងរុញច្រានមួយ ឆ្ពោះទៅគោលដៅដែលជនម្នាក់ប៉ងចង់បានយ៉ាងខ្លាំង ប៉ុន្តែវាតម្រូវឱ្យមានសេចក្ដីក្លាហានដែលកាន់តែខ្លាំងជាងមុនទៀត នៅពេលដែលនរណាម្នាក់ជំពប់ជើងដួល ហើយត្រូវតែខំប្រឹងប្រែងជាលើកទីពីរ ដើម្បីសម្រេចបានគោលដៅនោះ ។

សូមមានការប្ដេជ្ញាចិត្ត ដើម្បីខំប្រឹងប្រែង មានគំនិតចូលជាធ្លុងតែមួយ ដើម្បីធ្វើឱ្យសម្រេចនូវគោលដៅដ៏សក្ដិសមមួយ ហើយសេចក្ដីក្លាហានមិនត្រឹមតែដើម្បីប្រឈមមុខជាមួយនឹងឧបសគ្គទាំងឡាយដែលមានដោយចៀសមិនរួចប៉ុណ្ណោះទេ ប៉ុន្តែដើម្បីធ្វើការខិតខំប្រឹងប្រែងជាលើកទីពីរផងដែរ គឺគប្បីតម្រូវឱ្យមាននូវសេចក្ដីក្លាហានបែបនោះ ។ ជួនកាល សេចក្ដីក្លាហានគឺជាសម្លេងដ៏តូច នៅចុងបញ្ចប់នៃថ្ងៃនោះ ដែលនិយាយថា « ខ្ញុំនឹងព្យាយាមម្ដងទៀតនៅថ្ងៃស្អែក » ។

សូមឱ្យយើងចងចាំនូវ មូលដ្ឋានគ្រឹះទាំងនេះ កាលដែលយើងចាប់ផ្ដើមដំណើររបស់យើងទៅក្នុងឆ្នាំថ្មីនេះ បណ្ដុះនូវឥរិយាបទវិជ្ជមានមួយ បណ្ដុះនូវជំនឿមួយដែលថា យើងអាចសម្រេចបាននូវគោលដៅ និងការតាំងចិត្តទាំងឡាយរបស់យើង ហើយនិងបណ្ដុះនូវសេចក្ដីក្លាហានដើម្បីប្រឈមជាមួយនឹងឧបសគ្គអ្វីក៏ដោយដែលអាចមាននៅលើផ្លូវរបស់យើង ។ បន្ទាប់មកជីវិតដ៏បរិបូរណ៍នឹងជារបស់យើង ។ ■

### កំណត់ចំណាំ

1. វិល្លៀម ជេមស៍ នៅក្នុង Lloyd Albert Johnson, comp., *A Toolbox for Humanity: More Than 9000 Years of Thought* (2003), ទំព័រ 127 ។
2. ឆាលលេស ស្វិនឌល នៅក្នុង Daniel H. Johnston, *Lessons for Living* (2001), ទំព័រ 29 ។
3. វិល្លៀម សេកស្ពៀរ *King Henry the Eighth,* ការសម្ដែងវគ្គទី 3, ឆុតទី 2, បន្ទាត់ទី 456–58 ។
4. ថូម៉ាស ហ្វូលល័រ នៅក្នុង H. L. Mencken, ed., *A New Dictionary of Quotations* (1942), ទំព័រ 96 ។
5. រ៉ាហ្វ វ៉ាលដូ អិមើសុន នៅក្នុង Roy B. Zuck, *The Speaker's Quote Book* (2009), ទំព័រ 113 ។

## ការបង្រៀនចេញពីសារលិខិតនេះ

សូមពិចារណាពីការអញ្ជើញសមាជិកគ្រួសារឱ្យចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន នៅពេលដែលឥរិយាបទវិជ្ជមាន ការជឿលើខ្លួនពួកគេ ឬសេចក្ដីក្លាហានបានជួយពួកគេ ។ ឬអញ្ជើញពួកគេឱ្យរកមើលគំរូទាំងឡាយនៃគោលការណ៍ទាំងបីនេះនៅក្នុងព្រះគម្ពីរ ។ អ្នកអាចរៀបចំដើម្បីបង្រៀន ដោយការគិតពីព្រះគម្ពីរ ឬបទពិសោធន៍ផ្ទាល់ខ្លួនទាំងឡាយរបស់អ្នកប្រកបដោយការអធិដ្ឋាន ។

## យុវវ័យ

# សេចក្ដីក្លាហានដើម្បីពុះពារនឹងខ្យល់ព្យុះ

ដោយ មេដឌីសុន ម៉លី

នៅយប់ទីពីរនៃការបោះជំរុំក្រុមយុវនារីស្តេករបស់ខ្ញុំ មានភ្លៀងព្យុះ និងខ្យល់គួចយ៉ាងធំ ។ វួដរបស់ខ្ញុំមានយុវនារីប្រហែលជា 24 នាក់ ដែលចូលរួមនៅក្នុងការបោះជំរុំនោះ ជាមួយនឹងអ្នកដឹកនាំពីរនាក់ ហើយយើងទាំងអស់គ្នាត្រូវតែនៅក្នុងខ្ទមដ៏តូចមួយដើម្បីការពារខ្លួន ។ ភ្លៀងធ្លាក់មកយ៉ាងខ្លាំង ហើយខ្យល់ក៏កាន់តែបក់បោកខ្លាំងឡើងៗ ។ ខ្ញុំត្រូវតែបន្តរំឭកខ្លួនឯងអំពីការអធិស្ឋានសម្រាប់សុវត្ថិភាព ដែលប្រធានស្តេករបស់យើងបានអធិស្ឋានពីមុននោះ ។ វួដរបស់យើងក៏បានអធិដ្ឋានជាក្រុមផ្ទាល់របស់យើងផងដែរ នៅក្នុងខ្ទមរបស់យើង ហើយខ្ញុំបានអធិស្ឋានផ្ទាល់ខ្លួនខ្ញុំផងដែរ ។

ក្មេងស្រីជាច្រើននាក់បានមានការភ័យខ្លាច ហើយវាងាយនឹងប្រាប់បាន ថាហេតុអ្វីពួកគេមានការភ័យខ្លាច ។ ខ្ទមរបស់យើងមិនសូវជារឹងមាំប៉ុន្មានទេ ហើយយើងនៅក្បែរមាត់ស្ទឹងតែម្តង ។ ក្នុងរយៈពេលប្រហែល 20 នាទី ខ្យល់ព្យុះបានប្រែជាអាក្រក់ខ្លាំងទៅ រហូតដល់ស្តេកទាំងមូលត្រូវតែរត់ចេញពីខ្ទមវួដរបស់ពួកគេ ទៅកាន់ខ្ទមរបស់ទីប្រឹក្សាទាំងឡាយដែលនៅលើទីខ្ពស់ ។ ប្រធានស្តេករបស់ខ្ញុំបានអធិស្ឋានម្តងទៀត ហើយយើងបានច្រៀងចម្រៀងទំនុកតម្កើង ចម្រៀងកុមារ និងចម្រៀងសម្រាប់បោះជំរុំ ក្នុងការព្យាយាមដើម្បីលួងលោមខ្លួនឯង ។ មែនហើយ យើងបានភ័យខ្លាច ប៉ុន្តែយើងបានទទួលអារម្មណ៍ថា អ្វីៗនឹងមិនអីទេ ។ កន្លះម៉ោងក្រោយមក វាមិនមានបញ្ហាអ្វីទេក្នុងការត្រឡប់ទៅកាន់ខ្ទមវួដរបស់ពួកយើងវិញ ។

ក្រោយមក យើងបានដឹងថា អ្វីបានកើតឡើងចំពោះខ្យល់គួចនៅយប់នោះ ។ ព្យុះបានបំបែកចេញជាពីរ ។ ព្យុះមួយក្នុងចំណោមព្យុះទាំងពីរនោះ គួចបក់នៅជុំវិញពួកយើងទៅខាងស្តាំ ហើយមួយទៀតទៅខាងឆ្វេង ។ ព្យុះដែលយើងបានជួប គឺមិនមែនជាព្យុះដ៏អាក្រក់បំផុតនោះឡើយ !

ខ្ញុំដឹងថា ព្រះបានឮការអធិស្ឋានទាំងឡាយរបស់យើងនៅយប់នោះ ហើយថាទ្រង់បានការពារយើងពីព្យុះដ៏អាក្រក់បំផុតនោះ ។ ហេតុអ្វីខ្យល់គួចបំបែកជាពីរលើកលែងតែព្រះបានធ្វើដូច្នោះ ? ខ្ញុំដឹងថា នៅក្នុងព្យុះនៃជីវិត យើងអាចអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ជានិច្ច ហើយទ្រង់នឹងឮ ហើយឆ្លើយតបយើង ផ្តល់សេចក្តីក្លាហានដល់យើង និងការការពារ ដែលយើងត្រូវការដើម្បីឆ្លងកាត់វាដោយសុវត្ថិភាព ។



រូបថត © CORBIS

## កុមារ

# មេទ័ពមរ៉ូណៃ

មេទ័ពមរ៉ូណៃបានមានសេចក្តីក្លាហាន កាលដែលលោកបានប្រឈមមុខនឹងឧបសគ្គទាំងឡាយ ។ លោកស្រឡាញ់នូវសេចក្តីពិត ឥស្សរភាព និងសេចក្តីជំនឿ ។ លោកបានឧទ្ទិសជីវិតរបស់លោកក្នុងការជួយដល់ពួកសាសន៍នីហ្វៃ ការពារសេរីភាពរបស់ពួកគេ ។ អ្នកអាចក្លាយដូចជាមេទ័ពមរ៉ូណៃបាន ដោយការប្រឈមមុខជាមួយឧបសគ្គទាំងឡាយរបស់អ្នកដោយសេចក្តីក្លាហាន ។ អ្នកក៏អាចធ្វើទង់ជ័យនៃឥស្សរភាពរបស់អ្នកផ្ទាល់ ដោយការសរសេរនៅលើទង់ខាងក្រោមនេះ ឬនៅលើក្រដាសដោយឡែកមួយ នូវអ្វីៗដែលសំខាន់ដល់អ្នក និងក្រុមគ្រួសាររបស់អ្នក ។



**កន្លែងដែលត្រូវស្វែងរកបន្ថែមទៀត**

**អាលម៉ា 46:11–27** ទង់ជ័យនៃឥស្សរភាព

**អាលម៉ា 48:11–13, 16–17** គុណសម្បត្តិរបស់មរ៉ូណៃ

*សូមសិក្សាឯកសារនេះ ហើយបើអាចធ្វើទៅបាន សូមពិភាក្សាវាជាមួយនឹងបងប្អូនស្ត្រីដែលអ្នកចុះទៅសួរសុខទុក្ខ ។ សូមប្រើសំណួរទាំងឡាយដើម្បីជួយអ្នកពង្រឹងដល់បងប្អូនស្ត្រីរបស់អ្នក និងធ្វើឱ្យសមាគមសង្គ្រោះក្លាយទៅជាផ្នែកមួយដ៏សកម្មនៅក្នុងជីវិតផ្ទាល់របស់អ្នក ។*

សេចក្តីជំនឿ, ក្រុមគ្រួសារ, ការសង្គ្រោះ

# ការថែរក្សា និងការបម្រើតាមរយៈការបង្រៀនសួរសុខទុក្ខ



ប្រធាន ហិនរី ប៊ី អាវរិង ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ បានបង្រៀនថា « សេចក្តីសប្បុរស [ មានន័យ ] ជ្រាលជ្រៅជាងអារម្មណ៍នៃការសណ្តោសប្រណីមួយទៅទៀត » ។ « សេចក្តីសប្បុរសគឺបានកើតមកពីសេចក្តីជំនឿទៅលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងជាផលមួយនៃដង្វាយធួនរបស់ទ្រង់ ។ [1] សម្រាប់បងប្អូនស្ត្រី ការបង្រៀនសួរសុខទុក្ខអាចជាសេចក្តីសប្បុរសដែលនៅក្នុងទង្វើ ជារបៀបមួយដ៏សំខាន់ ដើម្បីអនុវត្តសេចក្តីជំនឿរបស់យើងទៅលើព្រះអង្គសង្គ្រោះ ។

តាមរយៈការបង្រៀនសួរសុខទុក្ខ យើងផ្តល់នូវការថែរក្សាដោយការទំនាក់ទំនងទៅបងប្អូនស្ត្រីម្នាក់ៗ ចែកចាយសារលិខិតនៃដំណឹងល្អ និងស្វែងយល់ពីតម្រូវការរបស់គាត់ និងក្រុមគ្រួសាររបស់គាត់ ។ បងស្រី ជូលី ប៊ី ប៊េក ជាប្រធានសមាគមសង្គ្រោះទូទៅ បានពន្យល់ថា « ការបង្រៀនសួរសុខទុក្ខក្លាយជាកិច្ចការរបស់ព្រះអម្ចាស់ នៅពេលដែលការយកចិត្តទុកដាក់របស់យើងផ្តោតទៅលើមនុស្ស ជាជាងភាគរយ » ។ « នៅក្នុងភាពពិតការបង្រៀនសួរសុខទុក្ខគឺមិនដែលចប់ឡើយ ។ វាជាផ្លូវមួយនៃជីវិត ជាជាងជាភារកិច្ចមួយ ។ ការបម្រើដោយស្មោះត្រង់ ក្នុងនាមជាគ្រូសួរសុខទុក្ខ គឺជាភស្តុតាងនៃភាពជាសិស្សរបស់យើង » ។ [2]

កាលដែលយើងផ្តល់នូវការថែរក្សាជាបន្តបន្ទាប់ និងដោយការអធិស្ឋាន នោះយើងរៀនពីរបៀបដើម្បីបម្រើ និងដើម្បីបំពេញទៅតាមតម្រូវការរបស់បងប្អូនស្ត្រីម្នាក់ៗ និងក្រុមគ្រួសាររបស់គាត់ឱ្យបានល្អបំផុត ។ ការបម្រើអាចមានទម្រង់ជាច្រើន—ខ្លះធំ ហើយខ្លះទៀតមិនសូវជាធំទេ ។ ប្រធាន ថូម៉ាស អេស ម៉ នសុន បានបង្រៀនថា « ជាញឹកញាប់ ទង្វើដ៏តូចនៃការបម្រើ គឺជាអ្វីទាំងអស់ដែលតម្រូវឱ្យមាន ដើម្បីលើក និងផ្តល់ពរជ័យដល់អ្នកផ្សេងទៀត ៖ សំណួរមួយទាក់ទងទៅនឹងក្រុមគ្រួសាររបស់មនុស្សម្នាក់ ពាក្យសម្តីនៃការលើកទឹកចិត្តខ្លីៗ ការលើកសរសើរដោយស្មោះត្រង់ សំបុត្រថ្លែងអំណរគុណដ៏តូចមួយ ការទូរស័ព្ទដ៏ខ្លីមួយ » ។ « ប្រសិនបើយើងធ្វើតាម ហើយយល់ដឹង ហើយប្រសិនបើយើងធ្វើតាមការបំផុសគំនិត ដែលបំផុសដល់យើង នោះយើងអាចសម្រេចបានល្អច្រើនណាស់ ។ ... ទង្វើនៃការបម្រើដែលផ្តល់ដោយកងទ័ពដ៏ធំនៃគ្រូសួរសុខទុក្ខរបស់សមាគមសង្គ្រោះ គឺមិនអាចរាប់អស់បានឡើយ ។ [3]

## ចេញពីព្រះគម្ពីរ

យ៉ូហាន 13:15, 34–35; 21:15; ម៉ូសាយ 2:17; គោលលទ្ធិ និងសេចក្តីសញ្ញា 81:5; ម៉ូសេ 1:39

## ចេញពីប្រវត្តិសាស្ត្ររបស់យើង

នៅក្នុងឆ្នាំ 1843 សមាជិកសាសនាចក្រនៅទីក្រុង ណៅវូ រដ្ឋ អិលលីណោយ ត្រូវបានបែងចែកចេញជាបួនវួដ ។ នៅក្នុងខែ កក្កដា ឆ្នាំនោះដែរ អ្នកដឹកនាំសមាគមសង្គ្រោះបានចាត់តាំងគណៈកម្មការចុះសួរសុខទុក្ខមួយ ដែលមានបងប្អូនស្ត្រីបួននាក់ប្រចាំវួដនីមួយៗ ។ ការទទួលខុសត្រូវរបស់គណៈកម្មការចុះសួរសុខទុក្ខរួមមាន ធ្វើការវាយតម្លៃទៅលើសេចក្តីត្រូវការទាំងឡាយ និងប្រមូលការបរិច្ចាគនានា ។ សមាគមសង្គ្រោះបានប្រើការបរិច្ចាគទាំងនេះ ដើម្បីផ្តល់ដល់អ្នកក្រីក្រខ្វះខាត ។ [4]

ពេលដែលគ្រូសួរសុខទុក្ខមិនប្រមូលការបរិច្ចាគទៀតទេ នោះពួកគេនៅតែមានការទទួលខុសត្រូវ ដើម្បីស្ទង់មើលពីសេចក្តីត្រូវការទាំងឡាយ—ខាងព្រលឹងវិញ្ញាណ និងខាងសាច់ឈាម—និងដើម្បីធ្វើកិច្ចការឱ្យបំពេញទៅតាមនឹងសេចក្តីត្រូវការទាំងនោះ ។ អ៊ីឡៃស្សា អរ ស្នូ ( 1804–87 ) ជាប្រធានសមាគមសង្គ្រោះទូទៅទីពីរ បានពន្យល់ថា ៖ « គ្រូម្នាក់ ... គួរតែមានព្រះវិញ្ញាណនៃព្រះអម្ចាស់ច្រើនជាប្រាកដកាលដែលគាត់ចូលទៅក្នុងផ្ទះមួយ ដើម្បីស្គាល់ពីវិញ្ញាណអ្វីដែលគាត់ជួបនៅក្នុងទីនោះ ។ ... សូមអង្វរចំពោះព្រះ និងព្រះវិញ្ញាណបរិសុទ្ធ ដើម្បីទទួល [ ព្រះវិញ្ញាណ ] ដើម្បីឱ្យអ្នកអាចជួបនឹងព្រះវិញ្ញាណនោះ ដែលគង់នៅក្នុងផ្ទះនោះ ... ហើយអ្នកអាចមានអារម្មណ៍ដើម្បីនិយាយនូវពាក្យនៃសេចក្តីសុខសាន្ត និងការលួងលោម ហើយប្រសិនបើអ្នកឃើញថា អារម្មណ៍របស់បងប្អូនស្រីម្នាក់រងា នោះសូមដាក់គាត់នៅក្នុងដួងចិត្តរបស់អ្នក ដូចជាអ្នកនឹងផ្តោបកូនតូចម្នាក់ទៅនឹងដើមទ្រូងរបស់អ្នក ហើយធ្វើឱ្យ [ នាង ] មានភាពកក់ក្តៅឡើង » ។ [5]

កំណត់ចំណាំ
1. ហិនរី ប៊ី អាវរិង "The Enduring Legacy of Relief Society," *Liahona*, Nov. 2009, ទំព័រ 121 ។
2. ជូលី ប៊ី ប៊េក "Relief Society: A Sacred Work," *Liahona*, Nov. 2009, ទំព័រ 114 ។
3. ថូម៉ាស អេស ម៉ នសុន "Three Goals to Guide You," *Liahona*, Nov. 2007, ទំព័រ 120–21 ។
4. សូមមើល *Daughters in My Kingdom: The History and Work of Relief Society* (2011), ទំព័រ 105 ។
5. អ៊ីឡៃស្សា អរ ស្នូ នៅក្នុង *Daughters in My Kingdom*, ទំព័រ 108 ។

## តើខ្ញុំអាចធ្វើអ្វីបាន ?

1. តើខ្ញុំកំពុងធ្វើអ្វីដើម្បីជួយបងប្អូនស្រីរបស់ខ្ញុំទទួលអារម្មណ៍ថា ខ្ញុំជាមិត្តម្នាក់ដែលស្រឡាញ់ និងខ្វល់ខ្វាយពីពួកគាត់ ?

2. តើខ្ញុំអាចក្លាយកាន់តែប្រសើរឡើងក្នុងការថែរក្សា និងខ្វល់ខ្វាយចំពោះអ្នកដទៃដោយរបៀបណា ?

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ www.reliefsociety.lds.org។

រូបថតដោយ ម៉ាតធ្យូ រៀរ

# សៀវភៅកំណត់ចំណាំ **សន្និសីទខែតុលា**

*«អ្វីដែលយើងជាព្រះអម្ចាស់បានមានបន្ទូល នោះយើងបានមានបន្ទូលហើយ ... ទោះជាដោយសម្លេងរបស់យើងផ្ទាល់ ឬក៏ដោយសម្លេងនៃពួកអ្នកបំរើរបស់យើងក្តី គឺដូចតែគ្នា» ( គ. និង ស. 1:38 )។*

នៅពេលអ្នកមើលសន្និសីទទូទៅខែតុលា ឆ្នាំ 2011 អ្នកអាចមើលឃើញទំព័រទាំងនេះ (និងសៀវភៅកំណត់ចំណាំសន្និសីទនៅក្នុងច្បាប់ទស្សនាវដ្ដីនាពេលអនាគត ) ដើម្បីជួយអ្នកសិក្សា និង អនុវត្តការបង្រៀនថ្មីៗរបស់ពួកព្យាការី និង ពួកសាវកដែលនៅរស់ ។



**រឿងចេញមកពីសន្និសីទ**

# មិនខ្លាចនឹងឈរតែម្នាក់ឯង

«បទពិសោធន៍ដំបូងរបស់ខ្ញុំ ខ្ញុំជឿលើការមានភាពក្លាហានក្នុងភាពជឿជាក់របស់ខ្ញុំ ដែលកើតមាន ពេលខ្ញុំបម្រើក្នុងទ័ពជើងទឹករបស់អាមេរិកនៅចុងសង្គ្រាមលោកលើកទី II ។ ...

« ខ្ញុំតែងចាំជានិច្ច ពេលថ្ងៃអាទិត្យបានមកដល់ បន្ទាប់ពីសប្តាហ៍ដំបូង [ នៃការបោះជំរុំហាត់ទាហាន ] ។ យើងបានទទួលដំណឹងដ៏រីករាយមកពីមន្រ្តីតែងតាំងជាន់ខ្ពស់ម្នាក់ ។ ដោយឈរយ៉ាងម៉ឺងម៉ាត់នៅលើទីលានក្នុងខ្យល់ដ៏ត្រជាក់មួយនៃរដ្ឋ កាលីហ្វូញ៉ា យើងបានឮបញ្ជារបស់គាត់ថា ៖ « ថ្ងៃនេះ អ្នករាល់គ្នាទៅព្រះវិហារ—អ្នករាល់គ្នាត្រូវទៅ លើកលែងតែខ្ញុំម្នាក់ប៉ុណ្ណោះ ។ ខ្ញុំត្រូវសម្រាក !’ បន្ទាប់មកគាត់ស្រែកថា ‘អ្នកទាំងអស់ណាដែលជាពួកកាតូលិក អ្នកជួបជុំគ្នានៅជំរុំដេកាទើរ— ហើយកុំត្រឡប់មកវិញរហូតដល់ម៉ោងបី ។ បោះជំហានដើរទៅមុខ !’ មានមនុស្សមួយក្រុមធំបានធ្វើតាមបញ្ជាគាត់ ។ រួចហើយគាត់ស្រែកបញ្ជាទៀតថា ៖ ‘អ្នកទាំងអស់ណាដែលជាសាសនាយូដា អ្នកជួបនៅជំរុំ ហែនរី—រហូតដល់ម៉ោងបីចាំត្រឡប់មកវិញ ។ បោះជំហានដើរទៅមុខ !’ មានមនុស្សមួយក្រុមតូចបានធ្វើតាមបញ្ជាគាត់ ។ រួចហើយគាត់និយាយថា ‘អ្នកដែលជាពួកប្រូតេស្តង់ អ្នកជួបនៅជំរុំ ហ្វារ៉ាហ្គាត់— រហូតដល់ម៉ោងបីចាំត្រឡប់មកវិញ ។ បោះជំហានដើរទៅមុខ !’

*ខ្ញុំមិនបានដឹងថាមានមនុស្សផ្សេងទៀតកំពុងឈរពីក្រោយខ្ញុំលើទីលាននោះឡើយ រហូតដល់ពេលនោះ ។*



« រំពេចនោះស្រាប់តែមានគំនិតកើតឡើងចំពោះខ្ញុំថា ‘ម៉នសុន អ្នកមិនមែនជាកាតូលិក អ្នកមិនមែនជា យូដា អ្នកមិនមែនជាប្រូតេស្តង់ ។ អ្នកជាមរមន ដូច្នេះអ្នកត្រូវឈរនៅទីនេះ !’ ខ្ញុំអាចអះអាងចំពោះអ្នកថា ខ្ញុំពិតជាមានអារម្មណ៍ឯកោមែន ។ ខ្ញុំពិតជាមានអារម្មណ៍ក្លាហាន និងការតាំងចិត្តមែន — តែក៏មានភាពឯកោដែរ ។

រួចហើយ ខ្ញុំបានឮសម្លេងដ៏ផ្អែមល្ហែមបំផុតដែលខ្ញុំពុំធ្លាប់ឮមន្រ្តីតែងតាំងជាន់ខ្ពស់នោះនិយាយពីមុនឡើយ ។ គាត់បានមើលមកខ្ញុំ ហើយសួរថា « ចុះពួកអ្នកហៅខ្លួនឯងជាអ្វីទៅ ? » ខ្ញុំមិនបានដឹងថាមានមនុស្សផ្សេងទៀតកំពុងឈរពីក្រោយខ្ញុំលើទីលាននោះឡើយ រហូតដល់ពេលនោះ ។ យើងម្នាក់ៗបានឆ្លើយស្ទើរតែព្រមគ្នាថា ‘ពួកមរមន !’ វាពិបាកណាស់ ដើម្បីរៀបរាប់ពីក្តីអំណរដែលមានក្នុងដួងចិត្តខ្ញុំ ពេលខ្ញុំក្រឡេកមើល ហើយឃើញពួកអ្នកបើកកប៉ាល់មួយក្រុមតូចផ្សេងទៀតនោះ ។

« មន្រ្តីតែងតាំងជាន់ខ្ពស់រូបនោះបានយកដៃអេះក្បាលក្នុងអារម្មណ៍នៃភាពប្រច្ចូកច្របល់ តែទីបំផុតបាននិយាយថា ‘ឥឡូវ ទៅរកកន្លែងមួយដើម្បីជួបគ្នាចុះ ។ ហើយចាំរហូតដល់ម៉ោងបីចាំត្រឡប់មកវិញ ។ បោះជំហានដើរទៅមុខ !’ ...

ទោះជាបទពិសោធន៍នោះចេញលទ្ធផលមកខុសពីអ្វីដែលខ្ញុំបានរំពឹងទុកក្តី ក៏ខ្ញុំសុខចិត្តឈរម្នាក់ឯងដែរ បើវាចាំបាច់នោះ ។

« ចាប់ពីថ្ងៃនោះមក មានពេលខ្លះគឺគ្មាននរណាម្នាក់សោះឈរនៅពីក្រោយខ្ញុំឡើយ ដូច្នេះហើយខ្ញុំ *ត្រូវ* ឈរតែម្នាក់ឯង ។ ខ្ញុំមានអំណរអ្វីម្លេះ ដែលខ្ញុំបានធ្វើការសម្រេចចិត្តជាយូរយារមកហើយ ដើម្បីបន្តរឹងមាំ ហើយស្មោះត្រង់ ដោយតែងរៀបចំខ្លួនជាស្រេចដើម្បីការពារសាសនារបស់ខ្ញុំ បើវាចាំបាច់នោះ » ។

**ប្រធាន ថូម៉ាស អេស ម៉នសុន « Dare to Stand Alone » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2011, 61–62 ។**

## សំណួរដើម្បីពិចារណា ៖

- តើការឈរដ៏រឹងមាំរបស់យើង មានឥទ្ធិពលអ្វីខ្លះដល់អ្នកដទៃ ?
- តើអ្នកអាចនៅចាំអំពីគ្រាមួយ ដែលភាពក្លាហាន និង ជំនឿស៊ប់របស់អ្នកត្រូវបានសាកល្បងដែរឬទេ ? តើអ្នកឆ្លើយតបដោយរបៀបណា ?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីរៀបចំខ្លួនយើងឱ្យឈររឹងមាំ ?

ចូរពិចារណាសរសេរគំនិតរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុ ឬពិភាក្សាជាមួយនឹងអ្នកដទៃ ។

ធនធានបន្ថែមអំពីប្រធានបទនេះ ៖ សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « Courage, Courageous » ថូម៉ាស អេស. ម៉នសុន, « The Call for Courage, » *Liahona* ខែ ឧសភា ឆ្នាំ 2004, 54–57; សិក្សាតាមប្រធានបទនៅ LDS.org, «សម្ពាធមិត្តភក្តិ» *កូនសៀវភៅដើម្បីកម្លាំងនៃយុវជន*

**ដើម្បីអាន មើល ឬស្តាប់ ប្រសាសន៍ក្នុងសន្និសីទទូទៅ សូមទស្សនា conference.lds.org**

# ទៅ ហើយធ្វើ

ខែ អលឌើរ អិល ថមភើរី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា ដើម្បីពន្លឿនការយល់ដឹងអំពីសាសនាចក្រ យើងគួរតែ ៖

ចេញមកពី « Perfect Love Casteth Out Fear » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2011, 42–43 ។



1. « ចូរម៉ឺងម៉ាត់នៅក្នុងការប្រកាសរបស់យើងអំពីព្រះយេស៊ូវគ្រីស្ទ ។ យើងចង់ឱ្យអ្នកដទៃដឹងថា យើងជឿថា ទ្រង់គឺជាតួអង្គដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សលោកគ្រប់គ្នា » ។



2. « ធ្វើជាគំរូសុចរិតចំពោះអ្នកដទៃ ។ ... ជីវិតរស់នៅរបស់យើង គួរតែធ្វើជាគំរូនៃសេចក្ដីល្អ និង គុណធម៌ នៅពេលយើងព្យាយាមដើម្បីធ្វើតាមគំរូរបស់ទ្រង់ចំពោះពិភពលោក» ។



3. « និយាយអំពីសាសនាចក្រ ។ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង យើងត្រូវបានប្រទានពរឱ្យឱកាសជាច្រើនដើម្បីចែកចាយជំនឿរបស់យើងជាមួយអ្នកដទៃ » ។

# ការសន្យានៃការព្យាករណ៍

« គ្មានមួយថ្ងៃណាដែលខ្ញុំពុំបានទំនាក់ទំនងជាមួយនឹងព្រះវរបិតាសួគ៌របស់ខ្ញុំ តាមរយៈការអធិស្ឋាននោះទេ ។ វាគឺជាការទំនាក់ទំនងមួយ ដែលខ្ញុំពេញចិត្ត—ខ្ញុំនឹងវង្វេងបើគ្មានទំនាក់ទំនងមួយនេះទេ។ ឥឡូវបើអ្នកមិនមានទំនាក់ទំនងជាមួយព្រះវរបិតាសួគ៌របស់អ្នកទេ ខ្ញុំសូមជម្រុញឱ្យអ្នកធ្វើការខិតខំឆ្ពោះទៅរកគោលដៅនោះ ។ នៅពេលអ្នកធ្វើដូច្នេះ អ្នកនឹងទទួលបានការបំផុសគំនិត និង ការដឹកនាំរបស់ទ្រង់នៅក្នុងជីវិតរបស់អ្នក—ដែលចាំបាច់សម្រាប់យើងម្នាក់ៗ បើសិនជាយើងត្រូវមានជីវិតរស់នៅខាងវិញ្ញាណ អំឡុងពេលការសម្រាករបស់យើងពីលើផែនដីនេះ ។ ការបំផុសគំនិត និងការដឹកនាំដូច្នេះ គឺជាអំណោយទានដែលទ្រង់ប្រទានដល់យើងដោយសេរី បើសិនជាយើងស្វែងរកទ្រង់នោះ » ។

ប្រធាន ថូម៉ាស អេស ម៉នសុន « Stand in Holy Places » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2011, 84។

## បំពេញក្នុងចន្លោះទំនេរ

1. « ចូរសិក្សាប្រកបដោយការអធិស្ឋានអំពី ____________ នឹងស្ថាបនាសេចក្ដីជំនឿទៅលើព្រះជាព្រះបិតា ទៅលើព្រះរាជបុត្រាសំណព្វរបស់ទ្រង់ និងដំណឹងល្អរបស់ទ្រង់ ។ វានឹងស្ថាបនាសេចក្ដីជំនឿរបស់អ្នកទៅលើព្យាការីរបស់ព្រះ ទាំងពីបុរាណ និង សម័យទំនើប ។ វាអាចនាំអ្នកខិតទៅជិតនឹងព្រះជាជាងសៀវភៅណាៗទាំងអស់ ។ វាអាចផ្លាស់ប្ដូរជីវិតឱ្យល្អប្រសើរឡើង » ។ (ហែនរី ប៊ី អាវរិង «A Witness,» *Liahona* ខែវិច្ឆិកា ឆ្នាំ 2011, 70) ។
2. « ____________ ក្លាយជាមិត្តដ៏ខ្ជាប់ខ្ជួនដែលពុំត្រូវបានធ្វើឱ្យទន់ខ្សោយដោយដំណើរនៃ ពេលវេលានោះទេ» ។ ( រីឆាត ជី. ស្កុត, « The Power of Scripture, » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2011, 6 ) ។
3. « សម្រាប់អ្នកទាំងឡាយដែលគិតថា ការសាកល្បងទាំងឡាយដែលគេប្រឈមមុខ អយុត្តិធម៌ ____________ ដែល គ្របដណ្ដប់លើភាពអយុត្តិធម៌ទាំងអស់នៃជីវិត » ។ ( យ៉ូនថិន អិល. ឃុក, « The Songs They Could Not Sing, » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2011, 106 ) ។
4. « នៅពេលយើងមាន ____________ យើងមានឆន្ទៈដើម្បីបម្រើ និងជួយអ្នកដទៃនៅពេលវាពុំសុខស្រួល និង ពុំមានគំនិតចង់បានការទទួលស្គាល់ ឬ ការតបស្នងគុណ ។ ( ស៊ីលវ៉ា អេច អាល់រែត « Charity Never Faileth » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2011, 115 ) ។

*ចម្លើយៈ 1. ព្រះគម្ពីរមរមន 2. ទន្ទេញខគម្ពីរ; 3. ដង្វាយធួន 4. សេចក្ដីសប្បុរស។*

ខាងឆ្វេង ៖ រចនាដោយ ប៉ុល ម៉ាន ខាងស្ដាំ ៖ *THE LORD JESUS CHRIST* ដោយ ដែល ផាសុន © 1983 IRI រូបថត ដោយ អិមមីលី លេសមែន រូបថតលំអរដោយ ចន លូកា និង គ្រីស្ទីនណា ស្មិធ

# ភាពជាអ្នកដឹកនាំតាម **របៀបរបស់ព្រះអម្ចាស់**

**ដោយ ក្រេក មើរវែល**
នាយកកម្មវិធីអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មនៅ BYU

*ពេលដែលយើងបម្រើ និងដឹកនាំតាមរបៀបដែលព្រះអម្ចាស់បានដឹកនាំ ដោយមិនគិតពីការហៅបម្រើរបស់យើង នោះយើងនឹងផ្ដល់ពរជ័យផង និងទទួលពរជ័យផង ។*

ពេលដែលបងប្រុស ចូនស៍ និងកូនប្រុសរបស់គាត់ត្រូវបានចាត់តាំងឱ្យទៅបង្រៀនតាមផ្ទះដល់ក្រុមគ្រួសារ វីល្លៀម នោះពួកគេបានចាប់ផ្ដើមការចុះសួរសុខទុក្ខជាប្រចាំខែ ។ តាមរយៈការចុះសួរសុខទុក្ខនោះ គីម ជាកូនស្រីម្នាក់នៅក្នុងក្រុមគ្រួសារនោះ បានរៀនដឹងថា ពួកគេបានគិតខ្វល់ខ្វាយចំពោះនាង ។ នាងបានមានសំណួរជាច្រើនអំពីដំណឹងល្អ ហើយបានមានភាពរីករាយក្នុងការសន្ទនាជាមួយពួកគេ ។

នៅរដូវក្ដៅមួយ នៅពេលដែលគីម កំពុងមានការពិបាកក្នុងការដឹងថាប្រសិនបើនាងមានទីបន្ទាល់មួយឬទេ នោះបងប្រុសចូនស៍ ជាមួយនឹងអ្នកកាន់បព្វជិតភាពមិលគីស្សាដែកមួយរូបផ្សេងទៀត ត្រូវបានគេស្នើសុំឱ្យចូលរួមនៅក្នុងការបោះជំរុំក្រុមយុវនារី ។ ក្រោយមក គីមបាននិយាយថាតើវាមានអត្ថន័យយ៉ាងណាក្នុងការដែលមានគ្រូបង្រៀនតាមផ្ទះរបស់នាងនៅទីនោះដែរ ។ នាងបានប្រាប់ក្រុមគ្រួសាររបស់នាងថា នាងបានកើននូវទីបន្ទាល់មួយអំពីសេចក្ដីស្រឡាញ់នៃព្រះអង្គសង្គ្រោះសម្រាប់នាងនៅពេលដែលបងប្រុង ចូនស៍ និងអ្នកកាន់បព្វជិតភាពម្នាក់ទៀតបានផ្ដល់ពរជ័យបព្វជិតភាពមួយដល់នាងនៅឯការបោះជំរុំនោះ តាមសំណូមពររបស់នាង ។

ដោយអារម្មណ៍ដ៏ត្រឹមត្រូវបំផុតនោះ គ្រូបង្រៀនតាមផ្ទះទាំងឡាយរបស់នាងគឺជាមិត្តចំពោះក្រុមគ្រួសារវីល្លៀម ។ ឥទ្ធិពលរបស់ពួកគេសំខាន់ចំពោះគីម និងឪពុកម្ដាយរបស់នាង—និងចំពោះព្រះអម្ចាស់ ។

### ភាពជាអ្នកដឹកនាំ និងការហៅបម្រើទាំងឡាយ

នៅក្នុងពិភពលោកសព្វថ្ងៃនេះ វាជារឿងសាមញ្ញក្នុងការវាស់វែងការរីកចម្រើនរបស់មនុស្សម្នាក់ដោយមុខតំណែងដែលធំទាំងឡាយនៃការទទួលខុសត្រូវក្នុងកន្លែងការងារ ឬដោយការឡើងប្រាក់ខែ ដែលជាសញ្ញានៃការកើនឡើងនូវស្នាដៃរបស់បុគ្គលម្នាក់ៗ ។ ជាញឹកញាប់ យើងសម្លឹងមើលទៅឯមុខតំណែងទាំងឡាយនៃការទទួលខុសត្រូវ ដែលអាចមើលឃើញ ថាជាកត្តាដែលធ្វើឱ្យបុគ្គលម្នាក់ជាបុគ្គលសំខាន់ ។ អញ្ចឹង វាមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេ ថាមនុស្សជាច្រើនមានការពិបាកក្នុងការដឹងពីរបៀបដ៏ល្អបំផុតដើម្បីវាស់វែងពីការរីកចម្រើនរបស់ពួកគេនៅក្នុងបញ្ហាខាងវិញ្ញាណ ។

ខ្ញុំធ្លាប់បានឮថា មានពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើនមានការសង្ស័យចំពោះឋានៈរបស់គេផ្ទាល់ ដោយសារតែពួកគេមិនទាន់ត្រូវបានហៅក្នុងមុខតំណែងជាអ្នកដឹកនាំនៅក្នុងសាសនាចក្រ ។ ប៉ុន្តែ ដោយការហៅបម្រើក្នុងភាពជាអ្នកដឹកនាំទាំងឡាយនោះ តើការរីកចម្រើនរបស់យើងត្រូវបានវាស់វែងដោយត្រឹមត្រូវទេ ?

តាមពិតទៅ ភាពជាអ្នកដឹកនាំមិនចាំបាច់មានការហៅបម្រើមួយនោះទេ ។ មនុស្សមួយចំនួនដែលប្រើប្រាស់នូវឥទ្ធិពលដ៏លើកតម្កើង និងលើកទឹកចិត្តនោះហើយ ដែលត្រូវបានចាត់ទុកថាមានភាពជាអ្នកដឹកនាំដ៏ពិតប្រាកដ គឺធ្វើដូច្នោះដោយមិនមានការហៅបម្រើ ឬមុខតំណែងនោះទេ ។ គោលលទ្ធិ និងសេចក្ដីសញ្ញា 121 បង្រៀនមេរៀនសំខាន់ៗមួយចំនួនអំពីភាពជាអ្នកដឹកនាំ ៖

« យើងបានរៀនដោយការពិសោធន៍ដ៏សោហ្មង ថាជាធម្មជាតិនៃមនុស្សស្ទើរគ្រប់រូប វំពេចណាពួកគេមានសិទ្ធិអំណាចបន្ដិចបន្តួច តាមដែលពួកគេស្មាន នោះពួកគេនឹងចាប់ផ្ដើមអនុវត្តអំណាចគ្រប់គ្រងដោយឥតសុចរិតភ្លាម ។

« ម្លោះហើយ បានជាមានមនុស្សជាច្រើនដែលត្រូវបានហៅ ប៉ុន្តែមានមនុស្សតែបន្តិចទេដែលត្រូវបានរើស ។

« គ្មានអំណាច ឬឥទ្ធិពលណាអាច ឬគប្បីកាន់កាប់ដោយសារបព្វជិតភាពបានឡើយ លើកលែងតែដោយការលួងលោម ដោយការអត់ធ្មត់ ដោយការទន់ភ្លន់ និងការស្លូតបូត និងដោយការស្រឡាញ់ស្មោះត្រង់ប៉ុណ្ណោះ

« ដោយចិត្តល្អ និងដោយការចេះដឹងពេញទី ដែលនឹងពង្រីកព្រលឹងឱ្យធំទូលំទូលាយ ដោយឥតលាក់ពុត និងដោយឥតមានឧបាយកលឡើយ » (ខ 39–42) ។

វាជារឿងធម្មតាទេ ក្នុងការច្រឡំពីភាពជាអ្នកដឹកនាំជាមួយនឹងការប្រាប់មនុស្សពីអ្វីដែលត្រូវធ្វើ ។ ការណ៍នោះអាចនាំទៅកាន់អំណាចគ្រប់គ្រងដោយឥតសុចរិត ។ វាមិនមែនជាការសមរម្យទេក្នុងការនិយាយថា « អ្នកត្រូវតែធ្វើដូចដែលខ្ញុំនិយាយ ព្រោះខ្ញុំ ( ដែលជាអ្នកកាន់បព្វជិតភាព ឬខ្ញុំត្រូវបានហៅដោយបព្វជិតភាព ) បាននិយាយថាដូច្នោះ » ។ មេរៀនដ៏សំខាន់មួយនៃកណ្ឌទី 121 គឺថាអ្នកដឹកនាំដ៏ពិតម្នាក់មិនផ្ដល់ការដឹកនាំ ហើយរំពឹងថាវាត្រូវបានធ្វើតាម យ៉ាងសាមញ្ញដោយព្រោះតែមុខតំណែងនោះទេ ។ ប៉ុន្តែ ភាពជាអ្នកដឹកនាំនៃបព្វជិតភាពគឺជាការអញ្ជើញ ។ ការអញ្ជើញដ៏ស្លូតបូតដោយផ្អែកលើការចេះដឹងដ៏បរិសុទ្ធ និងសេចក្ដីស្រឡាញ់ដ៏ស្មោះត្រង់ នឹងតែងតែជាការជម្រុញដ៏អស្ចារ្យជាង « ព្រោះខ្ញុំបាននិយាយថាដូច្នេះ » ។

វាជាការពិតដែលថា អ្នកដឹកនាំទាំងឡាយដែលមានទំនោរទៅកាន់ការបញ្ជា អាចសម្រេចបានកិច្ចការជាច្រើន ។ ប៉ុន្តែ ពួកគេពុំបានកំពុងដឹកនាំតាមរបៀបដែលព្រះអម្ចាស់បានបើកសម្ដែងនោះទេ ។ ហើយពួកគេពុំបានកំពុងតែអភិវឌ្ឍនូវសមត្ថភាពនៃភាពឯករាជ និងទំនុកចិត្ត ដែលគួរតែមាននៅក្នុងចំណោមអ្នកទាំងឡាយដែលពួកគេកំពុងដឹកនាំនោះទេ ។



**ចូរក្លាយជាសិស្សដ៏ស្មោះត្រង់ម្នាក់**

« អ្នកដឹកនាំសាសនាចក្រទាំងអស់ដែលត្រូវបានហៅឱ្យជួយអ្នកដទៃ ឱ្យក្លាយទៅជា ‘ អ្នកដើរតាមដ៏ពិតនៃ ... ព្រះយេស៊ូវគ្រីស្ទ ’ ( មរ៉ូណៃ 7:48 ) ... ។

« ពួកអ្នកដឹកនាំអាចបង្រៀនដល់អ្នកដទៃអំពីរបៀបដើម្បីក្លាយជា ‘ អ្នកដើរតាមដ៏ពិត ’ បានល្អបំផុតនោះគឺតាមរយៈគំរូផ្ទាល់ខ្លួនរបស់ពួកគាត់ ។ គំរូនេះ—ការក្លាយជាសិស្សស្មោះត្រង់ដើម្បីជួយដល់អ្នកដទៃឱ្យក្លាយទៅជាសិស្សស្មោះត្រង់—គឺជាគោលបំណងដ៏សំខាន់សម្រាប់ការហៅទាំងអស់ក្នុងសាសនាចក្រ ។

*ក្បួនខ្នាតភាគ 2 ៖ ការគ្រប់គ្រងសាសនាចក្រ* (ឆ្នាំ 2010) វគ្គ 3.1 ។

**ភាពជាអ្នកដឹកនាំដ៏ពិត**

សូមកត់ចំណាំថា ការហៅបម្រើ ឬមុខតំណែងនៃសិទ្ធិអំណាចមួយ មិនត្រូវបានរាយនៅក្នុងខ 41 ឬ 42 ថាជារបៀបមួយដ៏ត្រឹមត្រូវ ដើម្បីក្តោបក្តាប់អំណាច ឬឥទ្ធិពលនោះទេ ។ ប៉ុន្តែ អំណាច និងឥទ្ធិពលនៃអ្នកដឹកនាំដ៏ពិត គឺត្រូវបានប្រើប្រាស់តាមរយៈការល្ចួងលោម ការអត់ធ្មត់ ការទន់ភ្លន់ ការស្លូតបូត ការស្រឡាញ់ស្មោះត្រង់ ចិត្តល្អ និងការចេះដឹងដ៏បរិសុទ្ធ ។ ចរិតលក្ខណៈនៃភាពជាអ្នកដឹកនាំដ៏ពិតទាំងនេះ អាចត្រូវបានបង្ហាញឡើងដោយមនុស្សគ្រប់គ្នាដោយមិនគិតពីការហៅបម្រើ ឬមុខតំណែងនោះទេ ។

ការហៅបម្រើក្នុងភាពជាអ្នកដឹកនាំទាំងឡាយ គឺដូចគ្នាខ្លាំងណាស់ទៅនឹងកង់តូចបន្ថែមចំហៀងកង់ធំដែលជួយទប់លំនឹងកង់មួយ ។ កង់តូចបន្ថែមទាំងនោះជួយឱ្យកុមាររៀនពីរបៀបដើម្បីមានលំនឹង និងជិះកង់ដោយមានទំនុកចិត្ត ។ ការហៅបម្រើក្នុងភាពជាអ្នកដឹកនាំមួយ គឺដាក់មនុស្សនៅត្រង់កន្លែងមួយដើម្បីរៀនពីរបៀប ដើម្បីស្រឡាញ់ ដើម្បីអត់ធ្មត់ និងល្ចួងលោម តាមរយៈការចេះដឹងដ៏បរិសុទ្ធ និងចិត្តល្អ ។ ពួកគេអាចរៀនផងដែរថា ការប៉ុនប៉ងណាក៏ដោយ ដើម្បីបង្ខិតបង្ខំឱ្យមានការប្រព្រឹត្តិ នោះក៏មាននូវការចាកចេញនៃព្រះវិញ្ញាណ និងកាត់បន្ថយនូវប្រសិទ្ធិភាពផងដែរ ។

បន្ទាប់ពីការដោះលែងរបស់យើង យើងនឹងឃើញថា ប្រសិនបើយើងបានរីកចម្រើន និងបានរៀននៅក្នុងអំឡុងពេលនៃការហៅបម្រើរបស់យើងឬទេ ។ ដោយគ្មានការហៅបម្រើជាកម្លាំងរុញច្រាន តើយើងបានរៀនដើម្បីស្រឡាញ់ និងបម្រើអ្នកដទៃដែរឬទេ ? តើយើងបានរៀនដើម្បីបម្រើ ជាមួយនឹងអំណាចដែលជាឥទ្ធិពលល្អ យ៉ាងសាមញ្ញដោយព្រោះតែយើងជាជនម្នាក់ដែលយើងបានក្លាយជា ដែរឬទេ ?

ព្រះអម្ចាស់នឹងហៅយើងម្តងហើយម្តងទៀត អស់មួយជីវិតរបស់យើង ។ ទ្រង់ស្គាល់ដួងចិត្តរបស់យើង ។ ទ្រង់នឹងហៅយើង នៅពេលដែលទ្រង់ត្រូវការជំនាញ ការចេះដឹងជាក់លាក់ទាំងឡាយរបស់យើង ឬការស្គាល់របស់យើងជាមួយនឹងព្រះវិញ្ញាណ ។ ទ្រង់នឹងហៅយើងស្របទៅតាមឆន្ទៈរបស់យើងក្នុងការឮសម្លេងទ្រង់ និងស្រឡាញ់ដូចជាទ្រង់ស្រឡាញ់ដែរ ។

ពេលដែលយើងរៀនពីរបៀបដើម្បីក្លាយជាឥទ្ធិពលល្អមួយ នៅក្នុងរបៀបរបស់ព្រះអម្ចាស់ នោះយើងនឹងក្លាយជាមនុស្សដែលលើកអ្នកដទៃឡើង យ៉ាងសាមញ្ញដោយព្រោះថាយើងជាមនុស្សម្នាក់ដែលជាយើង ។ ការហៅបម្រើទាំងឡាយនឹងមិនមែនជាមូលហេតុចម្បងសម្រាប់ឥទ្ធិពលល្អរបស់យើងនោះទេ ។ ទោះជាយ៉ាងនោះក៏ដោយ នៅពេលណាដែលត្រូវបានសុំ យើងនឹងបម្រើបានយ៉ាងល្អនៅក្នុងកន្លែងណាដែលយើងត្រូវបានចាត់តាំងនៅក្នុងសាសនាចក្រ ។

មិនថាយើងបម្រើនៅក្នុងសាលាថ្ងៃអាទិត្យ ឬនៅក្នុងកម្មវិធីយុវវ័យ ជាគ្រូបង្រៀនតាមផ្ទះ ឬជាគ្រូសួរសុខទុក្ខ ឬសូម្បីតែជាប៊ីស្សព ឬជាប្រធានសមាគមសង្គ្រោះក៏ដោយ ក៏ការបម្រើរបស់យើងចំពោះអ្នកដទៃនឹងជាការបង្ហាញមួយពីសេចក្តីស្រឡាញ់របស់យើងចំពោះព្រះអង្គសង្គ្រោះ ។ ពេលដែលយើងបម្រើ និងដឹកនាំតាមរបៀបដែលព្រះអម្ចាស់បានដឹកនាំ ដោយមិនគិតពីការហៅបម្រើរបស់យើង នោះយើងនឹងផ្តល់ពរជ័យផង និងទទួលពរជ័យផង ។ ■

# គ្រូបង្រៀនសួរសុខទុក្ខ
## បានដឹកនាំខ្ញុំទៅឯព្រះយេស៊ូវគ្រីស្ទ

**ដោយ ចេន ភី បោរើរ**

*« [ ព្រះអម្ចាស់ ] មានព្រះបន្ទូលជាគម្រប់បីដង [ ទៅកាន់ពេត្រុស ] ថា តើពេញចិត្តនឹងខ្ញុំមែនឬអី ? ហើយ [ ពេត្រុស ] បានទូលឆ្លើយថា ព្រះអម្ចាស់អើយ ទ្រង់ជ្រាបគ្រប់ការណ៍ទាំងអស់ គឺទ្រង់ជ្រាបថា ទូលបង្គំពេញចិត្តនឹងទ្រង់ហើយ ។ ព្រះយេស៊ូវមានបន្ទូលទៅគាត់ថា ចូរឱ្យចំណីដល់ហ្វូងចៀមខ្ញុំស៊ីផង » ( យ៉ូហាន 21:17 ) ។*



**ពរជ័យទាំងឡាយនៃការបង្រៀនសួរសុខទុក្ខ**

« ស្ត្រីជាច្រើនបានរាយការណ៍ថា មូលហេតុដែលពួកគេត្រឡប់មកសកម្មក្នុងសាសនាចក្រវិញ ពីព្រោះតែគ្រូបង្រៀនសួរសុខទុក្ខដ៏ស្មោះត្រង់ម្នាក់បានមកសួរសុខទុក្ខពីមួយខែទៅមួយខែ ហើយបានបម្រើដល់ពួកគេ សង្គ្រោះពួកគេ ស្រឡាញ់ពួកគេ ផ្ដល់ពរជ័យដល់ពួកគេ ។ ...

« មានពេលជាច្រើន ពរជ័យដ៏សំខាន់បំផុតអំពីការសួរសុខទុក្ខរបស់អ្នក នឹងគ្រាន់តែជាការស្ដាប់ប៉ុណ្ណោះ ។ ការស្ដាប់នាំមកនូវការលួងលោម ការយល់ និងការព្យាបាល ។ ប៉ុន្តែ ពេលខ្លះអ្នកអាចនៅតែត្រូវមូរដៃអាវរបស់អ្នកឡើង ហើយទៅធ្វើកិច្ចការនៅក្នុងផ្ទះ ឬជួយលួងកូនដែលកំពុងយំ » ។

**បាបារ៉ា ថមសុន ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅ “And of Some Have Compassion, Making a Difference,” *Liahona,* Nov.** 2010, ទំព័រ 120 ។

នៅចុងទសវត្ស 1970 មានមិត្តម្នាក់បានសុំខ្ញុំឱ្យទៅសមាគមសង្គ្រោះជាមួយនាង ។ « នោះជាអ្វីទៅ ? » ខ្ញុំបានសួរ ។ មិត្តរបស់ខ្ញុំបាននិយាយយ៉ាងសាមញ្ញថា « មក ហើយមើលទៅ » ។ អស្ចារ្យ ! ខ្ញុំត្រូវបានធ្វើឱ្យជាប់ចិត្តតាំងពីគ្រាដំបូង ។

ក្រោយមកនៅរដូវក្ដៅនោះ លីអានបានមកផ្ទះរបស់ខ្ញុំ ហើយបាននិយាយថា នាងជាគ្រូបង្រៀនសួរសុខទុក្ខរបស់ខ្ញុំ ។ ការណ៍នេះហាក់ដូចជាចម្លែក ហើយក៏អស្ចារ្យផងដែរក្នុងពេលជាមួយគ្នានោះ ជាពិសេសពេលដែលខ្ញុំមិនមែនជាសមាជិកម្នាក់នៃសាសនាចក្រផង ។ នាងបានយកពេលវេលាពីកាលវិភាគដ៏រវល់របស់នាង ដើម្បីចែកចាយគំនិតខាងវិញ្ញាណជាមួយខ្ញុំ និងដើម្បីមើល ថាបើមានអ្វីដែលនាងអាចជួយខ្ញុំបាន ។ ខ្ញុំបានស្គាល់ពីវិញ្ញាណរបស់នាងថា នាងស្មោះត្រង់ ។ ខ្ញុំមិនដែលភ្លេចលីអាន និងសារលិខិតទាំងឡាយដែលនាងបានចែកចាយជាមួយខ្ញុំនោះទេ ។

ពីរឆ្នាំកន្លងផុតទៅ ហើយហ្វ្រេនស៊ីស បានផ្លាស់មកវួដរបស់យើង ។ តាមពិតទៅ វាមិនប្រាកដថាជាវួដ « របស់យើង » នោះទេ ដោយព្រោះខ្ញុំមិនទាន់ជាសមាជិកនៅឡើយទេ ប៉ុន្តែខ្ញុំបានគិតអំពីវាតាមរបៀបនោះ ។ មកទល់នឹងពេលនេះ ខ្ញុំបានមានកូនស្រីតូចពីរនាក់ ហើយខ្ញុំអាចមើលឃើញពីរបៀបដែលអង្គការជំនួយទាំងឡាយរបស់សាសនាចក្រផ្ដល់ពរជ័រដល់ជីវិតរបស់ពួកគេ ។ មិនថាមានភ្លៀង ឬមានថ្ងៃរះ ហ្វ្រេនស៊ីស ជាគ្រូបង្រៀនសួរសុខទុក្ខថ្មីរបស់ខ្ញុំ បានមកសួរសុខទុក្ខខ្ញុំដោយមានមេរៀនមួយដោយសំណើច រឿងមួយ ឬការលើកដៃជួយ ។ ខ្ញុំចាំបាននៅពេលមួយដែលហ្វ្រេនស៊ីស បានមកនៅរសៀលដ៏រវល់មួយ ។ ដោយឃើញថាខ្ញុំមិនអាចអង្គុយ និងជជែកគ្នាបាន នោះហ្វ្រេនស៊ីស បានកូរអាហារនៅលើចង្ក្រាន ខណៈដែលខ្ញុំកំពុងតែយកចិត្តទុកដាក់ទៅនឹងតម្រូវការរបស់កូនស្រីខ្ញុំ ។

ជាច្រើនឆ្នាំបានកន្លងផុតទៅ ហើយខ្ញុំបានផ្លាស់ប្ដូរទីលំនៅ ។ ថ្វីបើខ្ញុំមិនចង់ចាកចេញពីមិត្តភក្ដិក្នុងសាសនាចក្ររបស់ខ្ញុំក៏ដោយ នោះខ្ញុំក៏បានរកឃើញក្រុមបងប្អូនស្ត្រីដែលមានទីបន្ទាល់ដ៏រឹងមាំ និងមានចិត្តល្អនៅក្នុងសមាគមសង្គ្រោះនៅក្នុងវួដថ្មី [ របស់ខ្ញុំ ] ដែរ ។ គ្រូបង្រៀនសមាគមសង្គ្រោះម្នាក់បានឱ្យពួកយើងនូវបញ្ជីកិច្ចការតុបតែងដែលត្រូវធ្វើមួយ ហើយបានលើកទឹកចិត្តយើងឱ្យសរសេរ « ចូរមានចិត្តល្អ » នៅខាងលើក្បាលបញ្ជីទាំងឡាយរបស់យើងក្នុងថ្ងៃនីមួយៗ ។ បងប្អូនស្ត្រីទាំងឡាយអង្គុយនៅក្បែរខ្ញុំ ហើយខ្ញុំបានគិតថា វាជាគំនិតដ៏មហិមាមួយ ជាពិសេសដោយព្រោះវាគាំទ្រដល់បាវចនារបស់សមាគមសង្គ្រោះដែលថា « សេចក្ដីសប្បុរសពុំបាត់បង់ឡើយ » ( មរ៉ូណៃ 7:46 ) ។

បន្ទាប់មក ខ្ញុំបានអានរឿងមួយអំពីស្ត្រីអ្នកត្រួសត្រាយផ្លូវម្នាក់ ។ នៅពេលដែលស្ត្រីនោះនៅជាកុមារ ព្យាការីបានសុំគ្រួសារនាង ឱ្យជួយរៀបចំការតាំងលំនៅរបស់សហគមន៍ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅតំបន់ដាច់ស្រយាលមួយ ។ សោកនាដកម្មមួយបានកើតឡើង នៅពេលដែលបងប្អូនម្នាក់របស់នាងបានស្លាប់ ។ ម្ដាយរបស់នាងបានមានការសោកសៅយ៉ាងខ្លាំង



ក្រៃលែង ហើយភាពសោកសៅដ៏ជ្រាលជ្រៅនោះបានជ្រាបចូលទៅក្នុងក្រុមគ្រួសារ ។

ថ្ងៃមួយក្មេងស្រីតូចនេះបានសម្លឹងមើលទៅក្រៅតាមបង្អួច ។ ដោយឆ្ងាយតាមដែលនាងអាចមើលឃើញ នោះមានព្រិលដ៏ក្រាស់បានហ៊ុំព័ទ្ធផ្ទះដ៏តូចរបស់ក្រុមគ្រួសារនោះ ។ ពេលដែលក្មេងស្រីតូចនោះសម្លឹងមើលទៅឯជើងមេឃ នោះនាងបានឃើញមនុស្សពីរនាក់កំពុងធ្វើដំណើរយ៉ាងលំបាកសំដៅមកកាន់ផ្ទះនោះ ។ ពួកគេបានមក បានធ្វើដំណើរមកយ៉ាងយឺត ហើយភ្លាមនោះកុមារនោះបានស្គាល់ថាពួកគេជានរណា—ពួកគេគឺជាគ្រូបង្រៀនសួរសុខទុក្ខរបស់ម្ដាយនាង ។

រឿងនេះបានបំផុសគំនិតខ្ញុំ ។ ខ្ញុំបានទទួលបុណ្យជ្រមុជទឹកនៅក្នុងខែ ឧសភា ឆ្នាំ 1983 ។ វាគឺជាកិត្តិយសមួយដោយខ្លួនខ្ញុំបានក្លាយជាគ្រូបង្រៀនសួរសុខទុក្ខម្នាក់ ។ ខ្ញុំស្រឡាញ់នូវទំនាក់ទំនងជាមួយស្ត្រីជាច្រើនដែលធ្វើគំរូជា « ស្ត្រីគ្រប់លក្ខណ៍ » ដែល « មានតម្លៃជាជាងត្បូងទទឹមទៅទៀត » ( សុភាសិត 31:10 ) ។ វាជាការអស្ចារ្យណាស់ក្នុងការបាននៅជាមួយនឹងស្ត្រីទាំងឡាយ ដែលកំពុងពុះពារព្យាយាមដើម្បីមានចិត្តល្អ ដើម្បីស្រឡាញ់គ្នាទៅវិញទៅមក និងដើម្បីនាំអ្នកដទៃទៀតមកកាន់ព្រះគ្រីស្ទផងដែរនោះ ។ ■

*គ្រូបង្រៀនសួរសុខទុក្ខចែកចាយសារលិខិតដំណឹងល្អ និងពេលខ្លះការលើកដៃជួយ ។ បងប្អូនស្ត្រីទាំងឡាយ ដែលពួកគេសួរសុខទុក្ខត្រូវបានពង្រឹងដោយការចូលរួមគ្នាជាមួយនឹងស្ត្រីទាំងឡាយដែលខិតខំដើម្បីមានចិត្តល្អ ដើម្បីស្រឡាញ់គ្នាទៅវិញទៅមក និងដើម្បីនាំអ្នកដទៃទៀតមកកាន់ព្រះគ្រីស្ទ ។*

សម្រាប់ព័ត៌មានបន្ថែមទៀត សូមមើល Julie B. Beck, "'Daughters in My Kingdom': The History and Work of Relief Society," *Liahona,* Nov. 2010, ទំព័រ 112; និង Henry B. Eyring, "The Enduring Legacy of Relief Society," *Liahona,* Nov. 2009, ទំព័រ 121 ។

**តើគ្រូបង្រៀនសួរសុខទុក្ខបានទទួលពរជ័យដោយការបម្រើរបស់ពួកគេយ៉ាងដូចម្ដេចដែរ ?** បាបារ៉ា ថមសុន ជួយឆ្លើយសំណួរនេះនៅក្នុងសុន្ទរកថារបស់គាត់នៅឯការប្រជុំសមាគមសង្គ្រោះទូទៅ "And of Some Have Compassion, Making a Difference" (*Liahona,* Nov. 2010, ទំព័រ 120) ៖

« នៅពេលខ្ញុំបានចុះទៅបង្រៀនសួរសុខទុក្ខ ខ្ញុំតែងតែមានអារម្មណ៍ប្រសើរឡើង ។ ខ្ញុំត្រូវបានលើកឡើង ត្រូវបានស្រឡាញ់ និងបានទទួលពរជ័យ ជាធម្មតា គឺច្រើនជាងបងស្រីដែលខ្ញុំកំពុងទៅសួរសុខទុក្ខនោះ ។ សេចក្ដីស្រឡាញ់របស់ខ្ញុំបានកើនឡើង ។ បំណងប្រាថ្នារបស់ខ្ញុំក្នុងការបម្រើបានកើនឡើង ។ ហើយខ្ញុំអាចឃើញពីរបៀបដ៏ប្រពៃមួយ ដែលព្រះវរបិតាសួគ៌បានរៀបចំផែនការសម្រាប់យើង ដើម្បីមើលថែ និងខ្វល់ខ្វាយចំពោះគ្នាទៅវិញទៅមក ។

*សូមពិចារណាក្នុងការសរសេរទីបន្ទាល់របស់អ្នកអំពីការបង្រៀនសួរសុខទុក្ខ ឬការបង្រៀនតាមផ្ទះ នៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ។*

រូបថតរបស់ បស្ស៊ី ថមសុន © BUSATH.COM រៀបចំរូបថតដោយ ចន លូក

# ការជួយដល់កុមារ ឱ្យស្រឡាញ់ ព្រះគម្ពីរមរមន

*យើងបានរកឃើញថា ឧបករណ៍ទាំងនេះជាប្រយោជន៍នៅក្នុងការបង្រៀនដល់កូនៗរបស់យើងចេញពីព្រះគម្ពីរមរមន ។*

**ដោយ ខ្លាយឌ៍ ដេ វីល្លៀម**
ផ្នែកទំនាក់ទំនង

ពេលដែលប្រពន្ធខ្ញុំ និងខ្ញុំចិញ្ចឹមបីបាច់គ្រួសាររបស់យើង យើងមានបំណងប្រាថ្នាយ៉ាងជ្រាលជ្រៅ ដើម្បីបណ្ដុះនៅក្នុងកូនទាំងប្រាំនាក់របស់យើង នូវសេចក្ដីស្រឡាញ់ចំពោះព្រះគម្ពីរមរមន ។ ដូចជាជាងឈើទាំងឡាយដែរ យើងបានរៀនថា ឧបករណ៍ជាច្រើនប្រភេទផ្សេងៗគ្នា នឹងមិនត្រឹមតែជាប្រយោជន៍ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងចាំបាច់នៅក្នុងការបង្រៀនកូនៗយើងឱ្យស្រឡាញ់ព្រះគម្ពីរទៀតផង ។ យើងក៏បានដឹងផងដែរថា ការមានឧបករណ៍ ឬវិធីសាស្ត្រនានាក្នុងការបង្រៀនកូនៗរបស់យើងគឺជារឿងមួយ ហើយការស្គាល់ពីរបៀបដើម្បីប្រើឧបករណ៍ ឬវិធីសាស្ត្រទាំងនោះគឺជារឿងមួយផ្សេងទៀត ។

ជាងនោះទៅទៀត យើងបានដឹងថា យើងត្រូវការរៀនពីរបៀបដើម្បីបង្រៀនកូនៗយើង ឱ្យយកព្រះគម្ពីរមរមនមកអនុវត្តនៅក្នុងជីវិតរបស់ពួកគេ ហើយមើលពីទំនាក់ទំនងរបស់ព្រះគម្ពីរមរមនទៅនឹងពិភពលោកដែលពួកគេរស់នៅក្នុងនេះ ។ លទ្ធភាពរបស់យើងក្នុងការប្រើនូវយុទ្ធសាស្ត្រផ្សេងៗពីគ្នា ដើម្បីជួយកូនៗរបស់យើង បានផ្អែកជាដំបូង និងសំខាន់បំផុតទៅលើការយល់ដឹងផ្ទាល់ខ្លួនរបស់យើង អំពីព្រះគម្ពីរទាំងឡាយ ទីបន្ទាល់របស់យើងចំពោះសេចក្ដីពិតដ៏ពេញលេញរបស់ព្រះគម្ពីរទាំងនោះ និងសេចក្ដីពេញចិត្តរបស់យើងចំពោះព្រះគម្ពីរទាំងនោះ ។

## ការបង្រៀនដល់កូនក្មេងតូចៗ

ពីព្រោះតែភាសានៃព្រះគម្ពីរទាំងឡាយ មិនសូវជាសាមញ្ញ ហើយវាក្យស័ព្ទរបស់កុមារនៅមានកម្រិត នោះការបង្រៀនដល់កូនក្មេងតូចៗឱ្យស្រឡាញ់ព្រះគម្ពីរមរមនអាចជាការលំបាកមួយ ។ នៅពេលកូនៗរបស់យើងនៅក្មេង រយៈពេលនៃចំណាប់អារម្មណ៍របស់ពួកគេគឺខ្លី ហើយក៏ដូចជាពេលវេលាសិក្សាព្រះគម្ពីររបស់យើងដែរ ។ ជាញឹកញាប់យើងបានប្រើប្រាស់ព្រះគម្ពីរមានរូបភាពសម្រាប់ការសិក្សាព្រះគម្ពីរជាក្រុមគ្រួសារ ។

ដើម្បីពង្រឹងគោលលទ្ធិទាំងឡាយ ដែលកូនៗយើងអាន និងរៀននៅក្នុងការសិក្សាព្រះគម្ពីរ ជាញឹកញាប់ ខ្ញុំបានប្រើរឿងទាំងឡាយចេញពីព្រះគម្ពីរជារឿងនិទានមុនពេលចូលគេង ។ ច្រើនឆ្នាំក្រោយមក កូនស្រីរបស់ខ្ញុំបានចែកចាយថាតើវិធីនេះបានមានឥទ្ធិពលយ៉ាងណា ។ នាងបាននិយាយថា « ខ្ញុំគិតថា រឿងទាំងឡាយដែលបាននិទានម្ដងហើយម្ដងទៀតបានក្លាយជារឿងដែលពួកយើងពេញចិត្តណាស់ ។ ប៉ាបានអង្គុយក្បែរគ្រែរបស់ពួកយើង ហើយបានចែកចាយរឿងទាំងឡាយចេញពីព្រះគម្ពីរនានា ។ ពួកយើងស្រឡាញ់រឿងទាំងនោះ ហើយបានសុំស្ដាប់រឿងទាំងនោះម្ដងហើយម្ដងទៀត ព្រោះសូម្បីតែនៅពេលអាយុក្មេងយ៉ាងនោះ ក៏ពួកយើងអាចទទួលអារម្មណ៍ពីវិញ្ញាណនៃសារដំណឹងដែលរឿងទាំងនោះមាន ហើយបានដឹងថា ប្រជាជនដែលប៉ាបានប្រាប់ដល់ពួកយើង គឺជាប្រជាជនដ៏ក្លាហាន និងស្មោះត្រង់ ។ យើងចង់ក្លាយដូចជាពួកគេ » ។

## សម្របសម្រួលមេរៀនទាំងឡាយឱ្យស្របតាមតម្រូវការរបស់ក្រុមគ្រួសារយើង

ជាការពិតណាស់ ពេលដែលកូនៗរបស់យើងធំឡើង យើងបានអានពីព្រះគម្ពីរមរមន និងព្រះគម្ពីរទាំងឡាយឯទៀតដោយផ្ទាល់ ។ ពួកយើងបានព្យាយាមដោយស្មោះត្រង់ដើម្បីអានពីព្រះគម្ពីរជារៀងរាល់ព្រឹក ទោះបីជាកូនៗខ្លះនៅដណ្ដប់ភួយ ដោយបិទភ្នែកព្រឹមៗក៏ដោយ ។ ទោះជាយ៉ាងណាក៏ដោយ ឥឡូវនេះពួកគេប្រាប់ថា ពួកគេបានស្ដាប់ចងចាំ និងដាំគ្រាប់ពូជសម្រាប់អនាគត ។

យើងក៏បានសង្កត់ធ្ងន់លើព្រះគម្ពីរអំឡុងពេលរាត្រីក្រុមគ្រួសារផងដែរ ។ ឧទាហរណ៍ ជាញឹកញាប់យើងរួមបញ្ចូលសកម្មភាពទាំងឡាយ ដូចជាល្បែងព្រះគម្ពីរជាដើម ៖ សមាជិកគ្រួសារនឹងសម្ដែងរឿងមួយចេញពីព្រះគម្ពីរ ហើយសមាជិកគ្រួសារផ្សេងទៀតនឹងព្យាយាមទស្សទាយរឿងនោះ ។ កូនៗរបស់យើងក៏ចូលចិត្តលេងល្បែង « ខ្ញុំជានរណា ? » ផងដែរ—ជាល្បែងមួយដែលយើងនឹងផ្ដល់ដល់ពួកគេនូវតំរុយមួយចំនួន រហូតទាល់តែពួកគេអាចទស្សទាយបុគ្គលពីព្រះគម្ពីរមរមន ដែលយើងកំពុងរកអត្តសញ្ញាណនោះ ។ ពេលដែលកូនៗរបស់យើងមានអាយុច្រើនជាងមុន នោះពួកគេបានចូលរួមក្នុងការរៀបចំ និងឡើងធ្វើបទបង្ហាញមេរៀនទាំងឡាយ ។

ពេលដែលយើងសម្របសម្រួលរាត្រីក្រុមគ្រួសារទាំងឡាយរបស់យើងឱ្យស្របទៅនឹងតម្រូវការបច្ចុប្បន្នរបស់ក្រុមគ្រួសារយើង នោះយើង



រូបភាពគំនូរដោយ រ៉ូប៊ឺត ធី បារ៉េត

បានប្រើប្រាស់រឿង និងអត្ថន័យស៊ីជម្រៅពីព្រះគម្ពីរមរមន ដើម្បីជួយបង្រៀនគោលការណ៍ទាំងឡាយ ។ ឧទាហរណ៍ យើងបានទាញយកមេរៀនទាំងឡាយអំពីសីលធម៌ និងការជៀសវាងពីរូបអាសគ្រាម ពីដំបូន្មានរបស់អាលម៉ា ដល់កូនប្រុសរបស់គាត់ កូរីអានតុន អាលម៉ា 39 ។ មេរៀនមួយដ៏ល្អអំពីការជៀសវាងពីការសាក់រូបនៅលើរូបកាយរបស់យើង ត្រូវបានបង្កើតឡើងពីរឿងរបស់ពួកអាំលិសៃ នៅក្នុង អាលម៉ា 3 ។

ខ្ញុំបានរៀបចំមេរៀនទាំងឡាយអំពីការដោះស្រាយយ៉ាងត្រឹមត្រូវជាមួយនឹងការប្រកួតប្រជែងរវាងបងប្អូន ដោយផ្អែកលើជីវិតរបស់នីហ្វៃ ( សូមមើល នីហ្វៃទី1 7:20–21; 16:4–5 ), ជីវិតរបស់យ៉ាកុប ( សូមមើល នីហ្វៃទី2 2:1–3 ), និងជីវិតរបស់កូរីអានតុន ( សូមមើល អាលម៉ា 39:1, 10 ) ។ បញ្ញីប្រវត្តិដ៏មុឺងម៉ាត់របស់អាលម៉ា និងអាមូលេក នៅក្នុង អាលម៉ា 14:12–28 បង្រៀនអំពីការអត់ធ្មត់នៅក្នុងការរងទុក្ខ ។ គោលការណ៍ដ៏សំខាន់មួយដែលយើងបានរៀនជាមួយនឹងបញ្ហាទាំងនេះ រួមទាំងបញ្ហាជាច្រើនផ្សេងទៀត គឺដើម្បីធ្វើឱ្យប្រាកដថា យើងបានលើកឡើងពីបញ្ហាទាំងនេះជាមួយនឹងកូនៗរបស់យើង ពីមុនពេលដែលវាក្លាយជាបញ្ហាមួយនៅក្នុងជីវិតរបស់ពួកគេ ។

*ជាញឹកញាប់ យើងបានប្រើរឿងទាំងឡាយចេញពីព្រះគម្ពីរមរមនជារឿងនិទានមុនពេលចូលគេង ។*

## សួរសំណួរទាំងឡាយ

បន្ថែមទៅលើការអានព្រះគម្ពីរទាំងឡាយជាមួយកូនៗរបស់យើង យើងបានដឹងថា វាជាការសំខាន់ក្នុងការសួរសំណួរនានា ដែលនឹងជួយកូនៗរបស់យើងឃើញពីសារសំខាន់នៃអ្វីដែលពួកគេបានកំពុងតែអាននោះ ។ ភាពស្មុកស្មាញនៃសំណួរទាំងនេះខុសគ្នា អាស្រ័យទៅលើអាយុរបស់ពួកគេ ប៉ុន្តែអ្វីដែលសំខាន់នោះគឺដើម្បីបង្រៀនពួកគេឱ្យរកមើលនូវអត្ថន័យដ៏ជ្រាលជ្រៅទាំងឡាយ និងការអនុវត្ត ហើយដើម្បីជួយពួកគេឱ្យដឹង ថាតើមានអ្វីៗជាច្រើនយ៉ាងណា ដែលអាចរកបាននៅក្នុងព្រះគម្ពីរមរមន ។

ឧទាហរណ៍ ខ្ញុំបានសួរថា តើពួកគេគិតថា ហេតុអ្វីបានជានីហ្វៃនិយាយថាគាត់បាន « ឃើញសេចក្ដីទុក្ខវេទនាទាំងឡាយ នៅក្នុងដំណើរនៃជីវិត [ របស់គាត់ ] » ហើយនៅក្នុងបន្ទាត់បន្ទាប់នោះ គាត់និយាយអ្វីមួយដែលហាក់បីដូចជាផ្ទុយទៅវិញ ៖ ថាគាត់ « បានប្រោសប្រណីជាខ្លាំងពីព្រះអម្ចាស់ » ( នីហ្វៃទី1 1:1 ) ។ តាមរយៈការពិភាក្សារបស់យើង កូនៗរបស់យើងបានរកឃើញថា សូម្បីតែនៅពេលដែលព្រះអម្ចាស់បានរំដោះនីហ្វៃឱ្យរួចពីទុក្ខវេទនាទាំងឡាយរបស់គាត់ ទ្រង់ក៏បានប្រទានដល់នីហ្វៃនូវការយល់ដឹងដ៏មហិមាជាងមុនអំពីអាថ៌កំបាំងរបស់ទ្រង់ផងដែរ ( សូមមើល នីហ្វៃទី1 1:1, 20 ) ។

កុមារ និងយុវវ័យរៀនបានល្អបំផុត នៅពេលដែលយើងជួយពួកគេឱ្យរកឃើញសេចក្ដីពិតទាំងឡាយដោយខ្លួនគេផ្ទាល់ ។ ពេលដែលពួកគេធ្វើដូច្នោះ នោះពួកគេនឹងមានអារម្មណ៍បំផុសឱ្យស្រឡាញ់ និងប្រើប្រាស់ព្រះគម្ពីរមរមន អស់ពេញជីវិតរបស់ពួកគេ ហើយនឹងមានអារម្មណ៍ថាបានរៀបចំជាស្រេចដើម្បីជួយអ្នកដទៃទៀតឱ្យធ្វើដូចគ្នាដែរ ។

កូនៗរបស់យើងបានដឹងថា យើងបានដឹងថាព្រះគម្ពីរមរមនមាននូវរឿងរ៉ាវទាំងឡាយដ៏ពិតនៃមនុស្សពិតៗ ។ ពួកគេបានឃើញនូវអ្វីដែលយើងបានឃើញ ដឹងនូវអ្វីដែលយើងបានដឹង ហើយទទួលអារម្មណ៍ដែលយើងបានទទួលអំពីព្រះគម្ពីរមរមន ។ ការណ៍នេះបានធ្វើឱ្យទីបន្ទាល់របស់ពួកគេរឹងប៉ឹងឡើង បានជួយពួកគេឱ្យស្រឡាញ់ព្រះគម្ពីរមរមន និងបានដឹកនាំពួកគេឱ្យខំប្រឹងប្រែងដើម្បីធ្វើដូចគ្នាដែរ សម្រាប់កូនៗរបស់ពួកគេផ្ទាល់ ។ ■



# ការស្វែងរកចម្លើយទាំងឡាយ នៅក្នុងព្រះគម្ពីរមរមន

**ដោយ សារ៉ា ឌី ស្ម៊ីធ**

ដំណើរជីវិតរបស់យើងនៅលើផែនដីនេះអាចជាដំណើរដ៏ពិបាកមួយ ប៉ុន្តែព្រះវរបិតាសួគ៌ជាទីស្រឡាញ់របស់យើងមិនបានបញ្ជូនយើងមកទីនេះ ដើម្បីប្រឈមជាមួយនឹងព្យុះជីវិតតែម្នាក់ឯងនោះទេ ។ ជំនួយដ៏អស្ចារ្យបំផុតមួយក្នុងចំណោមជំនួយជាច្រើន ដែលទ្រង់ប្រទានដល់យើងគឺព្រះគម្ពីរមរមន ។ ព្រះគម្ពីរមរមនមិនត្រឹមតែបង្រៀនពីភាពពេញលេញនៃដំណឹងល្អប៉ុណ្ណោះទេ ប៉ុន្តែដឹកនាំយើងឱ្យឆ្លងរួចពីបញ្ហាទាំងឡាយដែលយើងជួបប្រទះផងដែរ ។ ពេលដែលយើងពិចារណាជ្រៅទៅក្នុងព្រះគម្ពីរមរមន ព្រះវិញ្ញាណនឹងជួយយើងស្វែងរកចម្លើយចំពោះបញ្ហា និងចម្ងល់ទាំងឡាយរបស់យើង ។

អែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងទីបន្ទាល់ថា ៖

« លើសជាងសៀវភៅដទៃទៀតទាំងអស់ដែលខ្ញុំស្គាល់ ព្រះគម្ពីរមរមនគឺជាប្រភពដ៏អស្ចារ្យបំផុត ដែលយើងមានសម្រាប់ជាចម្លើយដល់បញ្ហានៃជីវិតពិតទាំងឡាយ ។ …

« តើសេចក្តីសុខសាន្តបានចូលមកក្នុងជីវិតរបស់អ្នកទាំងឡាយណាដែលកំពុងមានការពិបាកជាមួយនឹងបញ្ហាពិតជាច្រើនយ៉ាងណាទៅ នៅពេលដែលពួកគេអាននៅក្នុងព្រះគម្ពីរមរមន ! គំរូទាំងឡាយនៃការដឹកនាំខាងព្រលឹងវិញ្ញាណ ដែលចេញមកពីព្រះគម្ពីរគឺមានច្រើនឥតគណនា » ។ [1]

សមាជិកទាំងឡាយចែកចាយពីរបៀបដែលពួកគេបានរកឃើញចម្លើយទាំងឡាយដែលពួកគេបានស្វែងរកនៅក្នុងព្រះគម្ពីរមរមន នៅក្នុងបញ្ជីប្រវត្តិខាងក្រោមនេះ ។

## ទទួលបទពិសោធន៍នូវការផ្លាស់ប្តូរមួយនៅក្នុងដួងចិត្ត

ទោះជាគាត់បានរៀនដំណឹងល្អកាលដែលគាត់នៅក្មេងក្តី តែប្រេ្គក ឡាសិន ( ឈ្មោះត្រូវបានផ្លាស់ប្តូរ ) មកពីរដ្ឋកាលីហ្វូញ៉ា សហរដ្ឋអាមេរិក បានធ្លាក់ចេញពីសាសនាចក្រនៅពេលក្រោយមក ។ គាត់បានចូលរួមនៅក្នុងការសេពគ្រឿងញៀន និងបទឧក្រិដ្ឋ ហើយមិនយូរប៉ុន្មានក៏បានជាប់នៅក្នុងគុក ។ គាត់ចង់កែប្រែជីវិតគាត់ឱ្យដូចដើមវិញ ប៉ុន្តែមិនដឹងថាត្រូវធ្វើយ៉ាងណា ។

ប្រេ្គក បានសរសេរថា « ពួកបុរសៗមកពីវួដនៅក្នុងមូលដ្ឋាននោះ បានបង្រៀនសាលាថ្ងៃអាទិត្យនៅក្នុងគុក » ។ « បុរសម្នាក់ក្នុងចំណោមបុរសទាំងនោះបានប្រាប់ថា ជីវិតរបស់ខ្ញុំនឹងប្រសើរឡើង ប្រសិនបើខ្ញុំអានព្រះគម្ពីរមរមន ។ ហើយនោះជាអ្វីដែលខ្ញុំបានធ្វើ ។

« ពេលដែលខ្ញុំបានចេញពីគុក ខ្ញុំបានត្រឡប់ទៅព្រះវិហារវិញ ប៉ុន្តែខ្ញុំនៅតែមានចំណង់ចង់ត្រឡប់ទៅរកទម្លាប់ចាស់ៗរបស់ខ្ញុំវិញ ។ កាលដែលខ្ញុំបន្តអានព្រះគម្ពីរមរមន នោះខ្ញុំបានរៀនអំពីប្រជាជនរបស់ស្តេចឡាម៉ូណៃ នៅក្នុង អាលម៉ា 19:33 ដែល 'ចិត្តគេបានផ្លាស់ប្តូរ ថាគេគ្មានបំណងនឹងធ្វើអំពើអាក្រក់ទៀតឡើយ' ។ ខ្ញុំបានចាប់ផ្តើមអធិស្ឋានដើម្បីមានការផ្លាស់ប្តូរនៅក្នុងដួងចិត្តនេះ » ។



« ខ្ញុំបានរៀនអំពីប្រជាជនរបស់ស្តេចឡាម៉ូណៃ នៅក្នុង អាលម៉ា 19:33 ដែល 'ចិត្តគេបានផ្លាស់ប្តូរ ថាគេគ្មានបំណងនឹងធ្វើអំពើអាក្រក់ទៀតឡើយ' ។ ខ្ញុំបានចាប់ផ្តើមអធិស្ឋានដើម្បីមានការផ្លាស់ប្តូរនៅក្នុងដួងចិត្តនេះ » ។

ប្រេ្គកបានរកឃើញចម្លើយចំពោះការអធិស្ឋានរបស់គាត់ ហេលេមិន 15:7 ដែលបង្រៀនថា « សេចក្តីជំនឿ និងការប្រែចិត្ត ដែលនាំមកឱ្យគេនូវការផ្លាស់ប្តូរនៅក្នុងចិត្តគេ » ។

« ពេលដែលខ្ញុំអាននូវពាក្យទាំងនោះ ទឹកភ្នែកបានហូរចុះមកកាត់ផ្ទៃមុខរបស់ខ្ញុំ ។ ព្រះវិញ្ញាណបានធ្វើទីបន្ទាល់ថា ព្រះវរបិតាសួគ៌របស់ខ្ញុំស្រឡាញ់ខ្ញុំ ហើយនឹងជួយខ្ញុំ ។ ខ្ញុំបានមានអារម្មណ៍ថា ប្រសិនបើខ្ញុំមានសេចក្តីជំនឿគ្រប់គ្រាន់ដើម្បីនិយាយជាមួយនឹងប៊ីស្សពរបស់ខ្ញុំ នោះវាគ្រប់គ្រាន់ហើយ ។ កាលដែលខ្ញុំបានដាក់អំពើបាបទាំងឡាយរបស់ខ្ញុំចុះនៅព្រះបាទព្រះអង្គសង្គ្រោះ នោះខ្ញុំបានទទួលនូវការផ្លាស់ប្តូរដ៏ពិតមួយនៅក្នុងដួងចិត្ត » ។

## ស្វែងរកផ្លូវរបស់នាង

ថ្ងៃមួយ ឡូរ៉ា ស្ទិនសុន ពីរដ្ឋអៃដាហូ សហរដ្ឋអាមេរិក បានមកផ្ទះដោយមានអារម្មណ៍តានតឹង និងដោយទឹកភ្នែក ។ នាងមិនទាន់រៀបការទេ ហើយផែនការសម្រាប់រៀនមហាវិទ្យាល័យ និងសម្រាប់ការងាររបស់នាង ដែលនាងបានសុបិន្តចង់បាននោះ ត្រូវបរាជ័យ ។ នាងបានសរសេរថា « ខ្ញុំឆ្ងល់ ប្រសិនបើខ្ញុំអាចបោះជំហានទៅទីណាមួយ » ។

« ខ្ញុំបានទទួលការបំផុសឱ្យបើកទៅក្នុងព្រះគម្ពីរមរមន ។ នៅក្នុងខបួនដំបូងនៃ នីហ្វៃទី1 18 ខ្ញុំបានរកឃើញចម្លើយមួយចំពោះកង្វល់

រចនារូបថត ដោយ វែលដិន ស៊ី អាន់ឌើរសុន



### ជំនួយដល់បញ្ហាផ្ទាល់ខ្លួនទាំងឡាយ

«[ ព្រះគម្ពីរមរមន ] អាចជួយដល់បញ្ហាផ្ទាល់ខ្លួនទាំងឡាយក្នុងរបៀបដ៏ពិតជាក់ស្តែងមួយ ។ តើអ្នកចង់លះបង់ចោលទម្លាប់អាក្រក់មួយដែរឬទេ ? តើអ្នកចង់ធ្វើឱ្យទំនាក់ទំនងក្នុងគ្រួសាររបស់អ្នកបានប្រសើរឡើងដែរឬទេ ? តើអ្នកចង់ពង្រីកសមត្ថភាពខាងវិញ្ញាណរបស់អ្នកដែរឬទេ ? ចូរអានព្រះគម្ពីរមរមន ! »

Elder Russell M. Nelson of the Quorum of the Twelve Apostles, "A Testimony of the Book of Mormon," *Liahona,* Jan. 2000, ទំព័រ 85 ។

ទាំងឡាយរបស់ខ្ញុំ ។ ខទាំងនេះពិពណ៌នាអំពីសំពៅដែលនីហ្វៃបានសង់ដើម្បីនាំក្រុមគ្រួសាររបស់គាត់ទៅកាន់ដែនដីសន្យា ។ វាជា 'សំពៅដ៏វិចិត្រ' ហើយមិនត្រូវបានសង់ឡើង 'តាមក្បួនរបស់មនុស្សដែរ' តែវាត្រូវបានសង់ឡើង 'តាមរបៀបដែលព្រះបានបង្ហាញខ្ញុំ' ( ខ 1–2 ) ។ នីហ្វៃបានប្រឹក្សាជាមួយនឹងព្រះអម្ចាស់ជាញឹកញាប់ខណៈដែលកំពុងសង់សំពៅ ។ នៅពេលដែលសំពៅត្រូវបានសង់រួចហើយ 'សំពៅនេះល្អ ឯក្បាច់ក្បូរសោតក៏ល្អវិចិត្រ...' ( ខ 4 ) ។

« ខ្ញុំបានដឹងថា ដំណើរផ្ទាល់របស់ខ្ញុំគឺ 'ល្អវិចិត្រ' ។ វាមិនត្រូវគ្នានឹងគំរូនៃមនុស្សនោះទេ ប៉ុន្តែនឹងនាំខ្ញុំទៅកន្លែងដែលខ្ញុំត្រូវទៅប្រសិនបើខ្ញុំស្វែងរកការដឹកនាំរបស់ព្រះអម្ចាស់ ។ ខទាំងនេះគឺជាពន្លឺនាំផ្លូវនៅក្នុងគ្រាដ៏ងងឹតមួយ ។ បញ្ហាទាំងឡាយរបស់ខ្ញុំមិនបានបញ្ចប់ត្រឹមមួយយប់នោះទេ ប៉ុន្តែខ្ញុំបានរកឃើញនូវទស្សនវិស័យដែលខ្ញុំត្រូវការ ។ ឥឡូវនេះ ខ្ញុំមានការងារដ៏ល្អដូចជារង្វាន់មួយ ដែលខ្ញុំមិនបានគ្រោងទុកជាមុន » ។

## ការរកឃើញនូវសក្ខីបទមួយទៀត

ពេលនៅជាយុវជនម្នាក់ អេឌ្រៀន ផាហ្ស ហ្សាមប្រាណូ មកពីប្រទេស ហុនឌូរ៉ាស បានឆ្ងល់ថា ហេតុអ្វីព្រះគម្ពីរប៊ីបនិយាយតែអំពីតំបន់ជុំវិញយេរូសាឡិម ហើយឆ្ងល់ថា ប្រសិនបើព្រះយេស៊ូវគ្រីស្ទបានទៅជួបជាតិសាសន៍ផ្សេងៗទៀតឬទេ ។

អេឌ្រៀនបានសរសេរថា « ជាច្រើនឆ្នាំក្រោយមក ពួកអ្នកផ្សព្វផ្សាយសាសនាពីរនាក់របស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ បានមកផ្ទះរបស់ខ្ញុំ » ។ « ពួកគេបានបង្ហាញខ្ញុំនូវព្រះគម្ពីរមរមន ហើយបានអញ្ជើញខ្ញុំឱ្យអាននៅក្នុងនីហ្វៃទី3 ដែលប្រាប់អំពីការយាងមកទ្វីបអាមេរិករបស់ព្រះគ្រីស្ទ ។

« ពេលដែលខ្ញុំបានអាន ខ្ញុំបាននឹកឃើញពីសំណួរទាំងឡាយដែលខ្ញុំបានមាន កាលខ្ញុំនៅពីក្មេង ។ ខ្ញុំបានរកឃើញចម្លើយទាំងឡាយ ។ ដោយសារព្រះគម្ពីរមរមន ខ្ញុំបានរៀនថា ព្រះយេស៊ូវគ្រីស្ទបានយាងមកទ្វីបអាមេរិក បន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ។ ខ្ញុំបានពេញដោយសេចក្តីអំណរ ពីព្រោះខ្ញុំបានដឹងថា ព្រះបានស្រឡាញ់កូនចៅរបស់ទ្រង់ ដោយមិនគិតពីទីកន្លែងឬកាលៈទេសៈអ្វីនោះទេ » ។

អេឌ្រៀន និងប្រពន្ធរបស់គាត់បានអធិស្ឋានជាមួយគ្នា ដើម្បីដឹងថាប្រសិនបើសាសនាចក្រពិតឬទេ ហើយពួកគេទាំងពីរនាក់បានទទួលទីបន្ទាល់មួយ ។ ពួកគេបានទទួលពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ហើយមួយឆ្នាំក្រោយមក ក្រុមគ្រួសាររបស់ពួកគេបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។

## ផ្គត់ផ្គង់ដល់ក្រុមគ្រួសាររបស់គាត់

នៅក្នុងអាយុ 30 ឆ្នាំ អេរិក ជេមស៍ មកពីរដ្ឋនូវ ម៉ិកស៊ិកូ សហរដ្ឋអាមេរិក ត្រូវបានធ្វើរោគវិនិច្ឆ័យថាមានជំងឺតម្រងនោម ។ ក្នុងនាមជាឪពុកវ័យក្មេងម្នាក់ គាត់បានមានការរំជួលចិត្តជាខ្លាំង ហើយឆ្ងល់ថាតើគាត់អាចមានលទ្ធភាពដើម្បីផ្គត់ផ្គង់ដល់ក្រុមគ្រួសាររបស់គាត់បានឬទេ ។

គាត់បានអាននៅក្នុងព្រះគម្ពីរមរមនថា នីហ្វៃបានមានចម្ងល់ដូចគ្នានោះដែរ នៅពេលដែលគាត់បានធ្វើបាក់ធ្នូរបស់គាត់ដែលធ្វើឡើងពីដែកដ៏ល្អ ។ ប៉ុន្តែ បន្ទាប់ពីបានធ្វើធ្នូមួយពីឈើហើយ នីហ្វៃបានមានលទ្ធភាពដើម្បីផ្តល់ចំណីដល់ក្រុមគ្រួសាររបស់គាត់ម្តងទៀត ។ ( សូមមើល នីហ្វៃទី1 16:18–23, 30–32 ) ។

អេរិកបាននិយាយថា « រឿងរបស់នីហ្វៃបានបំពេញព្រលឹងរបស់ខ្ញុំ ដូចជាពន្លឺមួយដ៏ត្រចេះត្រចង់ » ។ « សុខភាពដែលខ្ញុំបានមានភាពសប្បាយរីករាយជាមួយរហូតមកដល់ចំណុចនោះគឺប្រៀបដូចជាធ្នូធ្វើពីដែករបស់នីហ្វៃដូច្នោះដែរ ។ នៅពេលដែលសុខភាពរបស់ខ្ញុំបានធ្លាក់ចុះ វាប្រៀបដូចជាធ្នូរបស់ខ្ញុំបានបាក់ដែរ ។ ប៉ុន្តែ ខ្ញុំបានដឹងថា ព្រះអម្ចាស់បានប្រទានពរដល់ខ្ញុំជាមួយនឹងធ្នូឈើ ក្នុងទម្រង់ជាការផ្លាស់ប្តូរតម្រងនោម ។ ការផ្លាស់ប្តូរនោះនឹងផ្តល់កម្លាំងដល់ខ្ញុំដើម្បីថែរក្សាក្រុមគ្រួសាររបស់ខ្ញុំ ។ ការណ៍នេះបានផ្តល់ក្តីសង្ឃឹមដល់ខ្ញុំ ។ ជិត 10 ឆ្នាំ ក្រោយមក ខ្ញុំនៅតែបន្តផ្គត់ផ្គង់ដល់ក្រុមគ្រួសារខ្ញុំ និងបន្តបម្រើដល់ព្រះអម្ចាស់ យ៉ាងអស់ពីសមត្ថភាពរបស់ខ្ញុំ » ។

## បង្រៀនដល់កុមារអំពីការគោរពប្រតិបត្តិ

នៅពេលកូនៗរបស់គាត់នៅតូច ចូអាន ចូស វីសាន់វិច មកពីប្រទេសអាហ្សង់ទីន បានបើកក្នុងព្រះគម្ពីរមរមន នៅពេលដែលគាត់បានមានសំណួរទាំងឡាយអំពីរបៀបដើម្បីបង្រៀន និងចិញ្ចឹមបីបាច់កូន

ៗរបស់គាត់ ។ គាត់បានសរសេរថា « ប្រពន្ធខ្ញុំ និងខ្ញុំបានស្រាវជ្រាវក្នុងទំព័រទាំងឡាយរបស់ព្រះគម្ពីរ ដើម្បីរកការបំផុសគំនិតសម្រាប់កូនៗរបស់យើង ហើយយើងតែងតែបានរកឃើញចម្លើយទាំងឡាយ » ។

ក្រុមគ្រួសារវីសានូវិច បានបង្រៀនកូនៗរបស់ពួកគេអំពីការគោរពប្រតិបត្តិ ដោយចង្អុលបង្ហាញពួកគេទៅកាន់គំរូរបស់នីហ្វៃនៅក្នុង នីហ្វៃទី1 3:5–6 ៖

« បងៗរបស់កូនរអ៊ូរទាំថា ឪពុកបានតម្រូវឱ្យគេធ្វើការដ៏លំបាក ប៉ុន្តែមើលចុះ ឪពុកមិនបានតម្រូវគេទេ ប៉ុន្តែនេះជាព្រះបញ្ញត្តិនៃព្រះអម្ចាស់ទេតើ ។

« ហេតុដូច្នោះហើយ ទៅចុះកូនប្រុសឪពុក កូននឹងបានប្រោសប្រណីពីព្រះអម្ចាស់ ពីព្រោះកូនមិនបានរអ៊ូរទាំ ។

ចូអានបានសរសេរថា « យើងបានបង្រៀនកូនៗរបស់យើងថា នីហ្វៃបានគោរពដល់ឪពុកម្ដាយនៅលើផែនដីរបស់គាត់ និងការណ៍ទាំងឡាយរបស់ព្រះ » ។ « យើងបានដាក់គោលដៅមួយថា ក្នុងនាមជាក្រុមគ្រួសារមួយ យើងនឹងមានឥរិយាបទរបស់នីហ្វៃ គឺការគោរព និងការប្រតិបត្តិ ។

« កូនរបស់យើងម្នាក់ៗបានបម្រើបេសកកម្ម ។ យើងមិនចាំបាច់អូសទាញពួកគេឱ្យបម្រើនោះទេ ។ ពួកគេជាសិស្សដ៏ល្អ ជាមិត្តដ៏ល្អ និងជាកូនៗដ៏ល្អ ។ ក្រុមគ្រួសាររបស់យើងមានអ្វីៗជាច្រើនដែលត្រូវអរគុណ ប៉ុន្តែព្រះគម្ពីរមរមនជាជំនួយដ៏ធំសម្បើម ក្នុងការទៅដល់គោលដៅទាំងឡាយរបស់យើង » ។

### គេចចេញពីខ្សែទាំងឡាយនៃការញៀន

ពេលដែលកំពុងតយុទ្ធជាមួយនឹងការញៀនជាមួយអាហារ ស៊ូសាន ឡ័នថ៍ មកពីរដ្ឋយូថាហ៍ សហរដ្ឋអាមេរិក បានអធិស្ឋានសុំជំនួយ ។ នាងបានបើកទៅក្នុងព្រះគម្ពីរមរមន ហើយបានអានថា នីហ្វៃត្រូវបានរំដោះឱ្យរួចពីខ្សែទាំងឡាយបងប្រុសរបស់គាត់បានចងជុំវិញដៃ និងជើងរបស់គាត់ ។

« ឱ ព្រះអម្ចាស់អើយ ស្របតាមសេចក្ដីជំនឿរបស់ទូលបង្គំដែលមានចំពោះទ្រង់ សូមព្រះអង្គរំដោះទូលបង្គំ ... ព្រះពរ សូមប្រទានកម្លាំងដល់ទូលបង្គំ ដើម្បីឱ្យទូលបង្គំអាចផ្ដាច់ខ្សែដែលចងទូលបង្គំនេះបាន ។

« ហើយហេតុការណ៍បានកើតឡើងថា ... ខ្សែទាំងនោះក៏របូត » ( នីហ្វៃទី1 7:17–18 ) ។

ស៊ូសានបានសរសេរថា « បទគម្ពីរនេះបានពិពណ៌នាយ៉ាងប្រាកដដូចជាអារម្មណ៍ដែលខ្ញុំបានមាន—ត្រូវបានចងដោយខ្សែទាំងឡាយនៃការញៀន » ។ « ខ្សែដែលអាចមើលឃើញដែលចងនីហ្វៃនោះបានរបូតភ្លាមមួយរំពេច ពេលដែលគាត់បានសុំឱ្យមានការរំដោះ ។ ខ្សែរបស់ខ្ញុំគឺមើលមិនឃើញទេ ហើយខ្ញុំមិនអាចយកឈ្នះការញៀនរបស់ខ្ញុំក្នុងមួយរំពេចនោះឡើយ ប៉ុន្តែពេលដែលខ្ញុំបានអានពាក្យទាំងនោះ ខ្ញុំបានមានអារម្មណ៍ថាអ្វីមួយបានផ្លាស់ប្ដូរនៅក្នុងខ្ញុំ ។ ខ្ញុំបានមានអារម្មណ៍ដូចជាខ្សែដែលរុំជុំវិញដួងចិត្ត គំនិត និងរូបកាយរបស់ខ្ញុំបានរបូតចេញ ហើយខ្ញុំបានដឹងថា ខ្ញុំអាចយកឈ្នះការញៀនរបស់ខ្ញុំបាន » ។

ស៊ូសានបានមានការរីកចម្រើនយ៉ាងខ្លាំង ហើយដោយសារតែការបំផុសគំនិតដែលនាងបានរកឃើញនៅក្នុងព្រះគម្ពីរមរមន នោះនាងបានមានលទ្ធភាពដើម្បីផ្ដាច់ទម្លាប់ផ្សេងៗទៀតដែលបានចងនាង រួមទាំងកំហឹង ភាពអាត្មានិយម និងភាពឆ្មើងឆ្មៃផងដែរ ។ នាងបានពន្យល់ថា « ខ្ញុំដឹងថា ព្រះគម្ពីរមរមនជាព្រះបន្ទូលនៃព្រះ ហើយថាចម្លើយទាំងឡាយចំពោះសំណួរជីវិតនានាណាមួយ គឺអាចត្រូវបានរកឃើញនៅក្នុងទំព័រទាំងឡាយនៃព្រះគម្ពីរនោះ » ។ ■

**កំណត់ចំណាំ**

1. M. Russell Ballard, in "We Add Our Witness," *Tambuli,* Dec. 1989, ទំព័រ 13 ។



## ចម្លើយទាំងឡាយក្នុងព្រះគម្ពីរមរមន

- តើខ្ញុំគួរធ្វើអ្វីបន្ទាប់ទៀតនៅក្នុងជីវិតរបស់ខ្ញុំ ? ( សូមមើល អាលម៉ា 4:6; អាលម៉ា 37:36 ) ។
- តើខ្ញុំអាចធ្វើឱ្យអាពាហ៍ពិពាហ៍របស់ខ្ញុំប្រសើរឡើងដោយរបៀបណា ? ( សូមមើល នីហ្វៃទី1 5:1–9 ) ។
- ហេតុអ្វីខ្ញុំត្រូវរក្សាសៀវភៅកំណត់ហេតុមួយ ? ( សូមមើល យ៉ាកុប 1:2–4; អាលម៉ា 37:2–4; ហេលេមិន 3:13–15 ) ។
- តើខ្ញុំអាចក្លាយជាមិត្តដ៏ល្អប្រសើរម្នាក់ដោយរបៀបណា ? ( សូមមើល អាលម៉ា 15:18 ) ។
- តើខ្ញុំអាចបំពេញការហៅបម្រើរបស់ខ្ញុំដោយរបៀបណា ? ( សូមមើល អាលម៉ា 17:2–12 ) ។
- តើខ្ញុំគួរអធិស្ឋានអំពីអ្វី ? ( សូមមើល អាលម៉ា 34:17–27 ) ។
- តើដង្វាយធួនអាចជួយខ្ញុំឱ្យប្រែចិត្ត និងផ្លាស់ប្ដូរយ៉ាងណាដែរ ? ( សូមមើល អាលម៉ា 36 ) ។
- តើខ្ញុំគួរមានប្រតិកម្មយ៉ាងណា នៅពេលមាននរណាម្នាក់មានចិត្តចង្អៀតចង្អល់នោះ ? ( សូមមើល អាលម៉ា 60 ) ។
- តើខ្ញុំអាចការពារក្រុមគ្រួសារខ្ញុំពីការណ៍អាក្រក់នៅក្នុងលោកិយនេះដោយរបៀបណា ? ( សូមមើល ហេលេមិន 5:12; មរ៉ូណៃ 8:2–3 ) ។
- ហេតុអ្វីខ្ញុំគប្បីទៅព្រះវិហារ ? ( សូមមើល មរ៉ូណៃ 6:5–9 ) ។

យោបល់សម្រាប់ការសិក្សា ៖ សូមធ្វើបញ្ជីសំណួរផ្ទាល់ខ្លួនរបស់អ្នកមួយ ហើយរកមើលចម្លើយទាំងឡាយ ពេលដែលអ្នកសិក្សាព្រះគម្ពីរទាំងឡាយប្រកបដោយការអធិស្ឋាន ។

ខាងស្ដាំ ៖ រូបថតដោយ គ្រីស្ទីណា ស្មិត

*ភាពស្រដៀងគ្នា អាចដឹកនាំយើងឱ្យ « មាន សេចក្ដីអស្ចារ្យកាន់តែតិចទៅៗចំពោះទីសម្គាល់ ឬការអស្ចារ្យនីមួយៗអំពីស្ថានសួគ៌ » ។*





ដោយ អ័ដាម ស៊ី អូលសុន
ទស្សនាវដ្ដីសាសនាចក្រ

# ការរកឃើញជាថ្មីនូវ អច្ឆរិយវត្ថុពិភពលោកមួយ ... និង

## ការជៀសវាងពីគ្រោះថ្នាក់នៃ ភាពព្រងើយកន្តើយឯខាងវិញ្ញាណ



រូបថត ដោយ អ័ដាម ស៊ី អូលសុន ករណីលើកលែងដូចបានកត់ចំណាំ

ស៊ីវ៉ូ វីឡារីសិនស៊ីអូ ធ្វើការប៉ាន់ប្រមាណថា អំឡុងពេលបីឆ្នាំដំបូងរបស់គាត់ ក្នុងនាមជាមគ្គុទេសក៍ទេសចរណ៍ម្នាក់នៅក្នុងតំបន់យូស្កូ នៃប្រទេសពេរូ នោះគាត់បានដឹកនាំក្រុមទេសចរណ៍ជិត 400 ក្រុម ទៅកាន់ភ្នំ ម៉ាឈូ ភីឈូ ជា « ទីក្រុងបាត់បង់ » ដ៏ល្បីល្បាញមួយនៃអាណាចក្រអ៊ិងកាស ។ ទោះបីជាបន្ទាប់ពីការទស្សនាជាច្រើនដងរបស់គាត់យ៉ាងណាក៏ដោយ ក៏កន្លែងនេះ—ដែលត្រូវបានបញ្ចូលទៅក្នុងបញ្ជីផ្សេងៗនៃអច្ឆរិយវត្ថុពិភពលោកទាំងឡាយ—ពុំបានបាត់បង់នូវភាពអស្ចារ្យរបស់វាចំពោះគាត់ដែរ ។

គាត់បាននិយាយថា « តែងតែមានអ្វីមួយថ្មីដើម្បីរៀន » ។ ការចំណាយពេលជាច្រើនម៉ោង នាំក្រុមអ្នកទស្សនាមួយក្រុមឆ្លងកាត់ភ្នំ ម៉ាឈូ ភីឈូ គឺមិនមែនជាការចម្លែកទេសម្រាប់ស៊ីវ៉ូ ។ ទោះជាយ៉ាងក៏ដោយ គាត់បានឃើញ ថាតើវាមានភាពងាយស្រួលយ៉ាងណាក្នុងការបាត់បង់នូវភាពអស្ចារ្យនោះ ។ មិត្តរួមការងាររបស់គាត់មួយចំនួន ដឹកនាំដំណើរទស្សនាទាំងមូលត្រឹមតែក្នុង 45 នាទី ប៉ុណ្ណោះ ។ គាត់និយាយថា « ពួកគេបានបាត់បង់ចំណាប់អារម្មណ៍ » ។

ស៊ីវ៉ូ ជាសមាជិកម្នាក់នៃវួដ ឆាសហ្គី និងជាទីប្រឹក្សាជាន់ខ្ពស់ក្នុងស្តេក យូស្កូ ពេរូ អ៊ិនធី រេមី ជឿថា ការយល់ពីការមិនចាប់អារម្មណ៍របស់មិត្តរួមការងាររបស់គាត់ អាចជួយដល់សមាជិកសាសនាចក្រពង្រីកនូវចំណាប់អារម្មណ៍ចំពោះអច្ឆរិយវត្ថុពិភពលោកមួយផ្សេងទៀត—អច្ឆរិយវត្ថុដ៏សំខាន់បំផុតមួយ—« ការមួយដ៏អស្ចារ្យ ហើយចម្លែក » នៃដំណឹងល្អដែលបានស្ដារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ( នីហ្វៃទី2 25:17 ) ។

គ្រោះថ្នាក់នៃការបាត់បង់អច្ឆរិយវត្ថុ

ដោយត្រូវបានបោះបង់ចោលនៅចុងទសវត្សរ៍ឆ្នាំ 1500 ដោយពួកអ៊ិងកាស ហើយមិនត្រូវបានរកឃើញដោយពួកសាសន៍អេស្ប៉ាញដែលជាអ្នកច្បាំងដណ្ដើមយកប្រទេសពេរូ នោះទីក្រុងដាច់សង្វែងដែលនៅទីខ្ពស់ក្នុងជួរភ្នំ ពេរូវៀន អានដេស បានបាត់បង់ពីមនុស្សទាំងអស់ទៅ លើកលែងតែមួយចំនួនតូចប៉ុណ្ណោះ ។ ពេលចូលដល់សតវត្សរ៍ទី 20 ការរុករកឃើញរបស់វាដោយប្រទេសនានាខាងក្រៅ បាននាំមកនូវក្រុមអ្នកស្រាវជ្រាវ និងអ្នកទេសចរណ៍ជាច្រើន ។

ស៊ីវ៉ូបាននិយាយថា បន្ទាប់ពីការសិក្សាជាច្រើនទសវត្សរ៍ក្រោយមក « មនុស្សខ្លះបានគិតថា ពួកគេបានរកឃើញគ្រប់អ្វីៗទាំងអស់ដែលត្រូវស្វែងរកនៅភ្នំម៉ាឈូ ភីឈូ នេះ » ។ « នៅពេលដែលមនុស្សគិតថាគ្រប់អ្វីៗទាំងអស់ត្រូវបានរកឃើញអស់ហើយ ឬថាគ្រប់អ្វី



*កាលណាអ្នកស្រាវជ្រាវនៅតែសិក្សាអំពីភ្នំ ម៉ាឈូ ភីឈូ នោះពួកគេត្រូវបានផ្ដល់ឱ្យជាមួយនឹងការរកឃើញថ្មីៗទៀត និងចំណេះដឹងបន្ថែមទៀត ។*

ៗទាំងអស់ត្រូវបានធ្វើចប់ហើយ នោះពួកគេបានបោះបង់ចោល ឬបន្ទាបតម្លៃរបស់នោះ ឬការខិតខំប្រឹងប្រែងនោះ » ។

ស៊ីរ៉ូព្រួយបារម្ភថា អារម្មណ៍នៃភាពគ្រប់គ្រាន់ដូចគ្នានេះអាចកើតមានឡើងនៅក្នុងសាសនាចក្រ ។ គាត់បានឃើញថា អំពីរបៀបដែលពេលវេលា និងភាពស្រដៀងគ្នា អាចដឹកនាំសមាជិកខ្លះឱ្យ « មានសេចក្ដីអស្ចារ្យកាន់តែតិចទៅៗចំពោះទីសម្គាល់ ឬការអស្ចារ្យនីមួយៗអំពីស្ថានសួគ៌ ដរាបដល់ពួកគេ [ ចាប់ផ្ដើម ] រឹងរូសនៅក្នុងចិត្តរបស់គេ និងងងឹតងងល់នៅក្នុងគំនិតរបស់គេ ហើយ [ ចាប់ផ្ដើម ] មិនជឿអ្វីៗទាំងអស់ ដែលពួកគេបានឃើញ ហើយបានឮ » ( នីហ្វៃទី3 2:1 ) ។

ការបាត់បង់នូវភាពអស្ចារ្យនេះ អាចធ្វើឱ្យសមាជិកងាយទទួលនូវការកុហករបស់សាតាំង ដូចជា ៖ អ្នកមិនចាំបាច់ស្ដាប់ដល់អ្នកឡើងនិយាយទេ អ្នកបានដឹងវារួចអស់ទៅហើយ ។ អ្នកមិនចាំបាច់ទៅសាលាថ្ងៃអាទិត្យទេ អ្នកបានឮមេរៀននោះពីមុនមកហើយ ។ អ្នកមិនចាំបាច់សិក្សាព្រះគម្ពីរទាំងឡាយរបស់អ្នកទេ គ្មានអ្វីថ្មីនៅក្នុងនោះទេ ។

« ម្ល៉ោះហើយ អារក្សសាតាំង [ ចាប់យក ] ដួងចិត្តមនុស្សបាន » ( នីហ្វៃទី3 2:2 ) ។

ការមានបទពិសោធន៍នូវសេចក្ដីសោមនស្សរំភើបឡើងចុះចំពោះដំណឹងល្អ គឺពុំមែនជារឿងចម្លែកនោះទេ ។ ប៉ុន្តែអស់អ្នកណាដែលបណ្ដោយឱ្យការបង្អង់ក្នុងការរៀនសូត្រខាងវិញ្ញាណ ឱ្យពន្យាចូលទៅក្នុងជីវិតរស់នៅ នោះគឺបិតនៅក្នុងគ្រោះថ្នាក់នៃការបាត់បង់ « ទាំងអ្វីដែលពួកគេមាននោះផង » នៅក្នុងការយល់ដឹងខាងវិញ្ញាណ ( នីហ្វៃទី2 28:30; សូមមើលផងដែរ ម៉ាថាយ 25:14–30 ) ។

## អស្ចារ្យជាថ្មីម្ដងទៀត

ការយល់ពីសេចក្ដីពិតចំនួនបី បានជួយស៊ីរ៉ូ ឱ្យនៅតែអាចទទួលការបង្រៀនបាន ទោះជាមានការអូសទាញឱ្យមានភាពព្រងើយកន្ដើយក៏ដោយ ។

**1. មានអ្វីបន្ថែមទៀតដែលខ្ញុំត្រូវការដឹង ។**

អំឡុងពេលទាំងឡាយនៃការសិក្សាដំណឹងល្អយ៉ាងហ្មត់ចត់នៅក្នុងបេសកកម្មរបស់គាត់ និងជាគ្រូបង្រៀនថ្នាក់វិទ្យាស្ថានម្នាក់នោះ ស៊ីរ៉ូបានរកឃើញថា តែងតែមានអ្វីមួយបន្ថែមទៀតដើម្បីរៀន មិនថាវាជាគោលការណ៍ថ្មីមួយ ឬជាការអនុវត្តន៍ថ្មីមួយនៃគោលការណ៍ដែលគាត់ធ្លាប់បានដឹងរួចមកហើយក៏ដោយ ។ សំខាន់ជាងនោះទៅទៀត ចំណេះដឹងខាងវិញ្ញាណថ្មីនោះ គឺជាញឹកញាប់ជាអ្វីមួយ ដែលគាត់ត្រូវការដឹង ដើម្បីពុះពារឆ្លងកាត់ឧបសគ្គអ្វីក៏ដោយ ដែលគាត់កំពុងប្រឈមមុខជាមួយ—ឬដែលបម្រុងនឹងប្រឈមមុខជាមួយ ។

គាត់បាននិយាយថា « ផ្នែកមួយនៃការទទួលការបង្រៀនបាន គឺការចងចាំថា តែងតែមានអ្វីមួយដែលខ្ញុំមិនដឹង ដែលខ្ញុំប្រាកដជាត្រូវការដឹង » ។

**2. ខ្ញុំត្រូវការជំនួយពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីរៀននូវអ្វីដែលខ្ញុំត្រូវការរៀន ។**

នៅពេលអ្នកមិនដឹងពីអ្វី ដែលអ្នកត្រូវការដឹង នោះអ្នកត្រូវការគ្រូម្នាក់ដែលពោរពេញដោយការចេះដឹង ( សូមមើល យ៉ូហាន 14:26 ) ។ ពេលដែលស៊ីរ៉ូ សិក្សាព្រះគម្ពីរទាំងឡាយតែម្នាក់ឯង ឬជាមួយប្រពន្ធរបស់គាត់ ឬពេលដែលគាត់ចូលរួមនៅក្នុងថ្នាក់រៀន និងការប្រជុំនានានោះ គាត់តែងតែត្រូវបានរំឭកមិនឈប់ឈរថា វាមិនសំខាន់ទេ ថាគាត់បានអានខជាក់លាក់មួយ ឬបានឮពីអត្ថន័យដ៏ជាក់លាក់មួយញឹកញាប់ប៉ុណ្ណានោះ ។

គាត់និយាយថា « ព្រះវិញ្ញាណអាចបង្រៀនខ្ញុំនូវការណ៍ទាំងឡាយ ដែលខ្ញុំមិនធ្លាប់បានពិចារណាដល់ពីមុនមក » ។ « ព្រះវិញ្ញាណបរិសុទ្ធគឺជាគ្រូបង្រៀន » ។

**3. ការរៀនតម្រូវឱ្យមានការខិតខំប្រឹងប្រែងទៅលើផ្នែករបស់ខ្ញុំ ។**

ការរៀនគឺជាការអនុវត្តន៍ដែលសកម្ម មិនមែនអកម្មទេ ។ [1] វាតម្រូវឱ្យមានបំណងប្រាថ្នា ការយកចិត្តទុកដាក់ ការចូលរួម និងការអនុវត្តន៍នូវគោលការណ៍ទាំងឡាយដែលបានរៀន ( សូមមើល អាលម៉ា 32:27 ) ។

ស៊ីរ៉ូនិយាយថា « ខ្ញុំត្រូវតែទទួលយកការទទួលខុសត្រូវចំពោះការរៀន » ។ « ព្រះវរបិតានឹងមិនបង្ខំខ្ញុំ ឱ្យរៀនអ្វីនោះទេ » ។

## ភាពអស្ចារ្យដែលជារង្វាន់

សម្រាប់ស៊ីរ៉ូ ភ្នំ ម៉ាឈូ ភីឈូ គឺនៅតែជាអច្ឆរិយវត្ថុពិភពលោក ពីព្រោះ កាលណាអ្នកស្រាវជ្រាវនៅតែសិក្សាអំពីវា នោះពួកគេត្រូវបានផ្ដល់ឱ្យជាមួយនឹងការរកឃើញថ្មីៗទៀត និងចំណេះដឹងបន្ថែមទៀត ។

សូម្បីតែបន្ទាប់ពីការសិក្សាអស់មួយសតវត្សរ៍ហើយក្ដី ក៏អ្នកបុរាណវិទូទាំងឡាយទើបតែបានរកឃើញនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះប៉ុណ្ណោះ នូវទីលានបញ្ចុះសពគ្រឿងស្នូន និងរបៀបសង់ផ្ទៃរាបនៅជម្រាលភ្នំបន្ថែមទៀត ដែលទាំងអស់នេះបានបន្ថែមដល់អ្វីដែលបានដឹងរួចទៅហើយអំពីភ្នំ ម៉ាឈូ ភីឈូ និងពួកអ៊ិងកាស ។

បែបនេះគឺជាករណីជាមួយនឹងការសិក្សាដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ ស៊ីរ៉ូនិយាយថា « តែងតែមានអ្វីមួយដែលថ្មី ដើម្បីស្វែងរកឱ្យឃើញនៅក្នុងដំណឹងល្អ សម្រាប់អស់អ្នកណាដែលខំប្រឹងព្យាយាម » ។

គឺដូចជាការរកឃើញថ្មីៗទាំងឡាយនៅឯភ្នំ ម៉ាឈូ ភីឈូ សាងទៅលើការចេះដឹងពីមុននោះ ផ្ដល់ដល់អ្នកស្រាវជ្រាវនូវការយល់កាន់តែពេញលេញបន្ថែមទៀត « នរណាដែលពុំធ្វើចិត្តរឹងរូសទេ អ្នកនោះហើយដែលនឹងបានទទួលព្រះបន្ទូលរបស់ព្រះអង្គមួយភាគច្រើនជាង រហូតដល់អ្នកនោះអាចដឹងនូវសេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ រហូតដល់អ្នកនោះដឹងគ្រប់សេចក្ដី » ( អាលម៉ា 12:10; សូមមើលផងដែរ គ. និង ស. 50:24 ) ។

ស៊ីរ៉ូនិយាយថា « ដំណឹងល្អគឺជាប្រភពដ៏គ្មានទីបញ្ចប់នៃទឹករស់ ដែលយើងត្រូវត្រឡប់ទៅរកជាទៀតទាត់ » ។

## កិច្ចការដ៏អស្ចារ្យនៃអច្ឆរិយវត្ថុ

ពេលដែលស៊ីរ៉ូ មើលពីទីលយខ្ពស់មួយពីលើភ្នំ ម៉ាឈូ ភីឈូ នោះមានក្រុមទេសចរណ៍ជាច្រើនក្រុមផ្សេងៗគ្នាដើរក្នុងចំណោមអគារបុរាណទាំងឡាយ ។ សម្រាប់ស៊ីរ៉ូ សោកនាដកម្មនៅក្នុងការមិនចាប់អារម្មណ៍ក្នុងចំណោមមិត្តរួមការងារមួយចំនួនតូចរបស់គាត់នោះ មិនត្រឹមតែធ្វើឱ្យវាមានការឈឺចាប់ចំពោះពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់អស់អ្នកណាដែលទទួលបទពិសោធន៍នូវអច្ឆរិយវត្ថុនោះតាមរយៈពួកគេផងដែរ ។

ការរក្សាភាពអស្ចារ្យសម្រាប់ដំណឹងល្អនៅនៅរស់រវើក នឹងមិនត្រឹមតែផ្ដល់ពរជ័យដល់បុគ្គលម្នាក់ៗនោះទេ ប៉ុន្តែដល់អស់អ្នកណាដែលមានប្រាស្រ័យទាក់ទងជាមួយគាត់ផងដែរ ។ ស៊ីរ៉ូនិយាយថា « ការផ្លាស់ប្ដូរដែលដំណឹងល្អបានផ្លាស់ប្រែនៅក្នុងជីវិតរបស់មនុស្សនោះគឺជាអច្ឆរិយមួយ » ។ « ហើយអស់អ្នកណាដែលបានទទួលបទពិសោធន៍នៃការផ្លាស់ប្ដូរនោះ អាចក្លាយទៅជាអច្ឆរិយមួយខ្លួនឯងផ្ទាល់ នៅក្នុងជីវិតអ្នកផ្សេងទៀត » ។ ■





### កំណត់ចំណាំ

1. សូមមើល David A. Bednar, “Seek Learning by Faith,” *Liahona*, Sept. 2007, ទំព័រ 16 ។





# ការស្វែងរកការជម្រុញចិត្តក្នុងការអានព្រះគម្ពីរទាំងឡាយ

ដោយ វីលហ្វើរ ម៉ុនថេស លីអូន

យើងត្រូវអធិស្ឋានឱ្យមានការជម្រុញចិត្តឱ្យអានព្រះគម្ពីរទាំងឡាយព្រមទាំងសម្រាប់ការណែនាំពីព្រះវិញ្ញាណបរិសុទ្ធផងដែរ ។ យើងត្រូវតែមានភាពរីករាយនៅក្នុងព្រះគម្ពីរ ដែលជាសេចក្ដីរីករាយមកពីព្រះបន្ទូលនៃព្រះ ហើយទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ដែលបានផ្ដល់ឱ្យយើងតាមរយៈសារលិខិតដែលព្រះគម្ពីរផ្ដល់ដល់យើង ។ យើងពុំត្រូវអានតែអក្សរនោះឡើយ ដោយសារគោលបំណងដ៏សំខាន់នោះគឺដើម្បីធ្វើឱ្យយើងមានសេចក្ដីស្រឡាញ់យ៉ាងខ្លាំងទៅលើដំណឹងល្អដ៏អស្ចារ្យនេះ ។

គ្រប់ពេលដែលអ្នកស្រាវជ្រាវបទគម្ពីរទាំងឡាយ អ្នកនឹងបានរៀនបន្ថែមទៀត ហើយតាមរយៈបទគម្ពីរទាំងនោះអ្នកអាចចាប់ផ្ដើមដឹងពីព្រះហឫទ័យនៃព្រះវរបិតាសួគ៌របស់យើង ។ ជារឿយៗទ្រង់ឆ្លើយតបការអធិស្ឋានរបស់យើងតាមរយៈបទដ្ឋានព្រះគម្ពីររបស់សាសនាចក្រ ។ នៅពេលយើងមានអារម្មណ៍សុខសាន្ត និងទទួលនូវគំនិតដែលពោរពេញដោយការបំផុស នោះយើងអាចដឹងថាវាមកពីព្រះវរបិតាសួគ៌តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ( សូមមើលគ. និង ស. 8:1–3) ។

រូបថតនៃសត្វឡាមា © រូបភាពរបស់ហ្វូតូឌីស រូបថតនៃព្រះគម្ពីរ ដោយ ខូឌី បែល







**ដោយអែលឌើរ**
**ឌី ថត គ្រីស្តូហ្វឺសិន**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# ការស្គាល់នូវ ព្រះហស្តរបស់ព្រះ នៅក្នុងពរជ័យប្រចាំថ្ងៃរបស់យើង

*ការទូលសុំ និងការទទួលពរជ័យប្រចាំថ្ងៃពីព្រះហស្តរបស់ព្រះ ដើរតួយ៉ាងសំខាន់នៅក្នុងការរៀនទុកចិត្តលើទ្រង់ និងក្នុង ការស៊ូទ្រាំនឹងឧបសគ្គទាំងឡាយនៅក្នុងជីវិត ។*

លូកាបានកំណត់ត្រាថា មានសិស្សរបស់ទ្រង់ម្នាក់បានទូលសួរដល់ទ្រង់ថា « ព្រះអម្ចាស់អើយ សូមទ្រង់បង្រៀនយើងខ្ញុំឱ្យចេះអធិស្ឋានផង ដូចជាលោកយ៉ូហានបានបង្រៀនដល់សិស្សលោកដែរ » ( លូកា 11:1 ) ។ ក្រោយមកព្រះយេស៊ូវបានប្រទានទូវគំរូមួយនៃការអធិស្ឋានដែលត្រូវបានគេស្គាល់ថាជាការអធិស្ឋានរបស់ព្រះអម្ចាស់ ( សូមមើល លូកា11:2–4 សូមមើលផងដែរ ម៉ាថាយ 6:9–13 ) ។

រួមបញ្ចូលនៅក្នុងការអធិស្ឋានរបស់ព្រះអម្ចាស់គឺមានទូវការទូលសុំថា « សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ » ( ម៉ាថាយ 6:11 សូមមើលផងដែរ លូកា 11:3 ) ។ យើងទាំងអស់គ្នាមានទូវតម្រូវការជារៀងរាល់ថ្ងៃជាមូលហេតុដែលយើងត្រូវងាកទៅរកព្រះវរបិតាសួគ៌របស់យើង ។ ចំពោះមនុស្សមួយចំនួន វាគឺជានំប៉័ងមែនទែន—ដែលជា អាហារដែលត្រូវការដើម្បីទ្រទ្រង់ជីវិតនៅថ្ងៃនោះ ។ វាក៏អាចជាកម្លាំងខាងវិញ្ញាណ និងខាងសាច់ឈាមដើម្បីទប់ទល់នឹងជម្ងឺរ៉ាំរ៉ៃឬជាការព្យាបាលដោយសន្សឹមៗដែលពោរពេញដោយការឈឺចាប់បានមួយថ្ងៃទៀតផងដែរ ។ នៅក្នុងករណីផ្សេងទៀតវាអាចជាតម្រូវការបន្តិចបន្តួច ដូចជាអ្វីមួយដែលប្រើសម្រាប់កាតព្វកិច្ច ឬសកម្មភាពនានារបស់បុគ្គលម្នាក់នៅថ្ងៃនោះ—ឧទាហរណ៍ ការបង្រៀនមេរៀនមួយ ឬការប្រលងមួយ ។

ព្រះយេស៊ូវគ្រីស្ទបង្រៀនយើង ដែលជាពួកសិស្សរបស់ទ្រង់ ថាយើងគួរតែសម្លឹងទៅរកព្រះជារៀងរាល់ថ្ងៃសម្រាប់អាហារនោះ—ដែលជាជំនួយ និងការទ្រទ្រង់—ដែលយើងត្រូវការនៅថ្ងៃនោះ ។ ការអញ្ជើញរបស់ព្រះអម្ចាស់ឱ្យស្វែងរកទូវអាហារប្រចាំថ្ងៃពីព្រះហស្តនៃព្រះវរបិតាសួគ៌របស់យើងគឺស្តែងឱ្យឃើញពីព្រះដ៏ជាទីស្រឡាញ់មួយអង្គ ពីការគិតគូរសូម្បីតែជាសេចក្តីត្រូវការបន្តិចបន្តួចប្រចាំថ្ងៃរបស់កូនចៅទ្រង់ និងពីព្រះទ័យចាំជួយដល់ពួកគេម្នាក់ម្តងៗ ។ ទ្រង់កំពុងតែមានព្រះបន្ទូលថាយើងអាចសុំដោយសេចក្តីជំនឿចំពោះការណ៍នោះ « ដែលប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឱ្យ » ( យ៉ាកុប 1:5 ) ។ ជាការពិតណាស់ នោះគឺជា ការបញ្ជាក់ដ៏អស្ចារ្យ ប៉ុន្តែនៅត្រង់នេះគឺមានទូវអ្វីមួយដែលត្រូវធ្វើដែលវាជាការអស្ចារ្យជាងការដែលគ្រាន់តែជួយឱ្យរួចផុតពីមួយថ្ងៃទៅមួយថ្ងៃទៅទៀត ។ នៅពេលយើងស្វែងរក ហើយទទួលអាហារដ៏ទេវភាពជារៀងរាល់ថ្ងៃ នោះសេចក្តីជំនឿ និងទំនុកចិត្តរបស់យើងទៅលើព្រះ និងព្រះរាជបុត្រារបស់ទ្រង់នឹងមានការរីកចម្រើនឡើង ។

*ព្រះយេស៊ូវគ្រីស្ទបង្រៀនយើង ដែលជាពួកសិស្សរបស់ទ្រង់ថាយើងគួរតែសម្លឹងទៅរកព្រះជារៀងរាល់ថ្ងៃសម្រាប់អាហារនោះ—ដែលជាជំនួយ និងការទ្រទ្រង់—ដែលយើងត្រូវការនៅថ្ងៃនោះ ។*

## ការសម្លឹងទៅរកព្រះជារៀងរាល់ថ្ងៃ

បន្ទាប់ពីការជម្លៀសចេញដ៏ធំរបស់ពួកគេពីប្រទេស អេហ្ស៊ីបមកនោះពូជអំបូរអ៊ីស្រាអែលបានចំណាយពេល 40 ឆ្នាំនៅក្នុងទីរហោស្ថានពីមុនចូលទៅក្នុងដែនដីសន្យា ។ ក្រុមមនុស្សជាងមួយលាននាក់នេះត្រូវការអាហារដើម្បីបរិភោគ ។ ប្រាកដណាស់ ចំនួនមនុស្សដ៏ច្រើនស្ថិតនៅទីតាំងតែមួយនោះពុំអាចរស់នៅដោយពឹងផ្អែកតែលើការបរបាញ់សត្វដ៏យូរបានទៀតឡើយ ហើយជីវភាពមិនទឹងនរបស់ពួកគេនៅពេលនោះ គឺគ្មានអត្ថប្រយោជន៍ឡើយ ដើម្បីធ្វើការដាំដុះ ឬ ឬចិញ្ចឹមសត្វនៅក្នុងចំនួនដ៏គ្រប់គ្រាន់ណាមួយនោះ ។ ព្រះយេហូវ៉ាបានដោះស្រាយឧបសគ្គនេះដោយការប្រទានអាហារប្រចាំថ្ងៃដល់ពួកគេយ៉ាងអស្ចារ្យមកពីស្ថានសួគ៌គឺជា—នំម៉ាន៉ា ។ តាមរយៈម៉ូសេ ព្រះអម្ចាស់បានណែនាំដល់ប្រជាជនទាំងនោះឱ្យប្រមូលនំម៉ាន៉ាល្មមគ្រប់គ្រាន់សម្រាប់ថ្ងៃនីមួយៗ លើកលែងតែថ្ងៃពីមុនថ្ងៃឈប់សម្រាកប៉ុណ្ណោះដែលពួកគេត្រូវប្រមូលឱ្យល្មមគ្រប់គាន្រ់សម្រាប់ពីរថ្ងៃ ។

ថ្វីបើមានការណែនាំដ៏ជាក់លាក់របស់ម៉ូសេយ៉ាងណាក៏ដោយក៏មានមនុស្សមួយចំនួនបានព្យាយាមប្រមូលលើសពីអ្វីដែលល្មមគ្រប់គ្រាប់សម្រាប់មួយថ្ងៃ ហើយស្តុកទុកនំម៉ាន៉ាដែលនៅសល់ ៖

« រួចម៉ូសេប្រាប់ថា កុំឱ្យអ្នកណាទុកឱ្យសល់ដល់ព្រឹកឡើយ ។

« តែគេមិនបានស្តាប់តាមទេ ក៏មានអ្នកខ្លះបានទុកនំនោះដល់ព្រឹកនោះក៏កើតមានដង្កូវមានក្លិនស្អុយ » ( និក្ខមនំ 16:19–20 ) ។

ប៉ុន្តែ ដូចដែលបានសន្យា នៅពេលពួកគេបានប្រមូលឱ្យល្មមគ្រប់គ្រាន់សម្រាប់ពីរថ្ងៃនៃចំនួននំម៉ាន៉ាសម្រាប់ថ្ងៃធម្មតានៅថ្ងៃទីប្រាំមួយ នោះវាឥតមានធុំក្លិនស្អុយទេ ( សូមមើល និក្ខមនំ 16:24–26 ) ។ ប៉ុន្តែ ជាថ្មីម្តងទៀត ក៏មានអ្នកខ្លះពុំជឿឡើយដោយសារតែពុំបានឃើញ ហើយពួកគេបានចេញទៅប្រមូលនំម៉ាន៉ានៅថ្ងៃឈប់សម្រាក តែ « រកគ្មានសោះ » ( សូមមើល និក្ខមនំ 16:27–29 ) ។

ដោយការប្រទានផ្តល់នូវអាហារប្រចាំថ្ងៃមួយថ្ងៃម្តងៗ ព្រះយេហូវ៉ាបានព្យាយាមបង្រៀនអំពីសេចក្តីជំនឿទៅដល់ជាតិសាសន៍មួយដែលបានបាត់បង់យ៉ាងច្រើននូវសេចក្តីជំនឿនៃដូនតារបស់ខ្លួនអស់រយៈពេលជាង 400 ឆ្នាំ ។ ទ្រង់បានបង្រៀនពួកគេឱ្យទុកចិត្តលើទ្រង់ ។ ជាពិសេស កូនចៅអ៊ីស្រាអែលត្រូវតែដើរតាមទ្រង់ជារៀងរាល់ថ្ងៃ ហើយទុកចិត្តថាទ្រង់នឹងប្រទានអាហារល្មមគ្រប់គ្រាន់សម្រាប់ថ្ងៃស្អែក *និង* ថ្ងៃបន្តបន្ទាប់ទៀត ។ តាមរបៀបនោះទ្រង់នឹងមិនដែលឃ្លាតឆ្ងាយពីគំនិត និងដួងចិត្តរបស់ពួកគេឡើយ ។

មានគ្រាមួយ ពូជអំបូរអ៊ីស្រាអែលបានស្ថិតនៅក្នុងស្ថានភាពមួយដើម្បីផ្គត់ផ្គង់ដល់ខ្លួនឯង នោះពួកគេត្រូវបានតម្រូវឱ្យធ្វើដូច្នោះ ។ ទន្ទឹមនឹងនោះដែរ នៅពេលយើងទូលអង្វរដល់ព្រះសម្រាប់អាហារប្រចាំថ្ងៃរបស់យើង—សម្រាប់ជំនួយនៅក្នុងគ្រាដែលយើងពុំអាចផ្តល់ឱ្យដោយខ្លួនឯងបាន—នោះយើងនៅតែត្រូវធ្វើ និងផ្តល់យ៉ាងសកម្មនូវអ្វីដែលយើងអាចធ្វើបាន ។

## ការទុកចិត្តលើព្រះអម្ចាស់

មានពេលមួយពីមុនខ្ញុំត្រូវបានហៅឱ្យធ្វើជាអ្នកមានសិទ្ធិអំណាចទូទៅ ខ្ញុំបានប្រឈមនឹងបញ្ហាសេដ្ឋកិច្ចផ្ទាល់ខ្លួនមួយដែលបន្តមានអស់រយៈពេលជាច្រើនឆ្នាំ ។ វាបានលិចជន់ជោរនៅក្នុងសភាពធ្ងន់ធ្ងរនិងអាសន្ន ប៉ុន្តែវាមិនដែលរសាយបាត់ទៅសោះឡើយ ។ ពេលខ្លះឧបសគ្គនេះបានគម្រាមកំហែងដល់សុខុមាលភាពគ្រួសាររបស់ខ្ញុំហើយខ្ញុំបានគិតថាយើងអាចប្រឈមនឹងសេចក្តីវិនាសហិនហោចខាងហិរញ្ញវត្ថុ ។ ខ្ញុំបានអធិស្ឋានឱ្យមានអន្តរាគមន៍ដ៏អស្ចារ្យមួយចំនួនដើម្បីរំដោះយើង ។ ទោះបីជាខ្ញុំបានធ្វើការអធិស្ឋាននោះដោយចិត្តស្មោះអស់ពីចិត្តជាច្រើនដងយ៉ាងណាក្តី ក៏នៅទីបញ្ចប់ចម្លើយគឺជាពាក្យទេ ។ ទីបំផុតខ្ញុំបានរៀនអធិស្ឋានដូចដែលព្រះអង្គសង្គ្រោះបានអធិស្ឋាន ៖ « ប៉ុន្តែកុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ » (លូកា 22:42) ។ ខ្ញុំបានព្យាយាមស្វែងរកជំនួយពីព្រះអម្ចាស់ជាមួយនឹងជំហានតូចៗដែលដឹកនាំទៅរកដំណោះស្រាយចុងក្រោយមួយ ។

មានពេលខ្លះខ្ញុំបានបាត់បង់នូវធនធានទាំងអស់របស់ខ្ញុំ ហើយវាជាពេលដែលខ្ញុំគ្មានទីកន្លែងដែលត្រូវទៅ និងគ្មាននរណាម្នាក់ដែលត្រូវងាកទៅរកដើម្បីសុំជំនួយ ដើម្បីបំពេញនូវសេចក្តីត្រូវការចំពោះមុខឡើយ ។ ដោយពុំមានធនធានឯណាទៀត ខ្ញុំបានលត់ជង្គង់ចុះចំពោះព្រះវរបិតាសួគ៌របស់ខ្ញុំជាច្រើនដង ដោយទូលអង្វរសុំទាំងទឹកភ្នែកសម្រាប់ជំនួយរបស់ទ្រង់ ។ ហើយទ្រង់ពិតជាបានជួយ ។ ពេលខ្លះវាគ្មានអ្វីសោះក្រៅពីអារម្មណ៍នៃសេចក្តីសុខសាន្ត អារម្មណ៍នៃការបញ្ជាក់ថាអ្វីៗទាំងអស់នឹងមានផ្លូវដោះស្រាយ ។ ខ្ញុំប្រហែលជាមើលមិនឃើញថាផ្លូវនោះនឹងមានលក្ខណៈបែបណា ឬជាអ្វីនោះទេ ប៉ុន្តែទ្រង់បានឱ្យខ្ញុំដឹងដោយផ្ទាល់

ឬដោយប្រយោល ថា ទ្រង់នឹងបើកផ្លូវមួយសម្រាប់ខ្ញុំ ។ កាលៈទេសៈទាំងឡាយអាចផ្លាស់ប្ដូរ គំនិតថ្មី និងមានប្រយោជន៍មួយអាចជ្រាបចូលក្នុងចិត្ត ប្រាក់ចំណូលដែលមិនបានរំពឹងទុកមួយចំនួន ឬធនធានផ្សេងទៀតអាចនឹងកើតមានមកចំពេល ។ មិនដឹងជាយ៉ាងម៉េចដំណោះស្រាយមួយបានកើតមានឡើង ។

ទោះបីជាខ្ញុំបានរងការឈឺចាប់នៅពេលនោះក្ដី ក៏ឥឡូវនេះខ្ញុំមានអំណរគុណដែលពុំមានដំណោះស្រាយភ្លាមៗចំពោះបញ្ហារបស់ខ្ញុំ ។ ទោះជាខ្ញុំត្រូវបានបង្ខំចិត្តឱ្យងាកទៅរកព្រះសម្រាប់ជំនួយស្ទើរតែរាល់ថ្ងៃអស់រយៈពេលជាច្រើនឆ្នាំក្ដី ប៉ុន្តែវាបានបង្រៀនខ្ញុំពីរបៀបអធិស្ឋានពិត និងពីរបៀបទទួលចម្លើយចំពោះការអធិស្ឋាន ហើយបានបង្រៀនខ្ញុំតាមរបៀបមួយដ៏ត្រឹមត្រូវមួយឱ្យមានសេចក្ដីជំនឿលើព្រះ ។ ខ្ញុំបានស្គាល់ព្រះអង្គសង្គ្រោះរបស់ខ្ញុំ និងព្រះវរបិតាសួគ៌របស់ខ្ញុំតាមរបៀប និងក្នុងកម្រិតមួយដែលប្រហែលជាពុំកើតឡើងតាមរបៀបផ្សេង ឬប្រហែលជាត្រូវរង់ចាំយូរតទៅទៀត ។ ខ្ញុំបានរៀនថាអាហារប្រចាំថ្ងៃគឺជារបស់ដ៏មានតម្លៃមហិមា ។ ខ្ញុំបានរៀនថានំម៉ាន៉ានៅបច្ចុប្បន្ននេះអាចមានពិតដូចជានំម៉ាន៉ាខាងសាច់ឈាមនៃប្រវត្តិសាស្ត្រនៅក្នុងព្រះគម្ពីរប៊ីបផងដែរ ។ ខ្ញុំបានរៀនទុកចិត្តលើព្រះអម្ចាស់ដោយអស់ពីដួងចិត្តរបស់ខ្ញុំ ។ ខ្ញុំបានរៀនដើរតាមទ្រង់ពីមួយថ្ងៃទៅមួយថ្ងៃ ។

**ការដោះស្រាយបញ្ហានានា**

ការទូលសុំដល់ព្រះសម្រាប់អាហារប្រចាំថ្ងៃជាជាងទូលសុំនូវអាហារប្រចាំសប្ដាហ៍ ប្រចាំខែ ឬប្រចាំឆ្នាំក៏ជារបៀបមួយសម្រាប់

*ដោយការប្រទាននូវអាហារប្រចាំថ្ងៃមួយថ្ងៃម្ដងៗ ព្រះយេហូវ៉ាបានព្យាយាមបង្រៀនអំពីសេចក្ដីជំនឿ ទៅដល់ជាតិសាសន៍មួយដែលបានបាត់បង់យ៉ាងច្រើននូវសេចក្ដីជំនឿនៃដូនតារបស់ខ្លួនអស់រយៈពេលជាង 400 ឆ្នាំ ។ ទ្រង់បានបង្រៀនពួកគេឱ្យទុកចិត្តលើទ្រង់ ។*



យើងដើម្បីផ្តោតទៅលើបំណែកបញ្ហាតូចៗ ហើយងាយស្រួលគ្រប់គ្រងផងដែរ ។ ដើម្បីប្រឈមមុខនឹងអ្វីមួយដែលធំ នោះយើងប្រហែលជាត្រូវដោះស្រាយវាបន្តិចម្តងៗជារៀងរាល់ថ្ងៃ ។ ពេលខ្លះអ្វីទាំងអស់ដែលយើងអាចទ្រាំទ្របានគឺសម្រាប់តែមួយថ្ងៃ—ឬអាចជាពាក់កណ្តាលថ្ងៃ—គឺម្តងមួយៗ ។

នៅទសវត្សឆ្នាំ 1950 អ្នកម្តាយរបស់ខ្ញុំបានរួចផុតពីការវះកាត់ជម្ងឺមហារីកដ៏សាហាវ បន្ទាប់ពីបានការព្យាបាលដោយកម្មរស្មីដ៏ឈឺចាប់ជាច្រើនដងមក ។ គាត់បាននៅចាំថាម្តាយរបស់គាត់បានបង្រៀនគាត់ពីអ្វីមួយនៅពេលនោះ ហើយដែលវាបានជួយគាត់ចាប់តាំងពីពេលនោះមក ៖

« ម៉ាក់ឈឺយ៉ាងធ្ងន់ ហើយខ្សោយ ហើយនៅថ្ងៃមួយខ្ញុំបាននិយាយទៅកាន់គាត់ថា ‘ឱ ! ម៉ាក់អើយ កូនពុំអាចស៊ូទ្រាំនឹងការព្យាបាលបែបនោះដល់ទៅ 16 ដងទៀតបានឡើយ ។’

« គាត់បាននិយាយថា ‘តើថ្ងៃនេះកូនអាចទៅបានទេ ?’

« ‘បាន។’

« ‘កូនមាសម្តាយនោះគឺជាអ្វីដែលកូនត្រូវតែធ្វើនៅថ្ងៃនេះ ។’

« វាបានជួយម៉ាក់ជាច្រើនដងនៅពេលម៉ាក់ចងចាំដើម្បីធ្វើវាសម្រាប់មួយថ្ងៃ ឬធ្វើម្តងមួយៗ » ។

ព្រះវិញ្ញាណអាចដឹកនាំយើងពីពេលដែលត្រូវសម្លឹងទៅមុខ និងពេលដែលយើងគួរតែធ្វើសម្រាប់តែមួយថ្ងៃនេះ សម្រាប់គ្រាមួយនេះ ។

## ការឈោងចាប់ឱកាសរបស់យើង

ការទូលសុំ និងការទទួលអាហារប្រចាំថ្ងៃពីព្រះហស្តរបស់ព្រះដើរតួយ៉ាងសំខាន់ចំពោះការរៀនទុកចិត្តលើទ្រង់ និងចំពោះ

*យើងក៏ត្រូវការបំណែកប្រចាំថ្ងៃមួយនៃអាហារដ៏ទេវភាពដើម្បីក្លាយទៅជាអ្វីដែលយើងត្រូវប្រែក្លាយផងដែរ ។ ការប្រែចិត្ត ការធ្វើខ្លួនឱ្យប្រសើរ ហើយក្រោយមកឈានទៅរក « ខ្នាតកម្ពស់នៃសេចក្តីពោរពេញផងព្រះគ្រីស្ទ » គឺជាដំណើរការមួយជំហានម្តងៗ ។*



ការស៊ូទ្រាំនឹងឧបសគ្គទាំងឡាយនៅក្នុងជីវិត ។ យើងក៏ត្រូវការបំណែកប្រចាំថ្ងៃមួយនៃអាហារដ៏ទេវភាពដើម្បីក្លាយទៅជាអ្វីដែលយើងត្រូវប្រែក្លាយផងដែរ ។ ការប្រែចិត្ត ការធ្វើខ្លួនឱ្យប្រសើរ ហើយក្រោយមកឈានទៅរក « ខ្នាតកម្ពស់នៃសេចក្ដីពោរពេញផងព្រះគ្រីស្ទ » ( អេភេសូរ 4:13 ) គឺជាដំណើរការមួយជំហានម្ដងៗ ។ ការដាក់បញ្ចូលនូវទម្លាប់ថ្មី ហើយល្អត្រឹមត្រូវ ចូលទៅក្នុងអាកប្បកិរិយារបស់យើង ឬការយកឈ្នះលើទម្លាប់អាក្រក់ ឬការញៀនទាំងឡាយ ជាញឹកញាប់មានន័យថា ជាការខិតខំនៅថ្ងៃនេះ និងថ្ងៃស្អែក ប្រហែលជាច្រើនថ្ងៃ ច្រើនខែ និងឆ្នាំ រហូតដល់យើងទទួលបានជោគជ័យ ។ ប៉ុន្តែយើងអាចធ្វើវាបានពីព្រោះយើងអាចអំពាវនាវរកព្រះសម្រាប់នំប៉័ងជារៀងរាល់ថ្ងៃរបស់យើង សម្រាប់ជំនួយដែលយើងត្រូវការជារៀងរាល់ថ្ងៃ ។

ប្រធាន អិន អេលឌិន ថែនណឺ (1898–1982) ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ បាននិយាយថា ៖ « នៅពេលដែលយើងសញ្ជឹងគិតពីគុណតម្លៃនៃដំណោះស្រាយដើម្បីធ្វើឱ្យប្រសើរឡើង ចូរយើងកំណត់ដើម្បីដាក់វិន័យខ្លួនឯងឱ្យជ្រើសរើសយកដំណោះស្រាយដែលយើងជ្រើសរើសដោយប្រុងប្រយ័ត្ន ឱ្យពិចារណាពីគោលបំណងសម្រាប់ដំណោះស្រាយទាំងនោះ ហើយចុងក្រោយបង្អស់ត្រូវធ្វើការតាំងចិត្តដើម្បីគោរពតាមកិច្ចការទាំងនោះ និងពុំត្រូវអនុញ្ញាតឱ្យឧបសគ្គណាមួយរារាំងយើងបានឡើយ ។ ចូរយើងរំឭកខ្លួនឯងពេលចាប់ផ្ដើមនៃថ្ងៃនីមួយៗថាយើងអាចគោរពតាមដំណោះស្រាយមួយសម្រាប់ថ្ងៃនោះ » ។ [1]

អែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនទាពេលថ្មីៗនេះថាភាពខ្ជាប់ខ្ជួនក្នុងការអនុវត្តន៍ជារៀងរាល់ថ្ងៃដ៏សាមញ្ញមានដូចជាការអធិស្ឋានជាក្រុមគ្រួសារ ការសិក្សាព្រះគម្ពីរ និងរាត្រីជួបជុំក្រុមគ្រួសារគឺជាកត្តាដ៏សំខាន់ក្នុងការស្ថាបនាក្រុមគ្រួសារដ៏ជោគជ័យ ។ លោកបានមានប្រសាសន៍ថា « ភាពខ្ជាប់ខ្ជួនរបស់យើងនៅក្នុងការធ្វើកិច្ចការតូចៗដោយច្បាស់លាស់អាចដឹកនាំទៅរកលទ្ធផលខាងវិញ្ញាណដ៏អស្ចារ្យ » ។ [2]

ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន (1899–1994) ដោយបានលើកឡើងអំពីការកែប្រែចិត្ត បានផ្ដល់ការទូន្មាននេះថា ៖ « យើងត្រូវតែមានការប្រុងប្រយ័ត្ន នៅពេលយើងព្យាយាមប្រែក្លាយឱ្យកាន់តែ [ ដូចជាព្រះគ្រីស្ទ ] ថាយើងពុំត្រូវបាក់ទឹកចិត្ត និងអស់សង្ឃឹមឡើយ ។ ការប្រែក្លាយដូចជាព្រះគ្រីស្ទគឺជាការស្វែងរកពេញមួយជីវិត ហើយជាញឹកញាប់វាជាប់ទាក់ទងទៅនឹងការរីកចម្រើន និងការផ្លាស់ប្ដូរដែលមានសភាពយឺត ស្ទើរតែពុំអាចដឹងបាន » ។ [3]

## ការស្វែងរកជំនួយរបស់ព្រះអម្ចាស់នៅក្នុងការបម្រើ

ចូរចងចាំថាយើងពុំគួរគ្រាន់តែមើលតែផ្នែកខាងក្នុងនៅពេលយើងស្វែងរករង្វាស់ជារៀងរាល់ថ្ងៃនៃអាហារដ៏ទេវភាពនោះទេ ។ ប្រសិនបើយើងចង់ក្លាយដូចជាលោកចៅហ្វាយ ដែលទ្រង់បានយាងមក « មិនមែនឱ្យគេបម្រើដែរគឺដើម្បីនឹងបម្រើគេវិញ » ( ម៉ាកុស 10:45 ) នោះយើងនឹងស្វែងរកជំនួយរបស់ទ្រង់នៅក្នុងការបម្រើដល់អ្នកដទៃពីមួយថ្ងៃទៅមួយថ្ងៃ ។

ប្រធាន ថូម៉ាស អេស ម៉នសុន រស់នៅតាមគោលការណ៍នេះបានយ៉ាងប្រសើរជាងមនុស្សទាំងឡាយដែលខ្ញុំស្គាល់ ។ ការអធិស្ឋាននៅក្នុងចិត្តរបស់លោកគឺមានជានិច្ចថាព្រះនឹងបើកបង្ហាញពីសេចក្ដីត្រូវការ និងមធ្យោបាយនានាដល់លោកដើម្បីជួយដល់អ្នកទាំងឡាយដែលនៅជុំវិញលោកនៅគ្រប់ដែលបានប្រទានឱ្យ ឬគ្រាណាមួយនៅក្នុងថ្ងៃនោះ ។ គំរូមួយនៅពេលលោកធ្វើជាប៊ីស្សពបង្ហាញនូវការពិតថា ពេលខ្លះសូម្បីតែការធ្វើនូវកិច្ចការបន្តិចបន្តួច ដោយបានសហការជាមួយនឹងព្រះវិញ្ញាណ អាចនាំទៅរកផលផ្លែដ៏មហិមា ។

« មនុស្សម្នាក់ដែល [ ប្រធាន ម៉នសុន ] បានជួយគឺលោក ហារ៉ូល ហ្គាលឡាចឺ ។ ភរិយា និងកូនៗរបស់គាត់គឺសកម្មនៅក្នុងសាសនាចក្រ លើកលែងតែហារ៉ូល ។ កូនស្រីរបស់គាត់ សារុន បានសួរប៊ីស្សព ម៉នសុន ប្រសិនបើលោកអាច ‘ធ្វើអ្វីមួយ’ ដើម្បីនាំឪពុកនាងឱ្យត្រឡប់មកសកម្មវិញបាន ។ ក្នុងនាមជាប៊ីស្សព នៅថ្ងៃមួយលោកបានទទួលការបំផុសគំនិតឱ្យទូរស័ព្ទទៅ ហារ៉ូល ។ វាជាថ្ងៃមួយនារដូវក្ដៅ ជាពេលដែលលោក បានទៅគោះទ្វារកញ្ចក់របស់ហារ៉ូល ។ ប៊ីស្សពរូបនេះបានមើលឃើញ ហារ៉ូលកំពុងអង្គុយលើកៅអីជក់បារី ហើយអានកាសែត ។ ហារ៉ូលបានសួរដោយស្ងប់ស្ងាត់ ដោយពុំងាកមើលថា ‘នរណាហ្នឹង ?’ ។

ថមបានឆ្លើយវិញថា « ‘ប៊ីស្សពរបស់អ្នក’ ។ ‘ខ្ញុំចង់មកស្គាល់ និងអញ្ជើញអ្នកឱ្យទៅចូលរួមការប្រជុំរបស់យើងជាមួយនិងក្រុមគ្រួសាររបស់អ្នក ។’

គាត់បានឆ្លើយបដិសេធថា « ‘អត់ទេ ខ្ញុំរវល់ណាស់’ ។ គាត់ពុំដែលងាកមើលសោះ ។ ថមបានអរគុណគាត់ដែលបានស្ដាប់ ហើយបានចាកចេញទៅ ។ ក្រុមគ្រួសារបានផ្លាស់ប្ដូរទីលំនៅ ទាំងហារ៉ូលមិនបានចូលរួមនៅក្នុងការប្រជុំដដែល ។

*ប្រសិនបើយើងចង់ក្លាយដូចជាលោកចៅហ្វាយ ដែលទ្រង់បានយាងមក « មិនមែនឱ្យគេបម្រើដែរ គឺដើម្បីនឹងបម្រើគេវិញ » នោះយើងនឹងស្វែងរកជំនួយរបស់ទ្រង់នៅក្នុងការបម្រើដល់អ្នកដទៃពីមួយថ្ងៃទៅមួយថ្ងៃ ។*

« ច្រើនឆ្នាំក្រោយមក ... បងប្រុស ហ្គាលឡាចីបានទូរស័ព្ទទៅការិយាល័យរបស់អែលឌើរ ថូម៉ាស អេស ម៉នសុន ហើយបានសុំធ្វើការណាត់ជួបនឹងលោក ។

«... ក្រោយមកនៅពេលពួកគាត់ទាំងពីរបានជួបគ្នា ពួកគាត់បានឱបគ្នា ។ ហារ៉ូលបាននិយាយថា ‘ខ្ញុំ មកដើម្បីសុំទោសដែលពុំបានងើបចេញពីកៅអីរបស់ខ្ញុំ ហើយអញ្ជើញលោកឱ្យចូលមកខាងក្នុងនៅថ្ងៃនារដូវក្ដៅនោះ ដែលកន្លងផុតជាច្រើនឆ្នាំមកហើយ ។ ‘អែលឌើរ ម៉នសុន បានសួរគាត់ប្រសិនបើ [បាន] សកម្មនៅក្នុងសាសនាចក្រ ។ ហារ៉ូលបានឆ្លើយតប ដោយញញឹមថា ៖ ‘ឥឡូវនេះ ខ្ញុំជាទីប្រឹក្សាទីពីរនៅក្នុងគណៈប៊ីស្សពប្រចាំវួដរបស់ខ្ញុំ ។ ការអញ្ជើញរបស់អ្នកឱ្យមកកាន់ព្រះវិហារសាសនាចក្រ និងការឆ្លើយតបអវិជ្ជមានរបស់ខ្ញុំ បានតាមអន្ទងខ្ញុំរហូតធ្វើឱ្យខ្ញុំប្ដេជ្ញាចិត្តធ្វើអ្វីមួយចំពោះរឿងនេះ ។’ » [4]

## ការជ្រើសរើសជារៀងរាល់ថ្ងៃ

ការគិតអំពីអាហារប្រចាំថ្ងៃរបស់យើងរក្សាយើងឱ្យប្រុងប្រយ័ត្នអំពីភាពលម្អិតនៃជីវិតរបស់យើង នៃសារៈសំខាន់នៃកិច្ចការតូចៗដែលចូលមកក្នុងជីវិតរបស់យើង ។ ឧទាហរណ៍ បទពិសោធន៍បង្រៀនថា នៅក្នុងអាពាហ៍ពិពាហ៍ លំហូរដ៏ខ្ជាប់ខ្ជួននៃសន្ដានចិត្តល្អដ៏សាមញ្ញ ការជួយ និងការយកចិត្តទុកដាក់ធ្វើច្រើនថែមទៀតដើម្បីថែរក្សាសេចក្ដីស្រឡាញ់ឱ្យនៅគង់វង់ និងចិញ្ចឹមបីបាច់ការទំនាក់ទំនងប្រសើរជាងការផ្ដល់ឱ្យអំណោយដ៏ធំ ឬថ្លែងម្ដងម្កាលទៅទៀត ។

*« ខ្ញុំជានំប៉័ងដ៏រស់ដែលចុះពីស្ថានសួគ៌មក បើអ្នកណាបរិភោគនំប៉័ងនេះ នោះនឹងរស់នៅអស់កល្បជានិច្ច ឯនំប៉័ងដែលខ្ញុំឱ្យគឺជារូបសាច់ខ្ញុំដែលនឹងឱ្យជំនួសជីវិតមនុស្សលោក » ។*



ទន្ទឹមនឹងនោះដែរ នៅក្នុងការជ្រើសរើសជារៀងរាល់ថ្ងៃយើងអាចរារាំងឥទ្ធិពលបញ្ឆោតដ៏ជាក់លាក់ចេញពីការជ្រាតចូលមកក្នុងជីវិតរបស់យើង និងចេញពីការប្រែក្លាយទៅជាផ្នែកមួយនៃអ្វីដែលយើងក្លាយទៅជា ។ នៅក្នុងការពិភាក្សាក្រៅផ្លូវការមួយដែលអែលឌើរ នែល អេ ម៉ាក់ស្វែល ( 1926–2004 ) និងខ្ញុំបានពិភាក្សាជាច្រើនឆ្នាំមកហើយ នោះយើងបានសង្កេតឃើញថាបុគ្គលម្នាក់អាចគេចផុតពីរឿងអាសគ្រាម និងរូបភាពអាសគ្រាមបានដោយគ្រាន់តែធ្វើការជ្រើសរើសដ៏ត្រឹមត្រូវ ។ ផ្នែកមួយដ៏សំខាន់បំផុតគឺបញ្ហានៃការអប់រំខ្លួនឯងកុំទៅទីកន្លែងដែលមានរូបអាសគ្រាម—ទាំងខាងរូបកាយ ឬតាមប្រព័ន្ធអេឡិចត្រូនិក ។ ប៉ុន្តែ យើងទទួលស្គាល់ថាដោយសារតែវាជាការរាលដាលដ៏ចាក់ស្រេះ រឿងអាសគ្រាមអាចវាយប្រហារបុគ្គលម្នាក់ឱ្យគិតតែពីបញ្ហាផ្ទាល់ខ្លួនរបស់គាត់ទាំងស្រុងគួរឱ្យភ្ញាក់ផ្អើល ។ អែលឌើរ ម៉ាក់ស្វែលសង្កេតឃើញថា « មែនហើយ ប៉ុន្តែគាត់បដិសេធវាភ្លាមៗបាន ។ គាត់ពុំចាំបាច់អញ្ជើញវាឱ្យចូលមក ហើយឱ្យកៅអីវាអង្គុយនោះទេ » ។

រឿងដូចគ្នានេះធ្វើឱ្យកើតមាននូវឥទ្ធិពលទម្លាប់អវិជ្ជមាន ។ ការយកចិត្តទុកដាក់របស់យើងជារៀងរាល់ថ្ងៃចំពោះការចៀសវាងនូវរឿងបែបនេះនៅរាល់ការចាប់ផ្ដើមអាចការពារយើងពីការភ្ញាក់រឭកនាពេលអនាគតដោយការយល់ដឹងថាដោយសារតែភាពធ្វេសប្រហែស អំណាចអារក្ស ឬភាពទន់ខ្សោយបានចាក់ឫសចូលទៅក្នុងព្រលឹងរបស់យើង ។

នៅក្នុងជីវិតពិត ពុំមែនមានសុទ្ធតែរឿងមិនសំខាន់នៅពេញមួយថ្ងៃនោះឡើយ ។ សូម្បីតែអ្វីដែលមិនសំខាន់ និងច្រំដែលអាចជាការតូចតាចប៉ុន្តែអ្វីដែលសំខាន់ក្នុងការស្ដាបនាចង្កោមដែលដល់ពេលមួយបង្កើតជាការអប់រំ និងអាកប្បកិរិយា ហើយនិងរបៀបរៀបរយដែលតម្រូវឱ្យមានដើម្បីដឹងពីផែនការ និងសុបិនទាំងឡាយរបស់យើង ។ ហេតុដូច្នេះហើយ នៅពេលអ្នកទូលសុំនៅក្នុងការអធិស្ឋានសម្រាប់អាហារប្រចាំថ្ងៃរបស់អ្នក ចូរពិចារណាឱ្យបានស៊ីជម្រៅពីសេចក្ដីត្រូវការទាំងឡាយរបស់អ្នក—ទាំងអ្វីដែលអ្នកអាចខ្វះខាត និងអ្វីដែលអ្នកត្រូវតែការពារ ។ នៅពេលចូលដេក ចូរគិតអំពីភាពជោគជ័យ និងភាពបរាជ័យនៅថ្ងៃនោះ និងពីអ្វីដែលនឹងធ្វើឱ្យថ្ងៃស្អែកបានប្រសើរឡើងបន្តិច ។ ហើយសូមថ្លែងអំណរគុណព្រះវរបិតាសួគ៌របស់អ្នកសម្រាប់នំម៉ាន៉ាដែលទ្រង់បានដាក់នៅលើផ្លូវរបស់អ្នកដែលបានទ្រទ្រង់អ្នកពេញមួយថ្ងៃនោះ ។ ការសញ្ជឹងគិតរបស់អ្នកនឹងពង្រឹងសេចក្ដីជំនឿរបស់អ្នកទៅលើទ្រង់ ពេលអ្នកឃើញព្រះហស្ដរបស់ទ្រង់កំពុងតែជួយអ្នកឱ្យស៊ូទ្រាំនឹងកិច្ចការមួយចំនួន និងផ្លាស់ប្ដូរដល់មនុស្សដទៃទៀតនោះ ។ អ្នកនឹងអាចរីករាយសម្រាប់មួយថ្ងៃទៀត ជំហានមួយទៀតឆ្ពោះទៅរកជីវិតដ៏អស់កល្បជានិច្ច ។

**ការចងចាំពីនំប៉័ងជីវិត**

អ្វីដែលសំខាន់បំផុតនោះ ចូរចងចាំថាយើងមានទ្រង់ដែលជានំម៉ាន៉ាជាប្រភេទ និងនិមិត្តសញ្ញាមួយ ជាព្រះប្រោសលោះ ។

«យើងជានំប៉័ងជីវិត ។

« ពួកអយ្យកោអ្នករាល់គ្នាបានបរិភោគនំម៉ាន៉ានៅក្នុងទីរហោស្ថាន ហើយក៏ស្លាប់អស់ទៅ ។

« ឯនំប៉័ងដែលខ្ញុំនិយាយនេះគឺជានំប៉័ងដែលចុះពីស្ថានសួគ៌មកដើម្បីឱ្យអ្នកណាដែលបរិភោគមិនត្រូវស្លាប់ឡើយ ។

« ខ្ញុំជានំប៉័ងដ៏រស់ដែលចុះពីស្ថានសួគ៌មក បើអ្នកណាបរិភោគនំប៉័ងនេះ នោះនឹងរស់នៅអស់កល្បជានិច្ច ឯនំប៉័ងដែលខ្ញុំឱ្យគឺជារូបសាច់ខ្ញុំដែលនឹងឱ្យជំនួសជីវិតមនុស្សលោក » ( យ៉ូហាន 6:48–51 ) ។

ខ្ញុំសូមថ្លែងទីបន្ទាល់របស់ខ្ញុំអំពីភាពពិតដ៏សកម្មនៃនំប៉័ងជីវិតព្រះយេស៊ូវគ្រីស្ទ និងអំពីព្រះចេស្ដា និងភាពជោគជ័យដ៏គ្មានទីបញ្ចប់នៃដង្វាយធួនរបស់ទ្រង់ ។ នៅទីបំផុត មានតែដង្វាយធួន និងព្រះគុណរបស់ព្រះអង្គសង្គ្រោះប៉ុណ្ណោះដែលជាអាហារប្រចាំរបស់យើង ។ យើងគួរតែស្វែងរកទ្រង់ជារៀងរាល់ថ្ងៃ ដើម្បីធ្វើតាមព្រះហឫទ័យរបស់ទ្រង់ជារៀងរាល់ថ្ងៃ ដើម្បីឱ្យមានចិត្តតែមួយនឹងទ្រង់ដូចដែលទ្រង់មានព្រះទ័យតែមួយនឹងព្រះវរបិតាដែរ ( សូមមើល យ៉ូហាន 17:20–23 ) ។ នៅពេលយើងធ្វើដូច្នេះ សូមឱ្យព្រះវរបិតាសួគ៌របស់យើងប្រទានដល់យើងនូវអាហារប្រចាំថ្ងៃរបស់យើង ។ ■

*ដកស្រង់ចេញពីសុន្ទរកថាដែលបានផ្ដល់ឱ្យនៅក្នុងការប្រជុំពិសេសរបស់ប្រព័ន្ធអប់រំសាសនាចក្រនៅថ្ងៃទី 9 ខែ មករា ឆ្នាំ 2011 ។ ចំពោះអត្ថបទពេញលេញជាភាសាអង់គ្លេស សូមចូលទៅកាន់ speeches.byu.edu ។*

*នៅទីបំផុត មានតែដង្វាយធួន និងព្រះគុណរបស់ព្រះអង្គសង្គ្រោះប៉ុណ្ណោះដែលជាអាហារប្រចាំថ្ងៃរបស់យើង ។*

**កំណត់ចំណាំ**

1. រ. អេមឲ្យ៊ ឯកិយ្រ « Today I Will ... » *Liahona* ខែ មិនា ឆ្នាំ 2003 ទំព័រ 27–28 ។
2. David A. Bednar « More Diligent and Concerned at Home » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2009 ទំព័រ 20 ។
3. Ezra Taft Benson « A Mighty Change of Heart » *Tambuli,* ខែ មិនា ឆ្នាំ 1990 ទំព័រ 7 ។
4. Heidi S. Swinton, *To the Rescue: The Biography of Thomas S. Monson* ( ឆ្នាំ 2010 ) ទំព័រ 160–61 ។


Geo Albert Smith






# លោកបានរស់នៅតាមអ្វីដែលលោកបានបង្រៀន

*បទពិសោធន៍ទាំងឡាយដកស្រង់ចេញពីជីវិតរបស់ប្រធាន ចច អ័លប៊ើត ស្ម៊ីធ បង្ហាញថាលោកពុំគ្រាន់តែជឿលើដំណឹងល្អប៉ុណ្ណោះទេ—គឺលោកបានរស់នៅតាមដំណឹងល្អ ។*

**ដោយ ធិឌ បាទិស**
ផ្នែកកម្មវិធីសិក្សា

ល្ងាចដល់ចុងបញ្ចប់នៃថ្ងៃមួយដ៏តានតឹងមក ចន អេ វីឌស្វូបានអង្គុយនៅក្នុងការិយាល័យរបស់គាត់ « ដោយនឿយហត់យ៉ាងខ្លាំងក្រោយពីការងារ » ។ គាត់បានប្រឈមមុខនឹងបញ្ហាចំរោងចំរាស់គ្នា ហើយគាត់បានមានអារម្មណ៍ថាមានបន្ទុកដ៏ធ្ងន់ចំពោះការទទួលខុសត្រូវរបស់គាត់ ។ គាត់បានមានប្រសាសន៍ថា « ខ្ញុំនឿយហត់ណាស់ » ។

« ក្រោយមកស្រាប់តែឮសម្លេងគោះទ្វារ ហើយចច អ័លប៊ើត ស្ម៊ីធបានដើរចូលមក ។ លោកបានមានប្រសាសន៍ថា ‘ខ្ញុំកំពុងតែធ្វើដំណើរទៅផ្ទះក្រោយការងាររបស់ខ្ញុំ ។ ខ្ញុំបានគិតពីអ្នក និងបញ្ហាទាំងឡាយដែលអ្នកបានរំពឹងដើម្បីដោះស្រាយ ។ ខ្ញុំចូលមកដើម្បីលួងលោមអ្នក និងប្រសិទ្ធពរឱ្យអ្នក ។’

« ... ខ្ញុំពុំដែលភ្លេចពីពេលនោះឡើយ ។ យើងបានដើរជាមួយគ្នាមួយសន្ទុះ រួចហើយយើងបានបែកផ្លូវគ្នា លោកបានទៅផ្ទះ ។ ដួងចិត្តរបស់ខ្ញុំត្រូវបានលើកឡើង ។ ខ្ញុំលែងមានការព្រួយបារម្ភទៀតហើយ » ។

ដោយនឹកចាំពីបទពិសោធន៍នេះជាច្រើនឆ្នាំក្រោយមកក្នុងនាមជាសមាជិកម្នាក់នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ អែលឌើរ វីឌស្វូ (1872–1952) បានមានប្រសាសន៍ថា ៖ « នោះគឺជារបៀបរបស់ចច អ័លប៊ើត ស្ម៊ីធ ។ ... លោកបានលះបង់ពេលវេលា និងកម្លាំងរបស់លោកផ្ទាល់ » ។ [1]

ចច អ័លប៊ើត ស្ម៊ីធ (1870–1951) ដែលបានបម្រើជាប្រធានទីប្រាំបីនៃសាសនាចក្រ ពីឆ្នាំ 1945ដល់ឆ្នាំ 1951 បានជឿថាប្រសិនបើយើងពិតជាមានទីបន្ទាល់អំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ វានឹងសម្ដែងឱ្យឃើញនៅក្នុងជីវិតរបស់យើង–ជាពិសេសតាមរបៀបដែលយើងប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក ។ លោកបានបង្រៀនថា « ជីវិតមួយដែលត្រឹមត្រូវ ហើយខ្ជាប់ខ្ជួនគឺជាទីបន្ទាល់ដ៏រឹងមាំបំផុតថាយើងនឹងអាចថ្លែងពីសេចក្ដីពិតនៃកិច្ចការនេះ » ។ [2]

នៅក្នុងសៀវភៅ *Teachings of Presidents of the Church: George Albert Smith* ដែលជាកម្មវិធីសិក្សាសម្រាប់ថ្នាក់បព្វជិតភាពមិលគីស្សាដែក និងថ្នាក់សមាគមសង្គ្រោះក្នុងឆ្នាំ 2012 ទីបន្ទាល់របស់ប្រធាន ស្ម៊ីធ ត្រូវបានសម្ដែងចេញដែលពោរពេញដោយអំណាច—ទាំងតាមរយៈការបង្រៀនរបស់លោក និងតាមរយៈដំណើររឿងពីជីវិតរបស់លោក ។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនដកស្រង់ចេញពីដំណើររឿង និងការបង្រៀនទាំងនេះ ។

### អំណាចនៃសេចក្ដីមេត្តាករុណា

នៅថ្ងៃមួយនារដូវក្ដៅ មានកម្មករមួយចំនួនកំពុងតែជួសជុលផ្លូវនៅមុខផ្ទះរបស់ប្រធាន ស្ម៊ីធ ។ នៅពេលការងារនោះ

រូបភាពដោយ ចន ហាហ្វែន ទទួលបានសិទ្ធិអនុញ្ញាតពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ



កាន់តែមានភាពតានតឹង ហើយព្រះអាទិត្យក៏ចេះតែក្តៅឡើងៗ នោះពួកកម្មករទាំងនោះបានចាប់ផ្តើមប្រើភាសាទាំងឡាយដែលអាសគ្រាម និងប្រមាថ ។ ភ្លាមៗនោះពួកអ្នកជិតខាងម្នាក់បានចេញទៅ ហើយបានស្តីបន្ទោសដល់ពួកកម្មករទាំងនោះចំពោះភាសាប្រមាថមើលងាយរបស់ពួកគេ ដោយប្រាប់ថា ចច អ័លប៊ើត ស្ម៊ីធ រស់នៅជិតនេះ ។ ដោយពុំខ្វល់ ពួកកម្មករបានចាប់ប្រើពាក្យអសុរោះកាន់តែច្រើនថែមទៀត ។

ខណៈពេលនោះ ប្រធាន ស្ម៊ីធកំពុងតែនៅក្នុងផ្ទះបាយរៀបចំច្របាច់ក្រូចដាក់ថូ ។ លោកបានដាក់វា និងកែវមួយចំនួននៅលើថាស រួចយកចេញទៅក្រៅ ហើយបាននិយាយទៅកាន់ពួកកម្មករទាំងនោះថា « អ្នកទាំងអស់គ្នា អ្នកប្រហែលជាក្តៅហើយនឿយហត់ខ្លាំងហើយ ។ ហេតុអ្វីបានជាមិនមកអង្គុយនៅក្រោមដើមឈើរបស់ខ្ញុំនៅត្រង់នេះ ហើយហូបទឹកត្រជាក់សិនទៅ ? ។

ដោយបន្ទាបខ្លួន និងអំណរគុណ ពួកកម្មករបានទទួលយកការអញ្ជើញរបស់លោក ហើយបន្ទាប់ពីការសម្រាកដ៏រីករាយរបស់ពួកគេមក នោះពួកគេបានបញ្ចប់ការងាររបស់ខ្លួនដោយការគោរព និងដោយស្ងៀមស្ងាត់ ។ [3]

បទពិសោធន៍ដូចនេះបង្ហាញពីភាពជឿជាក់របស់ ចច អ័លប៊ើត ស្ម៊ីធថា យើងអាច « ប្រឈមនឹងបញ្ហានានារបស់យើងបានដោយវិញ្ញាណនៃសេចក្តីស្រឡាញ់ និងសេចក្តីមេត្តាករុណាចំពោះមនុស្សគ្រប់គ្នា » ។ [4] លោកបានមានប្រសាសន៍ថា « មានមនុស្សជាច្រើនដែលនឹងធ្វើខុស » ។ « មានមនុស្សជាច្រើននៅក្នុងចំណោមយើងនាបច្ចុប្បន្ននេះដែលបានវង្វេងផ្លូវ ប៉ុន្តែពួកគេគឺជាកូនចៅនៃព្រះអម្ចាស់របស់យើង ហើយទ្រង់ស្រឡាញ់ពួកគេ ។ ទ្រង់បានប្រទានដល់អ្នក និងខ្ញុំនូវសិទ្ធិដើម្បីទៅរកពួកគេដោយសេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់ និងសេចក្តីអត់ធ្មត់ ព្រមទាំងមានបំណងដើម្បីប្រទានពរ ខិតខំជួយពួកគេឱ្យឈ្នះលើកំហុសទាំងឡាយដែលពួកគេកំពុងតែធ្វើ ។ វាពុំមែនជាអភ័យឯកសិទ្ធិរបស់ខ្ញុំដើម្បីកាត់សេចក្តីនោះទេ ។ ... ប៉ុន្តែវាជាអភ័យឯកសិទ្ធិរបស់ខ្ញុំ ប្រសិនបើខ្ញុំឃើញពួកគេកំពុងតែធ្វើអ្វីមួយដែលខុស ប្រសិនបើអាចធ្វើបាន តាមវិធីណាមួយដើម្បីជួយពួកគេឱ្យត្រឡប់ចូលមកផ្លូវដែលដឹកនាំទៅរកជីវិតដ៏អស់កល្បជានិច្ចនៅក្នុងនគរសេឡេស្ទាលវិញ » ។ [5]

« ឱ!សេចក្តីអំណរ ឱ!ការល្បួងលោម ឱ!សេចក្តីរីករាយដែលអាចត្រូវបានបន្ថែមដល់ជីវិតនៃអ្នកជិតខាង និងមិត្តទាំងពួងរបស់យើងបានតាមរយៈសន្តានចិត្តល្អ ។ ខ្ញុំចង់សរសេរពាក្យនោះជាអក្សរធំ ហើយបង្ហាញវានៅលើអាកាស ។ សន្តានចិត្តល្អគឺជាអំណាចដែលព្រះបានប្រទានដល់យើងដើម្បីបើកដួងចិត្តទាំងឡាយដែលរឹងរូស និងបង្ក្រាបព្រលឹងនានាដែលរឹងទទឹង» ។ [6]

**ការចែកចាយដំណឹងល្អ**

ប្រធានស្ម៊ីធបានចាត់ទុកការចែកចាយដំណឹងល្អគឺជា « សេចក្តីមេត្តាករុណាដ៏ធំធេងបំផុត »។ [7] លោកបានទទួលស្គាល់ និងមានអំណរចំពោះសេចក្តីល្អដែលលោកបានឃើញនៅក្នុងព្រះវិហារផ្សេងទៀត ប៉ុន្តែលោកបានដឹងថាដំណឹងល្អដែលបានស្តារឡើងវិញមាននូវអ្វីមួយដែលវិសេសវិសាល និងមានតម្លៃដើម្បីផ្តល់ឱ្យកូនចៅមនុស្ស ។

មានពេលមួយខណៈដែលលោកបម្រើជាប្រធានបេសកកម្ម មានមនុស្សម្នាក់បាននិយាយទៅកាន់លោកថា « មែនហើយ អ្វីដែលខ្ញុំបានដឹងគឺថា ព្រះវិហាររបស់លោកគឺល្អដូចគ្នានឹងព្រះវិហារផ្សេងដែរ » ។

ប្រធាន ស្ម៊ីធ បានកំណត់ចំណាំថា « ខ្ញុំសន្និដ្ឋានថា គាត់បានគិតថាគាត់កំពុងតែផ្តល់នូវការសរសើរដ៏មហិមាដល់យើង » ។ « ប៉ុន្តែលោកបាននិយាយទៅកាន់គាត់ថា ៖ ‘ ប្រសិនបើសាសនាចក្រដែលខ្ញុំធ្វើជាតំណាងឱ្យនៅទីនេះពុំមានសារសំខាន់ដល់កូនចៅមនុស្សច្រើនជាងព្រះវិហារផ្សេងទេ នោះខ្ញុំបានធ្វើខុសក្នុងការបំពេញកាតព្វកិច្ចរបស់ខ្ញុំនៅទីនេះជាពុំខានឡើយ ។ ’» [8]

ប្រធាន ស្ម៊ីធបានបង្រៀនថា មូលហេតុមួយដែលសារលិខិតរបស់យើងមានសារសំខាន់ខ្លាំង គឺដោយសារថា « មានតែពួកបរិសុទ្ធតែប៉ុណ្ណោះដែលមានសិទ្ធិអំណាចពីព្រះវរបិតាសួគ៌ដើម្បីចាត់ចែងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ ។ ពិភពលោកនេះត្រូវការយើង » ។ [9]

ដោយសារតែការណ៍នេះ ប្រធាន ស្ម៊ីធបានមានបំណងចង់ឱ្យពួកបរិសុទ្ធថ្ងៃចុងក្រោយមាន « ចំណង់ដ៏ខ្លាំងក្លា និងសេចក្តីរំភើបដើម្បីចែកចាយជាមួយនិងកូនចៅព្រះវរបិតារបស់យើងនូវសេចក្តីល្អដែលទ្រង់បានប្រទានដល់យើងដោយចិត្តសប្បុរស » ។ [10]

លោកបានមានប្រសាសន៍ថា « ពេលខ្លះខ្ញុំមានអារម្មណ៍ថាយើងពុំបានដឹងគ្រប់គ្រាន់ពីសារសំខាន់នៃ [ ដំណឹងល្អ ] ថាយើងពុំបានបង្រៀនវាដោយចិត្តស្មោះសរដូចដែលតម្រូវឱ្យមាននោះឡើយ » ។ [11]

មានមិត្តដ៏ជិតស្និទ្ធម្នាក់បានសង្កេតពីរបៀបដែលប្រធានស្ម៊ីធបានពន្យល់ពី « ចិត្តស្មោះសរ » ក្នុងការចែកចាយដំណឹងល្អ ៖ « ខ្ញុំបានមានឱកាសធ្វើដំណើរតាមរថភ្លើងជាច្រើនដងជាមួយនឹងប្រធាន ស្ម៊ីធ ។ គ្រប់ពេលខ្ញុំបានសង្កេតឃើញថា នៅពេលការធ្វើដំណើរមានសភាពស្ងប់ស្ងាត់ នោះលោកនឹងយកប័ណ្ណប្រកាសពីរបីចេញពីកាបូប ហើយដាក់ចូលទៅក្នុងហោប៉ៅរបស់លោក ហើយក្រោយមកចាប់ផ្តើមដើរទៅរកពួកអ្នកធ្វើដំណើរ ។ ដោយឥរិយាបថដ៏ស្និទ្ធស្នាល ហើយរីករាយរបស់លោក នោះលោកនឹងស្គាល់អ្នករួមដំណើរម្នាក់យ៉ាងឆាប់រហ័ស ហើយនៅក្នុងរយៈពេលមួយដ៏ខ្លីខ្ញុំនឹងបានឮលោកបាប្រាប់ពីដំណើររឿងនៃការរកឃើញសាសនាចក្រនេះដោយព្យាការី យ៉ូសែប ស្ម៊ីធ ឬប្រាប់អំពីការជម្លៀសពួកបរិសុទ្ធចេញពី ទីក្រុង ណៅវូ និងឧបសគ្គ និង

ការលំបាកទាំងឡាយរបស់ពួកគេក្នុងការឆ្លងខ្ពង់រាបទៅកាន់រដ្ឋយូថាហ៍ ឬពន្យល់ពីគោលការណ៍នៃដំណឹងល្អខ្លះៗដល់មិត្តថ្មីថ្មោងរបស់លោក ។ ការសន្ទនាពីអ្នកធ្វើដំណើរម្នាក់ទៅអ្នកធ្វើដំណើរម្នាក់ទៀតនៅតែបន្តរហូតដល់ការធ្វើដំណើរនោះត្រូវបានបញ្ចប់ ។ ក្នុងរយៈពេលដែលខ្ញុំបានស្គាល់ប្រធាន ស្ម៊ីធ រហូតមក គឺលើសពីសែសិបឆ្នាំ ខ្ញុំបានដឹងថាទោះបីជាលោកនៅទីណាក៏ដោយ លោកជាមនុស្សដំបូង និងមុនគេបង្អស់ដែលធ្វើជាអ្នកផ្សព្វផ្សាយសាសនាសម្រាប់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » ។ [12]

## ការបង្រៀនដល់កូនចៅរបស់យើង

ចច អ័លប៊ើត ស្ម៊ីធ និងភរិយារបស់លោក លូស៊ី បានគោរពតាមបញ្ញត្តិដ៏ទេវភាពដោយហ្មត់ចត់ក្នុងការ « ចិញ្ចឹមកូនចៅ [ របស់ខ្លួនគាត់ ] នៅក្នុងពន្លឺ និងសេចក្ដីពិត » ( គ. និង ស. 93:40 ) ។ កូនស្រីរបស់ពួកគាត់ អេឌីត្យបានប្រាប់ពីពេលមួយដែលឪពុករបស់នាងបានភ្ជាប់យកនូវឱកាសបង្រៀនមួយ ។ នាងបានជិះឡានឈ្នួលចេញពីវេទិកាព្យាណូមកផ្ទះ ហើយព្រូឡានបានភ្លេចទារលុយថ្លៃឡានពីនាង ។ នាងបានរៀបរាប់ថា « ពុំដឹងជាយ៉ាងម៉េចព្រូឡាននោះបានដើរហួសខ្ញុំ ហើយខ្ញុំបានមកដល់គោលដៅរបស់ខ្ញុំដោយនៅតែកាន់កាក់ប្រាក់ប្រាំសេនក្នុងដៃរបស់ខ្ញុំដដែល ហើយខ្ញុំពិតជារីករាយដោយបានធ្វើដំណើរដោយពុំអស់លុយ ។

«... ខ្ញុំបានរត់ដោយរំភើបក្រៃលែងទៅរកលោកប៉ាដើម្បីប្រាប់គាត់អំពីសំណាងល្អរបស់ខ្ញុំ ។ គាត់បានស្ដាប់ពីដំណើររឿងរបស់ខ្ញុំដោយយកចិត្តទុកដាក់ ។ ខ្ញុំបានចាប់ផ្តើមគិតថាខ្ញុំបានទទួលជោគជ័យមួយដ៏ធំ ។ ...

« នៅពេលខ្ញុំបានបញ្ចប់រឿងរបស់ខ្ញុំ លោកប៉ាបានមានប្រសាសន៍ថា ‘កូនស្រីមាសឪពុក ប៉ុន្តែទោះបីជាព្រូឡាននោះពុំបានដឹងអំពីរឿងនេះក្តី ក៏កូនដឹង ហើយប៉ាក៏ដឹង ព្រមទាំងព្រះវរបិតាសួគ៌ក៏ជ្រាបពីរឿងនេះដែរ ។ ដូច្នេះ យ៉ាងហោចណាស់ក៏មានបីនាក់យើងដែលត្រូវតែរីករាយក្នុងការឃើញថាកូនបង់ពេញថ្លៃស្របតាមតម្លៃដែលកូនបានទទួល ។’ »

អេឌីត្យបានត្រឡប់ទៅកាច់ជ្រុងផ្លូវនោះវិញ ហើយបានបង់ថ្លៃឡានរបស់នាង ។ ក្រោយមកនាងបាននិយាយថា « ខ្ញុំពិតជាមានអំណរគុណចំពោះលោកប៉ាម្នាក់ដែលមានភាពឈ្លាសវៃល្មមគ្រប់គ្រាន់ដើម្បីចង្អុលបង្ហាញក្ដីមេត្តាពីកំហុសខ្ញុំ ពីព្រោះប្រសិនបើវាត្រូវបានព្រងើយកន្តើយ នោះខ្ញុំអាចគិតថាគាត់បានអនុមតិ » ។ [13]



ប្រធាន ស្ម៊ីធ បង្ហាញព្រះគម្ពីរមរមនដល់លោក ម៉ានី ធើរក្វយ្ស ( ខាងឆ្វេង ) និងលោក ម៉ាញអែលលីតូ បេហ្គេ ។

ខាងឆ្វេង ៖ ការថតរូប ដែលផ្ដល់សិទ្ធិអនុញ្ញាតពីបណ្ណសារប្រវត្តិសាសនាចក្រ

ប្រធាន ស្ម៊ីធ បានបង្រៀនសមាជិកសាសនាចក្រថាសេចក្ដីស្រឡាញ់មានទូវអំណាចដើម្បីបំផុសគំនិតកូនចៅយើងឱ្យរស់នៅដោយសុចរិត ៖ « ចូរបង្រៀនកូនចៅរបស់អ្នកឱ្យយល់ដឹងពីច្បាប់ក្រមសីលធម៌ ។ ចូរឱបក្រសោបពួកគេដោយដៃនៃសេចក្តីស្រឡាញ់របស់អ្នក ដើម្បីពួកគេនឹងគ្មានចំណង់ដើម្បីធ្វើតាមការល្បួងទាំងឡាយដែលមកពីអារក្សដែលហ៊ុមព័ទ្ធពួកគេគ្រប់ទិសទីកន្លែង » ។ [14]

« វាគឺជាកាតព្វកិច្ចរបស់យើង—ខ្ញុំគួរតែនិយាយថាវាគឺជាអភ័យឯកសិទ្ធិរបស់យើងក៏ដូចជាកាតព្វកិច្ចរបស់យើងផងដែរក្នុងការចំណាយពេលឱ្យបានគ្រប់គ្រាន់នៅជាមួយនឹងកូនចៅរបស់យើងដោយការពារសុវត្ថិភាព និងដើម្បីស្រឡាញ់ពួកគេឱ្យបានច្រើន ហើយនិងទទួលបានសេចក្តីស្រឡាញ់ពីពួកគេដើម្បីឱ្យពួកគេនឹងមានចិត្តរីករាយស្តាប់ដល់ដំបូន្មាន និងការទូន្មានរបស់យើង » ។ [15]

## ក្រុមគ្រួសារដ៏ទៅអស់កល្បជានិច្ច

ចច អ័លប៊ើត និងលូស៊ីស្ម៊ីធ រៀបការបានប្រហែលជា 40ឆ្នាំជាពេលដែលលូស៊ីបានចាប់ផ្តើមមានសុខភាពស្រុតចុះខ្សោយយ៉ាងយូរ ។ ទោះបីជាលោកបានព្រួយបារម្ភចំពោះនាង និងបានព្យាយាមលួងលោមនាងតាមដែលលោកអាចធ្វើទៅបានក្តី ក៏កាតព្វកិច្ចទាំងឡាយរបស់ប្រធាន ស្ម៊ីធក្នុងនាមជាអ្នកមានសិទ្ធអំណាចទូទៅមួយរូប ជារឿយៗបានតម្រូវឱ្យលោកឃ្លាតឆ្ងាយពីផ្ទះ ។ មានថ្ងៃមួយបន្ទាប់ពីប្រធាន ស្ម៊ីធបានធ្វើសុន្ទរកថានៅពិធីបុណ្យសពមួយមក មានមនុស្សម្នាក់បានហុចឱ្យលោកនូវក្រដាសដែលមានជាសារខ្លីមួយប្រាប់ឱ្យលោកប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះវិញ ។ ក្រោយមកលោកបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុរបស់លោកថា ៖

« ខ្ញុំបានចេញពីសាលាប្រជុំភ្លាម ប៉ុន្តែភរិយាជាទីស្រឡាញ់របស់ខ្ញុំបានផុតដង្ហើមពីមុនខ្ញុំបានទៅដល់ផ្ទះបាត់ទៅហើយ ។ នាងបាន

ប្រធានស្ម៊ីធបានចាត់ទុកការចែកចាយដំណឹងល្អគឺជា « សេចក្ដីមេត្តាករុណាដ៏ធំធេងបំផុត » ដោយសារ « មានតែពួកបរិសុទ្ធតែប៉ុណ្ណោះដែលមានសិទ្ធិអំណាចពីព្រះវរបិតាសួគ៌ដើម្បីចាត់ចែងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ ។ ពិភពលោកនេះត្រូវការយើង » ។

ទទួលមរណភាពក្នុងខណៈពេលដែលខ្ញុំកំពុងតែធ្វើសុន្ទរកថានៅឯពិធីបុណ្យសពនោះ ។ ពិតណាស់ខ្ញុំបានបាត់បង់ភរិយាម្នាក់ដែលមាននូវការលះបង់ខ្ពស់ ហើយខ្ញុំនឹងឯកោតែឯងដោយគ្មានរូបនាង » ។

លោកបានបន្តទៀតថា « ខណៈដែលក្រុមគ្រួសាររបស់ខ្ញុំជួបនូវទុក្ខព្រួយដ៏ធំនេះ យើងត្រូវបានលួងលោមចិត្តដោយការអះអាងពីការរួមរស់នឹង[ នាង ] វិញប្រសិនបើយើងបន្តស្មោះត្រង់នោះ ។ ... ព្រះអម្ចាស់មានព្រះទ័យមេត្តាយ៉ាងខ្លាំង និងបានដកយកចេញនូវរាល់អារម្មណ៍នៃសេចក្ដីស្លាប់ជាអ្វីដែលខ្ញុំមានអំណរយ៉ាងខ្លាំង » ។ [16]

ប្រធាន ស្ម៊ីធបានទទួលកម្លាំង និងការលួងលោមមកពីទីបន្ទាល់របស់លោកអំពីផែនការសង្គ្រោះ និងពិធីបរិសុទ្ធទាំងឡាយនៅក្នុងព្រះវិហារបរិសុទ្ធដែលបានផ្សារភ្ជាប់ក្រុមគ្រួសារសម្រាប់ភាពអស់កល្បជានិច្ច ។ លោកបានបង្រៀនថា ៖

« ការអះអាងថាទំនាក់ទំនងរបស់យើងនៅទីនេះក្នុងនាមជាឪពុកម្ដាយ និងកូនចៅ ជាស្វាមី និងភរិយានឹងបន្តនៅឯស្ថានសួគ៌ ហើយថានេះគឺគ្រាន់តែជាការចាប់ផ្ដើមនៃនគរដ៏ធំ ហើយរុងរឿងដែលព្រះវរបិតារបស់យើងបានរៀបចំទុកឱ្យយើងទទួលនៅឯជ្រុងម្ខាងទៀត វាបំពេញឱ្យយើងនូវសេចក្ដីសង្ឃឹម និងសេចក្ដីអំណរ ។

« ឥឡូវនេះដោយសារភរិយាជាទីស្រឡាញ់របស់ខ្ញុំ ព្រមទាំងឪពុកម្ដាយជាទីស្រឡាញ់របស់ខ្ញុំបានឃ្លាតចេញទៅ ហើយប្រសិនបើខ្ញុំគិត ដូចជាមនុស្សជាច្រើនបានគិត ថាពួកគេបានចាកចេញពីជីវិតរបស់ខ្ញុំជារៀងរហូត ហើយថាខ្ញុំនឹងមិនបានជួបពួកគេម្ដងទៀតឡើយ នោះវានឹងដកយកនូវសេចក្ដីអំណរដ៏មហិមាបំផុតមួយដែលមាននៅក្នុងជីវិតចេញទៅគឺ៖ គំនិតនៃការជួបជុំនឹងពួកគេម្ដងទៀត និងការទទួលនូវការស្វាគមន៍ និងសេចក្ដីស្រឡាញ់របស់ពួកគេ ព្រមទាំងការថ្លែងអំណរគុណដល់ពួកគេដោយអស់ពីជម្រៅនៃដួងចិត្តដែលពោរពេញដោយការដឹងគុណដ៏មហិមាចំពោះអ្វីៗគ្រប់យ៉ាងដែលពួកគេបានធ្វើសម្រាប់ខ្ញុំ » ។ [17]

« នៅពេលយើងដឹងថាសេចក្ដីស្លាប់គឺគ្រាន់តែជាជំហានមួយដែលកូនចៅរបស់ព្រះត្រូវឆ្លងកាត់ជារៀងរហូត និងថាវាស្របទៅតាមផែនការរបស់ទ្រង់ នោះវានឹងផ្ដាច់ចំណងនៃសេចក្ដីស្លាប់ ហើយនាំយើងឱ្យជួបគ្នាក្នុងសភាពពិតនៃជីវិតដ៏នៅអស់កល្បជានិច្ច ។ មានក្រុមគ្រួសារជាច្រើនត្រូវបានហៅឱ្យលាដល់អស់អ្នកទាំងឡាយដែលពួកគេស្រឡាញ់ជាបណ្ដោះអាសន្ន ។ នៅពេលសេចក្ដីស្លាប់បែបនោះកើតឡើង វារំខានដល់យើង ប្រសិនបើយើងនឹងបណ្ដោយវា ហើយវានឹងនាំមកនូវទុក្ខសោកដ៏ធំចូលមកក្នុងជីវិតរបស់យើង ។ ប៉ុន្តែប្រសិនបើភ្នែកខាងវិញ្ញាណរបស់យើងអាចត្រូវបានបើក ហើយយើងអាចមើលឃើញ នោះយើងនឹងត្រូវបានលួងលោមចិត្ត ជាមួយនឹងអ្វីដែលយើងបានមើលឃើញ ខ្ញុំជឿយ៉ាងពិតប្រាកដ ។ ព្រះអម្ចាស់ពុំបានទុកយើងចោលទាំងអស់សង្ឃឹមនោះឡើយ ។ ផ្ទុយទៅវិញ ទ្រង់បានប្រទានដល់យើងនូវគ្រប់ការអះអាងអំពីសុភមង្គលដ៏នៅអស់កល្បជានិច្ច ប្រសិនបើយើងនឹងទទួលយកដំបូន្មាន និងការប្រឹក្សារបស់ទ្រង់ខណៈដែលយើងរស់នៅក្នុងជីវិតរមែងស្លាប់នេះ ។

« នេះពុំមែនជាសុបិនដ៏ឥតប្រយោជន៍នោះទេ ។ សុបិនទាំងនេះគឺជាការពិត » ។ [18]




*ខាងលើបង្អស់ ៖ ប្រធាន ស្ម៊ីធ ជាមួយនិងកូនប្រុសរបស់លោក ចច អ័លប៊ើត ស្ម៊ីធ ជុញ្ញ័រ ។ ខាងលើ ៖ ជាការចេញផ្សាយមួយនាឆ្នាំ 1947 នៃទស្សនាវដ្ដី Time ដែលបានសរសេរអត្ថបទអំពី ប្រធាន ស្ម៊ីធ និងសាសនាចក្រ ។*

## សេចក្ដីស្រឡាញ់ និងការបម្រើ

ប្រធាន ស្ម៊ីធប្រហែលជាត្រូវបានស្គាល់យ៉ាងខ្លាំងចំពោះសេចក្ដីស្រឡាញ់ដែលលោកបានបង្ហាញដល់អ្នកដទៃ ។ លោកបានជឿថាសេចក្ដីស្រឡាញ់គឺជាកត្តាដ៏សំខាន់នៃដំណឹងល្អ ។ លោកបានប្រាប់ពួកបរិសុទ្ធថា « ប្រសិនបើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ពុំបានបណ្ដុះអារម្មណ៍នៃសេចក្ដីស្រឡាញ់នោះចំពោះអ្នកដទៃនៅក្នុងដួងចិត្តរបស់អ្នក ដូចដែលវាបានផ្ដល់ឱ្យអ្នកទេ នោះខ្ញុំចង់និយាយទៅកាន់អ្នកថា អ្នកពុំទាន់មានទូរភាពរីករាយពីផលដ៏ពោរពេញនៃអំណោយដ៏មហិមាដែលបានកើតមានលើផែនដីនៅពេលសាសនាចក្រនេះត្រូវបានរៀបចំឡើយ » ។ [19]

ក្នុងនាមជាប្រធាននៃសាសនាចក្រ ប្រធាន ស្ម៊ីធ បានប្រទានពរដល់ជីវិតមនុស្សរាប់ពាន់នាក់តាមរយៈកិច្ចការសុខុមាលភាពទូទាំងពិភពលោក និងកម្មវិធីផ្សេងៗទៀត ។ មិនតែប៉ុណ្ណោះ លោកនៅតែស្វែងរកពេលសម្រាប់ ធ្វើកិច្ចការបម្រើផ្ទាល់ខ្លួនតូចៗថែមទៀត ។ មានមិត្តភ័ក្តិរបស់លោកម្នាក់ គឺអែលឌើរ រីឆាត អិល អេវិន្ស (1906–71) នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានសរសេរថា ៖ « វាពុំមែនជារឿងមិនប្រក្រតីនោះទេក្នុងការឃើញលោក ពីមុន និងក្រោយម៉ោងធ្វើការ ដើរទៅកាន់សាលមន្ទីរពេទ្យ ចេញពីបន្ទប់មួយទៅបន្ទប់មួយ ដើម្បីប្រសិទ្ធពរ លើកទឹកចិត្ត និងការរីករាយជាមួយការមកដល់ដោយមិនបានរំពឹងរបស់លោកនៅក្នុងបន្ទប់ទាំងនោះដែលការលួងលោម និងការលើកទឹកចិត្តរបស់លោកត្រូវបានស្វាគមន៍ប្រកបដោយសេចក្ដីអំណរ ។ ... វាគឺជាចរិតលក្ខណៈរបស់លោកក្នុងការទៅគ្រប់ទីកន្លែងដែលលោកមានអារម្មណ៍ថាលោកអាចជួយ និងលើកទឹកចិត្តបាន » ។ [20]

ប្រធាន ថូម៉ាស អេស ម៉នសុន បានចែកចាយពីគំរូនៃសេចក្ដីស្រឡាញ់របស់ប្រធាន ស្ម៊ីធ ថា ៖ « នៅព្រឹកដ៏ត្រជាក់មួយ ទារដូវរងា ក្រុមសម្អាតផ្លូវ [ នៅក្នុងទីក្រុង សលត៍ លេក ] កំពុងតែរំកិលដុំទឹកកកដ៏ធំចេញពីដងវិថី ។ ក្រុមការងារដែលធ្លាប់ធ្វើការជាធម្មតាត្រូវបានទទួលជំនួយពីក្រុមកម្មករបណ្ដោះអាសន្នដែលត្រូវការការងារធ្វើ ។ មានកម្មករម្នាក់ពាក់តែអាវរងាមួយដ៏ស្ដើង ហើយកំពុងតែរងាយ៉ាងខ្លាំង ។ មានបុរសស្គមខ្ពស់មានពុកចង្កាដ៏សង្ហាម្នាក់បានឈប់នៅក្បែរក្រុមការងារនោះ ហើយបានសួរទៅកម្មករនោះថា ‘អ្នកត្រូវការលើសពីអាវរងានោះនៅពេលព្រឹកបែបនេះ ។ តើអាវរងារបស់អ្នកទៅឯណា ?’ កម្មករនោះបានឆ្លើយតបវិញថា គាត់ពុំមានអាវរងាទេ ។ ក្រោយមកអ្នកធ្វើដំណើររូបនោះបានដោះអាវក្រៅរបស់ខ្លួន ហើយបានហុចវាឱ្យទៅកម្មករនោះ រួចនិយាយថា ‘អាវរងានេះជារបស់អ្នក ។ វាជាស្បែកសត្វដ៏ក្រាស់ ហើយវានឹងធ្វើឱ្យអ្នកកក់ក្ដៅ ។ ខ្ញុំធ្វើការនៅទល់មុខផ្លូវនេះ ។’ ផ្លូវនោះគឺនៅខាងត្បូងព្រះវិហារបរិសុទ្ធ ។ សាសន៍សាម៉ារីដ៏ល្អរូបនេះដែលបានដើរចូលទៅក្នុងអគាររដ្ឋបាលរបស់សាសនាចក្រដើម្បីធ្វើការងារប្រចាំថ្ងៃរបស់ខ្លួន និងដោយគ្មានអាវរងារបស់គាត់នោះគឺជាប្រធាននៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ចច អ័លប៊ើត ស្ម៊ីធ ។ ទង្វើដ៏ថ្លៃថ្នូនៃសេចក្ដីសប្បុរសរបស់លោកបានបង្ហាញឱ្យឃើញពីដួងចិត្តដ៏ផ្អែមល្ហែមរបស់លោក ។ ពិតណាស់លោកគឺជាអ្នកថែរក្សាបងប្អូនប្រុសរបស់លោក » ។ [21]

## រឿងពិស្ដារអំពីជីវិតប្រចាំថ្ងៃ

មិនថាជាការចែកចាយសេចក្ដីជំនឿរបស់លោកជាមួយនឹងអ្នកធ្វើដំណើរតាមរថភ្លើង ឬការដោះអាវរងារបស់លោកឱ្យទៅកម្មករដែលរងាកំពុងធ្វើការនៅតាមផ្លូវនោះទេ ប្រធាន ចច អ័លប៊ើត ស្ម៊ីធ ក៏បានថ្លែងទីបន្ទាល់របស់លោកដោយខ្ជាប់ខ្ជួនតាមរយៈទង្វើក៏ដូចការបង្រៀនទាំងឡាយរបស់លោកដែរ ។ ប្រធានបទដ៏ល្បីល្បាញមួយដែលមាននៅក្នុងសៀវភៅ *Teachings of Presidents of the Church: George Albert Smith* គឺថាដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទគួរតែមានឥទ្ធិពលមួយដ៏អស្ចារ្យមកលើជីវិតរបស់យើង ។

នៅពេលមានអ្នកអង្កេតមើលម្នាក់បាននិយាយពីប្រធាន ស្ម៊ីធថា ៖ « សាសនារបស់លោកពុំមែនជាគោលលទ្ធិដែលស្ថិតនៅក្នុងកន្លែងស្ងាត់ដ៏ត្រជាក់នោះទេ ។ វាពុំមែនជាទ្រឹស្ដីនោះទេ ។ ចំពោះលោកវាមានអត្ថន័យយ៉ាងជ្រាលជ្រៅជាងផែនការដ៏ស្រស់ស្អាតដែលត្រូវបានគេកោតសរសើរទៅទៀត ។ វាមានន័យជ្រាលជ្រៅជាងទស្សនវិជ្ជានៃជីវិតទៅទៀត ។ ចំពោះមនុស្សម្នាក់ដែលប្រតិបត្តិដូចលោក សាសនាគឺជាវិធីរបៀបដែលមនុស្សម្នាក់រស់នៅតាម ជាអ្វីដែលគាត់ធ្វើកិច្ចការទាំងឡាយ ពុំមែនគ្រាន់តែនិយាយពាក្យផ្អែមល្ហែម ឬឱ្យទឹកត្រជាក់មួយកែវនោះទេ ។ សាសនារបស់លោកត្រូវតែឃើញការបង្ហាញដោយពិត ។ វាត្រូវតែជាតស្ដុតាងនៅក្នុងរឿងពិស្ដារនៃជីវិតប្រចាំថ្ងៃ » ។ [22]

ប្រធាន ជេ រ៉ូប៊ិន ក្លាក ជុញ្ញ័រ (1871–1961) ជាទីប្រឹក្សាម្នាក់របស់លោកនៅក្នុងគណៈប្រធានទីមួយ បានសង្ខេបពីជីវិតរបស់ប្រធានស្ម៊ីធ ដោយពាក្យពេចន៍ទាំងនេះថា ៖ « លោកគឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សដ៏កម្រដែលអ្នកអាចនិយាយថាលោកបានរស់នៅដូចដែលលោកបានបង្រៀន » ។ [23] ■

**កំណត់ចំណាំ**

1. John A. Widtsoe នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1951 ទំព័រ 99 សូមមើលផងដែរ *Teachings of Presidents of the Church: George Albert Smith* ( ឆ្នាំ2011 ) xxxvii–xxxviii ។
2. *Teachings: George Albert Smith* ទំព័រ 9 ។
3. សូមមើល *Teachings: George Albert Smith* ទំព័រ 223 ។
4. *Teachings: George Albert Smith* ទំព័រ 223 ។
5. *Teachings: George Albert Smith* ទំព័រ 227 ។
6. *Teachings: George Albert Smith* ទំព័រ 228 ។
7. *Teachings: George Albert Smith* ទំព័រ 124 ។
8. *Teachings: George Albert Smith* ទំព័រ 152 ។
9. *Teachings: George Albert Smith* ទំព័រ 125 ។
10. *Teachings: George Albert Smith* ទំព័រ 129 ។
11. *Teachings: George Albert Smith* ទំព័រ 150 ។
12. ព្រេស្តុន ណិព្ឋិ នៅក្នុង *Teachings: George Albert Smith* ទំព័រ 123 ។
13. សូមមើល *Teachings: George Albert Smith* ទំព័រ 235 ។
14. *Teachings: George Albert Smith* ទំព័រ 240 ។
15. *Teachings: George Albert Smith* ទំព័រ 228 ។
16. សូមមើល *Teachings: George Albert Smith* ទំព័រ xxvii ។
17. *Teachings: George Albert Smith* ទំព័រ 83–84 ។
18. *Teachings: George Albert Smith* ទំព័រ 76–77 ។
19. *Teachings: George Albert Smith* ទំព័រ 14 ។
20. រីឆាត អិល អេវិន្ស នៅក្នុង *Teachings: George Albert Smith* ទំព័រ 11–13 ។
21. ថូម៉ាស អេស ម៉នសុន នៅក្នុង *Teachings: George Albert Smith* ទំព័រ 13 ។
22. ព្រាយអិនត៍ អេស ហ៊ិងគ្លី នៅក្នុង *Teachings: George Albert Smith* ទំព័រ 2 ។
23. ជេ រ៉ូប៊ិន ក្លាក ជុញ្ញ័រ នៅក្នុង *Teachings: George Albert Smith* ទំព័រ 3 ។

ខាងឆ្វេង ៖ រូបថតប្រធាន ស្ម៊ីធ និងទីប្រឹក្សា ចុចពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ



# អាគុយ និងខ្យល់ដ៏ខ្លាំង

មានថ្ងៃមួយបន្ទាប់ពីវេណរបស់ខ្ញុំនៅឯព្រះវិហារបរិសុទ្ធអៃដាហូ ហ្វល អៃដាហូ ខ្ញុំបានស្ម័គ្រចិត្តនាំបងប្អូនប្រុសពីរនាក់ទៅកាន់ឡានរបស់ពួកគេ ដែលត្រូវបានរលត់នៅលើដងវិថីប៉ែកខាងត្បូងនៃអៃដាហូ ហ្វល រដ្ឋអៃដាហូ សហរដ្ឋអាមេរិក ។ មានប្ដីប្រពន្ធដ៏ចិត្តល្អមួយគូបានឈប់នៅអំឡុងថ្ងៃដ៏រងានាខែធ្នូនោះ ហើយបានដឹកបងប្រុស ថមសុន និងបងប្រុស ក្លាកពីត្រង់នោះទៅកាន់ព្រះវិហារបរិសុទ្ធ ។

បងប្រុស ថមសុន ត្រូវបានប្រាប់ថាឡានរបស់គាត់ត្រូវការអាគុយថ្មី ។ ខ្ញុំបាននាំគាត់ទៅទិញអាគុយនៅហាងលក់គ្រឿងបន្លាស់រថយន្តនៅក្បែរនោះ ហើយដោយសារតែខ្ញុំមានឧបករណ៍នៅក្នុងឡានរបស់ខ្ញុំ ទើបខ្ញុំបានឯកភាពដើម្បីប្ដូរវា ។

សំណាងល្អដែលខ្ញុំបានយកស្រោមដៃមួយគូ និងអាវរងារបស់ខ្ញុំមកជាមួយ។ ដោយបើកគម្របក្បាលឡានខាងមុខឡើង ខ្ញុំបានរៀបចំដើម្បីដោះអាគុយចាស់ចេញ ហើយដាក់អាថ្មីចូល ។

ដើម្បីប្ដូរអាគុយបាន ខ្ញុំត្រូវដោះគ្រឿងឡានជាច្រើនផ្នែកចេញ រួមទាំងធុងស្ដុកទឹកសម្រាប់ប្រដាប់លាងកញ្ចក់ឡានផងដែរ ។ រំពេចនោះខ្ញុំបានរកឃើញថាឧបករណ៍របស់ខ្ញុំមិនត្រូវនឹងខ្ចៅទាំងឡាយ ហើយវីសជាច្រើនមិនអាចមួលបានសោះ ។ ខ្ញុំបានប្រើឧបករណ៍ផ្សេង និងបានសាកល្បងផ្នែកផ្សេងទៀត ប៉ុន្ដែមិនអាចមួលបានឡើយ ។ សីតុណ្ហភាពនៅខាងក្រៅគឺប្រហែលជា 5 អង្សា ហ្វារិនហៃ (-15 អង្សាសេ ) ហើយល្បឿនរថយន្តធំៗដែលបើកកាត់បានបក់បង្កើតជាខ្យល់ដ៏ត្រជាក់ ។ ខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍រងា និងមានភាពទាល់ច្រកដ៏តានតឹង ។

ខ្ញុំបានងាកទៅរកជំនួយតែមួយគត់ដែលមាន ។ ខ្ញុំបានអធិស្ឋានដោយស្មោះអស់ពីចិត្ត ដោយរៀបរាប់ពីសេចក្ដីត្រូវការរបស់ខ្ញុំដល់ព្រះវរបិតាសួគ៌ និងដោយទូលសុំប្រសិនបើជាទ្រង់នឹងធ្វើឱ្យខ្ចៅ និងវីសទាំងឡាយចេញ ឬជួយខ្ញុំរកឃើញវិធីដើម្បីធ្វើវា ។ នៅពេលបញ្ចប់ការអធិស្ឋានរបស់ខ្ញុំ ខ្ញុំបានយកដង្កាប់ និងបានមួលវីសដ៏មាំម្ដងទៀត ។ វាបានធូររួចទៅហើយ ! ដោយបានបង្ហាញនូវអំណរគុណដោយស្ងៀមស្ងាត់ និងក្លៀវក្លា ខ្ញុំបានដោះវីសជាបន្ដបន្ទាប់ ។

មិនយូរប៉ុន្មានខ្ញុំបានជួបនឹងខ្ចៅមួយដែលតឹងណែននៅជាប់ជ្រៅក្នុងឡាននោះ ។ ដោយជួបនឹងភាពទាល់ច្រក ជាថ្មីម្ដងទៀត ខ្ញុំបានអធិស្ឋានកាន់តែស្មោះអស់ពីចិត្តទូលសុំជំនួយ ដោយមាននូវការទុកចិត្តកាន់តែខ្លាំង ។ ពេលនេះខ្ញុំមានអារម្មណ៍ដឹកនាំឱ្យដោះខ្ចៅដែលនៅជ្រៅៗមួយចំនួនមុនសិន ទើបដោះដង្កៀបក្បាលអាគុយចេញ ហើយខ្ញុំក៏បានធ្វើតាម ។ ខ្ចៅដ៏ជាប់នោះបានមួលចេញយ៉ាងងាយ ។ ក្នុងពេលតែពីរបីវិនាទីខ្ញុំដោះអាគុយចាស់នោះចេញបាន ។

ខ្ញុំបានដាក់អាគុយថ្មីចូល និងបានចាប់ខ្ចៅ និងវីសទាំងឡាយវិញដោយអស់ពីលទ្ធភាពដែលខ្ញុំអាចធ្វើបាន ទាំងម្រាមដៃទាំងអស់បានស្ពឹកយ៉ាងខ្លាំង ។ ក្រោយមកខ្ញុំបានតខ្សែជុំភ្លើងឡើងវិញ ។ បងប្រុស ថមសុនបានកាច់សោ និងបានញញឹមនៅពេលម៉ាស៊ីនចាប់ផ្ដើមឆេះ ។ ខ្ញុំបានបិទគម្របឡានខាងមុខនោះវិញដោយអំណរ ។ ខ្ញុំបាននៅខាងក្រៅប្រហែលមួយម៉ោង ហើយស្នងជើង និងប្រអប់ជើងរបស់ខ្ញុំត្រូវបានស្ពឹកនៅពេលខ្ញុំបានចូលទៅក្នុងឡានរបស់ខ្ញុំ ។

ខ្ញុំបានបើកតាមក្រោយបងប្រុស ថមសុន និងបងប្រុស ក្លាករហូតដល់ផ្ទះ ដើម្បីប្រាកដថា ពួកគាត់បានមកដល់ផ្ទះដោយសុវត្ថិភាព ។ នៅពេលខ្ញុំបានបើក

*ខ្ញុំបានប្រើឧបករណ៍ផ្សេង និងបានសាកល្បងផ្នែកផ្សេងទៀត ប៉ុន្តែគ្មានអ្វីរង្គើសោះ ។ ខ្ញុំបានត្រូវជាក់យ៉ាងខ្លាំង ធុញទ្រាន់និងភាពទាល់ច្រក ។*



ឡើង ម៉ាស៊ីនកម្តៅក្នុងឡានរបស់ខ្ញុំធ្វើឱ្យខ្ញុំមានអារម្មណ៍សុខស្រួល ហើយធ្វើឱ្យជើង និងបាតជើងរបស់ខ្ញុំចាប់ផ្តើមមានភាពកក់ក្តៅបន្តិចម្តងៗ ។ ខ្ញុំបានថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌យ៉ាងខ្លាំងចំពោះជំនួយរបស់ទ្រង់ ។ ជាលទ្ធផល ខ្ញុំពិតជាមានការស្ញើចសរសើរដោយដឹងថាទ្រង់បានឆ្លើយតបនឹងការអធិស្ឋានរបស់បងប្រុសទាំងនេះដោយបានចាត់ខ្ញុំទៅក្នុងនាមជាអ្នកបម្រើរបស់ទ្រង់ ។ តាមរបៀបដ៏អស្ចារ្យរបស់ទ្រង់ ទ្រង់បានបំពេញនូវសេចក្តីត្រូវការរបស់ពួកគាត់ និងបានបញ្ជាក់ពីសេចក្តីជំនឿរបស់ខ្ញុំឡើងវិញ ។ ■

**ស៊ីលី ប៊ែទឌិកសេន រដ្ឋអៃដាហូ សហរដ្ឋអាមេរិក**

# ទ្រព្យសម្បត្តិមួយដ៏មានតម្លៃ

ខ្ញុំធ្លាប់ធ្វើការនៅមជ្ឈមណ្ឌលសេវាកម្មអតិថិជនមួយកន្លែង ដែលមានការពិបាកសម្រាប់បុគ្គលិកទាំងឡាយធ្វើការសំណេះសំណាលនឹងគ្នា ។ ប្រធានរបស់យើងបានសម្រេចចិត្តរៀបចំអាហារថ្ងៃត្រង់មួយពេលទៅថ្ងៃសៅរ៍សម្រាប់ក្រុមទាំងមូល ដើម្បីផ្តល់ឱកាសឱ្យយើងបានស្គាល់គ្នា ។ គាត់បានប្រាប់យើងឱ្យយកវត្ថុមួយចំនួនដែលមានតម្លៃចំពោះយើង ហើយពន្យល់ពីមូលហេតុនៃសារៈសំខាន់របស់វា ។

នៅពេលខ្ញុំបានគិតអំពីសំណើរបស់គាត់ ខ្ញុំបានដឹងថានេះគឺជាឱកាសមួយដើម្បីបង្រៀនមិត្តរួមការងាររបស់ខ្ញុំអំពីដំណឹងល្អ ។ ដោយសារតែសាសនាគឺជាប្រធានបទមួយដែលងាយនឹងអាក់អន់ចិត្ត ខ្ញុំបានដឹងថាខ្ញុំត្រូវតែប្រុងប្រយ័ត្នចំពោះវត្ថុដែលខ្ញុំយក និងរបៀបដែលខ្ញុំពន្យល់ពីតម្លៃរបស់វាចំពោះខ្ញុំ ។

នៅពេលថ្ងៃញុំាអាហារថ្ងៃត្រង់បានមកដល់ យើងទាំងអស់គ្នារីករាយក្នុងការស្គាល់គ្នាទៅវិញទៅមកថែមទៀត ។ ក្រោយពីអាហារថ្ងៃត្រង់ប្រធានរបស់យើងបានចាប់ផ្តើមសកម្មភាពរបស់យើងដោយបង្ហាញវត្ថុដ៏មានតម្លៃរបស់គាត់—គឺអាល់ប៊ុមរូបថតក្រុមគ្រួសាររបស់គាត់ ។ គាត់បានប្រាប់យើងពីការលំបាកទាំងឡាយដែលគាត់បានឆ្លងកាត់ក្នុងខណៈដែលបែកបាក់ពីស្វាមីរបស់គាត់ ហើយក្លាយជាម្តាយទោល និងការចាប់ផ្តើមជីវិតថ្មីមួយ ។

ក្រោយពីការបង្ហាញផ្សេងទៀតមួយចំនួនមក វេណរបស់ខ្ញុំបានមកដល់ ។ ខ្ញុំបានប្រាប់មិត្តរួមការងារថាវត្ថុរបស់ខ្ញុំគឺជាអ្វីមួយដែលខ្ញុំយកមកតាមខ្លួនជារៀងរាល់ថ្ងៃ ៈ គឺជាចិញ្ចៀន ជ.ផ.ត. របស់ខ្ញុំ ។ ខ្ញុំបានប្រាប់ពួកគេថាតួអក្សរទាំងនោះមានន័យថា « ជ្រើសរើសផ្លូវត្រូវ » ហើយថាចិញ្ចៀននោះបានរំឭកខ្ញុំឱ្យគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះជាម្ចាស់ ។ មានមនុស្សមួយចំនួនបានសួរអំពីសាសនាចក្រ និងជំនឿរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលបានផ្តល់ឱកាសឱ្យខ្ញុំដើម្បីប្រាប់ពួកគេពីសារៈសំខាន់នៃក្រុមគ្រួសារនៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌យើងសម្រាប់កូនចៅរបស់ទ្រង់ ថាក្រុមគ្រួសារអាចរួមរស់នឹងគ្នាដ៏នៅអស់កល្បជានិច្ច ហើយថាយើងមានព្រះអង្គសង្គ្រោះមួយអង្គដែលបានលះបង់ជីវិតរបស់ទ្រង់សម្រាប់យើង ។ ខ្ញុំក៏បានចែកចាយបទពិសោធន៍មួយចំនួនទៅក្នុងបេសកកម្មរបស់ខ្ញុំផងដែរ ។ នៅពេលខ្ញុំបាននិយាយ ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណ រួមទាំងមិត្តរួមការងាររបស់ខ្ញុំផងដែរ ។

បន្ទាប់ពីថ្ងៃនោះមក មានមនុស្សមួយចំនួនបានសួរសំនួរផ្សេងទៀតអំពីដំណឹងល្អ ហើយខ្ញុំបានអញ្ជើញពួកគេមួយចំនួនទៅព្រះវិហារ ។ ក្រោយមកទៀតខ្ញុំបានផ្លាស់ប្តូរការងារ ហើយពុំដែលបានដឹងប្រសិនបើក្នុងចំណោមពួកគេបានមានចំណាប់អារម្មណ៍ចង់ដឹងបន្ថែមទៀតដែរ ឬក៏អត់នោះតែ ប៉ុន្តែខ្ញុំបានមានអារម្មណ៍ល្អដោយដឹងថាខ្ញុំបានប្រាប់ពួកគេថាសាសនាចក្រដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទមាននៅលើផែនដីនេះ ហើយថាព្រះវរបិតាសួគ៌មាននូវផែនការនៃសុភមង្គលសម្រាប់កូនចៅរបស់ទ្រង់ ។

ក្នុងនាមជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ យើងមានការទទួលខុសត្រូវដើម្បីចែកចាយដំណឹងល្អ ។ តាមរយៈវត្ថុដ៏តូចនិងសាមញ្ញទាំងឡាយដូចជាចិញ្ចៀន ជ.ផ.ត. យើងអាចបង្រៀនមេរៀនដ៏អស្ចារ្យដែលអាចធ្វើដំណើរការឆ្ពោះទៅរកសេចក្តីសង្គ្រោះនៃបងប្អូនប្រុសស្រីរបស់យើងបាន ។ ■

**វ៉ាហ្វាអែល បារីយ៉ូស សេនតា ហ្វេ អាហ្សង់ទីន**

***ដោយសារតែសាសនាគឺជាប្រធានបទមួយដែលងាយធ្វើឱ្យអាក់អន់ចិត្ត ខ្ញុំបានដឹងថាខ្ញុំត្រូវតែប្រុងប្រយ័ត្នអំពីវត្ថុដែលខ្ញុំចែកចាយ ។***



រចនារូបភាពដោយ ជី ប្រូន ផក់កេលសុន



*នៅពេលខ្ញុំអង្គុយនៅលើសាឡុង ទាំងអារម្មណ៍ក្តុកក្តួល ស្រាប់តែកូនប្រុសអាយុពីរឆ្នាំរបស់យើងបានដើរមកកាន់ភួយទទេនោះ ហើយខ្សឹបថា « សួស្តី ប្អូនស្រីតូច » ។*

# សូមអានព្រះគម្ពីរមរមនរបស់អ្នក

យើងគួរតែបានពោរពេញដោយសេចក្តីអំណរ ប៉ុន្តែដួងចិត្តរបស់យើងពោរពេញដោយទុក្ខព្រួយ និងដៃរបស់យើងទទេស្អាត ។ ដេប្រា ខាលីយ៉ា ខាតធើរ បានចូលមកដល់ថ្ងៃដែលនាងត្រូវកើត គឺថ្ងៃទី 26 ខែ មេសា ឆ្នាំ 2010 ប៉ុន្តែនាងបានស្លាប់ក្នុងផ្ទៃរបស់នាង ។

នៅពេលយើងដើរចូលទៅក្នុងផ្ទះរបស់យើង ខ្ញុំបានកាន់ភួយពណ៌ផ្កាឈូកដ៏តូចដែលយើងបានប្រើដើម្បីរុំ ដេប្រានៅឯមន្ទីរពេទ្យ ។ នៅពេលខ្ញុំអង្គុយនៅលើសាឡុងទាំងអារម្មណ៍ក្តុកក្តួល ស្រាប់តែកូនប្រុសអាយុពីរឆ្នាំរបស់យើងបានដើរមកកាន់ភួយទទេនោះ ហើយខ្សឹបថា « សួស្តី ប្អូនស្រីតូច ។ បងស្រឡាញ់ប្អូន » ។

ទឹកភ្នែកបានហូរមកលើផ្ទៃមុខរបស់ខ្ញុំ ហើយខ្ញុំខំងាកចេញ ។ កាលដែលខ្ញុំបានធ្វើដូច្នោះ ខ្ញុំបានឃើញពាក្យទាំងឡាយនៅក្នុងប័ណ្ណប្រកាសចេញពីទស្សនាវដ្តី *Friend* ដែលព្យួរនៅលើជញ្ជាំង ៖ « ព្រះវរបិតាសួគ៌របស់យើងនៅជិតបង្កើយត្រឹមតែការអធិស្ឋានមួយប៉ុណ្ណោះ ហើយព្រះវិញ្ញាណបរិសុទ្ធនៅបង្កើយក្បែរនឹងត្រចៀករបស់យើង » ។ [1]

ខ្ញុំបានចាប់ផ្តើមស្រោចដួងចិត្តរបស់ខ្ញុំទៅរកព្រះនៅក្នុងការអធិស្ឋានដ៏ស្ងៀមស្ងាត់ និងក្លៀវក្លា ។ នៅពេលខ្ញុំបានធ្វើដូច្នោះ ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណខ្សឹបប្រាប់ថា « សូមអានព្រះគម្ពីរមរមនរបស់អ្នកម្តងទៀត » ។ ខ្ញុំទើបតែបានអានវាចប់ ប៉ុន្តែអារម្មណ៍នោះមានភាពច្បាស់ ហើយគំនិតនោះគឺមានភាពប្រាកដប្រជា ។

លុះស្អែកឡើង ដោយក្រោកព្រឹកព្រលឹម ខ្ញុំបានចាប់ផ្តើមអានព្រះគម្ពីរមរមន ។ ខ្ញុំបានប្រើខ្មៅដៃ និងខ្មៅដៃពណ៌ដើម្បីគូសចំណាំគ្រប់ឃ្លាអំពីសេចក្តីជំនឿ ការអធិស្ឋាន សេចក្តីសង្ឃឹម លក្ខណៈរបស់ព្រះយេស៊ូវគ្រីស្ទ ការប្រកាសដំណឹងល្អ និងការស្តាប់តាមសម្លេងរបស់ព្រះអម្ចាស់ ។ ខ្ញុំបានដឹងថា ខ្ញុំត្រូវតែធ្វើអ្វីដែលនីហ្វៃ, អេណុស, មរ៉ូណៃ និងពួកព្យាការីផ្សេងទៀតនៅក្នុងព្រះគម្ពីរមរមនបានធ្វើនៅពេលពួកគេបានរងការឈឺចាប់ពីការសាកល្បងនានា ។ ហើយខ្ញុំត្រូវតែធ្វើវាដោយសេចក្តីស្រឡាញ់ដូចគ្នាចំពោះព្រះអង្គសង្គ្រោះដែលបានបំពេញជីវិតរបស់ពួកគេក្នុងគ្រាដ៏លំបាកទាំងឡាយ ។

អំឡុងពេលម៉ោងសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃទាំងនេះ ខ្ញុំបានទទួលអារម្មណ៍ថាព្រះហស្តរបស់ព្រះអម្ចាស់កំពុងឱបក្រសោបខ្ញុំដោយសេចក្តីស្រឡាញ់របស់ទ្រង់ ហើយខ្ញុំបានទទួលអារម្មណ៍ពីព្រះចេស្តានៃការបូជារបស់ទ្រង់ដែលធ្វើឱ្យធួននឹងបាបសម្រាប់មនុស្សទាំងអស់ ។ ព្រះវិញ្ញាណបានមានបន្ទូលមកកាន់ខ្ញុំ សេចក្តីសុខសាន្តបានគ្រប់ដណ្តប់មកលើខ្ញុំ ហើយចម្លើយទាំងឡាយបានកើតមានចំពោះការអធិស្ឋានដ៏ក្លៀវក្លារបស់ខ្ញុំ ។ ការពិចារណាពីព្រះបន្ទូលទាំងឡាយដែលខ្ញុំបានអានបានផ្តល់កម្លាំងដល់ខ្ញុំកាលណាខ្ញុំបានមានភាពសោកសង្រេង ។

ថ្ងៃមួយព្រះវិញ្ញាណបានធ្វើឱ្យពោរពេញដោយសេចក្តីអំណរនៅពេលខ្ញុំអានព្រះបន្ទូលទាំងនេះ ៖

« ឪពុកស្រឡាញ់កូនក្មេងតូចៗដោយសេចក្តីស្រឡាញ់ដ៏ឥតខ្ចោះ ហើយពួកកូនក្មេងគឺដូចគ្នាទាំងអស់ ហើយជាពួកអ្នកទទួលទាននៃសេចក្តីសង្គ្រោះ ។ ...

« កូនក្មេងតូចៗ ... រស់នៅក្នុង [ ព្រះ ] ពីព្រោះតែសេចក្តីមេត្តាករុណារបស់ទ្រង់ ។ ...

« ត្បិតមើលចុះ*អស់ទាំងកូនក្មេងតូចៗរស់នៅក្នុងព្រះគ្រីស្ទ* » ( មរ៉ូណៃ 8:17, 19, 22 ការបញ្ជាក់ន័យបានបន្ថែម ) ។

ខ្ញុំបានទទួលអារម្មណ៍ហាក់ដូចជាខ្ញុំអាចមើលឃើញកូនស្រីរបស់ខ្ញុំ*រស់* នៅក្នុងព្រះគ្រីស្ទ—ដោយមានស្នាមញញឹម និងភាពរីករាយ ហើយបានឱបក្រសោបនៅក្នុងព្រះហស្តរបស់ទ្រង់ ។ ចាប់តាំងពីវិនាទីនោះមក ខ្ញុំបានទទួលអារម្មណ៍នូវអំណាចដើម្បីស៊ូទ្រាំ ហើយខ្ញុំបានទទួលអារម្មណ៍នូវសេចក្តីសង្ឃឹមថ្មីមួយដែលឆេះឡើងនៅក្នុងព្រលឹងរបស់ខ្ញុំសម្រាប់ក្រុមគ្រួសាររបស់ខ្ញុំ ។ ខ្ញុំបានដឹងថាប្រសិនបើខ្ញុំនឹងខ្ជាប់ខ្ជួនចំពោះដង្វាយធួន ព្រះគម្ពីរនានា ពាក្យទាំងឡាយរបស់ពួកព្យាការីដែលនៅរស់ និងជាមួយគ្នាទៅវិញទៅមកតាមរយៈសេចក្តីសញ្ញារបស់យើងក្នុងព្រះវិហារបរិសុទ្ធ នោះយើងត្រូវបានរួមរស់នឹងគ្នាម្តងទៀតជាក្រុមគ្រួសារដ៏អស់កល្បជានិច្ច ។

ខ្ញុំស្រឡាញ់ព្រះគម្ពីរមរមន ដែលថ្លែងទីបន្ទាល់យ៉ាងច្បាស់អំពីព្រះយេស៊ូវគ្រីស្ទ អំពីអ្វីដែលទ្រង់បានធ្វើ និងធ្វើសម្រាប់យើង ព្រមទាំងអ្វីដែលយើងត្រូវធ្វើដើម្បីប្រែក្លាយដូចជាទ្រង់ ។ ព្រះគម្ពីរមរមននាំពន្លឺមកក្នុងជីវិតរបស់ខ្ញុំ និងបំពេញដល់ដួងចិត្តរបស់ខ្ញុំនូវសេចក្តីសង្ឃឹមលើព្រះគ្រីស្ទ ។ ■

**ជូរីលែន ខាតធើរ រដ្ឋវើរជិនញា សហរដ្ឋអាមេរិក**

**កំណត់ចំណាំ**

1. មកពី Elaine S. Dalton « At All Times, in All Things, and in All Places » *Liahona* ខែ មេសា ឆ្នាំ 2008 ទំព័រ 118 ។

# ស្បែកជើងរបស់ប៉ា

ជាច្រើនឆ្នាំកន្លងមកហើយខណៈដែលឪពុកម្ដាយរបស់ខ្ញុំកំពុងជួយសមាគមសង្គ្រោះរៀបចំសម្លៀកបំពាក់ ស្បែកជើងមួយចំនួន ព្រមទាំងរបស់របរផ្សេងទៀតដើម្បីបរិច្ចាគឱ្យអ្នកទ័លក្រ ប៉ារបស់ខ្ញុំបានកត់សម្គាល់ឃើញមានស្បែកជើងមួយគូដ៏ស្រស់ស្អាតនៅកណ្ដាលពំនូកនៃរបស់របរទាំងនោះ ។ នៅពេលនោះគាត់បានទទួលការជម្រុញចិត្តយ៉ាងខ្លាំងឱ្យទុកស្បែកជើងនោះ ។

ម៉ាក់របស់ខ្ញុំបានសើច ហើយនិយាយថា « ស្បែកជើងមួយគូនេះគឺតូចជាងជើងបងដល់ទៅបីលេខ ។ វាពុំល្មមទេ ! »

ទោះបីជាយ៉ាងណា ប៉ារបស់ខ្ញុំបានទទូចសុំយ៉ាងខ្លាំង ។ ក្រោយពីការនិយាយចំអកលេងជាច្រើនមកពីបងប្អូនស្រីទាំងឡាយ នៅទីបំផុតពួកគេបានអនុញ្ញាតឱ្យគាត់ទុកស្បែកជើងនោះ ។

នៅពេលគាត់បានមកដល់ផ្ទះភ្លាម គាត់បានសម្អាតស្បែកជើងនោះ បានញាត់ក្រដាសកាសែតចូល ហើយបានដាក់វាចូលក្នុងប្រអប់មួយនៅលើទូខោអាវរបស់គាត់ ។ យើងបានទទួលការណែនាំកុំឱ្យប៉ះប្រអប់នោះ ។ អស់រយៈពេលប្រាំឆ្នាំវាត្រូវបានទុកនៅកន្លែងដដែល ។

នៅថ្ងៃមួយ មានក្រុមគ្រួសារថ្មីមួយបានរើផ្ទះមកនៅជិតយើង ។ ពួកគេមានកូនពីរនាក់ និងកូនតូចអាយុប្រាំមួយខែម្នាក់ ។ មិនយូរប៉ុន្មាន ប្អូនស្រីរបស់ខ្ញុំ និងខ្ញុំបានក្លាយមិត្តភ័ក្ដិជាមួយនឹងក្មេងស្រីទាំងពីរនាក់របស់ពួកគេ ដែលមានអាយុស្របាលៗយើង ។ យើងបានចែកចាយជាមួយនឹងមិត្តភ័ក្ដិថ្មីរបស់យើងនូវអ្វីដែលយើងបានរៀននៅឯព្រះវិហារ ហើយយើងបានអញ្ជើញពួកគេឱ្យចូលរួមក្នុងថ្នាក់កុមារ ។ ពួកគេមានចិត្តរំភើប និងទទូចចង់រៀនបន្ថែមទៀតអំពីអ្វីដែលយើងបានចែកចាយជាមួយនឹងពួកគេ ។

បន្ទាប់ពីចេញពីថ្នាក់កុមារ ហើយត្រឡប់មកផ្ទះវិញ ពួកគេពុំបានឈប់និយាយអំពីសាសនាចក្រជាមួយនឹងឪពុកម្ដាយរបស់ពួកគេសោះ ។ ក្រោយមកប៉ាម៉ាក់របស់យើងបានអញ្ជើញក្រុមគ្រួសារទាំងមូលឱ្យស្ដាប់នូវការបង្រៀនរបស់ពួកអ្នកផ្សព្វផ្សាយសាសនា និងទៅកាន់ព្រះវិហារ ។ ពួកគេបានទទួលយកដោយសេចក្ដីអំណរ។ ពួកគេពេញចិត្តនឹងមេរៀនទាំងឡាយ ហើយយើងមានភាពរីករាយក្នុងការទៅកាន់ព្រះវិហារជាមួយនឹងពួកគេ។

ប៉ុន្តែនៅថ្ងៃសៅរ៍បានមកដល់ កូនស្រីទាំងឡាយរបស់ពួកគេហាក់ដូចជាមានការស្ទាក់ស្ទើរចិត្ត។ នៅពេលយើងបានសួរថាតើមានរឿងអ្វីកើតឡើង ពួកគេបាននិយាយថាប៉ាម៉ាក់របស់ពួកគេពុំចង់ទៅកាន់ព្រះវិហារទៀតឡើយ ។

យើងបានអស់សង្ឃឹម ហើយបានសុំឱ្យលោកប៉ាទៅនិយាយជាមួយនឹងប៉ាម៉ាក់របស់ពួកគេ ។ នៅពេលគាត់បានប្រាប់ពួកគេអំពីពរជ័យទាំងឡាយនៃការចូលរួមក្នុងព្រះវិហារ នោះឪពុករបស់ពួកគេបានឆ្លើយតបថា « បាទ ខ្ញុំដឹងរឿងទាំងអស់នេះ ។ បញ្ហាចោទគឺថាខ្ញុំពុំមានស្បែកជើងណាផ្សេងពាក់ក្រៅពីស្បែកជើងលេងវាយកូនបាល់របស់ខ្ញុំដែលមានជាយូរមកហើយ ហើយខ្ញុំដឹងថាយើងគួរតែទៅកាន់ការប្រជុំសាសនាចក្រដោយមានសម្លៀកបំពាក់សមរម្យ » ។



*ប៉ារបស់ខ្ញុំបានទទួលការជម្រុញចិត្តយ៉ាងខ្លាំងឱ្យទុកស្បែកជើងនោះទោះបីជាម៉ាក់របស់ខ្ញុំបានសើច ហើយនិយាយថា « ស្បែកជើងមួយគូនេះតូចជាងជើងបងដល់ទៅបីលេខ » ។*

នៅរំពេចនោះប៉ារបស់ខ្ញុំបានក្រឡេកទៅម៉ាក់របស់ខ្ញុំ។ គាត់បានដឹងយ៉ាងច្បាស់ពីអ្វីដែលត្រូវធ្វើ ។ ស្បែកជើងនៅក្នុងប្រអប់ខាងលើទូរខោអាវរបស់លោកប៉ាត្រូវនឹងជើងឪពុករបស់មិត្តភ័ក្ដិយើងម៉ាច់ ហើយក្រុមគ្រួសារទាំងមូលបានទៅកាន់ព្រះវិហារ ។ វាជាថ្ងៃអាទិត្យមួយដ៏អស្ចារ្យសម្រាប់យើង និងពួកគេ ។ មិនយូរប៉ុន្មានពួកគេបានក្លាយជាសមាជិកសាសនាចក្រ ហើយសព្វថ្ងៃនេះពួកគេជាក្រុមគ្រួសារមួយដ៏ស្រស់ស្អាតដ៏នៅអស់កល្បជានិច្ច ។

ខ្ញុំដឹងថាប៉ារបស់ខ្ញុំបានទទួលការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធឱ្យទុកស្បែកជើងនោះ ។ ជាលទ្ធផល ខ្ញុំតែងតែស្វែងរកការណែនាំរបស់ទ្រង់ក្នុងការស្វែងរកក្រុមគ្រួសារទាំងឡាយដែលរៀបចំខ្លួននឹងស្ដាប់ដំណឹងល្អ។ ខ្ញុំដឹងថាទ្រង់រៀបចំក្រុមគ្រួសារទាំងឡាយ ហើយខ្ញុំដឹងថាយើងត្រូវស្វែងរកពួកគេ និងនាំពួកគេមកឯព្រះគ្រីស្ទ ។ ■

**ព្រីស៊ីលឡា កូស្តា ហ្សាវៀ សៅ ប៉ូឡូ ប្រទេសប្រេស៊ីល**

# សម្លឹងមើលទៅលើ

*ឧបសគ្គមួយសម្រាប់យើងគ្រប់គ្នាគឺពុំ មែនក្រឡេកមើលសងខាងផ្លូវដើម្បីមើលពី របៀបដែលអ្នកដទៃកំពុងតែឆ្លុះបញ្ចាំងពី ជីវិតរបស់យើងនោះទេ ប៉ុន្តែសម្លឹងមើល ទៅលើដើម្បីមើលពីរបៀបដែល ព្រះវរបិតាសួគ៌ទតមើលយើង ។*





**ដោយ អែលឌើរ**
**ខាល ប៊ី យុក**
នៃពួកចិតសិបនាក់

កាលពីនៅក្មេង ខ្ញុំត្រូវបានហៅឱ្យបម្រើបេសកកម្មនៅ ហេមប៊ឺហ្គ ប្រទេសអាល្លឺម៉ង់ ។ នៅឯបេសកកម្មបំពាក់បំប៉នភាសា—ដែលនៅសព្វថ្ងៃនេះគេហៅថាមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា—ខ្ញុំមានការលំបាកយ៉ាងខ្លាំងក្នុងការរៀនភាសានោះ ។ នៅសប្ដាហ៍ទីមួយ និងទីពីរបានកន្លងផុតទៅ ខ្ញុំបានកត់សម្គាល់ឃើញថាពួកអ្នកផ្សព្វផ្សាយសាសនាផ្សេងទៀតនៅក្នុងមណ្ឌលរបស់ខ្ញុំបានមានការរីកចម្រើនលឿនជាងខ្ញុំ ។ ខណៈពេលដែលពួកគេកំពុងតែរីកចម្រើនទៅមុខដល់ជំហានដ៏ស្មុគស្មាញទាំងឡាយ *dies*, *ders*, and *das*es របស់ខ្ញុំពុំប្រើការកើតសោះ ។

ខ្ញុំបានចាប់ផ្ដើមព្រួយបារម្ភ—និងបាក់ទឹកចិត្ត ។ តើខ្ញុំអាចបម្រើបេសកកម្មមួយប្រកបដោយជោគជ័យបានដោយរបៀបណាទៅ បើខ្ញុំពុំអាចប្រាស្រ័យទាក់ទងនឹងមនុស្សដែលខ្ញុំត្រូវបានហៅឱ្យបង្រៀនបានផងនោះ ?

ខ្ញុំបានអធិស្ឋានសុំជំនួយ និងបានស្វែងរកពរជ័យបព្វជិតភាព ដែលបានផ្ដល់នូវការលួងលោមចិត្តមួយចំនួន ។ ប៉ុន្តែខ្ញុំបានបន្តស្រាវជ្រាវ និងជួបការលំបាក ហើយមានថ្ងៃមួយខ្ញុំបានទទួលអារម្មណ៍តានតឹង និងបារម្ភកាន់តែខ្លាំងជាងមុន ។ នៅពេលដៃគូរបស់ខ្ញុំ និងខ្ញុំបានដើរតាមច្រកផ្លូវ ខ្ញុំបានឈប់នៅឯបន្ទប់ដាក់ឥវ៉ាន់របស់អ្នកអនាម័យ ។ ខ្ញុំបានសុំដៃគូរបស់ខ្ញុំឱ្យរង់ចាំខ្ញុំមួយភ្លែត ។ ខ្ញុំបានចូលទៅក្នុងបន្ទប់ដ៏តូចនោះ ហើយបានលុតជង្គង់នៅលើក្រណាត់ជូតជើងមួយ ។ ខ្ញុំបានចាប់ផ្ដើមទូលអង្វរដល់ព្រះវរបិតាសួគ៌សម្រាប់ការបន្ធូរអារម្មណ៍ខ្លះៗ ។

ព្រះអម្ចាស់បានឆ្លើយតបនឹងការអធិស្ឋាននោះ ។ ខ្ញុំបានទទួលគំនិតនេះផុសចូលមកក្នុងគំនិតរបស់ខ្ញុំថា ៖ « យើងពុំបានហៅអ្នកឱ្យមករៀនចេះស្ទាត់នូវភាសាអាល្លឺម៉ង់ឡើយ ។ យើងគ្រាន់តែហៅអ្នកឱ្យបម្រើដោយអស់ពីចិត្ត អស់ពីគំនិត និងអស់ពីកម្លាំងរបស់អ្នកតែប៉ុណ្ណោះ » ។

ភ្លាមនោះ ខ្ញុំបានគិតថា « *ខ្ញុំអាចធ្វើការណ៍នោះបាន ។* ខ្ញុំអាចបម្រើដោយអស់ពីចិត្ត គំនិត និងកម្លាំងរបស់ខ្ញុំបាន ។ ប្រសិនបើនោះគឺជាអ្វីដែលព្រះអម្ចាស់បានហៅខ្ញុំឱ្យធ្វើ *ខ្ញុំអាចធ្វើបាន ។* » ខ្ញុំបានក្រោកឈរឡើងដោយទទួលអារម្មណ៍ធូរស្រាលយ៉ាងខ្លាំង ។

ចាប់តាំងពីពេលនោះមក របៀបដែលខ្ញុំវាស់ការរីកចម្រើនខាងភាសារបស់ខ្ញុំបានផ្លាស់ប្ដូរ ។ ខ្ញុំលែងប្រៀបធៀបការរីកចម្រើន និងជោគជ័យរបស់ខ្ញុំជាមួយនឹងដៃគូរបស់ខ្ញុំ ឬពួកអ្នកផ្សព្វផ្សាយសាសនាឯទៀតនៅក្នុងមណ្ឌលរបស់ខ្ញុំទៀតហើយ ។ ផ្ទុយទៅវិញ ខ្ញុំបានផ្ដោតទៅលើរបៀបដែលព្រះអម្ចាស់ទទួលចំពោះនូវអ្វីដែលខ្ញុំកំពុងតែធ្វើ ។ ជំនួសឱ្យការមើលជុំវិញដើម្បីប្រៀបធៀបខ្លួនរបស់ខ្ញុំជាមួយនឹងអ្នកដទៃ ខ្ញុំបានចាប់ផ្ដើមសម្លឹងមើលទៅលើ ដើម្បីនិយាយ ដើម្បីដឹងពីអ្វីដែល *ទ្រង់* មានព្រះតំរិះចំពោះការខិតខំរបស់ខ្ញុំ ។

ខ្ញុំពុំដឹងថាខ្ញុំបានរៀនភាសាចេះយ៉ាងលឿន ឬបានប្រសើរជាងមុនចាប់ពីពេលនោះមកឡើយ ប៉ុន្តែខ្ញុំលែងមានអារម្មណ៍ខ្វល់ខ្វាយដូចខ្ញុំធ្លាប់មានទៀតហើយ ។ ខ្ញុំបានដឹងពីអ្វីដែលព្រះអម្ចាស់មានព្រះទ័យឱ្យខ្ញុំធ្វើ ហើយវាស្ថិតនៅក្នុងអំណាចរបស់ខ្ញុំដើម្បីធ្វើវា ។

ខ្ញុំបានចាប់ផ្ដើមប្រឹក្សាជាមួយព្រះវរបិតាសួគ៌នៅពេលព្រឹក ដោយទូលទ្រង់ថាទូលបង្គំពុំដឹងថានឹងមានអ្វីកើតឡើងនៅថ្ងៃនេះទេ ប៉ុន្តែទូលបង្គំនឹងធ្វើឱ្យអស់ពីសមត្ថភាពរបស់ទូលបង្គំ ។ ខ្ញុំបានអធិស្ឋានថា « អ្វីដែលទូលបង្គំអាចរៀនបាន សូមអនុញ្ញាតឱ្យទូលបង្គំរៀនវា ប៉ុន្តែទោះជាយ៉ាងណា ទូលបង្គំនឹងថ្វាយដល់ទ្រង់នូវការខិតខំឱ្យអស់ពីលទ្ធភាពរបស់ទូលបង្គំ » ។

លុះពេលយប់ខ្ញុំបានអធិស្ឋានម្ដងទៀតដើម្បីរាយការណ៍ពីអ្វីដែលខ្ញុំបានរៀន និងអ្វីដែលបានធ្វើ ។ ខ្ញុំបានចែកចាយជាមួយនឹងព្រះវរបិតាដែលគង់នៅឯស្ថានសួគ៌ទាំងជោគជ័យ និងឧបសគ្គរបស់ខ្ញុំ ។ ខ្ញុំបានចាប់ផ្ដើមងាកទៅរកទ្រង់—ពុំមែនអ្នកផ្សេង ឬសូម្បីតែខ្លួនខ្ញុំឡើយ—ក្នុងការបញ្ជាក់ពីការរីកចម្រើនរបស់ខ្ញុំ ។

មេរៀនដែលខ្ញុំបានរៀននៅក្នុងបន្ទប់ដាក់អំបោសដ៏តូចនោះជាង 35ឆ្នាំកន្លងមកហើយនៅតែនៅជាប់ជាមួយនិងខ្ញុំអស់មួយជីវិតរបស់ខ្ញុំ តាមរយៈការហៅ និងការចាត់តាំងជាច្រើន ។ គ្រប់ពេលដែលខ្ញុំត្រូវបានសុំឱ្យ



ធ្វើអ្វីមួយដែលការរំពឹងទុកហាក់ដូចជាធំជាងអ្វីដែលខ្ញុំអាចធ្វើបាន នោះខ្ញុំចងចាំពីបទពិសោធន៍នោះ ហើយនិយាយមកកាន់ខ្លួនឯងថា « ចាំសិន ។ តើនរណាបានហៅអ្នក ? តើអ្នកកំពុងតែបម្រើនរណា ? តើនរណាទៅដែលអ្នកកំពុងតែព្យាយាមធ្វើឱ្យសប្បាយចិត្ត ? »

ពិភពលោកដែលយើងរស់នៅសព្វថ្ងៃនេះមានការវាស់វែងគ្រប់ប្រភេទទាំងអស់—វាភាគច្រើននៅខាងក្រៅខ្លួនយើង។ ខ្ញុំគិតថាការវាស់វែងដូចនោះអាចមានច្រើនជាពិសេសចំពោះពួកមជ្ឈិមវ័យវ័យក្មេង ។ អ្នកទៅសាលារៀន ហើយទទួលបានពិន្ទុ ប៉ុន្តែការណ៍នោះពុំចាំបាច់រាប់បញ្ចូលទៅនិងអ្វីផ្សេងទៀតដែលអ្នកជួបប្រទះនៅក្នុងមុខវិជ្ជាផ្សេងទៀត ឬក្រុមគ្រួសាររបស់អ្នក ឬស្ថានភាពជីវិតរបស់អ្នកឡើយ ។ ពេលខ្លះយើងត្រូវបានគេវិនិច្ឆ័យតាមរូបរាងខាងក្រៅរបស់យើង ឬតាមរយៈឡានដែលយើងបើកបរ ។ យើងប្រហែលជាកំណត់តម្លៃរបស់ខ្លួនឯងទៅលើចំនួនមិត្តភក្ដិដែលសរសេរនៅលើទំព័ររបស់យើងនៅក្នុងទំព័របណ្ដាញសង្គម ។ យើងបារម្ភអំពីអ្វីដែលអ្នកដទៃគិតចំពោះមនុស្សដែលយើងកំពុងតែដើរលេងជាមួយ ឬអ្វីដែលមនុស្សដទៃនឹងគិតបើសិនជាអ្នករៀបការពីមុនពេលរៀនចប់នោះ ។ វាជាការងាយស្រួលណាស់ក្នុងការជាប់អន្ទាក់ក្នុងការព្យាយាមធ្វើឱ្យអ្នកដទៃរីករាយ ប៉ុន្តែយើងពុំអាចទុកចិត្តលើរង្វាស់ផ្នែកខាងក្រៅដូច្នោះបានទេ ពិភពលោកនេះអាចមានភាពឆាប់រហ័សណាស់ទាំងការកោតសរសើរ និងការរិះគន់។

ខ្ញុំគិតថាសំណូមពរសម្រាប់យើងទាំងអស់គ្នា—ប៉ុន្តែប្រហែលជាពិសេសសម្រាប់ពួកមជ្ឈិមវ័យវ័យក្មេង—គឺការព្យាយាមកុំក្រឡេកមើលទៅសងខាងផ្លូវដើម្បីមើលពីរបៀបដែលអ្នកដទៃកំពុងវិនិច្ឆ័យពីជីវិតរបស់យើង ប៉ុន្តែត្រូវសម្លឹងមើលទៅលើដើម្បីមើលពីរបៀបដែលព្រះវរបិតាសួគ៌ទតមើលយើង។ ទ្រង់ពុំទតមើលរូបរាងខាងក្រៅនោះទេ ប៉ុន្តែទតចំពោះចិត្តវិញ ( សូមមើល សាំយូអែលទី1 16:7) ។ ហើយទ្រង់ជ្រាបដឹង ប្រសើរជាងអ្នកដទៃផ្សេងទៀត ពីអ្វីដែលយើងម្នាក់ៗត្រូវការ ។

ដូច្នោះតើយើងត្រូវ « សម្លឹងមើលទៅលើ ដោយរបៀបណា ? » នេះគឺជាគោលការណ៍មួយចំនួនដែលអាចជួយបាន ។

## ចូរភ្ជាប់ទៅនឹងអំណាចខាងវិញ្ញាណ

យើងអាចភ្ជាប់ទៅនឹងអំណាចខាងវិញ្ញាណដែលយើងត្រូវការក្នុងការធ្វើការសម្រេចចិត្តដោយការចាប់ផ្ដើមជារៀងរាល់ថ្ងៃដោយការអធិស្ឋាន និងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ។ ការអធិស្ឋាននោះអាចរួមមានទាំងការទូលសុំឱ្យងាយទទួលយកផែនការរបស់ព្រះសម្រាប់យើង ។ ទោះបីជាយើងពុំអាចមើលឃើញផែនការទាំងមូលក៏ដោយ ក៏យើងអាចសុំឱ្យងាយទទួលយកផ្នែកនៃផែនការដែលនឹងមកដល់នៅថ្ងៃនោះដែរ ។ នៅពេលដែលយើងងាយនឹងទទួលយក នោះយើងនឹងឃើញផលទាំងឡាយមកពីការជ្រើសរើសដើម្បីដើរតាមទ្រង់ ។ យើងនឹងមានលទ្ធភាពដើម្បីធ្វើតាមអារម្មណ៍ដែលយើងទទួល ។ ហើយយើងនឹងមានលទ្ធភាពដើម្បីធ្វើកិច្ចការលំបាកទាំងឡាយ និងធ្វើ នូវអ្វីៗទាំងអស់ដែលតម្រូវឱ្យធ្វើ ដោយហេតុផលត្រឹមត្រូវ ។

## សូមមានចិត្តស្មោះចំពោះការដឹកនាំដែលអ្នកទទួល

យើងអាច «សម្លឹងមើលទៅលើ » ដោយការមានចិត្តស្មោះចំពោះការដឹកនាំដែលយើងបានទទួលពីព្រះវរបិតាជាទីស្រឡាញ់តាមរយៈវិវរណៈផ្ទាល់ខ្លួន ។ ជួនកាលមានអ្នកដទៃបញ្ចុះបញ្ចូលយើងឱ្យចេញឆ្ងាយពីការធ្វើនូវអ្វីដែលយើងបានទទួល ហើយទោះបីជាពួកគេមាននូវគោលបំណងល្អក៏ដោយ ក៏យើងត្រូវតែមានចិត្តស្មោះចំពោះអ្វីដែលបានមាន។

ភរិយារបស់ខ្ញុំ និងខ្ញុំមានកូនស្រីម្នាក់កំពុងតែបម្រើបេសកកម្មពេញម៉ោងនៅក្នុងប្រទេស អេស្ប៉ាញ ។ កូនស្រីម្នាក់នោះបានចំណាយពេលសិក្សាថ្នាក់វិទ្យាល័យរបស់នាងនៅក្នុងប្រទេស នូវែលហ្សេឡង់ ខណៈពេលខ្ញុំកំពុងតែបម្រើជាប្រធានបេសកកម្ម ។ នៅពេលនាងមានអាយុ 21ឆ្នាំ នាងបាននិយាយថា «ប៉ា, ម៉ាក់ កូនគិតថាកូនត្រូវចេញបម្រើបេសកកម្ម » ។ ជាការពិតណាស់យើងរីករាយនឹងការសម្រេចចិត្តដ៏សុចរិតនេះ ប៉ុន្តែដោយដឹងថាវាជាការលះបង់មួយសម្រាប់នាងដែលត្រូវឃ្លាតពីមិត្តភ័ក្តិទាំងឡាយ និងក្រុមគ្រួសារក្នុងអំឡុងពេលវ័យជំទង់របស់នាង ខ្ញុំបានប្រាប់នាងថា «កូនបានបម្រើបេសកកម្មរួចហើយ » ។

*យើងអាច «សម្លឹងមើលទៅលើ » ដោយការមានចិត្តស្មោះចំពោះការដឹកនាំដែលយើងបានទទួលពីព្រះវរបិតាជាទីស្រឡាញ់តាមរយៈវិវរណៈផ្ទាល់ខ្លួន ។*



នាងបានញញឹម ហើយនិយាយថា « មិនពិតទេប៉ា គឺ *លោកប៉ា* វិញទេតើ ។ ឥឡូវនេះ *ខ្ញុំ* ចង់ចេញទៅបម្រើព្រះអម្ចាស់ » ។

ខ្ញុំបានតបដោយស្នាមញញឹមថា « យល់ព្រម » ។ « កូនបំពេញបេសកកម្មនោះចុះ ។ កូនធ្វើតាមការបំផុសគំនិតឱ្យបម្រើនោះ » ។

សព្វថ្ងៃនេះខ្ញុំមានភាពរីករាយពុំមែនដោយសារតែនាងបានបម្រើព្រះវរបិតាសួគ៌របស់នាង និងកូនចៅរបស់ទ្រង់នៅក្នុងប្រទេសអេស្ប៉ាញប៉ុណ្ណោះទេ តែរីករាយផងដែរដោយសារនាងបានធ្វើតាមអារម្មណ៍ដែលនាងបានទទួល ។ នាងពុំបានអនុញ្ញាតឱ្យសូម្បីតែខ្ញុំ—ដែលជាឪពុករបស់នាង—មកបញ្ចុះបញ្ចូលនាងឱ្យធ្វើនូវអ្វីផ្សេងទៀតក្រៅពីអ្វីដែលនាងបានទទួលថាត្រឹមត្រូវសម្រាប់ជីវិតរបស់នាង និងផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់នាងឡើយ ។

## កុំខ្លាចក្នុងការប្រព្រឹត្ត

ការរៀនសូត្រពីផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់ជីវិតរបស់យើងគឺជារឿងដ៏សំខាន់ណាស់ ប៉ុន្តែពេលខ្លះនៅពេលយើងបានរៀនលម្អិតច្រើនពេក គឺពីដើមរហូតដល់ចប់ រហូតធ្វើឱ្យយើងទៅជាភ័យខ្លាចក្នុងការប្រព្រឹត្តតាម ។ សូមកុំធ្លាក់ចូលទៅក្នុងអន្ទាក់នេះ ។ ចូរធ្វើការជ្រើសរើសល្អៗដោយប្រើប្រាស់ការវិនិច្ឆ័យដ៏ល្អបំផុតរបស់អ្នក ហើយឆ្ពោះទៅមុខជាមួយនឹងជីវិតរបស់អ្នក ។ យើងត្រូវបានប្រទានពរនៅពេលយើងធ្វើការជ្រើសរើសទាំងឡាយ ។ សូមកុំខ្លាចក្នុងការធ្វើការជ្រើសរើស ដោយសារតែអ្នកខ្លាចធ្វើខុសនោះឡើយ ។ សូមកុំខ្លាចក្នុងការសាកល្បងអ្វីដែលថ្មី ។ ដោយការធ្វើដូច្នោះ អ្នកនឹងរកឃើញសេចក្តីអំណរក្នុងការធ្វើដំណើរនោះ ។

## សូមឈរនៅត្រង់កន្លែងរបស់អ្នក

នៅពេលក្រុមគ្រួសាររបស់យើងរស់នៅក្នុងប្រទេសនូវែលហ្សេឡង់ ពេលខ្លះយើងបានមានអារម្មណ៍តានតឹងដោយសារតែឧបសគ្គជាច្រើនដែល ពួកសាសនាទាគន់ការី ពួកអ្នកប្រែចិត្តជឿថ្មី ពួកអ្នកផ្សព្វផ្សាយសាសនា និងមនុស្សផ្សេងទៀតកំពុងជួបប្រទះ ។ ជារឿយៗ យើងឃើញថាខ្លួនយើងកំពុងអធិស្ឋានសុំចម្លើយ—និងដោយរំពឹងទុកដើម្បីទទួលបានចម្លើយ*យ៉ាងឆាប់រហ័ស !*

យើងគ្រប់គ្នាពិតជាត្រូវការជំនួយ ។ ហើយពេលខ្លះដំណោះស្រាយដែលយើងស្វែងរក *ពិតជា* មកយ៉ាងឆាប់រហ័ស ។ ប៉ុន្តែពេលខ្លះទៀតវាមកតាមរបៀបផ្សេងជាងអ្វីដែលយើងបានសង្ឃឹមទុក ។ ឬ វាមកយឺតជាងអ្វីដែលយើងបានរំពឹងទុក ។ ហើយពេលខ្លះទៀត វាហាក់ដូចជា ការណ៍ទាំងនោះនឹងមិនកើតឡើងទាល់តែសោះ ។

ក្នុងករណីដូចនេះ ចូរជ្រើសរើសយកឥរិយាបថនៃការ « ឈរនៅត្រង់កន្លែងរបស់អ្នក » រហូតដល់ព្រះអម្ចាស់បញ្ជូនជំនួយមួយចំនួនមក ទោះជាវាយូរយ៉ាងណាក៏ដោយ ។ ប៉ុន្តែការឈរនៅត្រង់កន្លែងរបស់អ្នកពុំមានន័យថាឈរនៅស្ងៀមនោះទេ ។ ដូចដែលខ្ញុំបានលើកឡើង សូមកុំខ្លាចក្នុងការប្រព្រឹត្ត ។ បន្តធ្វើកិច្ចការល្អៗ ។ បន្តគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយ ។ បន្តអធិស្ឋាន សិក្សា និងធ្វើដោយអស់ពីសមត្ថភាពរបស់អ្នករហូតដល់អ្នកទទួលបានការដឹកនាំបន្ថែម ។ សូមកុំបោះបង់ចោលកន្លែងរបស់អ្នក ។ តាមពេលវេលារបស់ទ្រង់ព្រះអម្ចាស់នឹងអនុញ្ញាតឱ្យអ្វីទាំងអស់មានដំណើរការសម្រាប់សេចក្តីល្អរបស់អ្នក។

« ការសម្លឹងមើលទៅលើ » បានប្រទានពរដល់ជីវិតរបស់ខ្ញុំម្តងហើយម្តងទៀតចាប់តាំងពីបទពិសោធន៍របស់ខ្ញុំនៅក្នុងមជ្ឈមណ្ឌលបំពាក់បំប៉នភាសាសម្រាប់បេសកកម្ម ។ ដូចដែលមរមនពន្យល់នៅក្នុង ហេលេមិន 3:27 ថា « ព្រះអម្ចាស់ទ្រង់ប្រកបដោយសេចក្តីមេត្តាករុណាដល់អស់អ្នកណាដែលអំពាវនាវដល់ព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់ដោយចិត្តស្មោះស » ។ ខ្ញុំបានទទួល ហើយបានដកពិសោធន៍ពីសេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់របស់ទ្រង់ ។ ខ្ញុំដឹងថាសេចក្តីមេត្តាករុណារបស់ទ្រង់នឹងកើតមានចំពោះយើងទាំងអស់គ្នានៅពេលយើងជឿ និងអំពាវនាវដល់ព្រះនាមរបស់ទ្រង់ ។ ■



## សូមសម្លឹងទៅឯស្ថានសួគ៌

« ការសម្លឹងទៅឯស្ថានសួគ៌គួរតែជាការខិតខំដ៏យូរអង្វែងរបស់យើងពេញមួយជីវិត ។ មានមនុស្សឆ្កួតលីលាមួយចំនួនបែរខ្នងរបស់ខ្លួនចេញពីប្រាជ្ញារបស់ព្រះ និងធ្វើតាមការស្រើបស្រាលនៃសម័យកាលផ្លាស់ប្តូរការចាប់អារម្មណ៍ទៅលើប្រជាប្រិយភាពក្លែងក្លាយ និងភាពរំភើបតែមួយភ្លែត ។ ទង្វើរបស់ពួកគេដូចជាបទពិសោធន៍ដ៏មហន្តរាយរបស់អេសាវ ដែលបានប្តូរអំណាចមរតករបស់ខ្លួនជាមួយនឹងសម្លមួយចាន ។

« ចុះតើអ្វីទៅជាលទ្ធផលនៃទង្វើបែបនោះ ? ខ្ញុំ សូមថ្លែងទីបន្ទាល់ដល់អ្នករាល់គ្នានៅថ្ងៃនេះថា ការបែរចេញពីព្រះនឹងនាំមកនូវការផ្តាច់សេចក្តីសញ្ញា វិលាយក្តីសុបិន និងបំផ្លាញសេចក្តីសង្ឃឹមទាំងឡាយ ។ ខ្ញុំសូមអង្វរអ្នកឱ្យជៀសចេញពីភក់ជ្រៅនៃខ្សាច់ផុងមួយបែបនេះ ។ អ្នកមានទូវអំណាចមរតកបងច្បងដ៏ថ្លៃថ្លាមួយ ។ ជីវិតដ៏នៅអស់កល្បជានិច្ចក្នុងនគររបស់ព្រះវរបិតាយើងគឺជាគោលដៅរបស់អ្នក ។

« គោលដៅបែបនោះពុំអាចសម្រេចទៅបាននៅក្នុងការខិតខំដ៏រុងរឿងមួយតែមួយនោះទេ ប៉ុន្តែវាជាលទ្ធផលនៃសេចក្តីសុចរិតពេញមួយជីវិត ការបង្កើននៃការជ្រើសរើសដ៏ឈ្លាសវៃ ព្រមទាំងភាពខ្ជាប់ខ្ជួននៃគោលបំណង និងឧត្តមគតិដ៏ខ្ពង់ខ្ពស់ផងដែរ ។

« ដោយស្ថិតនៅក្នុងភាពច្របូកច្របល់នៃសម័យកាលរបស់យើង ទំនាស់នៃសតិសម្បជញ្ញៈ និងភាពចលាចលនៃជីវិត ប្រចាំថ្ងៃ សេចក្តីជំនឿដ៏ខ្ជាប់ខ្ជួនមួយបានក្លាយទៅជាយុថ្កាមួយសម្រាប់ជីវិតរបស់យើង » ។

President Thomas S. Monson, « Guideposts for Life's Journey » (Brigham Young University devotional address ថ្ងៃទី 13 ខែ វិច្ឆិកា ឆ្នាំ 2007) ទំព័រ 3 speeches.byu.edu ។



ទៅកាន់ **គោលដៅ**



## ហេតុអ្វីបានជាមានការដាក់សម្ពាធយ៉ាងខ្លាំងឱ្យយុវជនទាំងឡាយត្រូវចេញបេសកកម្ម? តើវាពុំមែនជាការសម្រេចចិត្តផ្ទាល់ខ្លួនទេឬ?

ការសម្រេចចិត្តផ្ទាល់ខ្លួនដែលយុវជនម្នាក់ៗត្រូវតែធ្វើនោះគឺប្រសិនបើគាត់នឹងបំពេញ ឬមិនបំពេញកាតព្វកិច្ចបព្វជិតភាពរបស់គាត់ដើម្បីបម្រើបេសកកម្មរបស់ខ្លួន ឬអត់។ ដូចដែលប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា ៖ « គ្រប់យុវជនដែលមានភាពស័ក្តិសម និងមានលទ្ធភាពគួរតែរៀបចំខ្លួនដើម្បីបម្រើបេសកកម្ម ។ ការបម្រើជាអ្នកផ្សព្វផ្សាយសាសនាគឺជាកាតព្វកិច្ចរបស់បព្វជិតភាព—ជាកាតព្វកិច្ចដែលព្រះអម្ចាស់រំពឹងចង់បានពីយើង ជាអ្នកដែលត្រូវបានប្រទានឱ្យនូវអ្វីៗជាច្រើន ។ យុវជនទាំងឡាយ ខ្ញុំសូមដាស់តឿនអ្នកឱ្យរៀបចំខ្លួនបម្រើជាអ្នកផ្សព្វផ្សាយសាសនា » ( « ខណៈយើងជួបគ្នាម្ដងទៀត » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 5–6) ។

ការរៀបចំខ្លួនចេញបេសកកម្មគឺជាផ្នែកមួយនៃបទពិសោធន៍របស់យុវជនដែលកាន់បព្វជិតភាពអើរ៉ុន ។ វាគឺជាកាតព្វកិច្ចរបស់គាត់ ហើយគាត់គួរតែមានអារម្មណ៍ការទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់គាត់នោះ ។ ពិតណាស់ គាត់ពុំគួរបម្រើបេសកកម្មដោយសារតែវាត្រូវបានរំពឹងទុក ឬដោយសារគាត់មានអារម្មណ៍ថាជាសម្ពាធនោះឡើយ គាត់គួរតែបម្រើដោយសារគាត់មានមានបំណងប្រាថ្នាដើម្បីចែកចាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ជាមួយនឹងអ្នកដទៃ ។

ប៉ុន្តែនៅពេលគាត់អធិស្ឋានអំពីការបម្រើបេសកកម្មមួយ គាត់គួរតែចងចាំផងដែរថាដោយការទទួលបព្វជិតភាព គាត់បានទទួលនូវការទទួលខុសត្រូវដ៏ពិសិដ្ឋនោះរួចទៅហើយដើម្បី « ព្រមាន, ពន្យល់ ទូន្មាន និងបង្រៀន ហើយអញ្ជើញមនុស្សទាំងអស់ឱ្យមករកព្រះគ្រីស្ទ » (គ. និង ស. 20:59) ដោយរួមបញ្ចូលទាំងការបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងផងដែរ ។ ប្រសិនបើយុវជនទាំងឡាយពុំអាចបម្រើបានដោយសារតែសុខភាពទន់ខ្សោយ ឬពិការភាព ពួកគេត្រូវបានលើកលែងដោយការគោរព ។ ■



## តើមានទេវតាការពារមែនឬ? តើខ្ញុំមានទេវតាមួយអង្គដែលបានចាត់ឱ្យមកការពារខ្ញុំដែរឬទេ ?

ពាក្យថា « ទេវតាការពារ » គឺមិនត្រូវបានប្រើនៅក្នុងព្រះគម្ពីរទាំងឡាយនោះទេ ផ្ទុយទៅវិញ ពួកទេវតាត្រូវបានលើកឡើងថាជា « ការបម្រើ » ( សូមមើល អេាមណៃ 1:25 មរ៉ូណៃ 7:22–29) ។ « ពួកទេវតានិយាយដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ » នីហ្វៃទី 2 32:3) ហើយជារឿយៗចូលរួមចំណែកនៅក្នុងបេសកកម្មរបស់ព្រះវិញ្ញាណបរិសុទ្ធ ដើម្បីលួងលោម ដឹកនាំ ការពារអ្នកស្មោះត្រង់ និងបើកបង្ហាញ ឬបញ្ជាក់ពីសេចក្ដីពិត ។ ហេតុដូច្នេះហើយ ព្រះវិញ្ញាណបរិសុទ្ធផ្ទាល់អាចត្រូវបានចាត់ទុកថាជាទេវតាការពារផងដែរ ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « ចាប់តាំងពីការចាប់ផ្ដើមរហូតមកដល់គ្រប់ការកាន់កាប់ត្រួតត្រាទាំងអស់ព្រះបានប្រើពួកទេវតា... នៅក្នុងបង្ហាញសេចក្ដីស្រឡាញ់ និងការខ្វល់ខ្វាយចំពោះកូនចៅរបស់ទ្រង់ ។ ... ទោះឃើញឬមិនឃើញពួកទ្រង់*តែងតែ*នៅក្បែរ » (« The Ministry of Angels » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2008 ទំព័រ 29) ។

ព្រះអម្ចាស់ពុំទាន់បានបើកសម្ដែងប្រសិនបើមានទេវតាដ៏ជាក់លាក់មួយអង្គត្រូវបានចាត់ឱ្យថែរក្សាមនុស្សម្នាក់នៅឡើយទេ ប៉ុន្តែអ្នកអាចត្រូវបានបញ្ជាក់ថាមាននូវការពារដ៏ទេវភាព និងការលួងលោម ។ ប្រសិនបើអ្នកអនុវត្តសេចក្ដីជំនឿ អ្នកនឹងមានជំនួយមកពីព្រះ រួមទាំងពួកទេវតាដែលបានចាត់មកដើម្បីពង្រឹង និងលួងលោមអ្នក ព្រមទាំងប្រទានដល់អ្នកនូវភាពក្លាហានដើម្បីធ្វើអ្វីដែលត្រឹមត្រូវ។ ■

## តើសាសនាចក្រមានឥរិយាបថយ៉ាងណាដែរចំពោះមនុស្សដែលប្រតិព័ទ្ធមនុស្សភេទដូចគ្នា ? តើការសេពគប់នឹងមនុស្សដែលមានអារម្មណ៍ប្រតិព័ទ្ធលើមនុស្សមានភេទដូចគ្នាវាមិនជាអ្វីទេមែនទេ?

សាសនាចក្រប្រឆាំងនឹងអាកប្បកិរិយាប្រតិព័ទ្ធមែនុស្សមានភេទដូចគ្នា ហើយយើងចាំជួយដោយការយល់ដឹង និងការគោរពចំពោះមនុស្សដែលមានចំណាប់អារម្មណ៍លើភេទដូចគ្នា។

ប្រសិនបើអ្នកស្គាល់មនុស្សដែលមានចំណាប់អារម្មណ៍លើភេទដូចគ្នា សូមធ្វើតាមគោលការណ៍ដូចគ្នាដែលអ្នកធ្វើនៅក្នុងមិត្តភាពផ្សេងទៀតរបស់អ្នក ៖ « ចូរជ្រើសរើសមិត្តភ័ក្ដិរបស់អ្នកដោយប្រុងប្រយ័ត្ន ។ ពួកគេនឹងមានឥទ្ធិពលដ៏ក្រៃលែងមកលើការគិត និងការប្រព្រឹត្តរបស់អ្នក ហើយថែមទាំងជួយកំណត់ឱ្យអ្នកក្លាយទៅជាមនុស្សម្នាក់ផ្សេងទៀតផង ។ ចូរជ្រើសរើសមិត្តភ័ក្ដិណាដែលឱ្យតម្លៃអ្នកដើម្បីអ្នកអាចពង្រឹង និងលើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងការរស់នៅតាមមាត្រដ្ឋានដ៏ខ្ពង់ខ្ពស់ ។ មិត្តពិតប្រាកដតែងជម្រុញអ្នកឱ្យកាន់តែល្អឡើង ។ ... ចូរប្រព្រឹត្តខ្លួនជាមួយមនុស្សគ្រប់គ្នាប្រកបដោយសន្ដានចិត្ត និងការគោរព » (*ដើម្បីកម្លាំងនៃយុវជន* [ កូនសៀវភៅ ឆ្នាំ 2001 ] ទំព័រ 12) ។

សាសនាចក្របង្រៀនថាទំនាក់ទំនងខាងផ្លូវភេទរបស់មនុស្សមាននូវគោលបំណងមួយនៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌ ។ ដើម្បីឱ្យយើងមានភាពសប្បាយរីករាយ និងបំពេញតាមគោលបំណងនោះ យើងត្រូវបានបញ្ជាឱ្យរស់នៅតាមច្បាប់ព្រហ្មចារីយ៍ភាព។ អាកប្បកិរិយាប្រតិព័ទ្ធលើមនុស្សមានភេទដូចគ្នាគឺផ្ទុយទៅនឹងគោលបំណងនោះ ហើយវាបំពានល្មើសទៅនឹងបញ្ញត្តិរបស់ព្រះ។

ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមាននរណាម្នាក់មានចំណាប់អារម្មណ៍លើមនុស្សដែលមានភេទដូចគ្នា ហើយពុំប្រព្រឹត្តតាមអារម្មណ៍ទាំងនោះទេ បុគ្គលនោះពុំបានប្រព្រឹត្តបាបទេ ។ បទដ្ឋានរបស់សាសនាចក្រសម្រាប់សីលធម៌គឺដូចគ្នាចំពោះមនុស្សគ្រប់រូប ពុំថាភេទមួយណាដែលមនុស្សម្នាក់មានចំណាប់អារម្មណ៍ទៅលើនោះទេ ។ មិនថាព្រះអម្ចាស់ ឬសាសនាចក្ររបស់ទ្រង់គឺពុំអាចលើកលែងឱ្យអាកប្បកិរិយាដែលល្មើសនឹងក្រិតវិន័យរបស់ទ្រង់ឡើយ ។ ជាថ្មីម្ដងទៀត យើងថ្កោលទោសដល់អាកប្បកិរិយាអសីលធម៌ ពុំមែនមនុស្សនោះទេ ។ ■

*ចំពោះព័ត៌មានបន្ថែមអំពីប្រធានបទនេះ សូមអាន Elder Jeffrey R. Holland, « Helping Those Who Struggle with Same-Gender Attraction »* Liahona, *ខែ តុលា ឆ្នាំ 2007 ទំព័រ 40 ។*

រចនារូបថតដោយ រ៉ូប៊ឺត ខាសី ពិណ្ណាទេញ្ញពី *BLESSED ART THOU AMONG WOMEN* ដោយ វលធើរ រេន © IRI



**ដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# ការរក្សាតាមសេចក្ដីសញ្ញានានា

## សារលិខិតផ្ញើដល់អ្នកទាំងឡាយណាដែលនឹងបម្រើបេសកកម្ម



គន្លឹះនៃការធ្វើកិច្ចការនេះ គឺជាការរក្សាសេចក្ដីសញ្ញានានា ។ គ្មានវិធីណាផ្សេងទៀតដែលយើងអាចប្រកាសប្រាប់ និងបង្ហាញនូវអំណាចនៃ ព្រះបាននោះទេ ។

ខ្ញុំនឹងនិយាយទៅកាន់អ្នកអំពីការរក្សាសេចក្ដីសញ្ញាដ៏មានសារៈសំខាន់បំផុត—ខ្ញុំរក្សាសេចក្ដីសញ្ញា នានារបស់ខ្ញុំ ហើយអ្នករក្សាសេចក្ដីសញ្ញារបស់អ្នក ។ នេះគឺជាប្រធានបទមួយដែលធំជាងការពិភាក្សាអំពីការគោរពប្រតិបត្តិទៅទៀត ទោះជាការគោរពប្រតិបត្តិគឺជាផ្នែកមួយនៃការរក្សាសេចក្ដីសញ្ញាយ៉ាងពិតប្រាកដក្ដី ។ ហើយវាគឺជាប្រធានបទមួយដែលមានលក្ខណៈផ្ទាល់ខ្លួន។

ពេលខ្លះវាគឺជារឿងដែលធម្មតាបំផុតដែលយើងអាចពិភាក្សានៅក្នុងផែនការនៃដំណឹងល្អ ពីព្រោះមានតែអ្នកធ្វើសេចក្ដីសញ្ញា និងអ្នករក្សាសេចក្ដីសញ្ញាប៉ុណ្ណោះ ដែលអាចប្រកាសយកពរជ័យទាំងឡាយនៃ នគរសេឡេស្ទាលបាន ។ ជាការពិតណាស់ នៅពេលដែលយើងនិយាយអំពីការរក្សាសេចក្ដីសញ្ញា នោះយើងនិយាយអំពីគោលបំណងនៃដួងចិត្ត និងព្រលឹង របស់យើងនៅក្នុងជីវិតរមែងស្លាប់នេះ ។

### ស្ថាបនាព្រះនគរដោយធ្វើសេចក្ដីសញ្ញាមួយម្ដងៗ

សេចក្ដីសញ្ញាមួយគឺជាចំណងកិច្ចសន្យាខាងវិញ្ញាណ ជាសេចក្ដីសន្យាដ៏មោះមុតចំពោះព្រះជាព្រះវរបិតារបស់យើងថា

យើងនឹងរស់នៅ ហើយគិត និង ប្រព្រឹត្តតាមរបៀបដ៏ជាក់លាក់ណាមួយ—ជារបៀបនៃព្រះរាជបុត្រារបស់ទ្រង់ ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ ជាការតបស្នង ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធសន្យានឹងយើងនូវជីវិតដ៏អស់កល្បជានិច្ចដែលមានភាពរុងរឿងយ៉ាងពេញលេញ ។

វាជារឿងគួរឱ្យចាប់អារម្មណ៍ណាស់ចំពោះខ្ញុំ ដែលសេចក្ដីសញ្ញាទាំងឡាយគឺត្រូវបានធ្វើឡើងដោយ ផ្ទាល់ខ្លួន និងជាលក្ខណៈបុគ្គល។ គឺមាននូវសេចក្ដីសញ្ញាមួយនៅគ្រានៃការធ្វើពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ដែលធ្វើឱ្យយើងចាប់ផ្ដើមទៅលើផ្លូវដែលនាំទៅរកជីវិតដ៏អស់កល្បជានិច្ច ។ ពិធីបរិសុទ្ធទាំងនោះគឺត្រូវបានធ្វើឡើងសម្រាប់បុគ្គលម្នាក់ៗ ម្នាក់ម្ដងៗ មិនថាតើមានចំនួនមនុស្សប៉ុន្មាននាក់ នឹងទទួលពិធីបរិសុទ្ធទាំងនោះឡើយ ។

គឺមាននូវសេចក្ដីសញ្ញាមួយនៅពេលដែលបុរសទទួលបព្វជិតភាព ។ ការប្រគល់ឱ្យនេះគឺតែងតែត្រូវបានផ្ដល់ឱ្យដល់បុគ្គលម្នាក់ម្ដងៗ ។

សេចក្ដីសញ្ញាដ៏ខ្ពស់បំផុតដែលយើងអាចធ្វើគឺនៅក្នុងព្រះវិហារបរិសុទ្ធ ។ ទីនោះហើយជាកន្លែងដែលយើងធ្វើសេចក្ដីសញ្ញាដ៏មោះមុតបំផុតរបស់យើងចំពោះព្រះវរបិតាសួគ៌ ហើយជាកន្លែងដែលទ្រង់បើកបង្ហាញដល់យើងនូវអត្ថន័យពេញលេញដ៏ពិតប្រាកដនៃសេចក្ដីសន្យារបស់ទ្រង់ចំពោះយើង ។ ជាថ្មីម្ដងទៀត ទាំងនេះគឺជាបទពិសោធន៍ផ្ទាល់ខ្លួន ទោះជាយើងទៅព្រះវិហារបរិសុទ្ធដើម្បីផ្សាភ្ជាប់ទៅនឹងបុគ្គលផ្សេងទៀតក្ដី ។

នោះហើយគឺជារបៀបដែលនគរនៃព្រះត្រូវបានស្ថាបនាឡើងដោយមនុស្សម្ដងម្នាក់ៗ— ធ្វើសេចក្ដីសញ្ញា ម្ដងមួយៗ រាល់ផ្លូវទាំងអស់នៅក្នុងដំណើរនៃជីវិតរមែងស្លាប់របស់យើង នាំឆ្ពោះទៅរកសេចក្ដីសញ្ញាចុងក្រោយនៃព្រះវិហារដ៏បរិសុទ្ធ ។

## តួនាទីនៃសេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធ

វាជារឿងដ៏សំខាន់សម្រាប់អ្នកដើម្បីយល់ថា ការទៅព្រះវិហារបរិសុទ្ធដើម្បីទទួលអំណោយទានពិសិដ្ឋផ្ទាល់ខ្លួនរបស់អ្នក ដោយរួមទាំងពិធីបរិសុទ្ធដ៏វិសេសវិសាលទាំងឡាយ ដែលរៀបចំអ្នកដើម្បីទទួលអំណោយទានពិសិដ្ឋនោះ គឺជាផ្នែកដ៏សំខាន់នៃការរៀបចំបេសកកម្មរបស់អ្នក និងការប្ដេជ្ញាចិត្តក្នុងបេសកកម្មរបស់អ្នក ។

នៅពេលដែលអ្នកទៅព្រះវិហារបរិសុទ្ធ នោះអ្នកនឹងចាប់ផ្ដើមយល់នូវសារៈសំខាន់នៃពិធីបរិសុទ្ធទាំងឡាយនៃព្រះវិហារបរិសុទ្ធ ទំនាក់ទំនងដែលមិនអាចកែប្រែបានរវាងអំណោយទានពិសិដ្ឋរបស់អ្នក និងជោគជ័យនៃកិច្ចការផ្សព្វផ្សាយសាសនារបស់អ្នក ។

ជាការពិតណាស់ ពាក្យថា*អំណោយទានពិសិដ្ឋ* បង្ហាញនូវខ្លឹមសារនៃទំនាក់ទំនងដ៏សំខាន់នោះ ។ អំណោយទានពិសិដ្ឋគឺជាអំណោយ ។ អំណោយទានពិសិដ្ឋគឺមានឫសពាក្យដូចគ្នានឹង *ចំណងដៃ* ដែលជាអំណោយពិសេសដែលគូស្វាមីភរិយាថ្មីចាប់ផ្ដើមនូវជីវិតដ៏នៅអស់កល្បជានិច្ចរបស់ពួកគេ ។ កាលដែលខ្ញុំធ្វើជាប្រធានសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ខ្ញុំបានចំណាយពេលវេលាមួយចំនួន ដើម្បីព្យាយាមបង្កើតមូលនិធិរបស់សាកលវិទ្យាល័យ មូលនិធិនោះគឺជាអំណោយដែលផ្ដល់ឱ្យដោយពួកអ្នកបរិច្ចាកដ៏សប្បុរស ។

នោះហើយគឺជាអ្វីដែលព្រះបានប្រទានដល់យើងគ្រប់ពេល





រូបថតដោយ គ្រីស្ទីណា ស្មីធ និង ម៉ាថាយ រៀរ

ដែលយើងធ្វើសេចក្ដីសញ្ញាជាមួយទ្រង់ ។ ទ្រង់ប្រទាន*អំណោយ*ឱ្យយើង ។ យើងសន្យាថានឹងធ្វើកិច្ចការជាក់លាក់មួយចំនួនស្រប ទៅតាមពិធីបរិសុទ្ធ ហើយទ្រង់សន្យាថានឹងប្រទានអំណោយដ៏ពិសេស ដើម្បីជាការតបស្នងមកវិញ—ជាអំណោយទានដ៏វិសេស អំណោយទានដែលមិនអាចកាត់ថ្លៃបាន អំណោយដែលមិនអាចប្រៀបបានឡើយ ។ ដូច្នេះខ្ញុំនិយាយទៅកាន់អ្នកដូចជាខ្ញុំនិយាយទៅកាន់ខ្លួនឯងថា—ប្រសិនយើងពិតជាចង់ទទួលបានជោគជ័យនៅក្នុងការហៅទាំងឡាយរបស់យើង ប្រសិនបើយើងចង់ទទួលបានរាល់ជំនួយ និងរាល់ប្រយោជន៍ ហើយរាល់ពរជ័យមកពីព្រះវរបិតា ប្រសិនបើយើងចង់ឱ្យទ្វារនៃស្ថានសួគ៌បើកចំហរចំពោះយើង ដើម្បីឱ្យយើងអាចទទួលអំណាចនៃព្រះ នោះយើងត្រូវតែរក្សាសេចក្ដីសញ្ញាទាំងឡាយរបស់យើង !

អ្នកដឹងហើយថា អ្នកមិនអាចធ្វើកិច្ចការនេះតែម្នាក់ឯងបានទេ ។ យើងត្រូវការជំនួយពីស្ថានសួគ៌ យើងត្រូវតែមាននូវ*អំណោយទានទាំងឡាយ* មកពីព្រះ ។ ទ្រង់បានបង្រៀនអំពីកិច្ចការនេះចាប់ តាំងពីគ្រាដំបូងនៃកិច្ចការនៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះមកម្ល៉េះ ។ នៅក្នុងការបង្រៀនពី « ការប្រោសលោះនៃស៊ីយ៉ូន » ព្រះអម្ចាស់បានមានបន្ទូលថា ៖

> « ដើម្បីឱ្យខ្លួនគេអាចបានរៀបចំជាស្រេច ហើយដើម្បីឱ្យរាស្ត្រយើងអាចត្រូវបានបង្រៀនឱ្យបានល្អឥតខ្ចោះទៅទៀត ហើយមានការពិសោធន៍ ហើយចេះដឹងបានយ៉ាងល្អឥតខ្ចោះអំពីកាតព្វកិច្ចរបស់ពួកគេ និងអ្វីៗដែលយើងតម្រូវឱ្យធ្វើពីស្នាដៃរបស់ឱ្យពួកគេ ។
>
> « ហើយកិច្ចការនេះពុំអាចបានកន្លងផុតទៅឡើយ រហូតដល់ពួក អែលឌើរ របស់យើងបានទទួលអំណាចពីស្ថានខ្ពស់ ។
>
> « ត្បិតមើលចុះ យើងបានរៀបចំអំណោយទានពិសិដ្ឋ និងព្រះពរដ៏មហិមាមួយទុក ដើម្បីចាក់មកលើពួកគេ ដរាបណាពួកគេមានចិត្តស្មោះត្រង់ ហើយនៅក្នុងភាពរាបទាបនៅចំពោះយើងតទៅ » ( គ. និង ស. 105:10–12 ) ។

កិច្ចការនេះគឺជាកិច្ចការដ៏សំខាន់ ហើយ ការប្រឆាំងរបស់មាសត្រូវចំពោះកិច្ចការនេះក៏ខ្លាំងក្លាណាស់ដែរ ដែលធ្វើឱ្យយើងត្រូវការអំណាចដ៏ទេវភាពដើម្បីជួយដល់កិច្ចប្រឹងប្រែងរបស់យើង ហើយជំរុញសាសនាចក្រទៅមុខដោយមិនផ្លាស់ប្ដូរ ។ គន្លឹះចំពោះកិច្ចការនោះសម្រាប់យើងម្នាក់ៗគឺជាសេចក្ដីសញ្ញាដែលយើងធ្វើនៅក្នុងព្រះវិហារបរិសុទ្ធ សេចក្ដីសន្យារបស់យើងដើម្បីគោរព និងលះបង់ ដើម្បីថ្វាយដល់ព្រះវរបិតា និងសេចក្ដីសន្យារបស់ទ្រង់ដើម្បីប្រទានដល់យើងនូវ « អំណោយទានពិសិដ្ឋដ៏មហិមា » ។

## សេចក្ដីសញ្ញាទាំងឡាយ និងកិច្ចការរបស់ព្រះអម្ចាស់

តើកិច្ចការនេះ ជួយអ្នកឱ្យមើលឃើញអំពីរបៀបដែលការសន្យាដ៏សំខាន់ផ្ទាល់ខ្លួនរបស់យើងម្នាក់ៗគឺជាទំហំ និង ភាពធ្ងុំផ្ដើងនៃកិច្ចការទាំងមូលដែរឬទេ? កិច្ចការផ្សព្វផ្សាយសាសនាក៏ដូចជាអ្វីៗផ្សេងទៀតនៅក្នុងផែនការនៃសេចក្ដីសង្គ្រោះផងដែរ ជោគជ័យដែលពួកអែលឌើរ និងពួកស៊ីស្ទើរនៅទូទាំងពិភពលោកទទួលបានគឺត្រូវបានធ្វើឡើងដោយការប្ដេជ្ញាចិត្តពីអ្នកផ្សព្វផ្សាយសាសនាម្នាក់ម្ដងៗ ។

យើងមិនធ្វើសេចក្ដីសញ្ញាជារួជ ឬស្ដេកទាំងមូលនោះទេ ។ មិនមែនទាំងអស់គ្នាទេ គឺយើងធ្វើសេចក្ដីសញ្ញាក្នុងនាមជាបងប្រុសប្រោន ឬបងប្រុស ប៊ីន ក្នុងនាមជាស៊ីស្ទើរ ជូនស៍ ឬស៊ីស្ទើរ ជេនសិន ។ គន្លឹះចំពោះកិច្ចការនេះគឺជាការរក្សានូវសេចក្ដីសញ្ញាទាំងឡាយជាលក្ខណៈបុគ្គលផ្ទាល់ ។

ខ្ញុំមិនដឹងថាអ្នកនឹងបម្រើបេសកកម្មនៅទីណានោះទេ ប៉ុន្តែខ្ញុំមិនជឿថាព្រះវរបិតាសួគ៌បានធ្វើសេចក្ដីសន្យាជាក់លាក់ណាមួយចំពោះបេសកកម្មរបស់អ្នក សំរាប់បេសកកម្មទាំងមូលនោះទេ ។ ខ្ញុំពិតជាដឹងថា ទ្រង់បានធ្វើនូវសេចក្ដីសន្យាដ៏មហិមាចំពោះអ្នករាល់គ្នាផ្ទាល់ ។

គឺនៅពេលដែលបេសកកម្មទាំងមូលត្រូវបានរួបរួមដោយកម្លាំងនៃសេចក្ដីសុចរិតរបស់អ្នកផ្សព្វផ្សាយសាសនាម្នាក់ៗ រក្សាសេចក្ដីសញ្ញាផ្ទាល់ខ្លួនរបស់អ្នកផ្សព្វផ្សាយសាសនាម្នាក់ៗ ពេលនោះហើយដែលយើងអាចរំកិលភ្នំទាំងឡាយបាន ។ នៅពេលដែលមាននូវការរួបរួម និងអំណាចបែបនេះ នោះអំណោយទានពិសិដ្ឋមក



ពីស្ថានសួគ៌ នឹងបានប្រទានមកដល់បុគ្គលម្នាក់ៗនៅក្នុងបេកកម្ម ដែលគ្មានអ្វីអាច « បញ្ឈប់ការងារមិនឱ្យរីកចម្រើនទៅមុខបានទេ » ។ តាមរបៀបនេះហើយ ដែល « សេចក្ដីពិតនៃព្រះនឹងទៅមុខដោយមោះមុត ដោយគុណធម៌ និងដោយឯករាជ្យ » ។ [1]

យើងមានទូវទំនុកចិត្ត នៅពេលដែលពុំមានកងទ័ពខ្សោយណាមួយក្នុងប្រវ៉ាក់ ឬក៏ពុំមានទូវស្នាមប្រេះទន់ខ្សោយណាមួយនៅលើអាវក្រោះនោះ។ សង្គ្រាមប្រឆាំងនឹងអំពើអាក្រក់ និងកំហុសឆ្គង គឺជាវិធីដែលគ្រប់ដំណឹងល្អទទួលបាន ជ័យជំនះ—គឺសម្រេចបានដោយការធ្វើសេចក្ដីសញ្ញាម្ដងមួយៗ ម្នាក់ម្ដងៗ ជាមួយអ្នកផ្សព្វផ្សាយសាសនាម្នាក់ម្ដងៗ ។

នោះហើយជាមូលហេតុដែលព្រះអម្ចាស់បានមានបន្ទូលទៅកាន់ពួកដឹកនាំសាសនាចក្រនៅសម័យដើមថា « អ្នករាល់គ្នានឹងត្រូវចងខ្លួន ដើម្បីប្រព្រឹត្តក្នុងបរិសុទ្ធភាពគ្រប់យ៉ាងនៅចំពោះយើង—ព្រោះដរាបណាអ្នករាល់គ្នាធ្វើត្រឹមការណ៍នេះ នោះសិរីល្អនឹងត្រូវបានបន្ថែមទៅនឹងនគរដែលអ្នករាល់គ្នាបានទទួល » ( គ. និង ស. 43:910 ) ។

នោះហើយគឺជាភាសានៃសេចក្ដីសញ្ញា ។ នោះគឺជាមូលហេតុត្រឹមត្រូវដែលយើងទៅព្រះវិហារបរិសុទ្ធដើម្បីធ្វើ—ដើម្បីចងភ្ជាប់ខ្លួនរបស់យើងទៅព្រះអម្ចាស់ និងចំពោះគ្នាទៅវិញទៅមក ហើយដោយកម្លាំងនោះ បន្ទាប់មក « ប្រព្រឹត្តក្នុងបរិសុទ្ធភាពគ្រប់យ៉ាង » ។ ជាការតបស្នង នោះព្រះចេស្ដា និងសិរីរុងរឿងនឹង បានមកលើយើង និងលើកិច្ចការរបស់យើង ។ វាមានតម្លៃខ្លាំងណាស់ចំពោះបរិបទនៃការរក្សាសញ្ញានោះ ព្រះអម្ចាស់មានបន្ទូលថា « យើងជាព្រះ អម្ចាស់ជាប់សន្យា កាលណាអ្នករាល់គ្នាប្រព្រឹត្តិតាមអ្វីដែលយើងមានបន្ទូល ប៉ុន្តែកាលណាអ្នករាល់គ្នាមិនប្រព្រឹត្តិតាមអ្វីដែលយើងមានបន្ទូលទេ នោះអ្នករាល់គ្នាពុំមានសេចក្ដីសន្យាឡើយ » ( គ. និង ស. 82:10 ) ។

ទុកចិត្តលើយើង ។ គន្លឹះនៃកិច្ចការនេះគឺការរក្សាសេចក្ដីសញ្ញារបស់យើង ។ គ្មានវិធីណាផ្សេងទៀតដែលយើងអាចប្រកាសប្រាប់ និងបង្ហាញនូវអំណាចនៃ ព្រះនោះទេ ។ អ្នកមានព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីប្រធានបទនោះ ។

អ្នកនឹងទៅព្រះវិហារបរិសុទ្ធដើម្បីរៀបចំខ្លួនរបស់អ្នកសម្រាប់បេកកម្មរបស់អ្នក ។ សូមរក្សាសេចក្ដីសញ្ញារបស់អ្នកដែលបានធ្វើនៅទីនោះ គឺធ្វើរាល់សេចក្ដីសញ្ញា ។ សេចក្ដីសញ្ញាដ៏ពិសិដ្ឋទាំងឡាយដែលយើងធ្វើជាមួយនឹងព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ គឺជាសេចក្ដីសញ្ញាសំរាប់បុគ្គលម្នាក់ៗ ។

## សេចក្ដីសញ្ញាដើម្បីថ្លែងទីបន្ទាល់

នៅពេលដែលយើងប្រាប់អ្នកឱ្យធ្វើកិច្ចការនេះ យើងចង់ឱ្យអ្នកដឹងថា យើងនឹងធ្វើដូចគ្នា ។ ខ្ញុំនឹងរក្សាសេចក្ដីសញ្ញារបស់ខ្ញុំផងដែរ ។ សេចក្ដីសញ្ញាមួយនៅក្នុងចំណោមសេចក្ដីសញ្ញាទាំងឡាយនោះ គឺការធ្វើជាសមាជិកម្នាក់នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ដែលជាសាក្សីពិសេសម្នាក់ « អំពីព្រះនាមនៃព្រះគ្រីស្ទនៅពេញសព្វក្នុងពិភពលោក » ( គ. និង ស. 107:23 ) ។ នៅក្នុងការរក្សាសេចក្ដីសញ្ញារបស់ខ្ញុំ ខ្ញុំមិនត្រឹមតែថ្លែងទីបន្ទាល់ចំពោះអ្នកនៅថ្ងៃនេះពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងការឆ្លងរបស់ទ្រង់នោះទេ គឺខ្ញុំធ្វើជាសាក្សី—ថែមទាំងត្រូវបានហៅ ត្រូវបានតែងតាំង បានអនុញ្ញាតឱ្យយកទីបន្ទាល់នោះទៅប្រាប់ដល់ពិភពលោកទៀតផង។ ឱ! យុវវ័យជាមិត្តដ៏ជាទីស្រឡាញ់ទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំរីករាយដើម្បីចូលរួមជាមួយអ្នកនៅក្នុងការបម្រើនោះ ។



ខ្ញុំដឹងថាព្រះនៅមានព្រះជន្មរស់ ថាទ្រង់គឺជាបិតារបស់យើងដែលគង់នៅស្ថានសួគ៌ពិតប្រាកដ ហើយថាទ្រង់នឹងរក្សាសេចក្ដីសញ្ញារបស់ទ្រង់ចំពោះយើងជារៀងរហូត ។ ខ្ញុំដឹងថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ជាព្រះរាជបុត្រសំណប់ខាងសាច់ឈាមតែមួយអង្គគត់នៃព្រះវរបិតា និងជាព្រះ សង្គ្រោះនៃពិភពលោក ។ ខ្ញុំដឹងថាទ្រង់បានទទួលរងការឈឺចាប់ ហូរព្រះលោហិត និងបានសុគតដើម្បីឱ្យយើងអាចមានជីវិតដ៏នៅអស់កល្បជានិច្ច ។

ខ្ញុំដឹងថាព្រះវរបិតា និងព្រះរាជបុត្រាបានយាងទៅជួបយុវជនគឺព្យាការីយ៉ូសែប ស្ម៊ីធ ជាព្យាការីដំបូង ដ៏អស្ចារ្យនៃគ្រាកាន់កាប់ត្រួតត្រានេះ ដែលលោកក៏បានបង្ហូរឈាមរបស់លោកទុកជាសក្ដីភាពនៃការហៅរបស់លោក ជានិមិត្តសញ្ញាដ៏សំខាន់នៃភាពស្មោះត្រង់របស់មនុស្សម្នាក់ចំពោះសេចក្ដីសញ្ញារបស់ខ្លួន ។ ខ្ញុំដឹងថាកូនសោព្យាការីទាំងឡាយត្រូវបានបញ្ជូនជាបន្តបន្ទាប់ ដែលមិនអាចកាត់ផ្ដាច់បាន ដល់បុរស 15 នាក់ទៀតរហូតមកដល់ពេលនេះ ពួកលោករស់នៅក្នុងការគ្រប់គ្រង និងបម្រើជាព្យាការី ដែលជាប្រធាន ថូម៉ាស អេស ម៉ុន សុន ជាសង្ឃជាន់ខ្ពស់ដែលជាអធិបតីរបស់ព្រះនៅលើផែនដីសព្វថ្ងៃនេះ ។

កិច្ចការនេះគឺជាការពិត ។ សេចក្ដីប្រកាសទាំងនេះគឺជាការពិត ។ ខ្ញុំស្គាល់ពួកលោកពុំដោយសារ បុរស ឬស្ត្រីដែលធ្លាប់រស់នៅក្នុងជីវិតរមែងស្លាប់នេះឡើយ ។ ខ្ញុំស្គាល់ពួកលោកដោយការបង្ហាញពីព្រះវិញ្ញាណបរិសុទ្ធ ដែលប្រទានការណែនាំដល់ជីវិតរបស់ខ្ញុំ និងផ្ដល់អត្ថន័យដល់ទីបន្ទាល់របស់ខ្ញុំ ហើយដែលបានបញ្ជូនខ្ញុំមក—ជាមួយអ្នក—ដើម្បីធ្វើជាសាក្សីពិសេសពីព្រះប្រោសលោះនៃពិភពលោក ។ ■

*ដកស្រង់ចេញពីសុន្ទរកថាចាក់ផ្សាយតាមផ្កាយរណប ស្ដីពីអ្នកផ្សព្វផ្សាយសាសនាកាលពីថ្ងៃទី 25 ខែ មេសា ឆ្នាំ 1997 ។*

**កំណត់ចំណាំ**

1. យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church* 4:540 ។





# យុវនារីទាំងឡាយ ចូរក្រោកឡើង ហើយបញ្ចាំងពន្លឺ !

**ដោយ គណៈប្រធានយុវនារីទូទៅ**

បាវចនារបស់មួយឆ្នាំនេះគឺជាការហៅអ្នកឱ្យធ្វើជាអ្នកដឹកនាំម្នាក់ ។ វាគឺជាការហៅមួយសម្រាប់អ្នកឱ្យដឹកនាំក្នុងភាពបរិសុទ្ធ ភាពសមរម្យ និងស្អាតស្អំ ។ វាគឺជាការហៅមួយឱ្យផ្លាស់ប្ដូរពិភពលោក !

នៅពេលដែលអ្នកក្លាយជាផ្នែកមួយនៃអង្គការយុវនារី នោះអ្នកត្រូវបានផ្ដល់ឱ្យនូវខ្សែកគុបភ្លើងពណ៌មាស និងពណ៌ស ដើម្បីពាក់ទុកជាការរំលឹកថា ក្នុងនាម ជាយុវនារីនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ អ្នកនឹងឈរសម្រាប់សេចក្ដីពិត និងសេចក្ដីសុចរិត ហើយក្រោកឈរឡើង ហើយទុកឱ្យពន្លឺរបស់អ្នកបញ្ចាំងពន្លឺចេញទៅក្នុងពិភពលោក ។ នោះមានន័យថា អ្នកនឹងឈរពិតចំពោះជោគវាសនាដ៏ទេវភាពរបស់អ្នក ជាបុត្រីដ៏មានតម្លៃរបស់ព្រះ ។ វាមានន័យថា អ្នកនឹងព្យាយាមឈរធ្វើជាសាក្សីដល់ព្រះអង្គសង្គ្រោះ « នៅគ្រប់ពេល និងគ្រប់សេចក្ដី និងគ្រប់ទីកន្លែង » ( ម៉ូសាយ 18:9 ) ។



យើងសង្ឃឹមថា នៅឆ្នាំនេះអ្នកនឹងពាក់ខ្សែកគប់ភ្លើងរបស់អ្នកដោយមោទនភាព ដើម្បីរំលឹកដល់ខ្លួនអ្នកថា អ្នកគឺជាគំរូចំពោះមនុស្សនៅជុំវិញខ្លួនអ្នក ។ អ្នកនឹង « បញ្ចាំងពន្លឺចេញទៅ » នៅពេលដែលអ្នក**អធិស្ឋាន**រៀងរាល់ថ្ងៃ **អាន** នៅក្នុងព្រះគម្ពីរមរមន **គោរពតាម**បទដ្ឋាននៅក្នុងសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* និង **ញញឹម** ។ យើងដឹងថា នៅពេលដែលអ្នករក្សាព្រះបញ្ញត្តិទាំងឡាយ ហើយរស់នៅតាមបទដ្ឋានដែលមាននៅក្នុងសៀវភៅ *ដើម្បីកម្លាំងនៃយុវវ័យ* អ្នកនឹងពោរពេញទៅដោយសេចក្ដីអំណរ និងមានគុណសម្បត្តិដើម្បីទទួលការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ។ ការដឹកនាំនេះនឹងធ្វើឱ្យយើងម្នាក់ៗធ្វើការជ្រើសរើសដែលនឹងជួយអ្នកឱ្យមានភាពសក្ដិសមដើម្បីទទួលប័ណ្ណចូលព្រះវិហារបរិសុទ្ធ ។

ក្នុងនាមជាគណៈប្រធានយុវនារីទូទៅ យើងសូមថ្លែងទីបន្ទាល់ថា កាលណាអ្នកធ្វើកិច្ចការទាំងនេះ នោះព្រះអង្គសង្គ្រោះនឹងគង់នៅទីកន្លែងនោះដើម្បីបំភ្លឺផ្លូវរបស់អ្នក ។ ទ្រង់សន្យាដល់អ្នកថា « យើងក៏ទៅជាពន្លឺរបស់អ្នករាល់គ្នា ... ហើយយើងនឹងរៀបចំផ្លូវសម្រាប់អ្នករាល់គ្នា បើសិនជាអ្នករាល់គ្នាកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង... ហើយអ្នករាល់គ្នានឹងដឹងថា គឺយើងនេះហើយដែលបាននាំអ្នករាល់គ្នាទៅ » ( នីហ្វៃទី1 17:13 ) ។ ■



## បាវចនាម៉្យូឆល 2012

*« ចូរក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅប្រយោជន៍ឱ្យពន្លឺរបស់អ្នកអាចបានទៅជាបមាណីយដល់សាសន៍នានា » ( គ. និង ស. 115:5 ) ។*





*ខាងលើ៖ អេលែន អេស ដាល់ថុន ( នៅកណ្ដាល ) ប្រធាន ម៉ារី អិន យុក( នៅខាងឆ្វេង ) ទីប្រឹក្សាទីមួយ និង អាន អិម ឌិប ( នៅខាងស្ដាំ ) ទីប្រឹក្សាទីពីរ ។ ខាងលើ៖ ដេវីឌ អិល យុក ( នៅកណ្ដាល ) ប្រធាន លែរី អិម ហ៊ីបបុន ( នៅខាងឆ្វេង ) ទីប្រឹក្សាទីមួយ និងអាល់ត្រាម អ្វូឆយ ( នៅខាងស្ដាំ ) ទីប្រឹក្សាទីពីរ ។*



# ធ្វើជាគំរូដែលបញ្ចាំងចេញទៅ

ដោយគណៈប្រធានយុវជនទូទៅ



យុវជនទាំងឡាយនៃសាសនាចក្រ—ឌីកុន គ្រូ និងសង្ឃនៃបព្វជិតភាពអើរ៉ុនដ៏វិសេស—អ្នកបានលើកដាក់លើខ្លួនអ្នកនូវព្រះនាមនៃព្រះអង្គសង្គ្រោះ អ្នកកាន់នូវបព្វជិតភាពដ៏បរិសុទ្ធរបស់ទ្រង់ អ្នកត្រូវបានហៅឲ្យធ្វើកិច្ចការរបស់ទ្រង់ ហើយប្រសិទ្ធិពរ ដល់អ្នកទាំងឡាយណាដែលស្គាល់អ្នក ។ ឥឡូវនេះគឺជាពេលសម្រាប់អ្នកដើម្បីបំពេញករណីយកិច្ចបព្វជិតភាពរបស់អ្នក ហើយ « បញ្ចាំងពន្លឺចេញទៅ » ទៅជា « បមាណីយដល់សាសន៍នានា » ( គ. និង ស. 115:5 ) ។

ឥឡូវនេះគឺជាពេលដើម្បី « ឲ្យពន្លឺរបស់អ្នករាល់គ្នាបានភ្លឺទៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អ ដែលអ្នករាល់គ្នាប្រព្រឹត្ត រួចសរសើរដំកើងដល់ព្រះវរបិតានៃអ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌ » ( ម៉ាថាយ 5:16 ) ។ ព្រះយេស៊ូវគឺជាគំរូដ៏ឥតខ្ចោះ ។ សូមព្យាយាមដើម្បីស្គាល់ទ្រង់ ធ្វើតាមទ្រង់ ហើយប្រែក្លាយកាន់តែដូចទ្រង់ តាមរយៈការគោរពបទបញ្ញត្តិរបស់ទ្រង់ និងការរក្សាបទដ្ឋានសាសនាចក្រ ដូចមានពិពណ៌នានៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ។ នៅពេលដែលអ្នកធ្វើដូច្នោះ អ្នកនឹងក្លាយជាកម្លាំងដែលបញ្ចាំងចេញទៅខាងវិញ្ញាណដល់អ្នកទាំងឡាយណាដែលទៅជុំវិញអ្នក ។

ព្រះអម្ចាស់បានមានបន្ទូលថា « ចូរអ្នករាល់គ្នាដែលកាន់ប្រដាប់ទាំងឡាយ នៃព្រះអម្ចាស់បានជ្រះស្អាតចុះ » ( គ. និង ស. 133:5 ) ។ ភាពស្អាតស្អំនៃសីលធម៌របស់អ្នកនឹងធ្វើឲ្យអ្នកបញ្ចាំងពន្លឺចេញទៅដោយមានពន្លឺពិសេសដល់សមាជិកវួដ ឬសាខារបស់អ្នក កាលណាអ្នកធ្វើជាតំណាងព្រះអម្ចាស់ដោយមានភាពសក្តិសមនៅក្នុងការបម្រើពិធីសាក្រម៉ង់ដ៏ពិសិដ្ឋដល់សមាជិករបស់អ្នកជារៀងរាល់សប្តាហ៍នោះ ។

សូមស្វែងរក និងចាប់យកឱកាសជារៀងរាល់ថ្ងៃដើម្បីបម្រើដល់ក្រុមគ្រួសារ មិត្តភក្តិ សមាជិកកូរ៉ុមរបស់អ្នក និងអ្នកដទៃទៀត ។ អ្នកនឹងក្លាយជាអ្នកបម្រើដែលមានចិត្តសប្បាយរីករាយនៃការបញ្ចេញពន្លឺដល់ពួកគេ និងដល់អ្នកទាំងឡាយណាដែលសង្កេតមើលអ្នកដោយស្ងប់ស្ងាត់ ។

បញ្ចាំងពន្លឺចេញទៅដោយចំណងមិត្តភក្តិដ៏ស្មោះស និងសណ្តានចិត្តល្អដល់មនុស្សទាំងអស់ ។ សូមចែកចាយនូវពរជ័យដ៏អស្ចារ្យពីសកម្មភាពទាំងឡាយរបស់សាសនាចក្រ និងការបង្រៀនដំណឹងល្អដល់មិត្តភក្តិរបស់អ្នក ។ សូមមានសេចក្តីក្លាហាន និងអញ្ជើញពួកគេឲ្យមករកពន្លឺ និងជីវិតនៃពិភពលោក—ដែលជាព្រះយេស៊ូវគ្រីស្ទ ។

យើងស្រឡាញ់អ្នក ។ យើងអធិស្ឋានសម្រាប់អ្នក ។ យើងសូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់ស្រឡាញ់អ្នក និងត្រូវការឲ្យអ្នកជួយស្ថាបនានគររបស់ទ្រង់ ។ ឥឡូវនេះគឺជាពេលសម្រាប់អ្នកដើម្បី « ក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ » ក្នុងនាមជាអ្នកកាន់បព្វជិតភាពដ៏បរិសុទ្ធរបស់ទ្រង់ ។ នៅពេលដែលអ្នកលើកដំកើងនូវបព្វជិតភាពនេះ និងបំពេញកាតព្វកិច្ចរបស់អ្នកចំពោះព្រះ នោះពន្លឺរបស់អ្នកនឹងក្លាយជា « បមាណីយដល់សាសន៍នានា » ។ ■





រចនារូបថតដោយ ម៉ាថាយ ឬ និងគ្រីស្ទីណា ស្មីធ ហើយនិងមេត្រូ ដាយអ៊ែ រូបថតរបស់គណៈប្រធានយុវជនទូទៅ © BUSATH PHOTOGRAPHY



# បញ្ចាំងពន្លឺចេញទៅ

យើងម្នាក់ៗមានទូវពន្លឺ ។ សូមចែកចាយនូវពន្លឺនោះ ។

( សូមមើល គ. និង ស. 115:5 ) ។

# គោលលទ្ធិ និង សេចក្ដីសញ្ញា 115:5។

*ព្រះអម្ចាស់បានដាក់បញ្ញត្តិឱ្យក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ ។*

**យើងប្រាប់អ្នកទាំងអស់គ្នា**

នៅក្នុងវិវរណៈនេះចាប់តាំងពីឆ្នាំ 1838 ព្រះអម្ចាស់បានប្រទានការណែនាំស្ដីអំពីការស្ថាបនាព្រះវិហារបរិសុទ្ធនៅហ្វារវេសត៍ រដ្ឋមិស្សួរី ក៏ដូចជាទីកន្លែងផ្សេងទៀតនៃការស្ថាបនាទីក្រុងស៊ីយ៉ូនផងដែរ ។ ទ្រង់ក៏បានប្រទានឈ្មោះនៃសាសនាចក្ររបស់ទ្រង់នៅក្នុងថ្ងៃចុងក្រោយថា ៖ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ តាមរយៈវិវរណៈនេះដែលបានថ្លែងទៅកាន់ពួកអ្នកដឹកនាំសាសនាចក្រទាំងឡាយនៃថ្ងៃចុងក្រោយនាថ្ងៃនោះ ដែលជាបទបញ្ញត្តិឱ្យ « ក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ » អនុវត្តចំពោះយើងទាំងអស់គ្នា ។

**ចូរក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ**

« ព្រះអម្ចាស់មានកិច្ចការដ៏មហិមាសម្រាប់យើងម្នាក់ៗធ្វើ ។



« ចូរក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ ប្រយោជន៍ឱ្យពន្លឺរបស់អ្នកអាចបានទៅជាបមាណិយដល់សាសន៍នានា » (គ. និង ស. 115:5) ។ ទ្រង់ទុកព្រះទ័យលើអ្នក ហើយទ្រង់ហៅ និងពឹងផ្អែកទៅលើអ្នកដើម្បីឱ្យមានជំហរកាន់តែខ្ពស់ និងមានពន្លឺកាន់តែភ្លឺ ចេញទៅនៅក្នុងឧបសគ្គទាំងនេះ ប៉ុន្តែនៅជាថ្ងៃដ៏អស្ចារ្យ » ។

**ប្រធាន ឌៀថើរ អែហ្វ. អុជដូហ្វ ជាទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ « សិទ្ធិរបស់អ្នកដើម្បីជ្រើសរើសត្រឹមត្រូវ » *New Era* ខែ សីហា ឆ្នាំ 2005 ទំព័រ 8 ។**

**ពន្លឺរបស់អ្នក**

តើអ្នកអាចបញ្ចាំងពន្លឺរបស់អ្នកចេញទៅយ៉ាងដូម្ដេច ? សូមធ្វើការពិចារណានូវគំនិតទាំងនេះ ហើយសរសេរចុះនូវគំនិតរបស់អ្នកមួយចំនួនចូលក្នុងសៀវភៅកំណត់ហេតុ ។

- មានសណ្ដានចិត្តល្អ សប្បុរស និងបន្ទាបខ្លួន ។
- ធ្វើជាតំណាង និងរស់នៅតាមបទដ្ឋាននៃសាសនាចក្រ ។
- សូមញញឹម និងបង្ហាញនូវសេចក្ដីអំណរនៃការរស់នៅតាមដំណឹងល្អ ។
- សូមចែកចាយដំណឹងល្អជាមួយនឹងមិត្តភក្តិរបស់អ្នក ។
- សូមថ្លែងទីបន្ទាល់របស់អ្នកអំពីសេចក្ដីពិត ។



៥ ប្រាកដមែន យើងប្រាប់អ្នកទាំងអស់គ្នាថា ចូរក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ ប្រយោជន៍ឲ្យពន្លឺរបស់អ្នកអាចបាន ទៅជាបមាណិយដល់សាសន៍នានា;

**សាសន៍នានា**



« នៅថ្ងៃនេះប្រជារាស្ត្ររបស់ព្រះអម្ចាស់កំពុងជួបជុំក្នុង « ចំណោមសាសន៍នានា ខណៈដែលពួកគេកំពុងតែជួបជុំគ្នានៅក្នុងរោងថ្វាយបង្គំ និងស្តេកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយដែលនៅពាសពេញសាសន៍នានា ។ ... ព្រះអម្ចាស់អំពាវនាវដល់អ្នកឱ្យធ្វើជាបង្គោលភ្លើងនៃសេចក្ដីសុចរិត ដើម្បីដឹកនាំដល់ជនទាំងឡាយណាដែលស្វែងរកសុវត្ថិភាព និងពរជ័យនៃស៊ីយ៉ូន » ។

**អែលឌើរ ឌី ថត គ្រីស្តហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « ចូរមកកាន់ស៊ីយ៉ូន » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2008 ទំព័រ 37 ។**

**បមាណិយ**

*បមាណិយ*—គឺជាកម្មវត្ថុ ជាធម្មតាគឺជាទង់ជ័យដែលចងជាប់នៅលើដង ហើយបានប្រើប្រាស់ដើម្បីជាសញ្ញានៃការជួបជុំ ឬជានិមិត្តសញ្ញា ។ សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 45:9។

« អ្នកកាន់បមាណិយ ដើរនាំមុខនៃបព្វហេតុដ៏



សក្តិសម ។ វាជាតំណាងឱ្យអ្វីដែលល្អ និងសមរម្យ ។ មនុស្សតែងតែលើកទង់ជាតិ ឬនិមិត្តសញ្ញាផ្សេងៗទៀត ដើម្បីបង្ហាញពីអត្តសញ្ញាណ គោលបំណង និងអង្គភាព ។ ...

« ក្នុងនាមជាអ្នកធ្វើតាមបមាណិយរបស់ទ្រង់ គឺយើងត្រូវជួយដល់ជនដែលមានចិត្តស្មោះត្រង់ឱ្យស្វែងរកព្រះយេស៊ូវ ។ យើងមិនត្រវីទង់ជាតិឡើង ។ ... ផ្ទុយទៅវិញ ក្នុងនាមជាអ្នកធ្វើតាម បមាណិយសម្រាប់ព្រះយេស៊ូវគ្រីស្ទ យើងមានឆន្ទះ និងមានអំណរគុណក្នុងការទទួលយកនូវនាមពិសិដ្ឋរបស់ទ្រង់មកលើខ្លួនយើង ។ យើងចូលរួមទៅក្នុងបព្វហេតុរបស់ទ្រង់តាមរយៈសេចក្ដីសញ្ញា » ។

**អែលឌើរ រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « បមាណិយរបស់អ្នកកាន់បមាណីនៃព្រះអម្ចាស់ » *Ensign* ខែ សីហា ឆ្នាំ 1991 ទំព័រ 7 ។**

*កំណត់ចំណាំរបស់អ្នកបោះពុម្ពផ្សាយ ៖ នៅទំព័រនេះពុំមែនមានន័យថាវាពន្យល់ដ៏ទូលំទូលាយពីខគម្ពីរដែលបានជ្រើសរើស វាគ្រាន់តែជាចំណុចការចាប់ផ្ដើមមួយសម្រាប់ការសិក្សាផ្ទាល់ខ្លួនរបស់អ្នកប៉ុណ្ណោះ ។*

# ព្រះ ឆ្លើយតមដល់ ការអធិស្ឋានទាំងពីរ



**ដោយ ខាឡូសស អាយវ៉ាន ហ្គាមីនឌ្បេ ប៉ាតីកូ**

កាលដែលខ្ញុំបានកំពុងបម្រើជាអ្នកផ្សព្វផ្សាយសាសនានៅទីក្រុង ដូរ៉េនហ្គូ ប្រទេសមិចស៊ិកូ នោះប្រធានបេសកកម្មរបស់យើង បានសុំណូមពរយើងឱ្យព្យាយាមធ្វើ « ការលះបង់ជារៀងរាល់សប្ដាហ៍ » ។ លោកបានសុំឱ្យយើងខំប្រឹងព្យាយាម ជាងធម្មតា ដោយការខំប្រឹងធ្វើការ និងដាក់គោលដៅច្បាស់លាស់នៅក្នុងសប្ដាហ៍ ។ ខ្ញុំ និងដៃគូមានជំនឿថា ប្រសិនបើយើងបានលះបង់តាមបែបនេះ នោះព្រះអម្ចាស់នឹងប្រទានពរជ័យដល់យើង ហើយយើងនឹងរកបានមនុស្សជាច្រើនដើម្បីបង្រៀន ។

ទោះជាយ៉ាងណាក្ដី នៅអំឡុងពេលសប្ដាហ៍នៃការលះបង់ យើងមិនសូវបានជោគជ័យទេ ។ យើងពុំរកបានក្រុមគ្រួសារណាមួយដើម្បីបង្រៀន ហើយយើងបានខកចិត្តជាខ្លាំង ។

នៅព្រឹកមួយបន្ទាប់ពីសប្ដាហ៍នោះ ខ្ញុំ និងដៃគូបានមើលផែនទីតំបន់របស់យើង ។ តំបន់របស់យើងមានទំហំធំណាស់ ប៉ុន្តែយើងបានមានអារម្មណ៍ថា យើងត្រូវទៅផ្នែកដែលនៅឆ្ងាយបំផុត ។

បន្ទាប់ពីយើងបានទៅដល់ទីនោះ យើងបានអធិស្ឋាន ហើយបានទូលដល់ព្រះវរបិតាសួគ៌ថា តើផ្លូវណា ហើយថាតើផ្ទះណាមួយដែលយើងគួរតែទៅ ។ នៅពេលដែលយើងបានអធិស្ឋានចប់ យើងបានមើលជុំវិញ ដើម្បីមើលផ្លូវទាំងអស់ ។ យើងបានឃើញរបងមួយដែលនៅជិតនោះ ហើយលួចមើលពីលើកំពូលរបងនោះ ។ យើងបានឃើញស្ត្រីម្នាក់កំពុងតែអង្គុយបិទ ភ្នែក ដែលមានអំបោសកាន់នឹងដៃ ។

ដៃគូរបស់ខ្ញុំបាននិយាយថា « ជំរាបសួរ ! » ហើយនៅពេលដែលស្ត្រីបានលឺយើង គាត់បានក្រោកឡើង ហើយបានបន្តបោសសំអាត ហាក់ដូចជាពុំមានរឿងអ្វីកើតឡើងឡើយ ។ បន្ទាប់មក យើងបានប្រាប់ដល់គាត់ថា យើងគឺជាពួកអ្នកផ្សព្វផ្សាយសាសនាមកពីសាសនាចក្រនៃព្រះ យេស៊ូវគ្រីស្ទ ហើយថាយើងមានសារលិខិតមួយដើម្បីជំរាបជូនគាត់ ។ គាត់បានអញ្ជើញយើងចូលក្នុងផ្ទះរបស់គាត់ ហើយយើងបានមាននូវការពិភាក្សាប្រកបដោយព្រះវិញ្ញាណ ។ យើងបានប្រាប់គាត់អំពីយ៉ូសែប ស្ម៊ីធ និងរបៀបដែលលោកបានចូលទៅក្នុងព្រៃដើម្បីអធិស្ឋានស្វែងរកសេចក្ដីពិត ហើយជាការឆ្លើយតបនឹងការអធិស្ឋាន ព្រះជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ បានយាងមកជួបលោក ។

គាត់បាននិយាយកាត់យើងថា « នោះជាការពិតហើយ » ។ ខ្ញុំដឹងថា ព្រះឆ្លើយតបការអធិស្ឋានរបស់យើង ។ នៅពេលដែលអ្នកនិយាយមកកាន់ខ្ញុំ ខ្ញុំបានកំពុងតែអធិស្ឋាន ហើយកំពុងតែទូលដល់ព្រះអម្ចាស់ឱ្យបញ្ជូនទរណាម្នាក់ដែលអាចដឹកនាំខ្ញុំទៅរកផ្លូវរបស់ទ្រង់ ហើយអ្នកក៏បានមកភ្លាមៗ » ។

យើងបានមានអារម្មណ៍នៃព្រះវិញ្ញាណ ហើយយើងបានថ្លែងទីបន្ទាល់ថា ព្រះបានបញ្ជូនយើងឱ្យទៅរកគាត់ ហើយថានៅពេលនោះយើង ក៏បានអធិស្ឋានផងដែរ ដើម្បីដឹងថាតើកូនចៅរបស់ទ្រង់ណាមួយដែលត្រូវការជំនួយរបស់យើង ។ មិនយូរប៉ុន្មាន ស៊ិស្ទើរ រ៉ូហ្វីណា បានទទួលបុណ្យជ្រមុជទឹក ។ នៅក្នុងសប្ដាហ៍បន្ទាប់ កូនៗរបស់គាត់ចៅរបស់គាត់ ថែមទាំងសាច់ញាតិរបស់គាត់បានទទួលបុណ្យជ្រមុជទឹកផងដែរ សរុបអ្នកផ្លាស់ប្រែចិត្តជឿចំនួន 20 នាក់នៅក្នុងតំបន់នោះ ។ ព្រះអម្ចាស់បានដឹកនាំផ្លូវយើងឱ្យទៅរក ស៊ិស្ទើរ រ៉ូហ្វីណា ហើយគាត់គឺជា មធ្យោបាយមួយដើម្បីចែកចាយដំណឹងល្អជាមួយនឹងក្រុមគ្រួសារ និងអ្នកជិតខាងរបស់គាត់ ។

ខ្ញុំដឹងថា ព្រះវរបិតាសួគ៌ប្រទានពរជ័យដល់យើង ប្រសិនបើយើងទូលសួរដល់ទ្រង់ ប៉ុន្តែ លុះត្រាតែទ្រង់បានសាកល្បងសេចក្ដីជំនឿយើងជាមុនសិន ។ ខ្ញុំមានអំណរគុណដែលដៃគូរបស់ខ្ញុំ និងខ្ញុំអាចធ្វើជាឧបករណ៍នៅក្នុងព្រះហស្តរបស់ទ្រង់ ហើយស្វែងរកឃើញមនុស្សដែលត្រៀមខ្លួនជាស្រេចដើម្បីស្ដាប់សារលិខិតនៃដំណឹងល្អ ។ ខ្ញុំដឹងថា ព្រះស្រឡាញ់យើង ហើយទ្រង់នឹងដឹកនាំយើង ប្រសិនបើយើងទូលសុំដល់ទ្រង់ ។ ■

រចនារូបភាពដោយ ឌីលីន ម៉ាស្ស

# ចូរស្មោះត្រង់

ដោយ អែលឌើរ ហ្គេរ៉ល កូសសែ
នៃពួកចិតសិបនាក់



រចនារូបភាពដោយ ដាវីឌ ស្មីធ

ពេលខ្ញុំមានអាយុ 20 ឆ្នាំ ខ្ញុំត្រូវធ្វើការប្រឡងមួយដ៏លំបាកដើម្បីអាចរៀននៅសាលាពាណិជ្ជកម្មមួយដ៏ល្បីឈ្មោះក្នុងប្រទេសបារាំង ។ ខ្ញុំបានសិក្សាច្រើនម៉ោងជារៀងរាល់ថ្ងៃអស់រយៈពេលពីរឆ្នាំ ។ ប៉ុន្តែខ្ញុំតែងតែទៅព្រះវិហារ និងថ្នាក់វិទ្យាស្ថាន ហើយបំពេញការទទួលខុសត្រូវរបស់ខ្ញុំក្នុងសាសនាចក្រជានិច្ច ។

ផ្នែកដ៏សំខាន់បំផុតនៃការប្រឡងនោះគឺជាការសម្ភាសន៍ ។ ខ្ញុំបានមានការសម្ភាសន៍មួយនៅសាលារៀនមួយ ហើយពេលពួកគេបានដឹងថាខ្ញុំជាសមាជិកនៃសាសនាចក្រនេះ ការសម្ភាសន៍នោះមិនបានដំណើរការទៅយ៉ាងល្អឡើយ ។

បន្ទាប់មកខ្ញុំបានប្រឡងចូលសាលារៀនដែលខ្ញុំចង់ទៅរៀនបំផុត ។ មួយរយៈក្រោយមកនៅក្នុងកិច្ចសម្ភាសន៍នោះ អ្នកសម្ភាសន៍បានចាប់ផ្ដើមសួរសំណួរអំពីអ្វីដែលខ្ញុំធ្វើក្រៅម៉ោងសិក្សារបស់ខ្ញុំ ។ ខ្ញុំបានដឹងថា វាគឺជាសំណួរវិជ្ជមាន ឬអវិជ្ជមានសម្រាប់ខ្ញុំ ។ ប៉ុន្តែខ្ញុំបានសម្រេចចិត្តភ្លាមថា ខ្ញុំត្រូវតែស្មោះត្រង់ចំពោះគោលការណ៍របស់ខ្ញុំ ។

ខ្ញុំបាននិយាយថា « ខ្ញុំគឺជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » រួចហើយខ្ញុំបានចំណាយពេល 15 នាទី ពន្យល់ពីអ្វីដែលខ្ញុំបានធ្វើនៅក្នុងសាសនាចក្រ ។

លោកនាយកសាលានោះបាននិយាយថា « អ្នកដឹងទេ ខ្ញុំត្រេកអរណាស់ដែលអ្នកបាននិយាយការណ៍នេះ ។ ពេលខ្ញុំនៅជានិស្សិត ខ្ញុំបានសិក្សានៅសហរដ្ឋអាមេរិក ហើយមិត្តសម្លាញ់របស់ខ្ញុំម្នាក់គឺជាមរមន ។ គាត់ជាបុរសម្នាក់ដ៏អស្ចារ្យ និងជាមនុស្សដែលមានសណ្ដានចិត្តល្អ ។ ខ្ញុំគិតថា ពួកមរមនគឺជាមនុស្សល្អណាស់ » ។

ខ្ញុំធូរទ្រូងមែនទែន ! ខ្ញុំគឺជាបេក្ខជនម្នាក់ក្នុងចំណោមបេក្ខជនដំបូងនៅឆ្នាំនោះ ដែលត្រូវបានទទួលឱ្យចូលរៀននៅសាលានេះ ។

នៅក្នុងរឿងនេះមាននូវមេរៀនពីរ ។ ទីមួយ យើងមិនគួរវិនិច្ឆ័យខុសទៅលើឥទ្ធិពលដែលយើងមានចំពោះអ្នកដទៃឡើយ ។ ទីពីរ យើងគួរតែស្មោះត្រង់ជានិច្ចចំពោះគោលការណ៍របស់យើង ។ សូមធ្វើឱ្យអស់ពីលទ្ធភាពរបស់អ្នក ហើយព្រះអម្ចាស់នឹងជួយអ្នកចំពោះកិច្ចការទាំងឡាយដែលនៅសល់ ។ ■



# ថ្ម ព្រួញ និងដុំព្រិល

*« ព្រះវិញ្ញាណនៃព្រះអម្ចាស់បានស្ថិតនៅជាមួយនឹងលោក ដរាបដល់គេពុំអាចគប់ដុំថ្មត្រូវលោក » (ហេលេមិន 16:2) ។*

**ដោយ ដាវីឌ អិល ហ្រ្វីសនេច**
ផ្នែកកម្មវិធីសិក្សា
ផ្អែកទៅលើដំណើររឿងពិត

ដើរត្រឡប់មកផ្ទះក្រោយពីរៀន ជាធម្មតាគឺពុំមែនជារឿងគួរឱ្យរីករាយនោះទេ ។ នៅពេលខ្លះ ខ្ញុំគិតអំពីកិច្ចការផ្ទះផ្នែកគណិតវិទ្យារបស់ខ្ញុំ នៅពេលខ្លះទៀត ខ្ញុំគិតអំពីអ្វីដែលយើងបានធ្វើនៅថ្នាក់ហាត់ប្រាណ ហើយនៅពេលខ្លះ ខ្ញុំដើរដោយពុំគិតអំពីអ្វីទាំងអស់ ។

ប៉ុន្តែថ្ងៃនេះគឺខុសពីសព្វដង ។ គំនិតរបស់ខ្ញុំគឺប្រកួតប្រជែងគ្នា ។ នៅខាងមុខខ្ញុំ ខ្ញុំមើលឃើញបុរសពីរនាក់ដែលខ្ញុំធ្លាប់លេងជាមួយពីមុន—ចស និងម៉ាកុស—កំពុងតែធ្វើដុំព្រិលនិងចង្អុលមកខ្ញុំ ។

« អេ៎ ! ដាវីឌ មកលេងជាមួយខ្ញុំមក ! » ចស បានស្រែកផង សើចផង ។ « យើងចង់បង្ហាញ អ្វីមួយដល់ឯង » ។

ម៉ាកុសស ក៏បានសើចផងដែរ ។

ចស និងម៉ាកុស ទាំងពីរនាក់មានអាយុបងខ្ញុំមួយឆ្នាំ ហើយពួកគេអាចគប់ដុំព្រិលខ្លាំងៗជាងខ្ញុំ ។ ខ្ញុំបានដឹងមិនយូរប៉ុន្មានទេ ពីមុនដែលពួកគេចាប់ផ្ដើមគប់ដុំព្រិលមកលើខ្ញុំ ។ ទោះបីជាតាមធម្មតាពួកគេល្អចំពោះខ្ញុំក្ដី ខ្ញុំបានគិតថា ប្រហែលជាពួកគេបានប្រុងប្រយ័ត្ន… ខ្ញុំបានគិតថា ប្រហែលជាពួកគេបានប្រចាប់ពួតដុំព្រិលនោះយ៉ាងរឹងហើយ ។

ខ្ញុំបានចាប់ផ្ដើមគិតអំពីរបៀបដែលខ្ញុំអាចបញ្ឈប់ការគប់ដុំព្រិលរបស់ពួកគេ ។

តើគួរតែរត់ឆ្លងផ្លូវដើម្បីគេចពីពួកគេឬ ? អត់ទេ ពួកគេនឹងសើចចំអកឱ្យខ្ញុំ ហើយនិយាយចំអកដាក់ខ្ញុំ ។

គួររត់ឱ្យលឿនកាត់ពីមុខពួកគេ ? អត់ទេ ពួកគេរត់លឿនជាងខ្ញុំ ហើយនឹងរត់ទាន់ខ្ញុំជាមិនខានទេ ។

ពួនដុំព្រិលដើម្បីការពារខ្លួនខ្ញុំ ? នោះមិនមែនជាគំនិតល្អនោះទេ ដោយការគិតថាពួកគេមានគ្នាពីរនាក់ ហើយខ្ញុំមានតែម្នាក់ឯង ។ ពួកគេក៏នៅកន្លែងខ្ពស់លើទួល ហើយខ្ញុំគ្មានកន្លែងដើម្បីពួននៅខាងក្រោមនោះទេ ។

ខ្ញុំបានសម្រេចចិត្តធ្វើរឿងតែមួយគត់ដែលខ្ញុំគិតថាល្អ—ដើរដោយស្ងប់ស្ងាត់ទៅមុខពួកគេ ហើយរង់ចាំឱ្យដុំព្រិលហោះចេញមក ។

នៅពេលដែលខ្ញុំទៅជិតដល់ទួលនោះ មាន



គំនិតមួយផុសឡើង ។ ខ្ញុំចងចាំពីសាំយ៉ូអែលសាសន៍លេមិន ដែលបានផ្សព្វផ្សាយដំណឹងល្អខណៈដែលកំពុងឈរលើទួលមួយ ។ នៅពេលដែលប្រជាជនមិនចូលចិត្តនូវអ្វីដែលគាត់កំពុងនិយាយ ពួកគេបានគប់ដុំថ្មទៅលើ និងបាញ់ព្រួញដាក់គាត់ផង ។

ខ្ញុំដឹងថាព្រះអម្ចាស់បានការពារសាំយ៉ូអែលឱ្យជៀសផុតពីដុំថ្ម និងផ្លែព្រួញទាំងឡាយ ។ ប្រហែលជាទ្រង់អាចធ្វើឱ្យដុំព្រិលកន្លងហួសខ្ញុំផងដែរ ។

ខ្ញុំបានពោលពាក្យអធិស្ឋាននៅក្នុងចិត្តខ្ញុំ ដោយសុំឱ្យព្រះវរបិតាសួគ៌ធ្វើកុំឱ្យដុំព្រិលនោះគប់ត្រូវខ្ញុំឡើយ ។ ខ្ញុំដឹងថា ខ្ញុំត្រូវមានសេចក្តីក្លាហាន មិនត្រូវមានការសង្ស័យ—ដូចជាសាំយ៉ូអែលអញ្ចឹង ។ ពេលដែលខ្ញុំបានទៅដល់ទួលនោះ ខ្ញុំមានអារម្មណ៍មានទុកចិត្តថា ខ្ញុំនឹងមិនរងការឈឺចាប់ឡើយ ។

គឺដូចជាអ្វីដែលខ្ញុំបានរំពឹងទុក ដុំព្រិលចាប់ផ្តើមហោះចេញមក ។ ដុំព្រិលពីរបីបានហោះរំលងក្បាលរបស់ខ្ញុំឮសូរវឺៗ ដែលខ្ញុំអាចទទួលបានចំហាយត្រជាក់ ដែលដុំព្រិលបានបោះទៅ ។ ដុំព្រិលខ្លះបានហោះរំលងដៃរបស់ខ្ញុំ ហើយមានដុំព្រិលពីរបីបានធ្លាក់នៅក្បែរជើងរបស់ខ្ញុំ ប៉ុន្តែគ្មានដុំព្រិលណាដែលគប់ត្រូវខ្ញុំនោះឡើយ ។ មួយក៏គ្មានដែរ !

ពួកគេបន្តគប់រហូតដល់ខ្ញុំនៅចំងាយដែលពួកគេមិនអាចគប់ដល់ ប៉ុន្តែខ្ញុំដឹងថា ខ្ញុំមានសុវត្ថិភាព ។ ការបន្តដើរត្រឡប់មកផ្ទះវិញរបស់ខ្ញុំគឺមិនមានអ្វីដែលគួរឱ្យរីករាយនោះទេ—ហើយខ្ញុំមិនអាចសប្បាយជាងនេះឡើយ ។ ខ្ញុំត្រូវបានការពារដូចជាសាំយ៉ូអែលសាសន៍លេមិន ។ ខ្ញុំដឹងថាការអធិស្ឋាន និងការអនុវត្តន៍សេចក្តីជំនឿលើព្រះអម្ចាស់បានប្រទានពរដ៏យដល់ខ្ញុំ ។ ■



« ខ្ញុំសូមថ្លែងទីបន្ទាល់ថា ការអធិស្ឋានកាន់តែមានអត្ថន័យ នៅពេលដែលយើងសុំដោយសេចក្តីជំនឿ និងធ្វើសកម្មភាព » ។

**អែលឌើរ ដាវីឌ អេ បេដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « សុំដោយសេចក្តីជំនឿ » *Liahona* ខែ ឧសភា ឆ្នាំ 2008 ទំព័រ 96 ។**

រចនារូបភាពដោយ ខេវីន ឃែល

# ទទួលទាននូវព្រះ
# គម្ពីរមរមន

កុមារជាច្រើននៅក្នុងសម័យនៃព្រះគម្ពីរមរមន បានមានឱកាសឃើញព្រះយេស៊ូវគ្រីស្ទ និង ស្ដាប់ដល់ព្រះបន្ទូលរបស់ទ្រង់ ។ តាមរយៈការអានព្រះគម្ពីរមរមន៍ជារៀងរាល់សប្ដាហ៍នៅក្នុងឆ្នាំនេះ នោះអ្នកក៏អាចរីករាយ « ដោយទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ » ( នីហ្វៃទី2 31:20 ) ។

សូមឱ្យមនុស្សពេញវ័យម្នាក់ជួយអ្នកកាត់ប្រដាប់កឹបចេញ ហើយទាញយកទំព័រផាត់ពណ៌នេះ ។ ជារៀងរាល់សប្ដាហ៍បន្ទាប់ពីអ្នកបានអានរួច សូមសូមផាត់ពណ៌នៅក្នុងចន្លោះទាំងអស់របស់លេខនោះក្នុងសប្ដាហ៍នោះ ។ ចំពោះយោបល់អំពីអ្វីដែលត្រូវអានជារៀងរាល់សប្ដាហ៍ សូមមើលទំព័រ 62 ។ អ្នកអាចអានដោយខ្លួនឯង ឬជាមួយក្រុមគ្រួសារអ្នក ។



គំនូរព្រាងដោយ ស្កត ប៉េក





យោបល់សំរាប់ការអានប្រចាំសប្ដាហ៍ « ទទួលទាននូវព្រះគម្ពីរមរមន »
( សូមមើលទំព័រ 60–61 )

| សប្ដាហ៍ | អាន |
|---|---|
| 1 | បុព្វកថានៃព្រះគម្ពីរមរមន |
| 2 | នីហ្វៃទី1 1:1–3, 18–20; 2:2–4; 3:2–7; 4:1–18 |
| 3 | នីហ្វៃទី1 8:2, 5–33 |
| 4 | នីហ្វៃទី1 16:9–10, 16–19, 23, 26, 28–32; អាលម៉ា 37:38–46 |
| 5 | នីហ្វៃទី1 17:8–11, 16–19, 49–55; 18:1–4 |
| 6 | នីហ្វៃទី2 2:11–13, 22–27; 4:15–16; 31:5–8, 17–21 |
| 7 | នីហ្វៃទី2 32:3–9; យ៉ាកុប 7:1–20 |
| 8 | អេណុស 1:1–13 |
| 9 | មូសាយ 1:9–10, 18; 2:1–2, 5–8, 16–19; 3:17, 19; 4:9–10; 5:15 |
| 10 | មូសាយ1 1:1–2, 20, 27–29; 12:1, 9, 14, 17–19, 35–36; 13:15–24 |
| 11 | មូសាយ 17:1–12, 20 |
| 12 | មូសាយ 18:1–17 |
| 13 | មូសាយ 21:1–15, 23–24 |
| 14 | មូសាយ 21:29–35; 22 |
| 15 | មូសាយ 23:1–7, 19–26, 36–39 |
| 16 | មូសាយ 24:8–25; 25:1, 14–19 |
| 17 | មូសាយ 27:6–24; អាលម៉ា 36:11–12, 16–24 |
| 18 | មូសាយ 27:32–37; 28:1–9 |
| 19 | អាលម៉ា 1:2–15; 2:1–9 |
| 20 | អាលម៉ា 2:10–18, 29–31; 5:1, 19, 26–27, 33 |
| 21 | អាលម៉ា 6:7–8; 7:9–12; 8:1–22 |
| 22 | អាលម៉ា 8:23–32; 9:1–8, 14–15 |
| 23 | អាលម៉ា 10:27–32; 11:21–46 |
| 24 | អាលម៉ា 12:1–7; 14:1–17 |
| 25 | អាលម៉ា 14:18–29; 15:1–13 |
| 26 | អាលម៉ា 17:1–3, 12–13, 17–39 |
| 27 | អាលម៉ា 18:1–4, 8–35 |
| 28 | អាលម៉ា 18:40–43; 19:1–2, 8–15, 18–19, 22–33 |
| 29 | អាលម៉ា 20:1–28 |
| 30 | អាលម៉ា 23:6–7, 16–18; 24:1–7, 16–27; 27:2–5, 14, 27–29 |
| 31 | អាលម៉ា 30:6–9, 12–14, 31–32, 35–39, 43–45, 49–50, 55–59 |
| 32 | អាលម៉ា 31:1, 5–7, 12–21, 37–38; 32:1, 5–6 |
| 33 | អាលម៉ា 32:26–43 |
| 34 | អាលម៉ា 37:3, 6, 8–11, 14–15; 43:1–9, 16–17, 43–47; 44:16–20 |
| 35 | អាលម៉ា 46:1–5, 11–16, 19–20; 48:7–13, 22–23; 49:25–26, 28 |
| 36 | អាលម៉ា 50:25–36; 51:5–6, 11, 13–16, 20–22 |
| 37 | អាលម៉ា 53:10–21; 56:2–11, 43–48, 55–56 |
| 38 | ហេលេមិន 2:2–11; 5:4–13 |
| 39 | ហេលេមិន 5:20–50 |
| 40 | ហេលេមិន 6:18–23; 7:6–13, 26–29; 8:1, 4, 10, 25–28 |
| 41 | ហេលេមិន 9:1–24 |
| 42 | ហេលេមិន 9:25–39; 10:1–6 |
| 43 | ហេលេមិន 13:1–7; 14:2–8; 16:1–3; នីហ្វៃទី3 1:4–9 |
| 44 | នីហ្វៃទី3 1:10–15, 21–23; 2:1–2; 8:2–7, 23; 9:1–2, 18–22 |
| 45 | នីហ្វៃទី3 11:1–17, 23–26 |
| 46 | នីហ្វៃទី3 17:1–24 |
| 47 | នីហ្វៃទី3 18:1–9, 19–21, 24, 35–39 |
| 48 | នីហ្វៃទី3 19:11–26; 20:1; 27:1–8 |
| 49 | នីហ្វៃទី3 28:1–9; នីហ្វៃទី4 1:1, 15, 23–26; មរមន 1:1, 11–17 |
| 50 | មរមន 2:1–2, 9, 23–24, 26–27; 3:2–3, 16–22 |
| 51 | អេធើរ 1:1, 33; 2:5, 16–25; 3:1, 4–14 |
| 52 | មរ៉ូណៃ 10:3–23 |





*អែលឌើរ អិម រ័សុល បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានចែកចាយនូវគំនិតមួយចំនួនពីប្រធានបទនេះ ។*

# តើខ្ញុំសម្រេច **គោលដៅ** របស់ខ្ញុំបានដោយរបៀបណា ?

យើងត្រូវតែមានសេចក្ដីជំនឿ ។ យើងត្រូវតែមានសេចក្ដីជំនឿជឿលើព្រះ ។ យើងត្រូវតែមានសេចក្ដីជំនឿជឿលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ ហើយពិតណាស់ យើងត្រូវតែមានសេចក្ដីជំនឿលើខ្លួនឯង ។

នៅពេលអ្នកដាក់គោលដៅមួយ ហើយតាំងចិត្តចំពោះការគ្រប់គ្រងខ្លួនឯងដ៏ចាំបាច់ ដើម្បីសម្រេចគោលដៅនេះ នោះអ្នកនឹងបំបាត់ចោលនូវបញ្ហាភាគច្រើននៅក្នុងជីវិតរបស់អ្នក ។ សូមចំណាយកម្លាំងរបស់អ្នកធ្វើនូវរឿងទាំងឡាយណាដែលនឹងធ្វើឱ្យមានភាពខុសប្លែកមួយកើតឡើង ។

បើគោលដៅរបស់អ្នកមានទូវភាពសុចរិត នោះចូរធ្វើវាចុះ ។

អ្នកត្រូវតែបណ្ដុះនូវបំណងប្រាថ្នាមួយដើម្បីអភិវឌ្ឍជំនាញនៃការដាក់គោលដៅដ៏សក្ដិសម ហើយច្បាស់លាស់ ។

*ដកស្រង់ចេញពី « Do Things That Make a Difference »* Ensign, *ខែ មិថុនា ឆ្នាំ 1983 ទំព័រ 69, 71, 72*

# សិទ្ធិជ្រើសរើស

អ្នកអាចប្រើមេរៀន និងសកម្មភាពនេះដើម្បីរៀនសូត្របន្ថែមទៀតពីបាវចនាថ្នាក់កុមារសម្រាប់ខែនេះ ។

## គឺជាអំណោយទានដើម្បីជ្រើសរើសសម្រាប់ខ្លួនរបស់យើងផ្ទាល់



« សួស្តីថ្ងៃកំណើត ជូលីអាណា ! » លោកប៉ាបាននិយាយ ។ គាត់បានហុចប្រអប់មួយដែលរុំដោយក្រដាសភ្លឺ ហើយមានចងបូឱ្យទៅជូលីអាណា ។

ជូលីអាណាបានញញឹម ។ នាងមានចិត្តរីករាយដោយបានទទួលអំណោយមួយពីប៉ារបស់នាង ហើយនាងចង់បើកប្រអប់នោះយ៉ាងខ្លាំង ។ តើអ្នកមានចិត្តរីករាយដូចជាជូលីអាណាដែរទេ ពេលអ្នកបានទទួលអំណោយមួយនោះ ? ព្រះវរបិតាសួគ៌បានប្រទានឱ្យយើងម្នាក់ៗនូវអំណោយមួយដ៏មានតម្លៃ ។ វាត្រូវបានហៅថា សិទ្ធិជ្រើសរើស ។ សិទ្ធិជ្រើសរើសគឺជាសមត្ថភាពដើម្បីធ្វើការជ្រើសរើសដោយខ្លួនឯង ។

ពីមុនយើងមកកាន់ផែនដីនេះ សាតាំងមិនចង់ឱ្យនរណាម្នាក់មានការជ្រើសរើសមួយនោះទេ ។ វាចង់បង្ខំយើងឱ្យមកកាន់ផែនដី ហើយធ្វើអ្វីដែលវាចង់ឱ្យយើងធ្វើ ។ ប៉ុន្តែព្រះវរបិតាសួគ៌បានជ្រាបថា វាគឺជាការសំខាន់ណាស់សម្រាប់យើងធ្វើការជ្រើសរើសដោយខ្លួនឯង ។ ជាមួយនឹងការជ្រើសរើសដ៏ត្រឹមត្រូវនីមួយៗដែលយើងជ្រើសរើស នោះយើងខិតកាន់តែជិតព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។ ទ្រង់ទាំងពីរអង្គសព្វព្រះទ័យឱ្យយើងធ្វើការជ្រើសរើសល្អ ដើម្បីយើងអាចត្រឡប់ទៅរស់នៅជាមួយទ្រង់ទាំងពីរម្តងទៀត ។

ក្នុងថ្នាក់កុមារឆ្នាំនេះ យើងនឹងរៀនអំពីរបៀបដែលយើងអាចប្រើសិទ្ធិជ្រើសរើសរបស់យើងដើម្បី ជ.ផ.ត. ជ្រើសផ្លូវត្រូវ ! ■



### ចម្រៀង និងបទគម្ពីរទាំងឡាយ

- « ខ្ញុំជាកូនរបស់ព្រះ » *គម្រោងពេលវេលាចែកចាយឆ្នាំ 2012* ទំព័រ 28
- នីហ្វៃទី2 2:27



### សម្រាប់តែអ្នក

នៅល្ងាចមួយ សូមគិតពីការជ្រើសរើសនានាដែលអ្នកបានធ្វើនៅថ្ងៃនោះ ។ សូមគូររូប សរសេរកំណាព្យ ឬនិពន្ធចម្រៀងមួយបទអំពីការជ្រើសរើសដ៏ល្អមួយដែលអ្នកបានធ្វើ ។



## ល្បែង ជ.ផ.ត

អ្នកអាចលេងល្បែងនេះជាមួយនឹងគ្រួសាររបស់អ្នក ដើម្បីរៀនបន្ថែមទៀតអំពីសិទ្ធិជ្រើសរើស ។ សូមកាត់រូបគ្រាប់ឡុកឡាក់ចេញ ហើយបិទវានឹងក្រដាសរឹង ។ សូមបត់រូបគ្រាប់ឡុកឡាក់នោះដូចដែលបានបង្ហាញខាងលើ បិទបន្ទះតូចៗនោះតាមកន្លែង ហើយទុកឱ្យគ្រាប់ឡុកឡាក់របស់អ្នកស្ងួត ។

សូមអង្គុយជារង្វង់ជាមួយនឹងគ្រួសាររបស់អ្នក ។ សូមឱ្យមនុស្សម្នាក់បង្វិលគ្រាប់ឡុកឡាក់នោះ ហើយអានទូរផ្នែកដែលផ្ងារ ។ សូមនិយាយអំពីការជ្រើសរើសផ្សេងៗគ្នាដែលអាចធ្វើទៅក្នុងស្ថានភាពនោះ ។ តើមានអ្វីអាចកើតឡើងជាមួយនឹងការជ្រើសរើសនីមួយៗ ? សូមហុចគ្រាប់ឡុកឡាក់នោះទៅឱ្យអ្នកបន្ទាប់បោះ ។

មានក្មេងប្រុសចំណូលថ្មីម្នាក់អង្គុយក្នុងថ្នាក់ជិតអ្នក ។
...............
តើអ្នកធ្វើយ៉ាងម៉េច ?

ប្អូនស្រីអ្នកចង់លេងជាមួយអ្នកនិងមិត្តភក្តិរបស់អ្នក ។
...............
តើអ្នកធ្វើយ៉ាងម៉េច ?

ជេរេមី សួរថាតើគាត់អាចចម្លងកិច្ចការសាលារបស់អ្នកបានទេ ។
...............
តើអ្នកធ្វើយ៉ាងម៉េច ?

ម៉ាទីន អញ្ជើញអ្នកមើលកុន នៅថ្ងៃអាទិត្យ ។
...............
តើអ្នកធ្វើយ៉ាងម៉េច ?

លី ជាមនុស្សចូលចិត្តសម្លុតគេ នៅសាលារៀន ។
...............
តើអ្នកធ្វើយ៉ាងម៉េច ?

បងប្រុសអ្នកធ្វើបាបអ្នក ។
...............
តើអ្នកធ្វើយ៉ាងម៉េច ?

រចនារូបភាពដោយ ម៉ារីអន រូស

# ព្រះគម្ពីរមរមនបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ

**ដោយ ដាយអាន អិល មែនហ៊្គិម**

ព្រះគម្ពីរសញ្ញាចាស់ប្រាប់យើងអំពីព្រះយេស៊ូវគ្រីស្ទពីមុនទ្រង់យាងមកកាន់ជីវិតលើផែនដី ។ ទ្រង់ត្រូវបានគេហៅថា ព្រះយេហូវ៉ា ។ ព្រះគម្ពីរសញ្ញាចាស់ប្រាប់យើងអំពីមនុស្សដែលបានដើរតាមព្រះយេហូវ៉ា ។

ព្រះគម្ពីរសញ្ញាថ្មីគឺជាព្រះគម្ពីរដែលប្រាប់យើងអំពីជីវិតនៅលើផែនដីរបស់ព្រះយេស៊ូវគ្រីស្ទ ។ ពួកសិស្សរបស់ទ្រង់បានសរសេរអំពីជីវិតរបស់ទ្រង់ និងការបង្រៀនរបស់ទ្រង់ ។

បងប្រុសរបស់យ៉ារេឌបានឃើញព្រះយេស៊ូវគ្រីស្ទ ។



សម្លេងរបស់ព្រះអម្ចាស់បានចូលមកក្នុងគំនិតរបស់អេណុសពេលគាត់បានអធិស្ឋាន ។



ព្រះគម្ពីរមរមនក៏បង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ និងមនុស្សដែលបានដើរតាមទ្រង់ផងដែរ ។

ព្រះគម្ពីរមរមនចាប់ផ្ដើមនៅក្នុងទីក្រុងយេរូសាឡិម អំឡុងពេលនៃព្រះគម្ពីរសញ្ញាចាស់ ប្រហែលជា 600 ឆ្នាំពីមុនព្រះយេស៊ូវបានប្រសូត ។ វាប្រាប់ពីរបៀបដែលព្យាការីលីហៃ និងគ្រួសាររបស់លោកបានចាកចេញពីទីក្រុងយេរូសាឡិម ហើយត្រូវបានដឹកនាំទៅកាន់ដែនដីសន្យា ដោយត្រូវឆ្លងកាត់មហាសមុទ្រនៅក្នុងពិភពថ្មី ។

ពួកព្យាការីនៅក្នុងព្រះគម្ពីរមរមនបានបង្រៀនថា ព្រះយេស៊ូវនឹងយាងមកកាន់ផែនដី ។ ពួកគាត់ក៏បានបង្រៀនផងដែរថា ការប្រែចិត្ត និងការដើរតាមព្រះយេស៊ូវគ្រីស្ទនឹងនាំមកនូវសុភមង្គល ។

បន្ទាប់ពីព្រះយេស៊ូវត្រូវបានគេឆ្កាង ហើយបានរស់ឡើងវិញនៅក្នុងទីក្រុងយេរូសាឡិម ទ្រង់បានយាងមកពិភពថ្មីដើម្បីបង្រៀនដល់ប្រជាជននោះ ។ ទ្រង់បានបង្រៀនអំពីបុណ្យជ្រមុជទឹក ពិធីសាក្រាម៉ង់ និងពីរបៀបដើម្បីស្រឡាញ់គ្នាទៅវិញទៅមក ។ ទ្រង់បានរៀបចំសាសនាចក្រមួយដោយមានពួកសាវកដប់ពីរនាក់ ។ ទ្រង់បានប្រមូលក្មេងតូចៗ ហើយប្រសិទ្ធពរដល់ពួកគេ ដូចដែលទ្រង់បានធ្វើក្នុងព្រះគម្ពីសញ្ញាថ្មីផងដែរ ។

ដូចគ្នានឹងពួកព្យាការីក្នុងព្រះគម្ពីរបរិសុទ្ធដែរ ពួកព្យាការីក្នុងព្រះគម្ពីរមរមនបាន

ខាងឆ្វេង ៖ រចនារូបភាពដោយ រ៉ូប៊ឺត ធី បារ៉េត ។ ខាងស្ដាំ ៖ រចនារូបភាពដោយ ផល ម៉ាន និងហ្គារី ខាប



លីហៃ បានឃើញព្រះយេស៊ូវគ្រីស្ទនៅក្នុងសុបិន ឬការនិមិត្ត ។

ស្ដេចបេនយ៉ាមីនបានបង្រៀនដល់ប្រជាជនអំពីដង្វាយធួនរបស់ព្រះយេស៊ូវ ។



ចែកចាយទីបន្ទាល់របស់ខ្លួនអំពីព្រះយេស៊ូវគ្រីស្ទ ។

ព្យាការីចុងក្រោយក្នុងព្រះគម្ពីរមរមន គឺម៉ូរ៉ូណៃ ដែលបានរស់នៅប្រហែលជា 400 ឆ្នាំបន្ទាប់ពីព្រះយេស៊ូវបានយាងមកកាន់ពិភពលោកថ្មី ។ ពីមុនគាត់ទទួលមរណភាព ម៉ូរ៉ូណៃបានសរសេរថា មនុស្សគ្រប់គ្នាដែលបានអានព្រះគម្ពីរមរមនអាចដឹងថាព្រះគម្ពីរនេះពិត បើសិនជាគេអធិស្ឋានដោយសេចក្ដីជំនឿ ។ ម៉ូរ៉ូណៃបានអញ្ជើញមនុស្សគ្រប់រូបឱ្យ « មករកព្រះគ្រីស្ទ » (ម៉ូរ៉ូណៃ 10:32)។

កុមារទាំងឡាយនៅសព្វថ្ងៃនេះក៏អាចអធិស្ឋានដើម្បីទទួលទីបន្ទាល់មួយថា ព្រះគម្ពីរមរមនជាព្រះគម្ពីរពិត ហើយថាព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះរបស់ពួកគេបានផងដែរ ។ ■

# ការបង្កើតមិត្តភាពនៅជុំវិញ
# ទូបប៉ាស៊ីហ្វិក






ដោយជេន ហាន់សិន ឡាសេធី

នៅពេលនិស្សិតគិលានុបដ្ឋាមួយចំនួនមកពីសាកលវិទ្យាល័យព្រិកហាំ យ៉ង បានរៀបចំខ្លួនទៅប្រទេសតុងហ្គា ពួកគេបានគិតថាវានឹងជារឿងមួយដ៏សប្បាយសម្រាប់កុមារមកពីរដ្ឋយូថាហ៍ និងប្រទេសតុងហ្គាក្លាយជាមិត្តនឹងគ្នា ។

ដូច្នេះនិស្សិតទាំងនោះបានសុំកុមារនៅវួដអ្លូកហ៊ីលស៍ទីប្រាំបួនក្នុងទីក្រុងប្រ៉ូវ៉ូ រដ្ឋយូថាហ៍ ឱ្យគូររូបភាពសម្រាប់កុមារនៅប្រទេសតុងហ្គា ។ ពួកគេក៏បានថតរូបកុមារទាំងនោះផងដែរ ។

នៅពេលពួកគេបានទៅដល់ប្រទេសតុងហ្គា និស្សិតពេទ្យទាំងនោះបានជួយក្នុងពេលវេលាចែកចាយនៅក្នុងវួដ ណេអៃហ្វូទីបី ។ ពួកគេបានឱ្យកុមារម្នាក់ៗនូវរូបគំនូរមួយ និងរូបថតមួយសន្លឹកមកពីកុមារក្នុងរដ្ឋយូថាហ៍ ។ កុមារទាំងនោះមានចិត្តរីករាយចង់ដឹងអំពីមិត្តថ្មីរបស់ពួកគេនៅរដ្ឋយូថាហ៍ ។

កុមារទាំងនោះបានគូររូបភាពសម្រាប់កុមារនៅរដ្ឋយូថាហ៍ ។ មានពួកគេមួយចំនួនបានសរសេរជាលិខិតអំពីខ្លួនឯង និងអំពីជីវិតនៅក្នុងប្រទេសតុងហ្គា ។ មានលិខិតមួយចំនួនត្រូវបានសរសេរជាភាសាអង់គ្លេស និងមួយចំនួនទៀតជាភាសាតុងហ្គា ។ ប្រធានអង្គការបឋមសិក្សារបស់ពួកគេបានសរសេរជាភាសាអង់គ្លេសដោយបកប្រែមកពីលិខិតជាភាសាតុងហ្គា ។ និស្សិតគិលានុបដ្ឋាទាំងនោះបានថតរូបកុមារទាំងនោះ ។

មានក្មេងប្រុសម្នាក់បានសរសេរថា « ខ្ញុំលេងបាល់ឱប ហើយប្រទេសតុងហ្គាមានអាកាសធាតុក្តៅណាស់ » ។ មានក្មេងស្រីម្នាក់បានសរសេរថា « ខ្ញុំស្រឡាញ់រូបភាពរបស់អ្នក ។ អ្នកស្រស់ស្អាត់ណាស់ ។ ខ្ញុំចូលចិត្តច្រៀង ដូចជាអ្នកដែរ » ។ មានក្មេងម្នាក់ទៀតបានសរសេរអំពីថ្នាក់កុមារ ហើយបានសម្តែងនូវសេចក្តីស្រឡាញ់ថា ៖ « មេរៀនរបស់ខ្ញុំនៅថ្ងៃនេះគឺអំពីពួកព្យាការី ។ ខ្ញុំចូលចិត្តអ្នកខ្លាំងណាស់ ! » ■





# ទ្រង់គង់នៅ **ទីនោះ**

**ដោយ រ៉ូសម៉ារី អិម វិកស្សុម**
ប្រធានអង្គការបឋមសិក្សាទូទៅ

*« យើងបានខិតខំអស់ពីដួងចិត្តនៅក្នុងការអធិស្ឋានដល់ព្រះ សូមឱ្យទ្រង់ចម្រើនកម្លាំងដល់យើង » (អាលម៉ា 58:10) ។*

**ន**ៅពេលកូនប្រុសរបស់យើងម្នាក់មានអាយុ 11 ឆ្នាំ គាត់បានក្រោកឡើងពីដំណេកទាំងឈឺក្បាលយ៉ាងខ្លាំង ។ ដំបូងឡើយខ្ញុំបានគិតថាគាត់គ្រាន់តែចង់ពន្យារពេលទៅសាលារៀនប៉ុណ្ណោះ ប៉ុន្តែរំពេចនោះបានដឹងថា គាត់គ្រុនក្ដៅយ៉ាងខ្លាំង ។ ខ្ញុំបានយកគាត់ទៅជួបគ្រូពេទ្យ ហើយមិនយូរប៉ុន្មានយើងបានត្រូវប្រញាប់ប្រញាល់ទៅមន្ទីរពេទ្យ ។ គាត់ត្រូវបានគេរកឃើញថាមានជម្ងឺរលាកស្រោមខួរឆ្អឹងខ្នង ជាជម្ងឺមួយដ៏ធ្ងន់ធ្ងរ ។

នៅពេលស្ថានភាពរបស់គាត់កាន់តែធ្ងន់ធ្ងរទៅ គាត់បានចាប់ផ្ដើមមានការប្រកាច់ ។ គ្រូពេទ្យបានសុំខ្ញុំឱ្យចេញពីបន្ទប់នោះ ។ នៅពេលខ្ញុំបានដើរនៅច្រកផ្លូវដើរ ខ្ញុំមានការភ័យខ្លាចហើយបានចាប់ផ្ដើមយំ ។ មានស្ត្រីម្នាក់ដែលខ្ញុំមិនបានស្គាល់បានមកឱបខ្ញុំ ។ ខ្ញុំបានអធិស្ឋានឰៗសុំឱ្យព្រះវរបិតាអាចជួយកូនប្រុសរបស់ខ្ញុំ ហើយថាអ្វីៗទាំងអស់នឹងបានប្រសើរឡើង ។ ខ្ញុំចងចាំពីអារម្មណ៍នៃសេចក្ដីសុខសាន្តដ៏អស្ចារ្យ ។

កូនប្រុសរបស់ខ្ញុំបានទទួលការវះកាត់ ហើយបានប្រើពេលជាច្រើនសប្ដាហ៍ដើម្បីបានជា សះស្បើយបាន ។ បច្ចុប្បន្ននេះ គាត់មានសុខភាពល្អ បានរៀបការ និងជាឪពុកដែលមានកូនស្រីដ៏ស្អាតពីរនាក់ ។ បទពិសោធន៍នេះគឺជាគំរូមួយចំពោះខ្ញុំពីអំណាចនៃការអធិស្ឋាន ។

មានចម្រៀងរបស់កុមារមួយបទដែលមានចំណងជើងថា « ការអធិស្ឋានរបស់កុមារ » ។ វាត្រូវបានសួរថា « ព្រះវរបិតា តើទ្រង់ពិតជានៅទីនេះឬ ? តើទ្រង់ឮ និងឆ្លើយការអធិស្ឋានកុមារម្នាក់ៗឬ ? ( *សៀវភៅចម្រៀងកុមារាកុមារី* ទំព័រ 12 ) ។

ហើយចម្លើយពិតគឺ ៖ ពិតមែនហើយ ទ្រង់គង់នៅទីនោះ ។

ប្រសិនបើអ្នកធ្លាប់ឆ្ងល់ថាតើព្រះវរបិតាសួគ៌មានព្រះជន្មរស់មែនឬ នោះវាជាពេលដើម្បីលុតជង្គង់ចុះ ហើយទូលថា « ព្រះវរបិតាសួគ៌ តើទ្រង់នៅទីនោះឬ ? តើខ្ញុំពិតជារស់នៅជាមួយទ្រង់ពីមុនខ្ញុំមកផែនដីមែនទេ ? តើខ្ញុំអាចត្រឡប់ទៅរស់នៅជាមួយទ្រង់ម្ដងទៀតដែរឬទេ ? »

ទ្រង់នឹងឆ្លើយតបការអធិស្ឋានរបស់អ្នក ។ ទ្រង់នឹងធ្វើឱ្យអ្នកដឹងថាទ្រង់គង់នៅទីនោះ ។ អ្នកពុំមែន នៅម្នាក់ឯងនោះទេ ។ យើងត្រូវការទ្រង់ជានិច្ច ហើយទ្រង់គង់នៅទីនោះសម្រាប់យើង ។ ■



# សម្លៀកបំពាក់សមរម្យ

**ដោយសារ៉ា នៅ**

ផ្អែកលើលើដំណើររឿងពិត

*« ចូរធ្វើជាគំរូដល់ពួកអ្នកជឿ » ( ធីម៉ូថេ ទី 1 4:12 ) ។*




4. អាណា ស្រឡាញ់ស៊ីស្ទើរពីរនាក់នៅក្នុងវួដរបស់នាង ។ ពួកគេបានចាប់ដៃរបស់នាងនៅព្រះវិហារ ពួកគេញញឹម នៅពេលដែលនាងបានលើកដៃលាតាមផ្លូវ ហើយពួកគេបានអធិស្ឋានជាមួយក្រុមគ្រួសាររបស់នាង នៅពេលដែលពួកគេមកបរិភោគអាហារពេលល្ងាច ។
5. អាណា អន្ទះសារចង់បង្ហាញពីសម្លៀកបំពាក់ថ្មីរបស់នាងដល់ពួកអ្នកផ្សព្វផ្សាយសាសនានៅថ្ងៃអាទិត្យ ។ នៅពេលដែលនាងបានឃើញពួកគេនៅព្រះវិហារ នាងបានបង្វិលខ្លួនជុំវិញដាក់ពួកគេ ។
ខ្ញុំមើលទៅដូចជាស៊ិស្ទើរហើយឥឡូវនេះ !
6. ប្អូនពិតជាមើលទៅដូចជាពួកយើងណាស់ ។
ហើយប្អូនមិនត្រឹមតែ មើលទៅ ដូចជាអ្នកផ្សព្វផ្សាយសាសនាម្នាក់នោះទេ ប្អូនគឺជា អ្នកផ្សព្វផ្សាយសាសនាម្នាក់ !
7. ម្ដាយរបស់ប្អូនបានប្រាប់យើងថា ប្អូនបានអធិស្ឋានសម្រាប់យើងគ្រប់សប្ដាហ៍ដូចដែលយើងបានសុំ ។ ហើយមើលចុះ ! យើងបាននាំមនុស្សម្នាក់មកព្រះវិហារនៅថ្ងៃនេះ ។ ការអធិស្ឋានរបស់ប្អូនកំពុងតែជួយយើង ។
អរគុណ អ្នកផ្សាយសាសនា អាណា ។

# ខ្ញុំអាចធ្វើជាអ្នកផ្សព្វផ្សាយសាសនាក្នុងពេលឥឡូវនេះ !

ដោយ ហ៊ីការី ឡូរថាស់
និងហិឡារី វ៉តឃីន ឡៃមិន

អាន់ណាកំពុតតែព្យាយាមធ្វើតាមគំរូរបស់ពួកអ្នកផ្សព្វផ្សាយសាសនា ។ ធ្វើតាមសេចក្ដីណែនាំខាងក្រោមនេះ ដើម្បីនាងអាចធ្វើការជ្រើសរើសនានាដែលនឹងជួយនាងឱ្យក្លាយជាអ្នកផ្សព្វផ្សាយសាសនាម្នាក់នាពេលនេះ ។

**អ្នកនឹងត្រូវការ** ៖ គ្រាប់ឡុកឡាក់មួយ ឬក្រដាស់ប្រាំមួយបំណែកដែលមានពីលេខ 1 រហូតដល់លេខ 6 ដាក់នៅក្នុងស្បោងក្រដាស់តូចមួយ កាក់មួយ គ្រាប់សណ្ដែកស្ងួត ឬវត្ថុតូចៗផ្សេងទៀតសម្រាប់មនុស្សម្នាក់ៗ ។

**របៀបលេង** ៖ អ្នកលេងម្នាក់ៗជ្រើសវត្ថុតូចមួយដើម្បីប្រើជាបំណែកមួយនៃល្បែង ។ ផ្លាស់វេណគ្នា បោះគ្រាប់ឡុកឡាក់ ឬចាប់លេខនៅក្នុងស្បោងនោះ ហើយរំកិលបំណែកនៃល្បែងរបស់អ្នកតាមលេខដែលអ្នកបោះ ឬចាប់បាន ។ បើអ្នកឈប់នៅត្រង់កន្លែងមួយដែលប្រាប់ពីអ្វីមួយដែលអ្នកផ្សព្វផ្សាយសាសនាធ្វើ សូមរំកិលទៅមុខមួយជំហានទៀត ។ សូមប្ដូរវេណគ្នារហូតដល់គ្រប់គ្នាបានឆ្លងកាត់នូវបន្ទាត់ផ្ដាច់ព័ត្រ ជាកន្លែងដែលពួកអ្នកផ្សព្វផ្សាយសាសនាកំពុងរង់ចាំ !



# ជំនួយសម្រាប់ឪពុកម្ដាយ

សូមនិយាយនឹងកូនរបស់អ្នកអំពីរបៀបនៃការស្លៀកពាក់ថ្ងៃថ្នូរបានបង្ហាញពីការគោរពចំពោះព្រះវរបិតាសួគ៌ និងចំពោះខ្លួនឯង ។ សូមសួរពួកគេពីហេតុផលដែលពួកគេគិតថាអ្នកផ្សព្វផ្សាយសាសនាស្លៀកពាក់ត្រឹមត្រូវ ។

សូមពិចារណាក្នុងការចែកចាយនូវទីបន្ទាល់របស់អ្នកអំពីកិច្ចការផ្សាយសាសនាជាមួយនឹងកូនរបស់អ្នក ។ អ្នកអាចចែកចាយរឿងនៃការប្រែចិត្តជឿរបស់អ្នក បរិយាយអំពីបទពិសោធន៍ដែលអ្នកបានធ្វើកិច្ចការផ្សាយសាសនា ឬនិយាយអំពីមូលហេតុដែលកិច្ចការផ្សព្វផ្សាយសាសនាសំខាន់ចំពោះអ្នក ។



# ព័ត៌មានសាសនាចក្រ

*សម្រាប់ព័ត៌មាន និងព្រឹត្តការណ៍សាសនាចក្របន្ថែម សូមទស្សនាគេហទំព័រ news.lds.org*

## មជ្ឈមណ្ឌលបណ្ដុះបណ្ដាលមជ្ឈឹមវ័យវ័យក្មេង សម្រាប់ជំនាន់កំពុងពេញវ័យ

**ដោយ ស្ទេផានី ជេន ចនសុន**
ទស្សនាវដ្ដីសាសនាចក្រ

មជ្ឈមណ្ឌលសាសនាចក្រសម្រាប់ពួកមជ្ឈឹមវ័យវ័យក្មេង គឺមិនគ្រាន់តែផ្ដោតទៅលើការពារជំនាន់កំពុងពេញវ័យពីការល្បួងទាំងឡាយរបស់លោកិយប៉ុណ្ណោះទេ — មជ្ឈមណ្ឌលគឺកំពុងតែរៀបចំពួកអ្នកដឹកនាំ នាពេលបច្ចុប្បន្ន និងពេលអនាគតរបស់សាសនាចក្រ ដើម្បីផ្លាស់ប្ដូរពិភពលោកផងដែរ ។

ដូចគ្នាទៅនឹងការរីកចម្រើននៃកម្មវិធីថ្នាក់វិទ្យាស្ថានដែរ មជ្ឈមណ្ឌលសម្រាប់ មជ្ឈឹមវ័យវ័យក្មេង — ដែលមានដំបូងគេនៅក្នុងទ្វីបអឺរ៉ុប — បានផ្ដល់ជាថ្នាក់រៀនអំពីសាសនា ក៏ជាកន្លែងមួយដែល ពួកមជ្ឈឹមវ័យវ័យក្មេងអាចប្រមូលផ្ដុំគ្នា ដើម្បីរៀបចំសកម្មភាពទាំងឡាយ ក្រៅពីការចំអិនអាហារពេលល្ងាច មកជាការធ្វើកិច្ចការសាសនា ងាកពីការលេងប៉េងប៉ុង ទៅជាការចែកចាយដំណឹងល្អ ។

### ការរីកចម្រើនរបស់សាសនាចក្រ តាមរយៈពួកមជ្ឈឹមវ័យវ័យក្មេង

មកដល់ចុងឆ្នាំ 2003 កម្មវិធីមជ្ឈមណ្ឌលសម្រាប់មជ្ឈឹមវ័យវ័យក្មេងបានចាប់ផ្ដើមឡើង ដោយមានមជ្ឈមណ្ឌលចំនួនបួន បានបើកនៅក្នុងទីក្រុងខាផីនហេហ្គេន ប្រទេស ដាណាម៉ាក និងទីក្រុងប៊ើរលីន ប្រទេស ហ៊ាមប័រ និងទីក្រុងលីអ៊ីសឹក ប្រទេស អាល្លឺម៉ង់ ។ អែលឌើរ អិល ថម ភែរី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានជួយលើកទឹកចិត្តបន្ថែម ដល់ការរីកចម្រើននៃកម្មវិធីនេះ នៅពេលប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី (ឆ្នាំ 1910–2008) បានហៅលោកឱ្យធ្វើជាអធិបតីលើតំបន់អឺរ៉ុប កណ្ដាលក្នុងឆ្នាំ 2004 ។

យោងតាមសម្ដីរបស់ អ៊ីរ៉ក ភីស្ទូតា ជាសហការីនាយកតំបន់នាពេលបច្ចុប្បន្ន នៃថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន នៅក្នុង ទ្វីបអឺរ៉ុប ពួកអ្នកដឹកនាំបព្វជិតភាពជាច្រើន នៅក្នុងទ្វីបអឺរ៉ុបបច្ចុប្បន្ន ក្នុងពេលនោះមានអាយុក្រោម 30 ឆ្នាំ ។

បងប្រុស ភីស្ទូតាបាននិយាយថា « ចំណាប់អារម្មណ៍ខាងវិញ្ញាណ ដែលអែលឌើរ ភែរី មានអំពីការរីកចម្រើនរបស់សាសនាចក្រនៅក្នុងទ្វីបអឺរ៉ុប នឹងកើតមានតាមរយៈអ្នកដែលមានអាយុ 18 ឆ្នាំ ដល់ 30 ឆ្នាំ ដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើ ពួកមជ្ឈឹមវ័យវ័យក្មេង និងពួកអ្នកដឹកនាំបព្វជិតភាព នៅគ្រប់កម្រិតទាំងអស់ក្នុងទ្វីបអឺរ៉ុប » ។ ចំណាប់អារម្មណ៍របស់អែលឌើរ ភែរី គឺនៅតែសំខាន់ចំពោះ ពួកមជ្ឈឹមវ័យវ័យក្មេងសព្វថ្ងៃនេះ លោកបានបន្តថា « ពីព្រោះវាជួយពួកគេ ឱ្យយល់ពីការទទួលខុសត្រូវរបស់ពួកគេចំពោះការរីកចម្រើនរបស់សាសនាចក្រ » ។

សព្វថ្ងៃនេះ មានមជ្ឈមណ្ឌលច្រើនជាង 140 កន្លែងនៅក្នុងទ្វីប អឺរ៉ុប ដោយមាន មជ្ឈមណ្ឌលចំនួន 30 បន្ថែមទៀតកំពុងដំណើរការ ។ មជ្ឈមណ្ឌលទាំងអស់ រៀបចំជំនាន់កំពុងពេញវ័យ ឱ្យផ្សាយដំណឹងល្អទៅកាន់ពិភពលោក ។

### ការកសាងនគរ និងមិត្តភាពនៅក្នុងប្រទេស ណ័រវេ

មជ្ឈមណ្ឌល មជ្ឈឹមវ័យវ័យក្មេង នៅក្នុងអូស្លូ ប្រទេសណ័រវេ គឺជាមជ្ឈមណ្ឌលមួយនៃមជ្ឈមណ្ឌលជាច្រើនដែលមជ្ឈឹមវ័យវ័យក្មេងទាំងឡាយកំពុងតែរៀនពីរបៀបដើម្បីកសាងនគរ ។ ថាគី ម៉ាធីលឌី ហ្គោឡោមីត មកពីប្រទេសបារាំង ។ ពួកអ្នកផ្សព្វផ្សាយសាសនា បានចាប់ផ្ដើមបង្រៀននាង នៅក្នុងមជ្ឈមណ្ឌលមួយនៅទីក្រុងប៉ារីស ក្នុងឆ្នាំ 2009 បន្ទាប់ពីមិត្តភិក្ដរបស់បងស្រីហ្គោឡោមីតបានអញ្ជើញនាង ឱ្យរៀនបន្ថែមពីដំណឹងល្អ ។

បងស្រី ហ្គោឡោមីតបានជ្រមុជទឹកនៅក្នុងឆ្នាំ 2010 ហើយបន្ទាប់មកបានផ្លាស់ទៅរស់នៅណ័រវេរយៈពេលមួយឆ្នាំ ជាកន្លែងដែលមជ្ឈមណ្ឌលសម្រាប់ពួកមជ្ឈឹមវ័យវ័យក្មេង បានបន្ដដើរតួយ៉ាងសំខាន់នៅក្នុងការរីកចម្រើនទីបន្ទាល់របស់នាង ។

បងស្រី ហ្គោឡោមីត បាននិយាយថា « មជ្ឈមណ្ឌល គឺដូចជាគេហដ្ឋានមួយទៀត ។ ប្រាកដណាស់ថា វាមានភាពកក់ក្ដៅ ជាងបន្ទប់ស្នាក់នៅរបស់ខ្ញុំទៅទៀត » ។ « អ្នកផ្សព្វផ្សាយសាសនាជាប្ដីប្រពន្ធក្នុងមជ្ឈមណ្ឌល គឺដូចជាឪពុកម្ដាយ — ជាមនុស្សដ៏អស្ចារ្យដើម្បីទៅជួបដើម្បីទទួលការលួងលោមចិត្ត និងដំបូន្មាន ។ ទាំងនៅទីក្រុងប៉ារីស និងទីក្រុងអូស្លូ ខ្ញុំអាចទៅជួបអ្នកផ្សព្វផ្សាយសាសនាជាប្ដីប្រពន្ធ ដើម្បីនិយាយអំពីដំណឹងល្អ ដែលខ្ញុំពុំអាចធ្វើបាននៅផ្ទះ ដោយគិតថាខ្ញុំ គឺជាសមាជិក តែម្នាក់ឯងនៅក្នុងគ្រួសារខ្ញុំ » ។

សែម ប៉ាសទីត បានជ្រមុជទឹកនៅឆ្នាំ 2009 ក៏ជាសមាជិកតែម្នាក់ឯងនៅក្នុងគ្រួសាររបស់គាត់ដែរ ។ ការធ្វើកិច្ចការអ្នកផ្សព្វផ្សាយសាសនានៅក្នុងមជ្ឈមណ្ឌលអូស្លូ បានជួយគាត់ ឱ្យចែកចាយដំណឹងល្អជាមួយនឹងសាច់ញាតិរបស់គាត់ នៅពេលគាត់បានត្រឡប់ទៅជួបពួកគេវិញ នៅប្រទេសណេប៉ាល់ ។ គាត់បានប្រាប់ពួកគេ អំពីបព្វជិតភាព និងព្រះគម្ពីរមរមន ដោយធ្លាប់បានជួយដល់ពួកអ្នកផ្សព្វផ្សាយសាសនាបង្រៀនមនុស្សឯទៀត នូវគោលការណ៍ដដែលនេះនៅក្នុងអូស្លូរួចហើយ ។

បងប្រុស បាសទីត បាននិយាយថា « គ្រួសាររបស់ខ្ញុំចង់មានអារម្មណ៍ដូចដែលខ្ញុំកំពុងតែមាននេះ » ។ « ពួកគាត់បានឃើញនូវភាពខុសប្លែកគ្នារវាង 'សែមពីមុន' និង 'សែមឥឡូវ' ។ ពីមុន ខ្ញុំគ្មានសេចក្ដីសង្ឃឹមទេ ។ ខ្ញុំគ្មានគំនិតវិជ្ជមានទេ ។ បន្ទាប់ពីពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំ ខ្ញុំធ្លាប់ចូលទៅ



*មជ្ឈមណ្ឌលទាំងឡាយសម្រាប់ពួកមជ្ឈឹមវ័យវ័យក្មេង គឺជាកន្លែងប្រមូលផ្តុំមួយ ដែលជំនាន់កំពុងពេញ វ័យ អាចរៀបចំខ្លួនដើម្បីមានឥទ្ធិពលលើពិភពលោក តាមរយៈសារដំណឹងល្អ ។*

ក្នុងមជ្ឈមមណ្ឌល ហើយអ្វីគ្រប់យ៉ាងមានភាពល្អប្រសើរជាងពីមុន » ។

មិនមែន តែបងប្រុសបាសទីតតែម្នាក់ប៉ុណ្ណោះទេ ដែលមានអារម្មណ៍ត្រូវបាន លើកស្ទួយនិងជម្រុញចិត្តដោយព្រះវិញ្ញាណ នៅក្នុងមជ្ឈមណ្ឌលនោះ ។ បេនយ៉ាមីន ហ្គ័រ មកពីប្រទេសស្កុតឡែន បានចំណាយពេលពីររដូវក្ដៅកន្លងទៅធ្វើការ នៅក្នុងអូស្លូ ហើយមើលឃើញមជ្ឈមណ្ឌល ដូចជាកន្លែងមួយដែលគាត់ចាំអំពីអ្វីដែលសំខាន់ពិតប្រាកដ ។

បងប្រុស ហ្គ័រ បាននិយាយថា « មជ្ឈមណ្ឌល គឺជាទីជម្រករបស់ខ្ញុំចេញពីលោកិយ » ។ « ខ្ញុំពិតជាមានអារម្មណ៍ សុខសាន្ត និងសុវត្ថិភាពមួយណាស់ពេលខ្ញុំនៅទីនោះ ។ ខ្ញុំគិតអំពីបទពិសោធន៍ដែលលើកទឹកចិត្តខ្លាំងបំផុតមួយចំនួនរបស់ខ្ញុំ វាកើតមានមកពីខ្ញុំអាចមកអង្គុយនៅក្នុងមជ្ឈមណ្ឌលនេះ ជាពិសេសនៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ហើយពិភាក្សាអំពីរឿងទាំងឡាយដែលធ្វើឱ្យយើងខ្វាយខ្វល់ខ្លាំង និងរឿងទាំងឡាយដែលយើងគិតថាពិបាក ។ បទពិសោធន៍ទាំងនេះ បានរំឭកខ្ញុំ អំពីសារៈសំខាន់នៃគោលការណ៍សាមញ្ញទាំងឡាយនៃដំណឹងល្អ » ។

## ការបណ្ដុះបណ្ដាលពួកមជ្ឈឹមវ័យវ័យក្មេង និងពួកអ្នកដឹកនាំនាពេលអនាគត

មជ្ឈមណ្ឌល សម្រាប់ពួកមជ្ឈឹមវ័យវ័យក្មេងទាំងឡាយ គឺធ្វើការច្រើនជាងការជួយដល់យុវវ័យពង្រឹងដល់មិត្តភក្តិ និងគ្រួសាររបស់ពួកគេនៅក្នុងដំណឹងល្អ ។ មជ្ឈមណ្ឌល គឺកំពុងតែបណ្ដុះបណ្ដាលពួកអ្នកដឹកនាំ ។ ពួកមជ្ឈឹមវ័យវ័យក្មេងនៅលីវ ត្រូវបានហៅឱ្យបម្រើក្នុងក្រុមប្រឹក្សា ថ្នាក់ដឹកនាំផ្លាស់វេណគ្នានៅក្នុងមជ្ឈមណ្ឌលទាំងឡាយ ហើយរៀបចំសកម្មភាព និងថ្នាក់រៀនផ្សេងៗ ។

បាបារ៉ា ម៉ាតូរ៉ូ ដែលមានដើមកំណើតជាជនជាតិយូហ្គានដា ប៉ុន្តែឥឡូវជាពលរដ្ឋណ័រវេម្នាក់ នាងបាននិយាយថា បទពិសោធន៍មួយនេះបានផ្ដល់ « ជាឱកាសដើម្បីទទួលបទពិសោធន៍សេចក្ដីស្រឡាញ់របស់ព្រះដែលមានសម្រាប់កូនចៅទាំងអស់របស់ទ្រង់ » ។ « វាបានពង្រឹងដល់ទីបន្ទាល់របស់ខ្ញុំ អំពីអង្គការរបស់សាសនាចក្រ ។ វាក៏បានបង្រៀនខ្ញុំផងដែរថា នគររបស់ព្រះ មិនអាចត្រូវបានកសាងឡើង ដោយមនុស្សតែម្នាក់ឡើយ ប៉ុន្តែកសាងឡើងដោយមនុស្សជាច្រើននាក់រួមគ្នាដោយសាមគ្គីភាព » ។

ខណៈដែលពួកមជ្ឈឹមវ័យវ័យក្មេង កំពុងតែទទួលការបំពាក់បំប៉ន់ដើម្បីអាចបម្រើនៅក្នុងការហៅក្នុងសាសនាចក្រនាពេលអនាគត ពួកគេក៏កំពុងតែទទួលនូវបទពិសោធន៍ ដែលនឹងជួយគេឱ្យក្លាយជាប្ដីឬប្រពន្ធ និងជាឪពុកឬម្ដាយ ដែលមានប្រសិទ្ធភាពផងដែរ ។ ពួកគេនឹងត្រូវបានរៀបចំ ដើម្បីផ្លាស់ប្ដូរពិភពលោក មិនគ្រាន់តែនៅក្នុងទីសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងគេហដ្ឋានផងដែរ ។

ហ្គូរ៉ាត និងភរិយារបស់គាត់ ណាន់ស៊ី ដែលបានបម្រើក្នុងមជ្ឈមណ្ឌលនៅត្រូនហ៊ីអម ប្រទេសណ័រវេ បាននិយាយថា « គោលការណ៍ថ្នាក់ដឹកនាំទាំងឡាយ ដែលបានរៀននៅក្នុងក្រុមប្រឹក្សាមជ្ឈឹមវ័យវ័យក្មេងនៅលីវ គឺដូចគ្នានឹងគោលការណ៍ទាំងឡាយ ដែលនឹងបម្រើដល់ ពួកមជ្ឈឹមវ័យវ័យក្មេងនៅលីវ ក៏ដូចជារបស់ឪពុកម្ដាយទាំងឡាយ អំពី — ការអត់ធ្មត់ ការទំនាក់ទំនង ការផ្ដល់ការណែនាំ និងការអនុញ្ញាតឱ្យមនុស្សប្រើសិទ្ធិជ្រើសរើសរបស់ពួកគេ ដើម្បីបំពេញកិច្ចការមួយ ហើយនិងការធ្វើតាមការបំផុសគំនិតទាំងឡាយរបស់ព្រះវិញ្ញាណ » ។

មជ្ឈមណ្ឌលទាំងឡាយសម្រាប់ពួកមជ្ឈឹមវ័យវ័យក្មេង នឹងបន្តប្រយុទ្ធប្រឆាំងនឹងអំពើបាប ដែលកំពុងតែរាលដាល នៅក្នុងពិភពលោក ដោយការធ្វើការដើម្បីប្រាកដថា ពួកអ្នកដឹកនាំនាពេលអនាគត របស់សាសនាចក្រ កំពុងតែរីកលូតលាស់កាន់តែឆាប់រហ័ស ។

បងប្រុស ភីសូតាបាននិយាយថា « ពួកមជ្ឈឹមវ័យវ័យក្មេងមកកាន់មជ្ឈមណ្ឌល ដើម្បីរៀនដឹងពីដំណឹងល្អ មិនមែនដឹងតែទ្រឹស្ដីប៉ុណ្ណោះទេ ប៉ុន្តែដោយការអនុវត្តន៍គោលការណ៍ទាំងឡាយ នៃការចែកចាយដំណឹងល្អ និងការបម្រើដល់មត្តិភក្តិរបស់ពួកគេ ដែលពុំមានជំនឿដូចជាពួកយើង » ។ « មជ្ឈមណ្ឌលទាំងឡាយ ជួយដល់មនុស្សជំនាន់ថ្មី និងជំនាន់ដែលបានរៀបចំយ៉ាងល្អ ដើម្បីបម្រើព្រះអម្ចាស់ដោយភាពក្លៀវក្លា និងដោយទស្សនៈវិស័យដ៏អស់កល្បជានិច្ចមួយ » ។ ■

# ពួកបរិសុទ្ធ នៅក្នុងប្រទេស ប្រេស៊ីល និង ចក្រភពអង់គ្លេស ចូលរួមនៅក្នុងថ្ងៃនៃការបម្រើ

បារប់តាំងពីគណៈប្រធានទីមួយបានអញ្ជើញសមាជិកគ្រប់រូបនៃសាសនាចក្រ កាលពីខែមេសាមុនឱ្យចូលរួម នៅក្នុងថ្ងៃនៃការបម្រើមួយអំឡុងពេលដើមឆ្នាំ នោះពួកបរិសុទ្ធនៅទូទាំងពិភពលោក ។ បានឆ្លើយតបចំពោះការអញ្ជើញនោះ ។ យ៉ាងហោចណាស់មាន ជាតិសាសន៍ចំនួនពីរគឺ — ចក្រភពអង់គ្លេស និង ប្រទេសប្រេស៊ីល — បានចូលរួម នៅក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នាមួយ ជាមួយនឹងសមាជិកដទៃទៀតនៅទូទាំងប្រទេសរបស់ពួកគេរៀងៗខ្លួន ។

**ចក្រភពអង់គ្លេស**

នៅថ្ងៃចន្ទ ទី 5 ខែ កញ្ញា ឆ្នាំ 2011 សមាជិកមកពី ស្តេកចំនួន 11 នៅក្នុងប្រទេសអង់គ្លេស ព្រមទាំងប្រធានតំបន់ អ៊ីរិច ដបុលយូ កូពីសឆ្កេរ នៃពួកចិតសិបនាក់ បានជួបជុំគ្នាធ្វើគម្រោងដៃជំនួយនៅក្នុងតូទីនហែម ម៉ាហ្សិស ។

ព្រឹត្តិការណ៍នោះ ពុំគ្រាន់តែបង្ហាញឱ្យឃើញពីបុណ្យគំរប់ខួបលើកទី 75 ឆ្នាំ នៃកម្មវិធីសុខមាលភាពរបស់សាសនាចក្រប៉ុណ្ណោះទេ ប៉ុន្តែ ក៏ជាការចាប់ផ្តើម យុទ្ធនាការនៃការសំអាតតាមផ្លូវរដ្ឋធានីរបស់ទីក្រុងឡុង ប្រចាំ ឆ្នាំ 2011 ជាផ្លូវការសារជាថ្មីម្តងទៀតផងដែរ ។ — នៅជាប់កែងត្រង់ការិយាល័យរបស់ចៅហ្វាយក្រុង — សមាជិកបានដកស្មៅ បានដាំស្ទូនផ្កា ចាំងឈើ កាត់មែកឈើដែលដុះលយចេញមក និងយកសម្រាមចេញពីសួន លី វីលី ។

នៅក្នុងថ្ងៃដដែលនោះដែរ ពួកសមាជិកនៅតំបន់ផ្សេងទៀតនៃទីក្រុងឡុង បានចូលរួមនៅក្នុងគម្រោង ដៃជំនួយ នៅ ពេទ្យកុមារហើរីនហោ និងពេទ្យកុមារ រីឆាតហោ ។

នៅ រីឆាតហោ មានសមាជិក 18 នាក់មកពីរ៉ូដ ស្ត្រាហ្វត់ បានលាបថ្នាំកន្លែងការិយាល័យមួយ បានដកស្មៅ កាត់ដើមឈើ បោសទីធ្លា និងជួសជុសឧបករណ៍ប្រើប្រាស់ជាច្រើន ។ ឆាឡូទី អ៊ុលឡារ៉ា ជាអ្នកគ្រប់គ្រងគម្រោងសម្រាប់គំម្រោងការបម្រើនៅពេទ្យកុមាររីឆាតហោ បាននិយាយថា នេះគឺជាការទំនាក់ទំនងដំបូងគេរបស់ពេទ្យកុមារ ជាមួយនឹងសាសនាចក្រ ។

គាត់បាននិយាយថា « ខ្ញុំបានរំភើបចិត្តយ៉ាងខ្លាំង ជាមួយនឹងរបៀបដែលពួកអ្នកស្ម័គ្រចិត្តបានធ្វើកិច្ចការរបស់គេដោយចិត្តក្លៀវក្លា និងអំណរ » ។ « សូម្បីតែកិច្ចការដ៏សាមញ្ញមួយ ដូចជាការបោសសំអាតផ្លូវ ក៏ត្រូវបានសំអាតយ៉ាងល្អបំផុតដែរ » ។

ជាច្រើនខែកន្លងមកនេះ ពួកសមាជិកសាសនាចក្រ នៅក្នុង គ្រែត ប្រិធិន និង អ៊ិរលែន ប៉ែកខាងត្បូង បានរៀបចំ និង ចូលរួមនៅក្នុងគម្រោង នៃការបម្រើយ៉ាងច្រើននៅទូទាំងប្រទេស ។

*មានស្តេកច្រើនជាង 11 ស្តេកមកពីប្រទេសអង់គ្លេស បានមកជួបជុំគ្នានៅថ្ងៃទី 5 ខែ កញ្ញា ឆ្នាំ 20011 ដើម្បីសម្តែងគម្រោងការបម្រើក្នុងតំបន់បីផ្សេងគ្នានៅក្នុង និងនៅជុំវិញទីក្រុងឡុង ។*



### ប្រេស៊ីល

នៅថ្ងៃទី 30 ខែ កក្កដា ឆ្នាំ 2011 ក្រុមអារកាត់ពិណលឿងបានគ្រប់គ្រងទិដ្ឋភាពគម្រោងនៃការបម្រើ រាប់រយកន្លែងនៅទូទាំងប្រទេសប្រេស៊ីល នៅក្នុងពិធីប្រារព្ធខួប លើកទី 12 នៃដៃជំនួយមរមន ជាកម្មវិធីមួយរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលព្យាយាមផ្ដល់ការបម្រើដល់សហគមន៍ និង ជួយសង្គ្រោះដល់ជនទុរគតិពីគ្រោះមហន្តរាយ ។

ជាក់ស្ដែង ដៃជំនួយមរមន (*Mãos que Ajudam*) បានបង្កើតឡើងនៅក្នុងប្រទេសប្រេស៊ីល ជាមធ្យោបាយ ដើម្បីធ្វើឱ្យមិត្តភក្ដិ និងអ្នកជិតខាង ស្គាល់ពីកិច្ចខិតខំប្រឹងប្រែង ខាងមនុស្សធម៌របស់សាសនាចក្រ ។ ឥឡូវវាបានប្រែក្លាយជាព្រឹត្តិការណ៍ដ៏ធំមួយប្រចាំឆ្នាំ ។

ថ្ងៃនៃការបម្រើក្នុងឆ្នាំនេះ គឺពោរពេញទៅដោយការច្រៀង ការសើច និងការទះដៃសរសើរ នៅពេល បុរស ស្ត្រី និងកុមារាកុមារីចំនួន 120,000 នាក់ បានបោសសំអាតដងផ្លូវ សំអាតសាលារៀន ជួសជុលអាគារកែលំអរសួនច្បារ ហើយបានចូលរួមនៅក្នុងគម្រោងបម្រើដទៃទៀត នៅក្នុងប្រទេសអាមេរិកឡាទីនដែលជាប្រទេសធំជាងគេ និងមានចំនួនប្រជាជនច្រើនជាងគេបំផុត ។ ពួកសមាជិកសាសនាចក្របានចាប់ដៃគ្នាជាមួយនឹងពួកសមាជិកក្នុងសហគមន៍ដើម្បីផ្ដល់ការបម្រើដែលនឹងជាប្រយោជន៍សម្រាប់មនុស្សគ្រប់គ្នា ។

នៅ រដ្ឋប៉ឺឡូ ហូរីស៊ុនទី ប្រទេស រីស៊ីហ្វី និង ប្រទេស បាហៃ មានពួកអ្នកស្ម័គ្រចិត្តច្រើនជាង 6,000 នាក់បានធ្វើចលនាប្រយុទ្ធប្រឆាំងនឹងជំងឺគ្រុនឈាម ។ នៅ រីអូ ឌឺ ចេនីរីអូ ពួកអ្នកស្ម័គ្រចិត្តបានសំអាត សាលារៀនរដ្ឋ និង មជ្ឈមណ្ឌលគាំពារទាំងឡាយ ។ នៅក្នុង ភូតូ អាលីហ្គ្រិ ពួកអ្នកស្ម័គ្រចិត្តចំនួន 1,500 នាក់បានសំអាតសាលារៀន និងខ្លះទៀតបានចូលរួមនៅក្នុងការបង្រៀនអំពីការកាពារពីការប្រើប្រាស់ថ្នាំញៀន ។

រយៈពេល ពីរខែកន្លងទៅនេះ មុនពេលថ្ងៃនៃការបម្រើ មានពួកអ្នកស្ម័គ្រចិត្ត ច្រើនជាង 500 នាក់ បានធ្វើការដើម្បីប្រមូលអាហារដែលបានបរិច្ចាគ ហើយបានផ្ដល់ទៅឱ្យក្រុមគ្រួសារទ័លក្រចំនួន 175 គ្រួសារនៅរដ្ឋសៅ ផូស៊ី នៅថ្ងៃទី 30 ខែ កក្កដា ។

ពួកសមាជិកនៅក្នុង បូមែនអូ បានបរិច្ចាគអាហារប្រហែល 300 ផោន (136 គីឡូក្រាម) ទៅឱ្យ *Casa de Apoio às Crianças Portadoras de Mielomeningocele e Neoplasia* (ទីជម្រក គាំទ្រដល់កុមារពិការពីកំណើតនិងដុះសាច់) ។ ពួកអ្នកស្ម័គ្រក៏បានបង្រៀនពីគោលការណ៍គ្រឹះក្នុងការស្តុកទុកអាហារទៅកាន់ស្ថាប័នផងដែរ ។

អ្នកធ្វើការខាងសង្គមកិច្ច អេឌ្រៀន ដេបេតិស រ៉ូហ្វ បាននិយាយថា « វិធីដែលយើងបានរៀន នឹងជួយយើងឱ្យចេះរក្សាទុកអាហារនៅក្នុងទូអាហាររបស់យើង ពីព្រោះអាហារភាគច្រើនរបស់យើងត្រូវខូចនៅក្នុងកន្លែងដែលសើម » ។ ■

***កំណត់ចំណាំរបស់អ្នកបោះពុម្ពផ្សាយ ៖*** *សូមចែកចាយបទពិសោធន៍ ថ្ងៃនៃការបម្រើរបស់អ្នកតាមគេហទំព័រ lds.org/service/welfare-75th-anniversary ។*

### បច្ចុប្បន្នភាព

ចំណងជើងរូបថតនៅទំព័រ 73 នៃ *លីអាហូណា* ខែ តុលា ឆ្នាំ 2011 គួរតែអានថា « ថតរូបដោយ មីហ្គាន គុលមែន » ។ ■

## ប្រធានបទម៉្យូតឆល ឆ្នាំ 2012 បានប្រកាសថា ៖ « ចូរក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ »

ប្រធានបទម៉្យូឆលសម្រាប់ឆ្នាំ 2012 គឺ « ចូរក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ ប្រយោជន៍ឱ្យពន្លឺរបស់អ្នកអាចបានទៅជាបមាណីយដល់សាសន៍នានា » (គ. និង ស. 115:5) ។

បទគម្ពីរនេះបានផ្ដល់ជាចំណែកនៃវិវរណៈមួយ ចំពោះព្យាការី យ៉ូសែប ស្ម៊ីធ នៅ ហ្វារវែស្ទ រដ្ឋមិសសួរី សហរដ្ឋអាមេរិក នៅក្នុងឆ្នាំ 1838 ដែលត្រូវបានថ្លែងទៅកាន់ ពួកអ្នកកាន់តំណែងជាអធិបតីនៃសាសនាចក្រនៅគ្រានោះ ប៉ុន្តែ ក៏ដូចជាប្រធានបទម៉្យូតឆល ដែលអនុវត្តចំពោះយុវវ័យដែលមានអាយុពី 12 ដល់ 18 ឆ្នាំ នៅទូទាំងសាសនាចក្រផងដែរ ។

ប្រធានបទនេះអាចត្រូវបានប្រើប្រាស់ដើម្បីជួយឱ្យកម្មវិធីបើករបស់ម៉្យូតឆលកាន់តែប្រសើរឡើង ប្រើជាប្រធានបទសម្រាប់ការឡើងនិយាយរបស់ពួកយុវវ័យនៅក្នុងការប្រជុំសាក្រាម៉ង់ និងដើម្បីផ្ដល់នូវជាសកម្មភាពផ្ដោតយកចិត្តទុកដាក់ដល់យុវវ័យ ដូចជាការបោះជំរំ សន្និសីទយុវវ័យ និងការប្រជុំធម្មនិដ្ឋាននានា ។ វាក៏អាចត្រូវបានប្រើប្រាស់ជាការផ្ដោតយកចិត្តទុកដាក់ទៅលើព្រឹត្តិការណ៍វប្បធម៌ពិសេសៗ ឬការរាំ តន្ត្រី និងសកម្មភាពសម្ដែងដទៃទៀត ។

ពួកអ្នកដឹកនាំសាសនាចក្រ ស្នើរសុំឱ្យ ពួកអ្នកដឹកនាំយុវវ័យប្រចាំតំបន់ ណែនាំប្រធានបទនេះ ជាមួយនឹង ឌី វី ឌី អំពី *Strength of Youth Media 2012: Arise and Shine Forth,* ដែលនឹងត្រូវផ្ញើរក្នុង អង្គភាពនានា នៅខែ វិច្ឆិកា ឆ្នាំ 2011 ។

ឌី វី ឌី នេះអាចត្រូវបានប្រើប្រាស់បន្ថែមទៅលើការប្រជុំ កូរ៉ុមក្នុងថ្នាក់រៀន សន្និសីទយុវវ័យ និងសកម្មភាពដទៃទៀតរបស់យុវវ័យនៅពេញមួយឆ្នាំ ហើយវានឹងមានជាភាសា ចិនកាតាំង អង់គ្លេស បារាំង អាល្លឺម៉ង់ អ៊ីតាលី ជប៉ុន កូរ៉េ ចិនកុកងឺ ព័រទុយហ្គាល់ រុស្ស៊ី និងភាសាអេស្ប៉ាញ ។

សម្ភារៈជំនួយបន្ថែមទៀត នឹងមាននៅក្នុងទស្សនាវដ្ដី *លីអាហូណា* និង *New Era* និង នៅលើគេហទំព័រ *LDS.org* នៅដើមឆ្នាំ 2012 ។ ■

## សាលាប្រជុំមានតាមអ៊ីនធើរណិតទូទាំងពិភពលោក

សាសនាចក្រដាក់ផែនការដើម្បីធ្វើឱ្យអ៊ីនធើណិតដែលមានល្បឿនលឿន ជាមួយនឹងប្រព័ន្ធបណ្ដាញឥតខ្សែ មានសម្រាប់សាលាប្រជុំទូទាំងពិភពលោកចំនួន 85 ភាគរយ ។

ពួកសមាជិក នឹងអាចប្រើគេហទំព័រស្វែងរកការងាររបស់សាសនាចក្រ ហើយចូលរួមនៅក្នុងកិច្ចការពង្សប្រវត្តិ ពីសាសាប្រជុំរបស់ពួកគេ ហើយពួកអ្នកដឹកនាំសាសនាចក្រ នឹងអាចគ្រប់គ្រងកំណត់ត្រា ដាក់ផ្ញើរទម្រង់បែបបទអ្នកផ្សព្វផ្សាយសាសនា និងចូលរួមនៅក្នុងការចាក់ផ្សាយបំពាក់បំប៉នថ្នាក់ដឹកនាំ ហើយគ្រូបង្រៀន នឹងអាចប្រើប្រាស់ព័ត៌មានដែលផលិតដោយសាសនាចក្រតាមអ៊ីនធើរណិតដើម្បីជួយបន្ថែមក្នុងមេរៀនរបស់ពួកគេ ។ ■

## សាសនាចក្រផ្ដល់ជំនួយសម្រាប់គ្រោះទុរភិក្សនៅអាហ្វ្រិកខាងកើត

ដោយមានមនុស្សច្រើនជាង 11.5 លាននាក់នៅអាហ្វ្រិកខាងកើត ដែលត្រូវការជំនួយជាបន្ទាន់ ពីស្ថានភាពនៃគ្រោះរាំងស្ងួតយ៉ាងអាក្រក់ សាសនាចក្រកំពុងធ្វើការជាមួយអង្គការនានា ដើម្បីជួយសម្រាលភាពអត់ឃ្លានតាមទម្រង់ផ្ដល់ ជាម្ហូបអាហារ ថ្នាំពេទ្យ ផ្នែកអនាម័យ សម្ភារៈនានា និងទីជម្រក ។

ពួកសមាជិកដែលមានបំណងប្រាថ្នាចង់ជួយដោយការប្រឹងប្រែង អាចបរិច្ចាគដល់មូលនិធិសប្បុរសធម៌ ។ ■

## បទពិសោធន៍នៅអឹម ធី ស៊ី ពង្រីកការបំពាក់បំប៉នដល់អ្នកផ្សព្វផ្សាយសាសនាថ្មីនៅក្នុងតំបន់បេសកកម្ម

ការប្រឹងប្រែងមួយបានចាប់ផ្ដើមឡើងនៅខែសីហា ឆ្នាំ 2011 គឺកំពុងតែនាំការបំពាក់បំប៉នដល់ពួកអ្នកផ្សព្វផ្សាយសាសនាចំនួន 12 សប្ដាហ៍បន្ថែមទៀត ដល់អ្នកដែលទើបតែចាកចេញពីមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា ។

រីឆាត ហ៊ីតុន ជានាយកគ្រប់គ្រងអឹម ធី ស៊ីប្រូវ៉ូ បានពន្យល់ថា នៅក្នុងការបំពាក់បំប៉នក្នុងតំបន់បេសកកម្ម មិនមែនជាកម្មវិធីថ្មីទេ ប៉ុន្តែជាការបំពាក់បំប៉នបន្ថែមមួយទៅលើការបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា នៅក្នុងអឹម ធី ស៊ី ។

គាត់បានមានប្រសាសន៍ថា « *សៀវភៅសិក្សារយៈពេល 12 សប្ដាហ៍ដំបូង* ចង្អុលប្រាប់ដល់អ្នកបង្ហាត់បង្រៀន និងដៃគូរអ្នកផ្សព្វផ្សាយសាសនាថ្មីរបស់ពួកគេ ទៅមើលធនធាននៅក្នុង *ប្រកាសដំណឹងល្អយើង* ដែលពួកគេត្រូវការខ្លាំងបំផុតនៅក្នុងរយៈពេល 12 សប្ដាហ៍ដំបូងរបស់ពួកគេ » ។ « វាគឺជាផែនទីផ្លូវមួយប្រាប់ពីរបៀបដើម្បី ... ធ្វើកិច្ចការបានពេញលេញក្នុងនាមជាពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ឱ្យលឿនបំផុតតាមដែលអាចធ្វើបាន » ។

ប្រធានបេសកកម្មទាំងឡាយ បានចាប់ផ្ដើមអនុវត្តសម្ភារៈការបំពាក់បំប៉នក្នុងតំបន់បេសកកម្ម សម្រាប់ពួកអ្នកផ្សព្វផ្សាយសាសនាថ្មីយ៉ាងឆាប់រហ័សបំផុត — ដែលមានរួមបញ្ចូលនូវឯកសារការបំពាក់បំប៉នចំនួនបី និងវីដេអូ វគ្គការសិក្សាជាដៃគូរថ្មី — ។ ■

*សូមអានបន្ថែមទៀតពីរឿងទាំងនេះ — និងរឿងផ្សេងទៀតនៅលើគេហទំព័រ — news.lds.org ។*

# ព័ត៌មានខ្លីៗអំពីពិភពលោក



*ព្រះវិហារ បរិសុទ្ធ សេន សាវ៉ាដ័រ អី សាវ៉ាដ័រ គឺជាព្រះវិហារបរិសុទ្ធកំពុងដំណើរការទី 135 របស់សាសនាចក្រនៅទូទាំងពិភពលោក ហើយជាព្រះវិហារបរិសុទ្ធទីបួននៅក្នុងអាមេរិកកណ្ដាល ។*

### ព្រះវិហារ បរិសុទ្ធ សេន សាវ៉ាដ័រ បានឧទ្ទិសឆ្លង

ព្រះវិហារ បរិសុទ្ធ សេន សាវ៉ាដ័រ អី សាវ៉ាដ័រ ត្រូវបានឧទ្ទិសឆ្លង នៅថ្ងៃអាទិត្យ ទី 21 ខែ សីហា ឆ្នាំ 2011 ដោយប្រធាន ហិនរី ប៊ី អាវរិង ជាទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ ។ វាគឺជាព្រះវិហារបរិសុទ្ធទីបួនរបស់សាសនាចក្រនៅក្នុងអាមេរិកកណ្ដាល និងជាព្រះវិហារបរិសុទ្ធទី 135 នៅទូទាំងពិភពលោក ។

មានមនុស្សប្រហែលជា 16,000 នាក់ បានចូលរួមប្រារព្ធពិធីតាមវប្បធម៌ចំនួនពីរ នៅថ្ងៃសៅរ៍ ទី 20 ខែសីហា ដែលដំណាលឡើងវិញពីប្រវត្តិវប្បធម៌ដ៏សម្បូរណ៍សប្បាយក្នុងតំបន់ តាមរយៈចម្រៀង និងការរាំ ។

### Create.LDS.org អញ្ជើញសមាជិកទាំងឡាយឱ្យបរិច្ចាគឯកសារជាសម្លេង

សាសនាចក្របានអញ្ជើញសមាជិកឱ្យផ្ញើរតន្ត្រី ដែលមានគុណភាពខ្ពស់ និងឯកសារជាសម្លេងដទៃទៀត ទៅកាន់ create.lds.org សម្រាប់ប្រើប្រាស់នៅក្នុងវិទ្យុ ប៉ុស្ដិ៍ មរមន និងនៅក្នុងផលិតកម្មព័ត៌មានផ្សេងៗទៀតរបស់សាសនាចក្រ ។ សមាជិកទាំងឡាយអាចអានព័ត៌មានលំអិតអំពីការអញ្ជើញនៅលើ news.lds.org ស្រាវជ្រាវដោយប្រើពាក្យគន្លឹះ « create.lds.org ») ហើយអាចផ្ញើរឯកសារតាម create.lds.org ។

### គម្រោងពេលវេលាចែកចាយសម្រាប់ឆ្នាំ 2012 អាចរកបាននៅលើអ៊ីនធើណិត

គណៈប្រធានអង្គការបឋមសិក្សាទូទៅ បានប្រកាសថា ប្រធានបទ ពេលវេលាចែកចាយសម្រាប់ឆ្នាំ 2012 គឺ « ជ្រើសរើសផ្លូវត្រូវ » ។ គណៈប្រធានអង្គការបឋមសិក្សា អាចរកគម្រោងនេះក្រោមពាក្យថា **“Primary”** នៅក្នុងផ្នែក **Serving in the Church** នៃ LDS.org ។

កាលពីមុន គម្រោងនេះចំនួន 10 ច្បាប់ ត្រូវបានផ្ញើទៅកាន់អង្គភាពនានាជារៀងរាល់ខែកក្កដា ប៉ុន្តែដោយសារតែអាចប្រើប្រព័ន្ធ អ៊ិនធើណិត នោះការផ្ញើរជាសំបុត្រនៅខែកក្កដា នឹងត្រូវបានបញ្ឈប់ ហើយសំណៅ 3 ច្បាប់ នឹងត្រូវបានផ្ញើរទៅកាន់អង្គភាពនីមួយៗដោយស្វ័យប្រវត្តិ នៅក្នុងការបញ្ជាទិញ កម្មវិធីសិក្សាប្រចាំឆ្នាំ ។ ■

# សេចក្ដីអធិប្បាយ

## ឧបករណ៍ដ៏មានអានុភាពមួយ

ខ្ញុំតែងតែជាវ *លីអាហូណា,* ជានិច្ច ប៉ុន្ដែនៅពេលខ្ញុំមិនសូវសកម្មខ្ញុំពុំបានអានវាជាញឹកញាប់ឡើយ ។ នៅថ្ងៃមួយ ពេលដែលខ្ញុំកំពុងតែសំអាតទូ និងខ្ញុំបានឃើញទស្សនាវដ្ដីចាស់ៗមួយចំនួន ។ នៅពេលខ្ញុំមើលវា មានរឿងមួយបានធ្វើឱ្យខ្ញុំចាប់អារម្មណ៍ ។ ជារឿងមួយនិយាយអំពីបងស្រីម្នាក់ដែលមិនសូវសកម្មអស់ជាច្រើនឆ្នាំ ហើយគ្មានបំណងត្រឡប់ទៅព្រះវិហារវិញទេ ។ ប៉ុន្ដែមានប៊ីស្សពដ៏បំផុសគំនិតម្នាក់ បានផ្ដល់ការហៅមួយដល់គាត់ ហើយគាត់ក៏បោះបង់ទម្លាប់អាក្រក់របស់គាត់ចោល រួចហើយត្រឡប់មកវិញ ។ រឿងនេះមានឥទ្ធិពលយ៉ាងជ្រាលជ្រៅ មកលើខ្ញុំ — វាគឺជាជំហានដំបូងរបស់ខ្ញុំ នៅក្នុងការត្រឡប់មកសកម្មវិញ ។ អស់រយៈពេលច្រើនឆ្នាំក្រោយមក ឥឡូវនេះទស្សនាវដ្ដី *លីអាហូណា* គឺជាឧបករណ៍ដ៏អានុភាពមួយ នៅក្នុងគេហដ្ឋានរបស់យើង ។ ពាក្យទូន្មានការណែនាំ និងទីបន្ទាល់ទាំងឡាយ នៅក្នុងទស្សនាវដ្ដី ជួយយើងជារៀងរាល់ថ្ងៃ ។

**ម៉ោម៉ា លីម៉ា សាឡីស ប្រូឌូល ប្រទេស ប្រេស៊ីល**

## រឿងនិទានសម្រាប់កុមារ — និងពួកមជ្ឈិមវ័យ

ខ្ញុំគឺជាម្ដាយរបស់កុមារតូចម្នាក់ ហើយជារៀងរាល់យប់មុនចូលគេង ខ្ញុំចូលចិត្តអានរឿងនិទានសម្រាប់កុមារចេញពីទស្សនាវដ្ដី *លីអាហូណា*ឱ្យវាស្ដាប់ ។ វាក៏ជាពរជ័យមួយសម្រាប់ខ្ញុំផងដែរ ពីព្រោះខ្ញុំបានរៀនអំពីព្រះយេស៊ូវគ្រីស្ទ ព្យាការី យ៉ូសែប ស្ម៊ីធ គារវភាព ការអធិស្ឋាន និងរឿងផ្សេងទៀតជាច្រើន ។ ចូរប្រកាន់ខ្ជាប់តែកិច្ចការល្អ !

**ស៊ុលវៀ រ៉ូអ៊ី ឌី ម៉ុនអូ អេកូអាឌ័រ**

*សូមបញ្ជូនមតិកែលំអ ឬមតិយោបល់របស់អ្នកទៅកាន់ liahona@ldschurch.org ។ ឯកសារដែលបានបញ្ជូនមក អាចនឹងធ្វើការកែសំរួលឡើងវិញ ដើម្បីធ្វើឱ្យមានភាពច្បាស់លាស់ ឬកែទំហំអត្ថបទ ។* ■

# គំនិតសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះគឺមានទូវអត្ថបទ និងសកម្មភាពទាំងឡាយ ដែលអាចយកមកប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួន ។*

**« ការស្វែងរកអាហារប្រចាំថ្ងៃរបស់យើង »** ទំព័រ 24 ៖ ចូរគិតអំពីការអានអំពីការអធិស្ឋានរបស់ព្រះអម្ចាស់ (សូមមើល ម៉ាថាយ 6:9–13) ហើយសួរដល់គ្រួសាររបស់អ្នកតើពួកគេគិតថា « សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ » មានន័យដូចម្ដេច ? បន្ទាប់មកសង្ខេបវគ្គទីមួយក្នុងអត្ថបទ ដែលអែលឌើរ គ្រីស្ដូហ្វឺសិន ពិភាក្សាពី « អាហារប្រចាំថ្ងៃ » ។ សូមពិចារណា អំពីការបន្ថែមទីបន្ទាល់របស់អ្នកថាព្រះយេស៊ូវគ្រីស្ទ គឺជានំបុ័ងនៃជីវិត ។

**« ចច អ័លប៊ើត ស្ម៊ីធ ៖ ទ្រង់រស់នៅដូចដែលទ្រង់បានបង្រៀន »** ទំព័រ 32 ៖ ប្រធាន ចច អ័លប៊ើត ស្ម៊ីធ « សូមជឿថាបើយើងពិតជាមានទីបន្ទាល់មួយអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ នោះវានឹងសម្ដែងចេញនៅក្នុងជីវិតរស់នៅរបស់ពួកយើង » ។ សូមរំឭកអត្ថបទនេះឡើងវិញជាមួយគ្រួសារអ្នក ។ បន្ទាប់មកអ្នកអាចសួរដល់សមាជិកគ្រួសារថា តើពួកគេបានរៀនអ្វីខ្លះ ពីគំរូរបស់ប្រធានស្ម៊ីធ អំពីការប្រព្រឹត្តិនឹងអ្នកដទៃដោយសណ្ដានចិត្តល្អនោះ ។ សូមសួរថា តើពួកគេអាចបង្ហាញពីសណ្ដានចិត្តល្អបន្ថែមទៀតដោយរបៀបណា ។

**« ចូរមើលទៅលើ »** ទំព័រ 42 ៖ សូមពិចារណាចែកចាយ បទពិសោធន៍ដែលអែលឌើរ យុក បានមាន កាលពីនៅជាអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងម្នាក់ រួចហើយសង្ខេបវគ្គដែលនៅសល់នៃអត្ថបទនោះ ។ សូមសួរដល់សមាជិកគ្រួសារថាតើពួកគេអាចផ្ដោតអារម្មណ៍ទៅលើអ្វី ដែលព្រះវរបិតាសួគ៌ព្រះតំរិះអំពីពួកគេជាជាងអ្វីដែលអ្នកដទៃគិតអំពីគេដោយរបៀបណា ។ អ្នកអាចបញ្ចប់ដោយការអាននៅសាំយូអែលទី1 16:7.



**« ការរក្សាសេចក្ដីសញ្ញាទាំងឡាយ »** ទំព័រ 48 ៖ ប្រសិនបើមាននរណាម្នាក់ នៅក្នុងគ្រួសាររបស់អ្នកកំពុងតែរៀបចំខ្លួន ដើម្បីបម្រើបេសកកម្ម អ្នកអាចនឹងចង់អានអត្ថបទទាំងមូល ហើយរៀបចំធ្វើបញ្ជីមួយ អំពីចំនុចសំខាន់នានាដែលអែលឌើរ អែលឡេន បានប្រាប់ ។ គូសបញ្ជាក់ទៅលើសេចក្ដីថ្លែង « គន្លឹះចំពោះកិច្ចការនេះ គឺការរក្សាសេចក្ដីសញ្ញាទាំងឡាយរបស់យើង » ។ សូមរំឭកឡើងវិញ ថាតើសេចក្ដីសញ្ញាមួយ គឺជាអ្វី រួចហើយសួរកុមារតូចៗ ថាតើពួកគេអាចរៀបចំខ្លួនចាប់ពីពេលឥឡូវ ដើម្បីធ្វើសេចក្ដីសញ្ញាទាំងឡាយដោយរបៀបណា ។

**« ទ្រង់នៅទីនោះ »** ទំព័រ 69 ៖ សូមច្រៀង « A Child's Prayer » (*Children's Songbook, 12*) ។ សូមអានពីបទពិសោធន៍ការអធិស្ឋានរបស់បងស្រី វីស្សូម ហើយលើកទឹកចិត្តដល់សមាជិកគ្រួសារ ឱ្យចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ អំពីការអធិស្ឋានផ្ទាល់ខ្លួន ។ អ្នកអាចសួរថា « តើអ្នកអាចគិតពីពេលមួយ ដែលអ្នកត្រូវបានលួងលោមចិត្តដោយការអធិស្ឋានបានឬទេ ? សូមបញ្ចប់ដោយទីបន្ទាល់អំពីការអធិស្ឋានរបស់អ្នក ។ ■

## សកម្មភាពសប្បាយ ជាសារដ៏អស់កល្បជានិច្ចមួយ

កាលនៅវ័យជំទង់ ខ្ញុំបានចូលរួមក្នុងរាត្រីជួបជុំគ្រួសារដោយស្ទាក់ស្ទើរ ។ ខ្ញុំបានគិតថា ខ្ញុំមានអ្វីត្រូវធ្វើដែលប្រសើរជាងនេះ ។

នៅយប់ថ្ងៃចន្ទមួយ បន្ទាប់ពីមានការលំបាកខ្លះៗដើម្បីធ្វើរាត្រីជួបជុំគ្រួសារ នោះម្ដាយរបស់ខ្ញុំបានជូតតុបាយ ហើយបានដាក់នំផ្លែឈើរីតូចមួយ នៅចំពីមុខពួកយើងម្នាក់ៗ ។ ខ្ញុំបានខំរកមើលសម — ប៉ុន្ដែគ្មានសមឡើយ ! ម៉ាក់បានពន្យល់ថា យើងនឹងមានការប្រណាំងញ៉ាំនំ ប៉ុន្ដែពួកយើងមិនអាចប្រើឧបករណ៍ ឬ ដៃរបស់យើងបានឡើយ ។ អ្នកឈ្នះទើបមានសិទ្ធិអូតអាង ។

ពួកយើងបានញ៉ាំយ៉ាងលឿនបំផុតតាមដែល យើងអាចធ្វើបាន ។ មិនយូរប៉ុន្មាន តុបាយ មុខ និងសម្បុរសំពត់របស់ពួកយើង ប្រឡាក់សុទ្ធតែនំឈើរី ។ ខ្ញុំមិនចាំបានថាអ្នកណាឈ្នះនោះទេ ប៉ុន្ដែខ្ញុំចាំបាននូវការសើចដ៏ក្អាកក្អាយ និងការសប្បាយយ៉ាងពិតក្នុងគ្រួសារខ្ញុំ ។ ខ្ញុំពុំបានដឹងទាំងស្រុងអំពីរាត្រីនោះទេ តែឥឡូវខ្ញុំមានអំណរគុណថា វាល្អខ្លាំងណាស់ដើម្បីមានកន្លែងដ៏សុវត្ថិភាព និង ជាទីស្រឡាញ់ដែលហៅថាជាគេហដ្ឋាន និងមានមនុស្សចាំថែរក្សាខ្ញុំ ។

ខ្ញុំចាំប្រាកដថា នៅយប់នោះយើងមានចម្រៀង និងមេរៀន ហើយម្ដាយរបស់ខ្ញុំត្រូវចំណាយពេលយ៉ាងច្រើនដើម្បីរៀបចំ និងសំអាតវា ។ ប៉ុន្ដែខ្ញុំមានអំណរគុណចំពោះសកម្មភាពមួយ ដែលបានបង្រៀនសារលិខិតមួយ អំពីសារៈសំខាន់នៃក្រុមគ្រួសារ ដែលខ្ញុំត្រូវការ — ចាប់តាំងពីពេលនោះមក និងរហូតតទៅ ។ ■

**ហ្សេធើរ ម៉ាក់ល័រ តូស្ស៊ូរ កាលីហ្វូញ៉ា សហរដ្ឋអាមេរិក**

# ការរៀនសូត្រពីអ្នកជំនាញ



**ដោយ ចច ស៊ី រ៉ូប៊ីនសិន**

ក្នុងនាមជាគ្រូពេទ្យវះកាត់ម្នាក់ ជារឿយៗខ្ញុំត្រូវបានគេសួរពីរបៀបដែលខ្ញុំទទួលបានជំនាញរបស់ខ្ញុំ ។ មានមនុស្សមួយចំនួនគិតថា នៅពេលមនុស្សចូលរៀន ហើយមើលនូវការវះកាត់ រួចនឹងចេះធ្វើវាហើយ ។ ថែមទាំងមាននូវការនិយាយលេងសើចមួយនៅក្នុងការបំពាក់បំប៉នថា ៖ បានមើលម្ដង បានធ្វើម្ដង នោះនឹងអាចបង្រៀនបានហើយ ។ ប៉ុន្តែ នេះពុំមែនជាការពិតឡើយ ។

ខ្ញុំបានទទួលជំនាញ និងចំណេះដឹងអាជីពរបស់ខ្ញុំនៅក្រោមការដឹកនាំពីពួកគ្រូពេទ្យដ៏មានទេពកោសល្យ ហើយអត់ធ្មត់ជាច្រើននាក់ ។ ដំបូងខ្ញុំបានចាប់ផ្ដើមដោយការមើលពីចម្ងាយ រួចហើយចូលមកជិត ។ បន្ទាប់ពីបានសង្កេតមើលរយៈពេលមួយឆ្នាំ ខ្ញុំបានទទួលនូវកិច្ចការតូចៗ ដោយជួយគ្រូពេទ្យវះកាត់ និង « ជំនួយការទីមួយ » របស់ពួកគេ—ជាជំនួយការគ្រូពេទ្យវះកាត់ ។

លុះមួយឆ្នាំក្រោយមកទៀត ខ្ញុំត្រូវបានអនុញ្ញាតឱ្យឈរនៅទល់មុខនឹងគ្រូពេទ្យពីជ្រុងតុម្ខាងទៀត ហើយដើរតួនាទីជាជំនួយការទីមួយអំឡុងពេលធ្វើការវះកាត់ធម្មតា ។ លុះមួយឆ្នាំ ឬពីរឆ្នាំក្រោយមកទៀត ខ្ញុំត្រូវបានអនុញ្ញាតឱ្យធ្វើជាជំនួយការទីមួយនៅក្នុងការវះកាត់ដ៏ស្មុគស្មាញជាច្រើន ។ បន្ទាប់មក ខ្ញុំបានចាប់ផ្ដើមធ្វើការវះកាត់ដ៏សាមញ្ញបំផុត ដូចជាការព្យាបាលរោគក្លូន ខណៈដែលគ្រូពេទ្យជំនាញដើរតួជាជំនួយការទីមួយរបស់ខ្ញុំ ។

នៅឆ្នាំចុងក្រោយនៃការបំពាក់បំប៉នរបស់ខ្ញុំ—ប្រាំពីរឆ្នាំបន្ទាប់ពីខ្ញុំបានបញ្ចប់ពីសាលាវេជ្ជសាស្ត្រ—ខ្ញុំត្រូវបានអនុញ្ញាតឱ្យធ្វើការវះកាត់ដ៏ស្មុគស្មាញ ខណៈដែលគ្រូពេទ្យវះកាត់ដើរតួជាជំនួយការទីមួយ ។ ខ្ញុំបានរកឃើញថា ពួកគ្រូបង្រៀនដ៏អស្ចារ្យបំផុតអាចធ្វើឱ្យការវះកាត់នោះកាន់តែងាយស្រួលបានដោយសារតែជំនួយការរបស់ពួកគេ ពីព្រោះពួកគេអាចបង្ហាញខ្ញុំនូវអ្វីដែលត្រូវធ្វើនៅក្នុងរបៀបច្បាស់លាស់ ហើយសាមញ្ញ—ជារបៀបដែលពួកគេបានរៀនតាមរយៈដំណើរការណែនាំដូចគ្នានេះដែរ ។

*ក្នុងនាមជាសិស្សពេទ្យផ្នែកវះកាត់ម្នាក់ ខ្ញុំតែងតែមានមនុស្សម្នាក់ដែលមានជំនាញនៅក្បែរខ្ញុំជានិច្ច ។ ក្នុងនាមជាកូនម្នាក់របស់ព្រះ ខ្ញុំមានឱកាសដូចគ្នា ។*

ខ្ញុំមិនបានមានអំណរគុណទាំងស្រុងចំពោះគ្រូពេទ្យជំនាញដ៏អស្ចារ្យ និងមានទេពកោសល្យទាំងនោះ ដែលបានធ្វើជាជំនួយការទីមួយរបស់ខ្ញុំឡើយ រហូតដល់ខ្ញុំបានបញ្ចប់ការបំពាក់បំប៉ន ហើយបានធ្វើវាដោយខ្លួនឯងនោះ ។ ប៉ុន្តែ សូម្បីតែ 30ឆ្នាំ ក្រោយមក ពួកគ្រូបង្រៀនរបស់ខ្ញុំស្ថិតនៅក្នុងគំនិតរបស់ខ្ញុំ ពេលខ្ញុំបានប្រើជំនាញដែលពួកគាត់បានបង្រៀន បង្ហាត់បង្ហាញនិងកែតម្រូវយ៉ាងច្បាស់ជារៀងរាល់ថ្ងៃ ។

ការរៀនសូត្រពីគោលការណ៍ទាំងឡាយនៃដំណឹងល្អគឺគ្មានអ្វីខុសប្លែកគ្នាឡើយ ។ យើងត្រូវបានបង្រៀនមួយបន្ទាត់ម្ដងៗតាមរយៈបទពិសោធន៍—ដោយគ្រូបង្រៀនដែលមានចិត្តអត់ធ្មត់បំផុតម្នាក់ ។ យើងសំឡឹងទៅទ្រង់ ដើរតាមគំរូរបស់ទ្រង់ ទូលសុំការបំផុសគំនិត ហើយព្រះវរបិតាសួគ៌យើងប្រទានការដឹកនាំដល់យើង—ជារឿយៗបានទទួលតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ប្រសាសន៍របស់ព្យាការីនៅរស់ ព្រះគម្ពីរ និងអ្នកផ្សេងទៀតដែលស្រឡាញ់ និងបម្រើ ។ អ្នកនាំផ្លូវរបស់យើងឈរជាតំណាងនៅក្បែរខ្លួនយើង ពេលយើងទទួលបាននូវភាពជឿជាក់ ដោយការធ្វើឱ្យផ្លូវរបស់យើងមានភាពស្រួល ដោយការផ្ដល់នូវការកែតម្រូវដែលត្រូវការ ដោយឆ្លើយនឹងសំណួរនានា និងដោយការផ្ដល់នូវការទុកចិត្តកាន់តែច្រើនឡើងៗ នៅពេលយើងបង្ហាញថាយើងសក្ដិសមនឹងទទួលការណ៍នោះ ។

មាននិស្សិតពេទ្យផ្នែកវះកាត់មួយចំនួនមានចិត្តអន្ទះសារចង់ធ្វើដោយខ្លួនឯង និងតាមវិធីរបស់ខ្លួនផ្ទាល់ ។ ដូចគ្នានេះដែរ ពេលខ្លះយើងព្យាយាមធ្វើដោយគ្មានអ្នកនាំផ្លូវដ៏ជំនាញរបស់យើង ។ ប៉ុន្តែខ្ញុំបានរៀន នៅក្នុងរយៈពេលជាច្រើនឆ្នាំជាគ្រូពេទ្យវះកាត់ម្នាក់ថា សូម្បីតែនៅពេលនេះខ្ញុំតែងតែចង់បាន និងឱ្យតម្លៃចំពោះជំនួយការទីមួយម្នាក់ដែលចេះច្រើនជាងខ្ញុំជានិច្ចក្ដី—ជាពិសេសនៅពេលជីវិត និងព្រលឹងមានតុល្យភាព !

ការរីកចម្រើនរបស់យើងនៅក្នុងដំណឹងល្អបានចាប់ផ្ដើមនៅក្នុងជីវិតមុនជីវិតនេះ ហើយបានបន្តនៅទីនេះ ហើយប្រាកដណាស់វានឹងបន្តយ៉ាងយូរបន្ទាប់ពីជីវិតរមែងស្លាប់នេះត្រូវបានបញ្ចប់ ។ ប៉ុន្តែនៅរាល់ដំណាក់កាលនៃជីវិតរបស់យើង ព្រះអង្គសង្គ្រោះរបស់យើងបានយាងឆ្លងកាត់មុន ដោយបង្ហាញនូវជំនាញដែលចាំបាច់ដើម្បីទទួលបានភាពជោគជ័យ ។ ហើយទ្រង់អញ្ជើញមនុស្សទាំងអស់ឱ្យពឹងផ្អែកមកលើទ្រង់ និងភាពស្ទាត់ជំនាញរបស់ទ្រង់ ។ ■

រូបថត© ISTOCKPHOTO




ហាមថតចម្លង

ពន្លឺនៃពិភពលោក ដោយ ហ្វូរ៉ឹដ លីយ៉ន

*« មើលចុះ យើងជាក្រិត្យវិន័យ ហើយជាពន្លឺ ។ ចូរផ្ចង់មកយើង ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត ទើបអ្នករាល់គ្នានឹងរស់ ត្បិតយើងនឹងប្រទានជីវិតដ៏នៅអស់កល្បជានិច្ច ដល់អ្នកណាដែលកាន់ខ្ជាប់ដរាបដល់ចុងបំផុត ។*

*« មើលចុះ យើងបានប្រទានបញ្ញត្តិទាំងឡាយដល់អ្នករាល់គ្នា ដូច្នេះ ចូរធ្វើតាមបញ្ញត្តិទាំងឡាយរបស់យើង ។ ហើយនេះជាក្រិត្យវិន័យ ហើយជាសេចក្ដីព្យាករណ៍របស់ពួកព្យាការី ត្បិតរបស់ទាំងនោះបានធ្វើទីបន្ទាល់ដ៏ពិតប្រាកដអំពីយើង » ( នីហ្វៃទី3 15:9–10 ) ។*



*កាលដែលយើងសិក្សាព្រះគម្ពីរមរមនរៀងៗខ្លួន ជាក្រុមគ្រួសារ និងនៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យរបស់យើងនៅក្នុងឆ្នាំនេះ—ដូចផាលីហៃដែរ—យើងអាចពិចារណាមើលទៅលើកំណត់ត្រាពីបុរាណទាំងនេះ ហើយនិងឃើញថាកំណត់ត្រាទាំងនោះគឺ « គួរឱ្យចង់បាន មែនហើយ ព្រមទាំងមានប្រយោជន៍ជាអតិបរិមាចំពោះយើង ដរាបដល់យើង [ អាច ] ថែរក្សានូវព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ ទុកដល់កូនចៅយើង » ( នីហ្វៃទី1 5:21 ) ។ សូមមើល « ការជួយដល់កុមារឱ្យស្រឡាញ់ព្រះគម្ពីរមរមន » ទំព័រ 14 និង « ការស្វែងរកចម្លើយទាំងឡាយនៅក្នុងព្រះគម្ពីរមរមន » ទំព័រ 16 ។*

CAMBODIAN
4 02104 81258 7